វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍ (វបសអ)

# លើកកម្ពស់អភិបាលកិច្ចធនធានទឹក នៅកម្ពុជា៖ ការវិភាគអ្នកពាក់ព័ន្ធ

## ស្វែងយល់អំពីតួនាទី ទស្សនវិស័យ និងបញ្ហាប្រឈមរបស់អ្នកពាក់ព័ន្ធ ដើម្បីគ្រប់គ្រងនិងអភិវឌ្ឍធារាសាស្ត្រ និងផ្ទៃរងទឹកភ្លៀងប្រកបដោយប្រសិទ្ធភាព



**ឈាំង ធិរុណ   ខៀវ ដារ៉ាវី**

Philip HIRSCH និង Isabelle WHITEHEAD

ឯកសារពិភាក្សាលេខ ៥៤

ខែកក្កដា ២០១១

ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI

# លើកកម្ពស់អភិបាលកិច្ច ធនធានទឹកនៅកម្ពុជា៖ ការវិភាគអ្នកពាក់ព័ន្ធ

ស្វែងយល់អំពីតួនាទី ទស្សនវិស័យ និងបញ្ហាប្រឈមរបស់អ្នកពាក់ព័ន្ធ
ដើម្បីគ្រប់គ្រង និងអភិវឌ្ឍធារាសាស្ត្រ និងផ្ទៃរងទឹកភ្លៀងប្រកបដោយប្រសិទ្ធភាព

ឯកសារពិភាក្សាលេខ ៥៤

**ឈាំង ភិរុណ   ខៀវ ដារ៉ាវី**

Philip HIRSCH និង Isabelle WHITEHEAD

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍**

ភ្នំពេញ ខែកក្កដា ឆ្នាំ២០១១

**បេសកកម្ម វបសអ**

ក្នុងលក្ខណៈជា វិទ្យាស្ថានកម្ពុជាឯករាជ្យផ្នែកស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ វបសអ មានបេសកកម្មរួមចំណែកដល់ការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋកម្ពុជា តាមរយៈការស្រាវជ្រាវមានគុណភាពខ្ពស់ពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយចំណេះដឹង និងការកសាងសមត្ថភាព ។

វបសអ ប្រឹងប្រែងបំពេញបេសកកម្មនេះ ដោយធ្វើការជាដៃគូជាមួយស្ថាប័នសាធារណៈ និងសង្គមស៊ីវិលកម្ពុជា ស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក និងដោយគោរពដល់សមត្ថភាពរបស់ប្រជាពលរដ្ឋ និងស្ថាប័នកម្ពុជា ចំណេះដឹង និងបទពិសោធន៍ក្នុងស្រុក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជា ។

**© រក្សាសិទ្ធិឆ្នាំ២០១១ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ដែលអាចយកទៅចម្លងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

ISBN-10: 99950–52–45-4

**លើកកម្ពស់អភិបាលកិច្ចធនធានទឹកនៅកម្ពុជា៖ ការវិភាគអ្នកពាក់ព័ន្ធ**

Improving the Governance of Water Resources in Cambodia: A Stakeholder Analysis

**អ្នកនិពន្ធ៖**

| | |
|---|---|
| ណាំង ភិរុណ | អ្នកស្រាវជ្រាវ កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន នៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) |
| ខៀវ ដារ៉ាវី | អតីតអ្នកស្រាវជ្រាវ កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន នៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) |
| Philip HIRSCH | សាស្ត្រាចារ្យភូមិវិទ្យាមនុស្ស នៃមហាវិទ្យាល័យវិទ្យាសាស្ត្រ ផ្នែកភូគព្ភសាស្ត្រ និងនាយកមជ្ឈមណ្ឌលស្រាវជ្រាវមេគង្គអូស្ត្រាលី នៃសាកលវិទ្យាល័យស៊ីដនី |
| Isabelle WHITEHEAD | អ្នកស្រាវជ្រាវ កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន នៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) |


*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈរបស់វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាទេ ។*

រូបក្របមុខ៖ ប្រព័ន្ធធារាសាស្ត្រ ស្វាយចេក ខេត្តកំពង់ឆ្នាំង

**វិទ្យាស្ថាន** CDRI

☞ អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ខ័ណ្ឌទួលគោក

✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

☎ ទូរស័ព្ទ៖ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣

ទូរសារ៖ (៨៥៥-២៣) ៨៨០-៧៣៤

អ៊ីមែល៖ cdri@cdri.org.kh គេហទំព័រ៖ http://www.cdri.org.kh

កែសម្រួល និងរចនាដោយ៖ ម៉េន ច័ន្ទធីតា អ៊ុំ ចាន់ថា និង យូ សិទ្ធីរិទ្ធិ

បោះពុម្ពនៅប្រទេសកម្ពុជាដោយសហគ្រាស T & S Printing

# មាតិកា


បញ្ជីរូបភាព តារាង និងឧបសម្ព័ន្ធ ..... v
បញ្ជីអក្សរកាត់ ..... vii
សេចក្តីថ្លែងអំណរគុណ ..... ix
ខ្លឹមសារសង្ខេប ..... 1

**១. សេចក្តីផ្តើម** ..... 9
១.១ សាវតារ ..... 9
១.២ សំណួរស្រាវជ្រាវ ..... 10

**២. វិធីសាស្ត្រស្រាវជ្រាវ - ការវិភាគអ្នកពាក់ព័ន្ធចម្រុះ** ..... 11
២.១ ការកំណត់អត្តសញ្ញាណ និងតួនាទីអ្នកពាក់ព័ន្ធសំខាន់ៗ ..... 11
២.២ ការប្រមូលទិន្នន័យ ..... 11
*២.២.១ ការសម្ភាសអ្នកពាក់ព័ន្ធសំខាន់ៗ ..... 11*
*២.២.២ អង្កេតដល់មូលដ្ឋាន និងការប្រជុំក្រុមគោលដៅ ..... 12*
*២.២.៣ សិក្ខាសាលាថ្នាក់ខេត្ត ..... 13*

**៣. ការសិក្សាបណ្ណាល័យសាស្ត្រ** (**ការសិក្សាតាមឯកសារស្រាវជ្រាវ**) ..... 15
៣.១ មតិឯកភាពបច្ចុប្បន្នលើនិយមន័យពាក្យ "អ្នកពាក់ព័ន្ធ" ..... 15
៣.២ ការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងការធ្វើឲ្យវិវត្តទស្សនទាននៃអភិបាលកិច្ចធនធានទឹក ..... 16
៣.៣ ឯកសារស្រាវជ្រាវ និងការអនុវត្តជាក់ស្តែងស្តីពី កគទច និងការចូលរួមរបស់អ្នកពាក់ព័ន្ធ ..... 17
៣.៤ ទស្សនទាននៃការវិភាគអ្នកពាក់ព័ន្ធ៖ និយមន័យ និងផលប្រយោជន៍សម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ ..... 18

**៤. ការវិភាគអ្នកពាក់ព័ន្ធ** ..... 19
៤.១ ព័ត៌មានសង្ខេបអំពីទិដ្ឋភាពនៃអ្នកពាក់ព័ន្ធក្នុងតំបន់សិក្សា ..... 19
៤.២ តួនាទីអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងធនធានទឹក ..... 20
*៤.២.១ អ្នកពាក់ព័ន្ធថ្នាក់ជាតិ ..... 20*
*៤.២.២ អ្នកពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ ..... 25*
*៤.២.៣ បណ្តាអ្នកពាក់ព័ន្ធនៅកម្រិតប្រព័ន្ធធារាសាស្ត្រ ..... 28*
*៤.២.៤ ទិដ្ឋភាព និងទស្សនវិស័យអ្នកផ្តល់ជំនួយ ..... 31*

**៥. ការពិភាក្សា និងបទពិសោធន៍** ..... 33
៥.១ តួនាទី និងទស្សនវិស័យរបស់អ្នកពាក់ព័ន្ធលើ IWRM ឬ PIMD ..... 33
៥.២ បញ្ហាដែលកើតមានឡើង ..... 35
*៥.២.១ ការលើកកម្ពស់ការចូលរួមរបស់អ្នកពាក់ព័ន្ធ ..... 35*
*៥.២.២ ពង្រឹងកិច្ចសហការក្នុងចំណោមអ្នកពាក់ព័ន្ធ ..... 37*

*៥.២.៣ ដោះស្រាយបញ្ហាប្រឈមនៃកិច្ចសហការក្នុងអាងផ្ទៃរងទឹកភ្លៀង ឬអាងទន្លេ ........ 39*
*៥.២.៤ ពង្រឹងតួនាទី និងគណនេយ្យភាពរបស់ សកបទ ........ 40*
*៥.២.៥ ធានាការគាំទ្រហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងធនធានទឹក ........ 41*
៥.៣ មេរៀនដែលទទួលបាន៖ ឆ្ពោះទៅអភិបាលកិច្ចល្អក្នុងការគ្រប់គ្រងធារាសាស្ត្រ ........ 42
*៥.៣.១ លើកកម្ពស់កិច្ចសហការរវាង សកបទ និង អាជ្ញាធរមូលដ្ឋាន ........ 42*
*៥.៣.២ សំណើបង្កើតរចនាសម្ព័ន្ធសហការថ្មី៖ "បង្កើនទំហំ" វិធាននៃការគ្រប់គ្រងសហគមន៍ ........ 43*
*៥.៣.៣ លើកកម្ពស់ការទទួលការខុសត្រូវរបស់អ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងធារាសាស្ត្រ និងផ្ទៃរងទឹកភ្លៀង ........ 44*

**៦. សេចក្ដីសន្និដ្ឋាន** ........ 51
**ឯកសារយោង** ........ 57
**ឧបសម្ព័ន្ធ** ........ 62
**បញ្ជីឯកសារពិភាក្សារបស់វិទ្យាស្ថាន** CDRI ........ 66

# បញ្ជីរូបភាព តារាង និងឧបសម្ព័ន្ធ

## បញ្ជីរូបភាព


រូបភាព ១៖ ផែនទីនៃទីតាំងសិក្សា ........ 13
រូបភាព ២៖ បំណែងចែកអ្នកពាក់ព័ន្ធ ការបង្ហាញមែកធាង មួយ ពីរ ឬបី ........ 16
រូបភាព ៣៖ ទិដ្ឋភាពដ៏មមាញឹកនៃអ្នកពាក់ព័ន្ធក្នុងអាងបឹងទន្លេសាប ........ 20
រូបភាព ៤៖ ទិដ្ឋភាពអ្នកពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ........ 21
រូបភាព ៥៖ រចនាសម្ព័ន្ធ សកបទ ........ 28
រូបភាព ៦៖ អាងស្ទឹងជ្រៃបាក់ ........ 29
រូបភាព ៧៖ រចនាសម្ព័ន្ធទូទៅនៃប្រព័ន្ធដែលបានសិក្សា ........ 30
រូបភាព ៨៖ អនុគណៈកម្មាធិការសម្រាប់គ្រប់គ្រងធារាសាស្ត្រ និងផ្ទៃរងទឹកភ្លៀង (ICMS )ដែលស្នើឲ្យបង្កើតឡើង ........ 43


## បញ្ជីតារាង


តារាងទី ១៖ ម៉ាទ្រីកវិភាគ និងកំណត់អ្នកពាក់ព័ន្ធ ក្នុងការងារគ្រប់គ្រងធារាសាស្ត្រ និងផ្ទៃរងទឹកភ្លៀងនៅប្រទេសកម្ពុជា ..... 45


## បញ្ជីឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី ១៖ ការប្រជុំ ឬប្រធានបទពិភាក្សា និងអ្នកផ្តល់ព័ត៌មាន ........ 62
ឧបសម្ព័ន្ធទី ២៖ ដៃគូអភិវឌ្ឍន៍សំខាន់ៗ ........ 64

# បញ្ជីអក្សរកាត់

| | |
|---|---|
| កកបទ | ក្រុមកសិករប្រើប្រាស់ទឹក (Farmer Water User Groups) |
| កអសសគ្រទ | កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹក (Water Resources Management Research Capacity Development Programme) |
| ក្រករន | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (Ministry of Agriculture Forestry and Fisheries) |
| ក្រឃស | ក្រុមប្រឹក្សាឃុំ/សង្កាត់ (Commune Councils) |
| ក្រធទឧ | ក្រសួងធនធានទឹក និងឧតុនិយម (Ministry of Water Resources and Meteorology) |
| ក្របទក | ក្រុមការងារបច្ចេកទេសទឹក និងកសិកម្ម (Technical Working Group on Agriculture and Water) |
| គជអប | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (The National Committee for Sub-National Democratic Development) |
| គគធទច | គ្រប់គ្រងធនធានទឹកចម្រុះ (Integrated Water Resource Management approach) |
| គវមវស | គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ (Decentralisation and Deconcentration) |
| គធកក | គ្រប់គ្រងធារាសាស្រ្តដោយមានការចូលរួម និងកិច្ចអភិវឌ្ឍន៍ (Participatory Irrigation Management and Development) |
| ដនថ | ដំណើរការ និងការថែទាំ (Operation and Maintenance) |
| ថសទ | ថ្លៃសេវាកម្មប្រើប្រាស់ទឹក (Irrigation Service Fee) |
| ធអអ | ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank) |
| ភអប | ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (Agence Française de Développement) |
| ភសអជ | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (Japan International Cooperation Agency) |
| មករន | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (Department of Agriculture, Forestry and Fisheries) |
| មធទឧ | មន្ទីរធនធានទឹក និងឧតុនិយម (Department of Water Resources and Meteorology) |
| យកទ | យុទ្ធសាស្រ្តកសិកម្ម និងទឹក (Strategy for agriculture and Water) |
| របជខ | រដ្ឋបាលជលផលខេត្ត (Provincial Fisheries Administration) |
| ររក | រាជរដ្ឋាភិបាលកម្ពុជា (Royal Government of Cambodia) |
| លបទស | លេខាធិការដ្ឋានបបនីយជីវមណ្ឌលទន្លេសាប (Tonle Sap Biosphere Reserve Secretariat) |
| វបសអ | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (Cambodia Development Resource Institute) |
| សកបទ | សហគមន៍កសិករប្រើប្រាស់ទឹក (Farmer Water User Community) |
| អទស | អាជ្ញាធរទន្លេសាប (Tonle Sap Authority) |
| អគធអ | អនុគណៈកម្មាធិការគ្រប់គ្រងធារាសាស្រ្ត និងអាងទន្លេ (Irrigation and Catchment Management Sub-committee - ICMS) |
| អម | អាជ្ញាធរមូលដ្ឋាន (Local Authority) |
| AusAID | ទីភ្នាក់ងារអូស្រ្តាលីសំរាប់ការអភិវឌ្ឍអន្តរជាតិ (Australian Aid for International Development) |
| CNMC | គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (Cambodia National Mekong Committee) |
| FAO | អង្គការស្បៀងអាហារ និងកសិកម្ម (Food and Agriculture Organization) |
| IFAD | មូលនិធិអន្តរជាតិដើម្បីអភិវឌ្ឍន៍កសិកម្ម (International Fund for Agricultural Development) |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Fund) |

| | |
|---|---|
| IPMP | កម្មវិធីគ្រប់គ្រងថ្នាំសម្លាប់សត្វល្អិតចម្រុះ (Integrated Pest Management Programme) |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (Japan International Cooperation Agency) |
| MoE | ក្រសួងបរិស្ថាន (Ministry of Environment) |
| MOI | ក្រសួងមហាផ្ទៃ (Ministry of Interior) |
| PRDC-Excom | គណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត (Provincial Rural Development Committee-Executive Committee) |
| SAW | យុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងធនធានទឹក (Strategy for agriculture and Water) |
| UNDP | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (United Nation Development Programme) |
| WFP | អង្គការកម្មវិធីស្បៀងអាហារពិភពលោក (World Food Programme) |
| WHO | អង្គការសុខភាពពិភពលោក (World Health Organization) |

# សេចក្ដីថ្លែងអំណរគុណ

អ្នកនិពន្ធសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះបណ្ឌិត Rebecca F. Catalla ទីប្រឹក្សាបច្ចេកទេស លោក យ៉ែម ដារ៉ាវ័ត្ត អតីតអ្នកសម្របសម្រួលកម្មវិធីធនធានធម្មជាតិ និងបរិស្ថាន និងអតីតអ្នកដឹកនាំកម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹក (កអសសគ្រទ) លោក ចែម ផល្លា លោក គឹម សួ អ្នកដឹកនាំ កអសសគ្រទ អ្នកស្រី ជា ជូកញ្ញា Jessie Connell អ្នកស្រាវជ្រាវ និង លោកស្រី Susan Watkins ដែលបានចូលរួមផ្ដល់ជាយោបល់ ការពិគ្រោះ កិច្ចសហការ និងការសម្របសម្រួល ដើម្បីចងក្រង និងបោះពុម្ពឯកសារពិភាក្សានេះឡើង។ អ្នកនិពន្ធក៏សូមថ្លែងអំណរគុណដល់បណ្ឌិត ពេជ្យ សុខែម អ្នកគ្រប់គ្រងក្រុមអភិវឌ្ឍន៍គម្រោងអន្តរជាតិ និងជាជំនាញការជាន់ខ្ពស់ផ្នែកអភិបាលកិច្ចបរិស្ថាននៃក្រុមហ៊ុន Hatfield Consultants Partnership និងជាទីប្រឹក្សាបច្ចេកទេសផ្នែកអភិបាលកិច្ចនៃគម្រោង កអសសគ្រទ ដែលបានចូលរួមផ្ដល់យោបល់លើឯកសារនេះ។

យើងខ្ញុំសូមអរគុណជាពន្លឹកចំពោះអ្នកស្រាវជ្រាវរបស់ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) មានជាអាទិ៍ លោក រស់ បានសុខ លោក លន់ ពេជ្យដារ៉ា អ្នកស្រី សំ ស្រីមុំ និងមន្ត្រីសហការ មកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លោក ខោល ម៉ានី មន្ត្រីសហការមកពីក្រសួងធនធានទឹក និងឧតុនិយម លោក នង គាមនី ដែលបានចូលរួមសហការសម្របសម្រួល និងផ្ដល់យោបល់ដ៏មានតម្លៃក្នុងការស្រាវជ្រាវនេះ។

អ្នកនិពន្ធសូមអរគុណជាអនេកដល់បណ្ឌិត ស៊ិន សុរិទ្ធិ មន្ត្រីថ្នាក់តំបន់នៃ AusAID ដែលផ្ដល់ការប្រឹក្សា និងពិនិត្យជាប្រចាំលើការវិវឌ្ឍន៍ និងគុណភាពនៃការស្រាវជ្រាវ។ យើងខ្ញុំក៏សូមថ្លែងអំណរគុណជាពិសេសចំពោះលោក ច័ន្ទ ស៊ីណាត អគ្គលេខាធិការរងនៃក្រសួងធនធានទឹក និងជាសហប្រធាននៃ កអសសគ្រទ និងបណ្ឌិត ម៉ក់ សឿន ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្មដែលបានផ្ដល់ការណែនាំដ៏មានតម្លៃដល់ការស្រាវជ្រាវនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណជាពន្លឹកដែរ ដល់អ្នកដែលបានចូលរួមឆ្លើយសម្ភាសន៍ និងផ្ដល់ចំណេះដឹងមូលដ្ឋាន រួមទាំងការពិនិត្យអង្កេតលើទស្សនវិស័យ និងបញ្ហានានាក្នុងការគ្រប់គ្រងធនធានទឹកក្នុងប្រទេសកម្ពុជា ពិសេសនៅតាមតំបន់បានជ្រើសរើសយកមកសិក្សា និងដល់មន្ត្រីនៃក្រសួងធនធានទឹក និងក្រសួងកសិកម្ម ដែលបានគាំទ្រ និងចូលរួមក្នុងការអនុវត្តកម្មវិធីនៃគម្រោង កអសសគ្រទ និងដល់លោកប្រធានមន្ទីរ និងមន្ត្រី នៃមន្ទីរធនធានទឹក និងឧតុនិយម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ និងខេត្តពោធិ៍សាត់ ដែលបានចូលរួមយ៉ាងសកម្មក្នុងការងារស្រាវជ្រាវបណ្ដុះបណ្ដាល និងផ្សព្វផ្សាយ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់លោកប្រធាន និងសមាជិកសហគមន៍កសិករប្រើប្រាស់ទឹក (សកបទ) ដែលបានរួមចំណែកប្រមូលទិន្នន័យ ផ្ដល់ចំណេះដឹង និងមតិលើការស្រាវជ្រាវ និងដល់តំណាងអភិបាលខេត្ត លោកអភិបាល និងអភិបាលរងស្រុក ក្រុមប្រឹក្សាឃុំ/សង្កាត់ ប្រធានភូមិ និងកសិករទាំងអស់ដែលចូលរួមសហការយ៉ាងសកម្មក្នុងការស្រាវជ្រាវ។

ជាទីបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសដល់ថ្នាក់ដឹកនាំជាន់ខ្ពស់នៃវបសអ លោក ឡារី ស្រ្តេន្ធ នាយកប្រតិបត្តិ និងលោក អ៊ឹង ស៊ានលី នាយកផ្នែកប្រតិបត្តិការនៃវិទ្យាស្ថាន CDRI ដែលបានគ្រប់គ្រង ណែនាំ និងផ្ដល់ការណែនាំដ៏មានតម្លៃ ជួយជំរុញ និងលើកទឹកចិត្តដល់យើងខ្ញុំយ៉ាងខ្លាំង ក្នុងការចងក្រងឯកសារស្រាវជ្រាវនេះ។

# ខ្លឹមសារសង្ខេប


គេឃើញមានបញ្ហាលំបាកជាច្រើន ជាពិសេសផ្នែកអភិបាលកិច្ចធនធានទឹក ដែលតួអង្គពាក់ព័ន្ធទាំងឡាយនៅកម្ពុជាត្រូវប្រឈមមុខដោះស្រាយ។ កសិករ ភ្នាក់ងាររដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន សុទ្ធតែមានតួនាទីក្នុងការងារគ្រប់គ្រងធនធានទឹកនៅកម្ពុជា។ ប៉ុន្តែបច្ចុប្បន្ន តួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធទាំងនោះ មិនទាន់បានកំណត់ជាក់លាក់នៅឡើយទេ។ ទន្ទឹមនឹងនេះ ក៏មានលេចឡើងនូវគំនិតសហសម័យនៃការងារអភិបាលកិច្ចធនធានទឹក ដែលទាមទារឲ្យមានការចូលរួមប្រកបដោយភាពជាម្ចាស់លើធនធាន ពីសំណាក់សហគមន៍មូលដ្ឋាន ដែលកំពុងប្រើប្រាស់ធនធានទាំងនោះកាន់តែច្រើនឡើងៗ។ ប្រការនេះ ទាមទារឲ្យមានការកែលម្អ និងការគិតគូរឡើងវិញពីនីតិវិធីដែលអ្នកពាក់ព័ន្ធទាំងអស់ធ្វើទំនាក់ទំនងគ្នាទៅវិញទៅមក ហើយនិងការធ្វើសេចក្ដីសម្រេចនានាដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់ទឹក។

ឯកសារនេះបានវិភាគទៅលើ តួនាទី ទំនាក់ទំនង និងទស្សនវិស័យរបស់អ្នកពាក់ព័ន្ធនានាក្នុងការងារគ្រប់គ្រងធនធានទឹកនៅកម្ពុជា ដោយផ្ដោតសំខាន់លើការគ្រប់គ្រងធារាសាស្ត្រ និងអាងផ្ទៃរងទឹកភ្លៀង។ ការវិភាគក៏បានផ្ដោតទៅលើកម្រិតនៃភាពស្របគ្នា ឬគម្លាតគ្នាក្នុងចំណោមអ្នកពាក់ព័ន្ធ ព្រមទាំងភាពស្របគ្នា ឬគម្លាតគ្នានៃតួនាទីផ្លូវការរបស់ពួកគេក្នុងការអនុវត្តជាក់ស្ដែងដែរ។ ទិន្នន័យទទួលបានពីការធ្វើសម្ភាសន៍អ្នកពាក់ព័ន្ធសំខាន់ៗ អង្កេតស្ថានភាពជាក់ស្ដែង ការពិភាក្សាតាមក្រុមគោលដៅ និងសិក្ខាសាលាផ្សព្វផ្សាយព័ត៌មាន ត្រូវបានយកមកវិភាគដើម្បីសម្រាំងយកបញ្ហាចម្បងទាក់ទងនឹងតួអង្គពាក់ព័ន្ធក្នុងការងារអភិបាលកិច្ចធនធានទឹកនៅកម្ពុជា និងសម្រាប់យកមកបំពេញចន្លោះប្រហោងក្នុងការយល់ដឹង។ ឯកសារនេះបានបន្តពិនិត្យស៊ីជម្រៅទៅលើភ្នាក់ងារ និងស្ថាប័នមួយចំនួនដែលពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានទឹក ដើម្បីស្វែងយល់ពីសក្ដានុពល និងកម្រិតសមត្ថភាពនាពេលបច្ចុប្បន្ន។ គំហើញនៃការស្រាវជ្រាវ ត្រូវបានបង្ហាញឡើងតាមវិធីសាស្ត្រមួយដែលជួយឲ្យអ្នកធ្វើសេចក្ដីសម្រេចចិត្តលើគោលនយោបាយសាធារណៈ អាចយកទៅធ្វើការប្រៀបធៀប និងវាយតម្លៃនូវជម្រើសគោលនយោបាយដ៏ចាំបាច់នានា។

វិធាននៃទ្រឹស្ដីជាច្រើនត្រូវបានយកមកប្រើ ក្នុងការសិក្សាស្រាវជ្រាវនេះ។ បំណែងចែកក្រុមអ្នកពាក់ព័ន្ធដែលបានបង្កើតឡើង ជាផ្នែកមួយនៃការវិភាគ ដែលជួយឲ្យអ្នកស្រាវជ្រាវអាចកំណត់ក្រុមអ្នកពាក់ព័ន្ធបានដោយផ្អែកលើ អំណាច (ឥទ្ធិពល) ភាពពេញច្បាប់ (លើផលប្រយោជន៍) និង ភាពបន្ទាន់ របស់ពួកគេ។ ការវិភាគនេះមិនមែនផ្អែកលើការបង្កើតវិធានវិភាគតាមទ្រឹស្ដីតែមួយមុខនោះទេ ប៉ុន្តែបានផ្អែកលើព័ត៌មានជាច្រើនដែលទទួលបានតាមរយៈឯកសារនានា ស្ដីពីរចនាសម្ព័ន្ធអ្នកពាក់ព័ន្ធ និងយន្តការអភិបាលកិច្ច ជាពិសេសឯកសារស្ដីពីដំណោះស្រាយបញ្ហាជាប់ទាក់ទងនឹងអភិបាលកិច្ចធនធានទឹក។ ការគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) ត្រូវមានកិច្ចសហការយ៉ាងសមស្រប និងការចូលរួមយ៉ាងសកម្មពីសំណាក់អ្នកពាក់ព័ន្ធមកពីគ្រប់វិស័យ ហើយវិធាននៃការគ្រប់គ្រងធនធានទឹកចម្រុះនេះសោត ក៏ត្រូវមានការគិតគូរពិចារណាលើទិដ្ឋភាពសង្គម វប្បធម៌ នយោបាយ សេដ្ឋកិច្ច និងបរិស្ថាននៃធនធានទឹក ដែលមានអន្តរទំនាក់ទំនងរវាងគ្នា និងមានតម្លៃស្មើៗគ្នា។

## លទ្ធផលស្រាវជ្រាវសំខាន់ៗ

ការសិក្សាបានបង្ហាញថា ប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធជនបទក្នុងប្រទេសកម្ពុជា ត្រូវបានកសាងក្រោមថវិការបស់រាជរដ្ឋាភិបាល រួមទាំងថវិការបស់អ្នកផ្ដល់ជំនួយអន្តរជាតិ និងការចូលរួមបដិភាគរបស់ប្រជាពលរដ្ឋអ្នកទទួលផលប្រយោជន៍ពីគម្រោងតាមរយៈការបរិច្ចាគដីធ្លី និងកម្លាំងពលកម្ម។ បញ្ហាជាប់ទាក់ទងនឹងធនធានទឹក តែងត្រូវបានដោះស្រាយ (ជួនកាលមានលក្ខណៈត្រួតគ្នា) ដោយក្រសួង និងគណៈកម្មាធិការនានាដែលមានអាណត្តិ បំណងប្រាថ្នា និងគោលនយោបាយជាក់លាក់ផ្សេងៗគ្នា។ ការទទួលខុសត្រូវលើគោលនយោបាយ និងផែនការគ្រប់គ្រងធនធានទឹក កំពុងត្រូវបានធ្វើប្រតិភូកម្មទៅឲ្យរដ្ឋអំណាចថ្នាក់ក្រោមជាតិ និងមន្ទីរធនធានទឹក និងឧតុនិយមខេត្ត។ ការធ្វើវិមជ្ឈការនៃការគ្រប់គ្រងទឹកនេះ អនុវត្តស្របគ្នាទៅនឹងដំណើរការធំទូលាយនៃកំណែទម្រង់ថ្នាក់ជាតិរបស់រដ្ឋាភិបាល ដែលទទួលស្គាល់នូវតម្រូវការឲ្យមានការបញ្ចូលប្រព័ន្ធអភិបាលកិច្ចថ្មីនៅថ្នាក់ខេត្ត ក្រុង និងស្រុក។

ប៉ុន្តែប្រព័ន្ធអភិបាលកិច្ចធនធានទឹក ត្រូវជួបបញ្ហាប្រឈម ដោយសារកង្វះយន្តការឆ្លើយតបឲ្យបានត្រឹមត្រូវ និងការសហការសមស្របរវាងស្ថាប័ននៅកម្រិតផ្សេងៗរបស់រដ្ឋាភិបាល។ ម៉្យាងទៀត ក៏ត្រូវធ្វើការកែលម្អមួយចំនួនដើម្បីលើកកម្ពស់ដំណើរការយន្តការអភិបាលកិច្ចតាមខ្សែបណ្តោយ នៅក្នុងទំនាក់ទំនងរវាងស្ថាប័នរដ្ឋាភិបាលថ្នាក់កណ្តាល (ក្រសួង) រដ្ឋអំណាចខេត្ត/មូលដ្ឋាន និងកសិករ ក៏ដូចជាការកែលម្អយន្តការអភិបាលកិច្ចតាមរយៈខ្សែទទឹង ដើម្បីជួយគាំទ្រដល់ការធ្វើសេចក្តីសម្រេចផ្សេងៗនៅតាមនាយកដ្ឋានពាក់ព័ន្ធ រដ្ឋអំណាចថ្នាក់ឃុំ និងភូមិ។ ដើម្បីអនុវត្តគោលនយោបាយគ្រប់គ្រងធារាសាស្ត្រដោយមានការចូលរួមនិងកិច្ចអភិវឌ្ឍន៍ (PIMD) ប្រកបដោយប្រសិទ្ធភាព ការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋាភិបាល ជាពិសេសក្រសួង និង មន្ទីរធនធានទឹក និងឧតុនិយម អ្នកផ្តល់ជំនួយ អាជ្ញាធរមូលដ្ឋាន សហគមន៍ កសិករប្រើប្រាស់ទឹក (សកបទ) និងកសិករ ត្រូវតែកំណត់ឲ្យបានច្បាស់លាស់។ PIMD ដែលទទួលស្គាល់នូវតម្រូវការ ឲ្យមានការចូលរួមកាន់តែច្រើនពីសហគមន៍មូលដ្ឋាន ដើម្បីកែលម្អការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ[១] បាននិងកំពុងអនុវត្តនៅកម្ពុជា។ ដោយសង្ខេប PIMD ក្នុងបរិបទកម្ពុជា មានន័យថា សកបទ មានការទទួលខុសត្រូវ និងអំណាចដ៏សំខាន់ ដើម្បីគ្រប់គ្រង ជួសជុល និងកែលម្អប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ និងដើម្បីលើកកម្ពស់និងដឹកនាំការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រថ្មីៗ។ PIMD ត្រូវបានចាត់ទុកជាគោលនយោបាយថ្នាក់ជាតិនៅកម្ពុជា និងជាយុទ្ធសាស្ត្រស្នូលសម្រាប់លើកកម្ពស់ការចូលរួមរបស់កសិករក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ[២]។

និរន្តរភាពនៃការគ្រប់គ្រងធារាសាស្ត្រ ពឹងផ្អែកសំខាន់លើការអនុវត្តនរបស់កសិករ សកបទ ហើយនិងជំនួយគាំទ្រផ្នែកសម្ភារៈ និងថវិការបស់ស្ថាប័នពាក់ព័ន្ធ ដូចជា ក្រសួងធនធានទឹក និងឧតុនិយម មន្ទីរធនធានទឹក និងឧតុនិយម ទាយក និងអង្គការសង្គមស៊ីវិល។ ការសិក្សាកម្រិតភូមិ បានបង្ហាញនូវវិសមភាពរវាងអាណត្តិផ្លូវការដែលផ្តល់ឲ្យ សកបទ និងប្រសិទ្ធភាពពិតប្រាកដរបស់អាណត្តិនេះ។ ទោះបីជា សកបទ មានការទទួលខុសត្រូវស្របច្បាប់តាមបែបបទរដ្ឋបាលក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រក៏ដោយ ក៏កសិករភាគច្រើនមិនបានបង្ហាញស្មារតីជាម្ចាស់លើប្រព័ន្ធធារាសាស្ត្រ ឬគម្រោងធារាសាស្ត្រទេ ហើយនៅតែបន្តស្នើសុំជំនួយឧបត្ថម្ភពីរដ្ឋអំណាចមូលដ្ឋាន និងមន្ទីរធនធានទឹក ដើម្បីដោះស្រាយបញ្ហានានាដែលកើតចេញពីការប្រើប្រាស់ទឹកដដែល។ ម៉្យាងទៀត ដោយសារប្រព័ន្ធធារាសាស្ត្រ ភាគច្រើនពុំមានប្រព័ន្ធប្រឡាយស្រោចស្រពគ្រប់គ្រាន់ សកបទ ក៏ជួបការលំបាកក្នុងការប្រមូលថ្លៃសេវាកម្មប្រើប្រាស់ទឹក (ថសទ) ដ៏ចាំបាច់សម្រាប់យកមកដំណើរការ និងថែទាំប្រព័ន្ធធារាសាស្ត្រ។ កង្វះស្មារតីជាម្ចាស់របស់សហគមន៍មូលដ្ឋានលើប្រព័ន្ធធារាសាស្ត្រ មួយផ្នែកកើតចេញពីកង្វះភាពពេញលក្ខណៈច្បាប់នៃ សកបទ ដែលបង្កឡើងដោយសារការលំបាក និងភាពយឺតយ៉ាវក្នុងដំណើរការចុះបញ្ជីទទួលស្គាល់ជាផ្លូវការ។ ទោះបីបានក្លាយជាស្ថាប័នឯករាជ្យមានអាណត្តិច្បាស់លាស់ក្នុងកិច្ចសហការ និងសម្របសម្រួលរាល់បញ្ហាពាក់ព័ន្ធនឹងធនធានទឹកក៏ដោយ ក៏ សកបទ នៅខ្វះសិទ្ធិអំណាចគ្រប់គ្រាន់សម្រាប់ដោះស្រាយបញ្ហា ហើយត្រូវជួបការលំបាកក្នុងការដោះស្រាយ និងគ្រប់គ្រងទំនាស់។ ដូច្នេះហើយក្នុងការអនុវត្តជាក់ស្តែង សកបទ ត្រូវពឹងផ្អែកលើរដ្ឋអំណាចមូលដ្ឋាន ស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល និងអង្គការអន្តរជាតិផ្សេងៗ ដើម្បីបំពេញតួនាទីស្នូលរបស់ខ្លួន។

មានអ្នកពាក់ព័ន្ធជាច្រើនបានផ្តល់ជំនួយហិរញ្ញវត្ថុសម្រាប់យកទៅអភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ប៉ុន្តែការរៀបចំថវិកាសម្រាប់ចំណាយលើការដំណើរការ និងថែទាំប្រព័ន្ធធារាសាស្ត្រឲ្យមាននិរន្តរភាព នៅមានការខ្វះខាតនៅឡើយ។ ចាប់ពីឆ្នាំ១៩៧៩ មកទល់បច្ចុប្បន្ន ទឹកប្រាក់ដ៏ច្រើនរួមមាន ថវិកាជាតិ កម្ចីពីធនាគារ និងហិរញ្ញវត្ថុទទួលបានពីអ្នកផ្តល់ជំនួយត្រូវបានយកទៅស្តារ សាងសង់ (និងគ្រប់គ្រង) ប្រព័ន្ធធារាសាស្ត្រ ទំនប់ការពារទឹកជំនន់ និងតម្លើងស្ថានីយបូមទឹក។ និរន្តរភាពហិរញ្ញវត្ថុសម្រាប់ទ្រទ្រង់ការផ្តល់សេវាកម្មធារាសាស្ត្រ គួរតែអាចសម្រេចទៅបានតាមការរំពឹងទុក ព្រោះសេវាកម្មនេះបានផ្តល់ទៅឲ្យអ្នកប្រើប្រាស់ទឹកដែលបានយល់ព្រមជាមុនលើការបង់ថ្លៃសេវាកម្ម។ ក៏ប៉ុន្តែ សកបទ មួយចំនួនបានឲ្យដឹងថាកសិករមិនចង់ចូលរួមចំណែកក្នុងដំណើរការ និងការថែទាំប្រព័ន្ធធារាសាស្ត្រទេ។ ដើម្បីដោះស្រាយបញ្ហានេះ សកបទ ត្រូវរកជំនួយថវិកាគាំទ្រពីរដ្ឋាភិបាល ជាពិសេសក្រសួងធនធានទឹក និងមន្ទីរធនធានទឹក ក៏ដូចជាពីគ្រប់ទីភ្នាក់ងារផ្តល់ជំនួយដទៃទៀត។ ខាងរដ្ឋាភិបាល ក៏បានខិតខំលើកទឹកចិត្តដល់វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល (NGOs) និងអង្គការអន្តរជាតិ ឲ្យចូលរួមវិនិយោគ និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រខ្នាតតូច មធ្យម និងធំ។

---

១ នាយករងនៃនាយកដ្ឋាន សកបទ នៃក្រសួងធនធានទឹក ក្នុងបទបង្ហាញស្តីពី មេរៀន និងដំណោះស្រាយស្តីពី PIMD នៅក្នុងសិក្ខាសាលាថ្នាក់ជាតិ រៀបចំដោយអង្គការសេដាក (CEDAC ឬមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា) នៅសណ្ឋាគារភ្នំពេញ ថ្ងៃទី១៧ ធ្នូ ២០០៩។

២ នាយកដ្ឋាន សនកទ នៃក្រសួងធនធានទឹក នៃព្រះរាជាណាចក្រកម្ពុជា។

ដើម្បីគ្រប់គ្រងធនធានទឹកក្នុងបរិបទអាងផ្ទៃរងទឹកភ្លៀង ត្រូវមានការលើកកម្ពស់គណនេយ្យភាព តម្លាភាព សមភាព និងការចូលរួមពីសាធារណជន នៅក្នុងគោលនយោបាយអភិបាលកិច្ចធនធានទឹក ព្រមទាំងការប្ដេជ្ញាចិត្តខ្ពស់ពីអ្នកពាក់ព័ន្ធ។ ការកែលម្អប្រព័ន្ធអភិបាលកិច្ចធនធានទឹក ដែលបង្កើតឡើងក្រោមក្របខ័ណ្ឌច្បាប់មានស្រាប់នៅកម្រិតអាងទន្លេ (ស្ទឹង) នឹងជួយគាំទ្រសមត្ថភាព សកបទ អាជ្ញាធរមូលដ្ឋាន និងស្ថាប័នមូលដ្ឋាន ដើម្បីគ្រប់គ្រងធនធានទឹកឲ្យមាននិរន្តរភាពក្នុងបរិបទសង្គម និងបរិស្ថានមួយដ៏ទូលំទូលាយ។

ការអនុវត្តគោលនយោបាយគ្រប់គ្រងធនធានទឹកចម្រុះ PIMD និងគោលនយោបាយផ្ទេរការគ្រប់គ្រងធារាសាស្ត្រ[៣] និងការបង្កើត សកបទ នៅថ្នាក់មូលដ្ឋានត្រូវអនុវត្តដោយប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ ជាពិសេសលើទិដ្ឋភាពគោលនយោបាយ វប្បធម៌ សេដ្ឋកិច្ច-សង្គមកិច្ច និងលក្ខណៈរូបវ័ន្ត ដែលមាននៅតាមតំបន់នីមួយៗ។ កិច្ចសហការ និងការងារវិមជ្ឈការនៅសហគមន៍ មូលដ្ឋាននៅយឺតយ៉ាវ ជាពិសេសអភិបាលកិច្ចធនធានទឹក ហើយត្រូវការពេលវេលាបន្ថែមទៀតដើម្បីអាចសម្រេចបានល្អតាមគោលដៅ។ ក្នុងតំបន់ជាច្រើនជុំវិញអាងទន្លេសាប ប្រជាជន និងសហគមន៍មូលដ្ឋាន នៅបន្តពឹងផ្អែកលើកិច្ចសហការ ឬគាំទ្រពីរចនាសម្ព័ន្ធនយោបាយមូលដ្ឋាននៅឡើយ ដូចជា ក្រុមប្រឹក្សាឃុំ/សង្កាត់ អភិបាលស្រុក មន្ទីរពាក់ព័ន្ធនានា ដើម្បីធ្វើការសម្រេចចិត្តសំខាន់ៗ។ ក្រុមការងារបច្ចេកទេសទឹក និងកសិកម្ម (ក្របទក) ក៏បានទទួលស្គាល់ដែរថា មុខងារខ្លះ របស់អ្នកពាក់ព័ន្ធនៅមិនទាន់សហការគ្នាបានល្អទេ ហើយនៅមានគម្លាត និងភាពត្រួតស៊ីគ្នាខ្លះៗ ដែលត្រូវធ្វើការកែលម្អ នៅក្នុងកំណែទម្រង់រដ្ឋបាលសាធារណៈ។

ជាបន្ថែមលើតម្រូវការឲ្យមានរចនាសម្ព័ន្ធសហការកាន់តែប្រសើរ និងប្រព័ន្ធអភិបាលកិច្ចកាន់តែមានគណនេយ្យភាព គេក៏ត្រូវពិចារណាពីវិនិយោគផងដែរ ដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនៃប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់។ ប្រព័ន្ធធារាសាស្ត្រពុំមានតម្លៃបច្ចេកទេស និងហិរញ្ញវត្ថុទេ បើសិនជាពុំអាចផ្ដល់អត្ថប្រយោជន៍ពិតប្រាកដ និងទាន់ពេលវេលាដល់កសិករ។

## លទ្ធផលរកឃើញជាធាតុសំខាន់សម្រាប់ការរៀបចំគោលនយោបាយគ្រប់គ្រងធនធានទឹក

ចំណុចមួយក្នុងវិធីសាស្ត្រស្រាវជ្រាវដោយមានការចូលរួម គឺត្រូវស្នើឲ្យអ្នកពាក់ព័ន្ធលើកគោលការណ៍សំខាន់ៗដោយផ្អែកតាមការអនុវត្តជាក់ស្ដែង សម្រាប់យកទៅដោះស្រាយបញ្ហាប្រឈមនានាដែលបានជួបប្រទះក្នុងការងារគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ។ តាមនេះគេឃើញថា អ្នកពាក់ព័ន្ធមួយចំនួនចង់ឲ្យមានការជួយគាំទ្រផ្នែកបច្ចេកទេសបន្ថែម និងការបកស្រាយពន្យល់ឲ្យបានច្បាស់លាស់ អំពីតួនាទី និងលក្ខណៈពិសេសនៃការគ្រប់គ្រងទឹកចម្រុះ ហើយនិងទំនាក់ទំនងរបស់វាទៅនឹងគោលនយោបាយដទៃទៀត ដូចជា គោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និង PIMD ជាដើម។ ទោះបីជាគោលនយោបាយទាំងនេះត្រូវបានយកទៅអនុវត្តនៅថ្នាក់ជាតិក្ដី ប៉ុន្តែនៅក្នុងសហគមន៍មូលដ្ឋានមិនទាន់ឃើញមានយកទៅអនុវត្តពេញលេញទេ។ ជោគជ័យនៃការអនុវត្តគំនិតផ្តួចផ្តើមថ្នាក់ជាតិទាំងអស់នេះអាស្រ័យទៅលើភាពរឹងមាំនៃរចនាសម្ព័ន្ធអភិបាលកិច្ចមូលដ្ឋាន សមត្ថភាពដឹកនាំថ្នាក់មូលដ្ឋាន សមត្ថភាពគ្រប់គ្រង និងបច្ចេកទេសជំនាញផងដែរ។

គំហើញនៃការស្រាវជ្រាវ អាចការផ្ដល់ជាការសន្និដ្ឋានបានថា ត្រូវមានរចនាសម្ព័ន្ធមួយចំនួនដើម្បីកែលម្អកិច្ចសហការកម្រិតអាងទន្លេ ឬកម្រិតខេត្ត ដែលអាចបង្កើននូវបច្ចេកទេសជំនាញ ដើម្បីជួយដល់ សកបទ បណ្ដាស្ថាប័នរដ្ឋាភិបាល និងក្រុមអ្នកពាក់ព័ន្ធឯទៀត ដោយពុំមានដកហូតនូវសិទ្ធិអំណាចរបស់ពួកគេក្នុងការធ្វើសេចក្ដីសម្រេចចិត្តលើធនធានរបស់ពួកគេ។ ផ្អែកលើមតិឆ្លើយតបរបស់អ្នកពាក់ព័ន្ធ ការស្រាវជ្រាវនេះក៏បានស្នើឡើងនូវរចនាសម្ព័ន្ធថ្មីមួយ គឺការបង្កើតអនុគណៈកម្មាធិការគ្រប់គ្រងធារាសាស្ត្រ និងអាងទន្លេ (ICMS) ដើម្បីគ្រប់គ្រងធនធានទឹកនៅថ្នាក់ក្រោមជាតិ។ អនុគណៈកម្មាធិការនេះ អាចមានទម្រង់ផ្សេងៗគ្នា ផ្អែកតាមភូមិសាស្ត្រជាក់ស្ដែង។

ដើម្បីជាជំនួយដល់ការពិភាក្សា នៅក្នុងអនុសាសន៍ដូចតទៅនេះមានការបកស្រាយពន្យល់ពីគោលបំណង និងមុខងាររបស់អនុគណៈកម្មាធិការ ការកំណត់នូវជម្រើសមួយចំនួន និងការពិចារណាសំខាន់ៗ សម្រាប់ការបង្កើតអនុគណៈកម្មាធិការនេះ។ គោលបំណងចម្បងនៃការគិតគូរពិចារណាទាំងនេះ គឺដើម្បីធានាថា បទពិសោធន៍ពីអតីតកាលបានជួយដល់ការ

៣ គោលនយោបាយនេះ ស្ថិតក្រោមគោលនយោបាយដើម្បីនិរន្តរភាពនៃកិច្ចដំណើរការ និងការថែទាំប្រព័ន្ធធារាសាស្ត្រ ដែលមានចែងក្នុងប្រកាសរបស់ក្រសួងធនធានទឹកលេខ ៣០៦ ចុះថ្ងៃទី ២០ មិថុនា ២០០០ (ជំពូក ២,២ ទំព័រ ៤)។

អភិវឌ្ឍរចនាសម្ព័ន្ធថ្មី ហើយកំណែប្រែថ្មីពិតជាជួយគាំទ្រដល់រចនាសម្ព័ន្ធមានស្រាប់ មិនបង្កើតឲ្យមានភាពត្រួតស៊ីគ្នានៃតួនាទី និងបានជាជំនួយសម្រាប់កិច្ចពិភាក្សាស្វែងរកការមូលមតិគ្នា (Consensus) ថាតើអនុគណៈកម្មាធិការនេះមានអាណត្តិកម្រិតណា និងតើគួររក្សាតម្លាភាពយ៉ាងណាដើម្បីកុំឲ្យប៉ះពាល់ដល់តួនាទី និងអំណាចដ៏សំខាន់នៅក្នុងមូលដ្ឋាននៃ សកបទ ដែលទើបបង្កើតថ្មី។

អនុសាសន៍នៃគោលនយោបាយទាំងនេះ ត្រូវបានលើកមកពិភាក្សានៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ កម្រិតសហគមន៍ បន្ទាប់មកទើបដាក់ឆ្លងអង្គសិក្ខាសាលាថ្នាក់ខេត្តជាបន្តបន្ទាប់ ដែលមានការចូលរួមពី សកបទ និងមន្ទីរធនធានទឹក។ សិក្ខាសាលាទាំងនេះ ធ្វើឡើងក្នុងគោលបំណងដោះស្រាយបញ្ហាសំខាន់ៗទាក់ទងនឹងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងគោលនយោបាយគ្រប់គ្រងធនធានទឹកចម្រុះ ដែលកំណត់បានតាមរយៈវិភាគអ្នកពាក់ព័ន្ធទាំងអស់។

## អនុសាសន៍ទី ១៖ គួរបង្កើតអនុគណៈកម្មាធិការគ្រប់គ្រងធារាសាស្ត្រ និងអាងទន្លេ

គួរពិចារណាបង្កើត ICMS នៅថ្នាក់ក្រោមជាតិ ដើម្បីជួយជំរុញកិច្ចសហការរវាង សកបទ មន្ទីរពាក់ព័ន្ធខេត្ត និងអាជ្ញាធរមូលដ្ឋាន ក្នុងការធ្វើសេចក្តីសម្រេចលើការងារសមាហរណកម្ម ផែនការ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹកក្នុងកម្រិតអាងទន្លេ។ អនុគណៈកម្មធិការនេះនឹងជួយបង្កើនការយល់ដឹងជាទូទៅអំពី PIMD និង គោលនយោបាយគ្រប់គ្រងធនធានទឹកចម្រុះ ក្នុងចំណោម សកបទ អាជ្ញាធរមូលដ្ឋាន និងមន្ទីរពាក់ព័ន្ធខេត្ត ក៏ដូចជាជួយគាំទ្រដល់ការធ្វើសមាហរណកម្មសហគមន៍នានានៅប៉ែកខាងលើ និងខាងក្រោមខ្សែទឹក ហើយជួយណែនាំដល់សហគមន៍ទាំងនោះឲ្យផ្តល់នូវធនធានដ៏ចាំបាច់សម្រាប់ជាមធ្យោបាយដល់ការកសាងរចនាសម្ព័ន្ធអភិបាលកិច្ច នៅក្នុងគោលនយោបាយគ្រប់គ្រងអាងទន្លេរបស់រាជរដ្ឋាភិបាលកម្ពុជាថែមទៀតផង។

### *មុខងាររបស់ អកធអ*

- លើកកម្ពស់ដំណើរការ "ពីក្រោមទៅលើ" នៃគម្រោងអភិវឌ្ឍន៍ និងគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ខ្នាតតូច មធ្យម និងធំ ក្នុងបរិបទអាងទន្លេ ដោយគិតគូដល់គោលការណ៍គ្រឹះរបស់ គោលនយោបាយគ្រប់គ្រងធនធានទឹកចម្រុះ ផលប្រយោជន៍របស់អ្នកពាក់ព័ន្ធ ទាំងអស់ និងនិរន្តរភាពនៃធនធានធម្មជាតិ។
- រួមសហការជាមួយស្ថាប័នពាក់ព័ន្ធ ដូចជា ក្រសួងធនធានទឹក ក្រសួងកសិកម្ម មន្ទីរធនធានទឹក មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គការសង្គមស៊ីវិល អភិបាលខេត្ត អាជ្ញាធរមូលដ្ឋាន រាជបណ្ឌិតសភា និងមជ្ឈមណ្ឌលស្រាវជ្រាវ ដូចជា វបសអ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យកសិកម្ម សាកលវិទ្យាល័យអន្តរជាតិ និងទាយក ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង ធនាគារពិភពលោក ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ដើម្បីស្វែងរកជំនួយគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ។
- ផ្តល់ទីកន្លែងដើម្បីផ្លាស់ប្តូរជំនាញបច្ចេកទេសបន្ថែម រួមមាន ការផ្តល់មតិប្រឹក្សាជំនាញរវាងបណ្តាមន្ទីរពាក់ព័ន្ធខេត្ត NGOs ទាយក និងជំនាញការអន្តរជាតិ ក្នុងការងារជលសាស្ត្រ និងការគ្រប់គ្រងធនធានទឹកចម្រុះ ដើម្បីឲ្យអនុគណៈកម្មាធិការអាចបំពេញនូវមុខងារជាមជ្ឈមណ្ឌលផ្តល់សេវាកម្មម្រាប់ សកបទ។
- ផ្តល់ជាវេទិកាសម្រាប់ការអែអង្គាសថវិកា និងការផ្តល់មតិប្រឹក្សាផ្តល់ដោយ NGOs និង ទាយក។
- ផ្តល់ជាឱកាសសម្រាប់ការដោះស្រាយជម្លោះពីប្រព័ន្ធធារាសាស្ត្រមួយទៅមួយ និងសម្រាប់ សកបទរួមគ្នាធ្វើផែនការដាំដុះរបស់ខ្លួន តាមរយៈការទទួលបានព័ត៌មានដ៏ចាំបាច់ ដោយផ្អែកលើចំណេះដឹងផ្នែកសង្គម និងជលសាស្ត្រ។
- ធ្វើការត្រួតពិនិត្យ និងវាយតម្លៃផលប៉ះពាល់ និងការងារផ្សេងៗពាក់ព័ន្ធនឹងធនធានទឹក នយោបាយទឹក និងប្រសិទ្ធភាពនៃសភាពរបស់អនុគណៈកម្មាធិការ ដោយប្រើវិធីសាស្ត្រវាយតម្លៃដោយមានការចូលរួម។

### *បញ្ហាគួរពិនិត្យពិចារណា*

ក្នុងការកំណត់រចនាសម្ព័ន្ធអភិបាលកិច្ចនៃ ICMS គួរពិចារណាអំពីបញ្ហាមួយចំនួនដូចខាងក្រោម៖

- *ស្ថាប័នដឹកនាំ និងសមាជិកអនុគណៈកម្មាធិការ៖* ការកំណត់ស្ថាប័នរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ និងសមស្រប ដើម្បីដឹកនាំអនុគណៈកម្មាធិការ មានសារៈសំខាន់ណាស់។ បញ្ហានេះរួមមាន ការកំណត់ថា តើអនុគណៈកម្មាធិការនេះត្រូវស្ថិតក្រោមការដឹកនាំរបស់ថ្នាក់គ្រប់គ្រងខេត្ត ឬថ្នាក់អាងទន្លេ? ហើយតើស្ថាប័នរដ្ឋាភិបាលណាខ្លះដែលត្រូវធ្វើជាប្រធានអនុគណៈកម្មាធិការនេះ ឬមួយខុទ្ទកាល័យខេត្តគួរដឹកនាំការងារនេះ ដោយផ្អែកលើគោលនយោបាយថ្នាក់ជាតិរបស់រាជរដ្ឋាភិបាលស្ដីពីការគ្រប់គ្រងធនធានទឹកចម្រុះ (កគធទច) និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ?

- *អាណត្តិនិងសមត្ថកិច្ច៖* អនុគណៈកម្មាធិការនេះ ត្រូវមានអាណត្តិពេញលេញ មានប្រសិទ្ធភាពតម្លាភាព និងមិនប៉ះពាល់ដល់អំណាចធ្វើការសម្រេចចិត្តរបស់ សកបទ និងស្ថាប័នពាក់ព័ន្ធដទៃ។ យន្តការសម្រាប់បង្កើតគណនេយ្យភាពចំពោះថ្នាក់ក្រោមសំខាន់ខ្លាំងណាស់ ដើម្បីធ្វើឲ្យ សកបទ បំពេញតួនាទីជាតំណាងសហគមន៍ពិតប្រាកដ និងអាចទទួលជំនួយបច្ចេកទេស និងថវិកា តាមរយៈអនុគណៈកម្មាធិការខាងលើ។ សកបទ ត្រូវរាយការណ៍ទៅអនុគណៈកម្មាធិការ ដើម្បីអនុវត្តសមត្ថកិច្ចរបស់ខ្លួន ក្នុងករណី ចរចា កាត់ក្ដី និងសហការជាមួយបណ្ដា សកបទ ពាក់ព័ន្ធ។ អនុគណៈកម្មាធិការនេះ ក៏អាចត្រូវមានតួនាទីជាអ្នកផ្ដល់ប្រឹក្សា ជាជាងជាអ្នកមានសមត្ថកិច្ចពេញលេញលើការសម្រេចលើការងារបែងចែកទឹក នៅកម្រិតប្រព័ន្ធធារាសាស្ត្រ ឬកម្រិតអាងទន្លេ ដើម្បីទុកឲ្យសហគមន៍មូលដ្ឋាននៅមានតួនាទីស្នូលក្នុងការត្រួតពិនិត្យលើការសម្រេចចិត្ត អំពីបញ្ហាសំខាន់ៗ[៤]។

- *ភាពខុសប្លែកគ្នារវាងអាងទន្លេ និងប្រព័ន្ធធារាសាស្ត្រ៖* ការបង្កើតឲ្យមានអនុគណៈកម្មាធិការនៅថ្នាក់ខេត្ត ឬថ្នាក់អាងទន្លេ បានផ្ដល់នូវរចនាសម្ព័ន្ធដឹកនាំក្នុងបរិបទមួយជាក់លាក់ ដែលក្នុងនោះសមត្ថកិច្ចអាចក្លាយជាកម្លាំងក្នុងការធ្វើសេចក្ដីសម្រេចលើការងារគ្រប់គ្រងទឹក និងធារាសាស្ត្រ របស់ សកបទ អាជ្ញាធរមូលដ្ឋាន និងមន្ទីរជុំវិញខេត្ត។ អនុគណៈកម្មាធិការនេះ អាចមានទម្រង់ និងរចនាសម្ព័ន្ធដឹកនាំផ្សេងៗគ្នានៅតាមតំបន់នីមួយៗ ដោយផ្អែកលើលក្ខណៈធម្មជាតិនៃអាងទន្លេ និងកម្រិតសមត្ថភាពអ្នកពាក់ព័ន្ធ។ ICMS នេះ គួររៀបចំឡើងសម្រាប់អាងទន្លេមួយជាក់លាក់ ដោយផ្អែកលើកត្តាថា តើ ICMS នេះ មានតួនាទីស្របគ្នាកម្រិតណានឹងសមត្ថកិច្ចនៃរដ្ឋបាលខេត្ត?

- *ការពិគ្រោះយោបល់បន្ថែមជាមួយអ្នកពាក់ព័ន្ធ៖* អនុគណៈកម្មាធិការគួរបង្កើតឡើងបន្ទាប់ពីបានធ្វើការសិក្សា ឬការពិគ្រោះយោបល់រួមគ្នា។ អនុគណៈកម្មាធិការនេះមិនគួរបង្កើតឡើងសម្រាប់ជា "ខែលការពារ" ដោយពុំមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធនោះទេ។ ដំណើរការបង្កើតអនុគណៈកម្មាធិការនេះ ត្រូវមានការសម្របសម្រួលគ្នារវាងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីឲ្យអនុគណៈកម្មាធិការទទួលបានជោគជ័យ។

## អនុសាសន៍ទី ២៖ ការអប់រំបណ្ដុះបណ្ដាល

ត្រូវយកចិត្តទុកដាក់បណ្ដុះបណ្ដាលអ្នកពាក់ព័ន្ធនៅមូលដ្ឋាន ជាពិសេសមន្ត្រីមន្ទីរធនធានទឹក ក្រុមប្រឹក្សាឃុំ/សង្កាត់ កសិករ និងសមាជិកគណៈកម្មាធិការ សកបទ អំពីគោលនយោបាយ និងច្បាប់សំខាន់ៗ ដើម្បីបង្កើនការយល់ដឹងពីសិទ្ធិ និងកាតព្វកិច្ចរៀងៗខ្លួន ក្នុងការប្រើប្រាស់ធនធានធម្មជាតិ។ វគ្គបណ្ដុះបណ្ដាលគួរផ្ដោតលើមុខវិជ្ជាដូចខាងក្រោម៖

- ច្បាប់ស្ដីពីការគ្រប់គ្រងធនធានទឹក ព្រៃឈើ ជលផល ដីធ្លី និងបរិស្ថាន
- គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និង PIMD
- ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាល[៥] (Organic Law)

---

៤ អ្នកពាក់ព័ន្ធគាំទ្រការស្នើបង្កើតអនុគណៈកម្មាធិការថ្មី ដើម្បីគ្រប់គ្រងធនធានទឹកកម្រិតអាងផ្ទៃរងទឹកភ្លៀង រួមមាន កសិករ សកបទ អាជ្ញាធរមូលដ្ឋាន (ប្រធានភូមិ/ឃុំ, អភិបាលស្រុក, មន្ត្រីខេត្ត និងអភិបាលរងខេត្ត) ស្ថាប័នរដ្ឋាភិបាល និង NGOs ដែលទៅចូលរួមក្នុងសិក្ខាសាលាថ្នាក់ខេត្ត បានរៀបចំឡើងនៅតាមខេត្តកំពង់ឆ្នាំង កំពង់ធំ និងពោធិ៍សាត់ កាលពីខែកុម្ភៈ ដល់ មេសា ២០១០។

៥ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ, RGC 2008។

- គោលការណ៍ណែនាំ និងបទដ្ឋានស្តីពីច្បាប់រដ្ឋបាល

### អនុសាសន៍ទី៣៖ ការកសាងសមត្ថភាពគ្រប់គ្រង និងដឹកនាំនៅមូលដ្ឋាន

ត្រូវកសាងសមត្ថភាពគណៈកម្មាធិការ សកបទ និងក្រុមប្រឹក្សាឃុំ/សង្កាត់ ដើម្បីគ្រប់គ្រងធនធានទឹកឲ្យបានត្រឹមត្រូវ និងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដឹកនាំសហគមន៍ ពិសេសសមត្ថភាពជំនាញពាក់ព័ន្ធនឹង៖

- ការដឹកនាំ សម្របសម្រួល និងទំនាក់ទំនង
- ការបែងចែកថវិកា និងគ្រប់គ្រងហិរញ្ញវត្ថុ
- ការគ្រប់គ្រងធនធានធម្មជាតិ
- ការគ្រប់គ្រង និងអភិវឌ្ឍន៍គម្រោង
- ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ និងដំណាំកសិកម្ម

### អនុសាសន៍ទី៤៖ លើកកម្ពស់គណនេយ្យភាព សកបទ

លើកកម្ពស់គណនេយ្យភាព សកបទ និងអាជ្ញាធរមូលដ្ឋាន តាមរយៈកិច្ចសហការរឹងមាំពីសំណាក់អ្នកពាក់ព័ន្ធ។ គណៈកម្មាធិការ សកបទ ត្រូវអនុវត្តការងាររបស់ខ្លួនស្របតាមតួនាទី និងកាតព្វកិច្ចមានចែងក្នុងលក្ខន្តិកៈដោយទទួលស្គាល់ថា ជំនួយឧបត្ថម្ភផ្នែកថវិកា គឺមានកម្រិត។ បញ្ហាត្រូវយកចិត្តទុកដាក់ រួមមាន៖

- លើកទឹកចិត្តកសិករឲ្យទទួលស្គាល់ពីសារៈសំខាន់នៃ ថ្លៃសេវាកម្មប្រើប្រាស់ទឹក ហើយចូលរួមដោយសាទរក្នុងការដំណើរការ និង ការថែទាំ (ដនថ) ប្រព័ន្ធធារាសាស្ត្រប្រកបដោយនិរន្តរភាព។
- ផ្សព្វផ្សាយ និងបំផុសកសិករឲ្យចូលរួមក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ធារាសាស្ត្រ ចាប់ពីដំណាក់កាលដំបូង និងក្នុងដំណាក់បន្តបន្ទាប់នៃគម្រោង។
- ធ្វើឲ្យប្រព័ន្ធធារាសាស្ត្រផ្តល់ប្រយោជន៍ដល់កសិករបានកាន់តែច្រើន ដោយរិះរកបច្ចេកទេសថ្មីៗ និងសមស្របសម្រាប់គ្រប់គ្រងទឹក និងស្វែងរកបច្ចេកទេសកសិកម្មប្រពលវប្បកម្មល្អៗ ដើម្បីឲ្យកសិករទទួលបានផល និងចំណូលកាន់តែច្រើន។
- ផ្តល់ទឹក និងព័ត៌មានកសិកម្មទាន់ពេលដល់កសិករ និងជំរុញពួកគាត់ឲ្យមានស្មារតីស្រឡាញ់ទ្រព្យសម្បត្តិសាធារណៈ។

#### *បញ្ហាគួរពិនិត្យពិចារណា*

សកបទ ខ្លះ បានលើកថា បើសិនប្រព័ន្ធធារាសាស្ត្រ និងសមត្ថភាពគ្រប់គ្រងរបស់ សកបទ មិនទាន់លើកកម្ពស់ឲ្យបានសមស្របតាមចិត្តកសិករដែលរំពឹងចង់បានទឹកគ្រប់គ្រាន់នោះទេ ការបង្កើនគណនេយ្យភាពរបស់ សកបទ ការអនុវត្តតាមគោលនយោបាយគ្រប់គ្រងធនធានទឹក និងការចូលរួមរបស់អ្នកពាក់ព័ន្ធនឹងជួបការលំបាក។

### អនុសាសន៍ទី ៥៖ ការបង្កើនកិច្ចសហការនៅតំបន់អាងទន្លេសាប

ការធ្វើវិមជ្ឈការនៃការគ្រប់គ្រងធនធានទឹក មិនអាចសម្រេចបានទេប្រសិនបើអ្នកពាក់ព័ន្ធនានា ជាពិសេសកសិករ មិនបានយល់ច្បាស់ និងមិនចូលរួមការពារនិងថែទាំទ្រព្យសម្បត្តិរួម។ បញ្ហាសំខាន់មួយចំនួនដែល អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធនៅជុំវិញអាងទន្លេសាប គួរគិតគូពិចារណារួមមាន៖

- ធ្វើការចែករំលែកការយល់ដឹងអំពីគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ និងការគ្រប់គ្រងធារាសាស្ត្រដោយមានការចូលរួម និងកិច្ចអភិវឌ្ឍន៍ ដល់អ្នកពាក់ព័ន្ធនានា ដើម្បីឲ្យពួកគេបាន យល់ដឹងច្បាស់។
- ធ្វើប្រតិភូកម្មការទទួលខុសត្រូវក្នុងកម្រិតមួយសមស្រប ដូចជា ការធ្វើផែនការ ការអនុវត្តការគ្រប់គ្រង ការធ្វើសេចក្ដីសម្រេចក្នុងការងារគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹក ទៅដល់សហគមន៍មូលដ្ឋាន សកបទ អង្គការសង្គមស៊ីវិលវិស័យឯកជន។ល។ ដើម្បីបង្កើនការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន។
- ចែករំលែកថវិកាសម្រាប់កិច្ចដំណើរការ និងកិច្ចការរដ្ឋបាល ដើម្បីគាំទ្រសហគមន៍មូលដ្ឋាន មានជាអាទិ៍ ផ្នែកគណនេយ្យភាព និងហិរញ្ញវត្ថុ/សហប្រត្តិការហិរញ្ញវត្ថុ។
- ធ្វើកំណែទម្រង់ និងលើកកម្ពស់ការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងកម្រិតអាងទន្លេសាប ដើម្បីឲ្យមានសមាជិកចូលរួមច្រើនលើសពីសមាជិករបស់អនុគណៈកម្មាធិការ ដោយបង្កើនកិច្ចសហការល្អរវាងសហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិលវិស័យឯកជន និងមន្ទីរពាក់ព័ន្ធជុំវិញខេត្ត ហើយកំណត់បញ្ហាអាទិភាព និងបញ្ហាបន្ទាន់ ដើម្បីយកមកដោះស្រាយ ឲ្យបានសមស្រប និងទាន់ពេល។

## អនុសាសន៍ទី ៦៖ ការស្រាវជ្រាវបន្ថែម

ករណីសិក្សា និងសិក្ខាសាលាថ្នាក់ខេត្ត ដែលធ្វើឡើងនៅបណ្ដាខេត្តទាំង ៣ បានបង្ហាញថា ការបញ្ចូលសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ទៅក្នុងរចនាសម្ព័ន្ធ សកបទ (ជាសមាជិកគណៈកម្មាធិការ សកបទ) អាចជួយរក្សាមុខងារច្បាប់ និងប្រតិបត្តិការរបស់ សកបទ បានល្អ។ អ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានមួយចំនួនបានលើកថា ការធ្វើសមាហរណកម្មនេះនឹងបង្កើនតួនាទីនិងគណនេយ្យភាពរបស់គណៈកម្មាធិការ សកបទ តាមរយៈ

- ការពង្រឹងអំណាចសកបទ ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ។
- កិច្ចសហការ និងសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ។
- ការលើកកម្ពស់ការចែករំលែកព័ត៌មានស្ដីអំពី គោលនយោបាយទឹក និងកសិកម្ម។
- ការកែលម្អគុណភាព និងដំណើរការធ្វើសេចក្ដីសម្រេចចិត្ត និងផែនការ លើគម្រោងអភិវឌ្ឍន៍ និងវិនិយោគ។
- ការកាត់បន្ថយទំនាស់តឹងតែងជាមួយអាជ្ញាធរមូលដ្ឋាន និងបង្កើនទំនុកចិត្ត និងការចូលរួមពីសាធារណជន។

ដូច្នេះ ការស្រាវជ្រាវបន្ទាប់ត្រូវអនុវត្តលើប្រធានបទមួយចំនួនដូចខាងក្រោម៖

- តើ សកបទ និង ក្រុមប្រឹក្សាឃុំ/សង្កាត់ អាចលើកកម្ពស់ការចូលរួមរបស់កសិករ ឬការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រង ធនធានទឹកយ៉ាងណា ដើម្បីធានានិរន្តរភាពនៃប្រព័ន្ធធារាសាស្ត្រ?
- ក្នុងបរិបទនៃអភិបាលកិច្ចធារាសាស្ត្រ និងផ្ទៃរងទឹកភ្លៀង តើគោលនយោបាយ PIMD និងវិមជ្ឈការនិងវិសហមជ្ឈការ អាចត្រូវបានបន្សាំ និងអនុវត្តដោយមានប្រសិទ្ធភាពយ៉ាងដូចម្ដេច ?
- តើភាពជាដៃគូរវាងរដ្ឋាភិបាល ទាយក សហគមន៍ និងវិស័យឯកជន ក្នុងការគ្រប់គ្រងធារាសាស្ត្រ អាចបង្កើតឡើងយ៉ាងណាបាន? តើយន្តការអ្វីមានប្រសិទ្ធភាពបំផុតសម្រាប់ពង្រឹងភាពជាដៃគូនេះ?
- តើគួរបញ្ចូលសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃគណៈកម្មាធិការ សកបទ ដើម្បីជួយគាំទ្រផ្នែក បច្ចេកទេស និងសមត្ថកិច្ច ដែរឬទេ?

# សេចក្តីផ្តើម

## ១.១ សាវតារ

ប្រទេសកម្ពុជាសំបូរទៅដោយធនធានទឹក ហើយត្រូវពឹងផ្អែកលើធនធានទាំងនោះ នៅក្នុងវិស័យសេដ្ឋកិច្ចដ៏ចម្បង សម្រាប់ប្រជាជនភាគច្រើន ពោលគឺ កសិកម្ម និងជលផល។ កម្ពុជាកំពុងប្រឈមនឹងបញ្ហាជាច្រើនក្នុងការអភិវឌ្ឍ គ្រប់គ្រង និងអភិរក្សធនធានទឹក ដើម្បីឲ្យការប្រើប្រាស់ទឹកអនុវត្តទៅបានប្រកបដោយប្រសិទ្ធភាព សមភាព និងនិរន្តរភាព។ ក្នុងការងារអភិវឌ្ឍន៍ និងគ្រប់គ្រងធារាសាស្ត្រក្នុងបរិបទអាងផ្ទៃរងទឹកភ្លៀង[៦] តួអង្គពាក់ព័ន្ធនានា រួមមាន កសិករ ស្ថាប័នរដ្ឋបាល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា កំពុងជួបបញ្ហាប្រឈមយ៉ាងខ្លាំងខាងផ្នែកអភិបាលកិច្ច។

ស្ថាប័នពាក់ព័ន្ធមួយចំនួនបានទាមទារចំណែក (នៃការគ្រប់គ្រង) ឬសិទ្ធិជាម្ចាស់លើធនធានសាធារណៈ ហើយក្នុងពេលជាមួយគ្នា ក៏មានអាជ្ញាធរច្រើនជាន់ថ្នាក់ដែលពាក់ព័ន្ធក្នុងការគ្រប់គ្រង និងការធ្វើសេចក្តីសម្រេចទាក់ទិននឹងការអភិវឌ្ឍ និងបែងចែកធនធានទឹក។ ស្ថាប័នរដ្ឋបាលមានជំនាញផ្សេងៗគ្នាជាច្រើនដែលជួនកាលមានការខ្វែងមតិគ្នាផង ក៏ត្រូវធ្វើការជាមួយគ្នាដើម្បីដោះស្រាយបញ្ហាគ្រប់គ្រងធនធានទឹកនេះដែរ។

ប្រទេសកម្ពុជា មានវិធីរៀបចំការគ្រប់គ្រងជាក់លាក់សំរាប់តួអង្គពាក់ព័ន្ធផ្សេងៗគ្នា ដែលកំពុងមានឥទ្ធិពលលើការអភិវឌ្ឍ ការប្រើប្រាស់ និងការអភិរក្សធនធានទឹក។ ការគ្រប់គ្រងទឹកដែលដំណើរការបានល្អ ទាមទារឲ្យមានការយល់ដឹងស្របគ្នាអំពីការទទួលខុសត្រូវ និងតួនាទីរបស់អ្នកពាក់ព័ន្ធនីមួយៗ ប៉ុន្តែអ្នកពាក់ព័ន្ធមកពីស្ថាប័នមួយ អាចមិនបានយល់ឃើញដូចគ្នានឹងអ្នកពាក់ព័ន្ធមកពីស្ថាប័នមួយផ្សេងទេ ហើយករណីនេះក៏តែងកើតមាននៅតាមប្រទេសដទៃទៀតដែរ។

អភិបាលកិច្ចធនធានទឹក ពាក់ព័ន្ធទៅនឹងវិស័យសាធាណៈ វិស័យឯកជន អ្នកធ្វើការនៅថ្នាក់សហគមន៍មូលដ្ឋាន ឬតួអង្គពាក់ព័ន្ធផ្សេងទៀត។ "អភិបាលកិច្ច" ជាពាក្យមួយដែលហាក់ថ្មីថ្មោងបន្តិច ហើយប្រភពដើមពិតប្រាកដរបស់វា ក៏គេពុំបានដឹងច្បាស់ដែរ (Clever & Franks, 2005)។ ស្នងការសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិប្រចាំទ្វីបអាស៊ី និងប៉ាស៊ីហ្វិកខាងត្បូង (UNESCAP) បានឲ្យនិយមន័យពាក្យអភិបាលកិច្ចថាជា ដំណើរការនៃការសម្រេចចិត្ត និងជាដំណើរការដែលតាមរយៈនោះការសម្រេចចិត្តផ្សេងៗត្រូវបានអនុវត្ត (ឬមិនត្រូវបានអនុវត្ត) (UNESCAP, 2009) )។ ការស្រាវជ្រាវមួយទៀតបានកំណត់និយមន័យពាក្យ អភិបាលកិច្ច ថាជាទំនាក់ទំនងនៃអំណាចឯករាជ្យ រវាងស្ថាប័នពាក់ព័ន្ធផ្សេងគ្នាក្នុងសកម្មភាពរួមគ្នាមួយ (Germy, 1998)។ ប៉ុន្តែនៅក្នុងសាកលភាវូបនីយកម្ម និងប្រជាតិបតេយ្យភាវូបនីយកម្ម ដែលកំពុងកើតមាននៅកម្រិតខុសៗគ្នា ការពាក់ព័ន្ធនៃវិស័យឯកជន និងវិស័យទីបី (អង្គការសង្គមស៊ីវិល) ក្នុងការបង្កើតគោលនយោបាយ ការផ្តល់សេវាកម្ម និងការផ្តល់ឲ្យអំណាចឲ្យ អង្គការសង្គមស៊ីវិល បានចោទសំណួរពីតួនាទីជាប្រពៃណីរបស់រដ្ឋាភិបាលក្នុងការរៀបចំជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ បញ្ហាប្រឈមទាំងអស់នេះ ទាមទារឲ្យមានការគិតគូរឡើងវិញពីទំនាក់ទំនង និងដំណើរការធ្វើសេចក្តីសម្រេចនៅក្នុងសង្គម ដែលស្តែងឡើងតាមរយៈពាក្យថ្មីមួយគឺ "អភិបាលកិច្ច" (Clever & Franks, 2005)។

ក្នុងការសិក្សាស្រាវជ្រាវនេះ ពាក្យ **អភិបាលកិច្ចធនធានទឹក** សំដៅដល់ វិធីសាស្ត្រគ្រប់គ្រងធនធានទឹកមួយដែលក្នុងនោះ អំណាចត្រូវបានគេរៀបចំ ចែករំលែក និងចរចាគ្នានៅក្នុងសង្គម ព្រមទាំងអន្តរកម្ម និងដំណើរការផ្សេងៗដែលពាក់ព័ន្ធក្នុងការសម្រេចចិត្តពីរបៀបរបបត្រូវអភិវឌ្ឍ និងប្រើប្រាស់ធនធានទឹក ក៏ដូចជា ត្រូវបែងចែកផលប្រយោជន៍ និងហានិភ័យ។ ក្នុងនេះក៏មានទាំង ឥទ្ធិពលគ្រប់បែបយ៉ាងដែលកើតមានតាមការរៀបចំរបៀបវារៈ និងការពិចារណាពីជម្រើសផ្សេងៗ ការរៀបចំស្ថាប័ននិងអង្គការចាត់តាំង និងតាមមធ្យោបាយអនុវត្តកិច្ចការទាំងនេះនៅក្នុងការគ្រប់គ្រងទឹកប្រចាំថ្ងៃជាក់ស្តែង។ ដូច្នេះ អភិបាលកិច្ចមិនមែនការងារផ្តាច់មុខរបស់រដ្ឋនោះទេ ហើយក៏មិនស្ថិតក្នុងកម្រិត ឬសៀវភៅពិសេសមួយជាក់លាក់នោះដែរ ប៉ុន្តែវាផុសចេញពីអន្តរកម្មផ្សេងៗរវាងរដ្ឋ សហគ្រាសអាជីវកម្ម និងស្ថាប័នមិនស្វែងរកចំណេញ នៅតាមកម្រិតជាច្រើន។

៦ ជាការផ្តល់ទឹកតាមបែបធម្មជាតិ និងជាអន្តរកម្មដ៏ស្មុគស្មាញរវាងផ្នែកនានាដែលជាប់ទាក់ទងគ្នាចុះឡើងនៃប្រព័ន្ធជលសាស្ត្រ និងប្រព័ន្ធអេកូឡូស៊ីផ្សេងៗទៀត។

ទោះជាប្រើប្រាស់និយមន័យណាមួយក៏ដោយ ក៏គេឃើញច្បាស់ថា កង្វល់របស់អ្នកពាក់ព័ន្ធសំខាន់ខ្លាំងណាស់នៅក្នុងទស្សនទាននៃអភិបាលកិច្ច និងនៅក្នុងការបង្កើតដំណើរការគ្រប់គ្រង។ ក្នុងការអភិវឌ្ឍរចនាសម្ព័ន្ធអភិបាលកិច្ចល្អ ត្រូវមានការយល់ដឹងច្បាស់ពីការពិតជាក់ស្តែង និងភាពស្មុគស្មាញនៃទំនាក់ទំនង និងផលប្រយោជន៍របស់អ្នកពាក់ព័ន្ធខុសៗគ្នា ដើម្បីវាយតម្លៃ និងប៉ាន់ប្រមាណពីផលប៉ះពាល់ ព្រមទាំងវាយតម្លៃពីសមត្ថភាពមនុស្ស។ ឯកសារនេះ ធ្វើការវិភាគទៅលើអ្នកពាក់ព័ន្ធនានា ដែលចូលរួមក្នុងការងារអភិបាលកិច្ចធនធានទឹក ក្នុងបរិបទនៃការគ្រប់គ្រងធារាសាស្ត្រ និងអាងទន្លេ ដើម្បីផ្តល់ព័ត៌មានអំពី៖

- បុគ្គល ក្រុម និងស្ថាប័ន ដែលអាចរងផលប៉ះពាល់ និងអាចទទួលប្រយោជន៍ពី ការគ្រប់គ្រងធនធានទឹក និងធនធានពាក់ព័ន្ធឯទៀត ដូចជាត្រីជាដើម
- បុគ្គល ក្រុម និងស្ថាប័ន ដែលអាចមានឥទ្ធិពល និងរួមចំណែកដល់ដំណើរការគ្រប់គ្រងធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀត។

ឯកសារនេះព្យាយាមធ្វើការវិភាគលើតួនាទី ទំនាក់ទំនង និងទស្សនៈរបស់អ្នកពាក់ព័ន្ធ ដែលធ្វើការក្នុងវិស័យគ្រប់គ្រងធនធានទឹកនៅប្រទេសកម្ពុជា ដោយផ្តោតសំខាន់ទៅលើការគ្រប់គ្រងធារាសាស្ត្រ និងអាងទន្លេ។ ការវិភាគត្រូវបានរចនារៀបចំឡើង ដើម្បីពិនិត្យលើកម្រិតនៃភាពដូចគ្នា និងភាពខុសគ្នារវាងអ្នកពាក់ព័ន្ធនានា និងរវាងតួនាទីជាផ្លូវការរបស់អ្នកពាក់ព័ន្ធ និងការអនុវត្តជាក់ស្តែងរបស់ពួកគេ។ ការវិភាគក៏បានផ្តល់នូវអនុសាសន៍ផ្នែកគោលនយោបាយមួយចំនួន ដើម្បីជួយដល់អ្នកធ្វើសេចក្តីសម្រេចផងដែរ (សូមអានផ្នែក ៦.១)។

## ១.២ សំណួរស្រាវជ្រាវ

ការស្រាវជ្រាវនេះផ្តោតលើ សំណួរស្រាវជ្រាវសំខាន់ៗចំនួន ៣ គឺ៖

១. តើតួអង្គណាខ្លះដែលជាអ្នកពាក់ព័ន្ធដ៏សំខាន់ក្នុងការងារអភិបាលកិច្ចធនធានទឹកនៅកម្ពុជា? តើមានយន្តការ និងរបៀបរៀបចំកិច្ចសហការជាផ្លូវការអ្វីខ្លះ រវាងអ្នកពាក់ព័ន្ធទាំងនោះ?

២. តើតួនាទី ទំនាក់ទំនង និងការយល់ដឹងរបស់អ្នកពាក់ព័ន្ធសំខាន់ៗ មានលក្ខណៈដូចម្តេច ក្នុងរបៀបរៀបចំអភិបាលកិច្ចធនធានទឹកបច្ចុប្បន្ន ហើយតើវាដំណើរការដោយរលូនជាមួយគ្នាល្អឬទេ ក្នុងចំណោមអ្នកពាក់ព័ន្ធនៅកម្រិតផ្សេងៗគ្នា?

៣. តើមានភាពស្រប និងមិនស្របគ្នាអ្វីខ្លះ រវាងតួនាទីជាផ្លូវការ និងការអនុវត្តជាក់ស្តែងរបស់អ្នកពាក់ព័ន្ធនានា?

# វិធីសាស្ត្រស្រាវជ្រាវ - ការវិភាគអ្នកពាក់ព័ន្ធចម្រុះ

ការស្រាវជ្រាវនេះ អនុវត្តដំណើរការវិភាគតាមលំដាប់ថ្នាក់[៧] ដើម្បីស្វែងយល់ស៊ីជម្រៅពីទិន្នន័យប្រមូលបានពីមូលដ្ឋាន និងបណ្តុះគំនិតបន្ថែមអំពីការងារអភិបាលកិច្ចធនធានទឹកបច្ចុប្បន្ន។ ការស្រាវជ្រាវបានប្រមូលទិន្នន័យចាំបាច់តាមរយៈការសម្ភាសជាមួយអ្នកពាក់ព័ន្ធពហុផ្នែក ការចុះអង្កេតដល់កន្លែង ការប្រជុំពិភាក្សាជាមួយក្រុមគោលដៅ និងសិក្ខាសាលាផ្សព្វផ្សាយការស្រាវជ្រាវថ្នាក់ខេត្ត។ ការវិភាគធ្វើឡើងក្នុងគោលបំណងសំខាន់ៗបីយ៉ាងគឺ៖

- កំណត់បញ្ហាសំខាន់ៗទាក់ទងនឹងអភិបាលកិច្ចធនធានទឹកនៅកម្ពុជា ព្រមទាំងកំណត់ និងដោះស្រាយបញ្ហាចន្លោះប្រហោងនៃចំណេះដឹងនាបច្ចុប្បន្នលើការងារនេះ
- ពិនិត្យលើស្ថាប័ន និងតួអង្គពាក់ព័ន្ធនានាដែលពាក់ព័ន្ធនឹងការងារគ្រប់គ្រងទឹក ដើម្បីស្វែងយល់ឲ្យបានច្បាស់ពីសមត្ថភាព និងសក្តានុពលរបស់ពួកគេ
- កំណត់ក្របខ័ណ្ឌនៃការស្រាវជ្រាវ ដើម្បីឲ្យអ្នកកសាងគោលនយោបាយសាធារណៈអាចយកលទ្ធផលទៅធ្វើការប្រៀបធៀប និងវាយតម្លៃលើជម្រើសគោលនយោបាយនានា។

## ២.១ ការកំណត់អត្តសញ្ញាណ និងតួនាទីអ្នកពាក់ព័ន្ធសំខាន់ៗ

ក្រុម និងបុគ្គលដែលពាក់ព័ន្ធគ្នាទៅវិញទៅមកក្នុងមុខងារ និងការប្រើប្រាស់ធនធានទឹក បានកំណត់ឃើញដោយលើកសំណួរដូចខាងក្រោម៖

- តើអ្នកណាខ្លះទទួលបានអត្ថប្រយោជន៍ពីការប្រើប្រាស់ធនធាន ឬប្រព័ន្ធធារាសាស្ត្រទាំងនោះ?
- តើអ្នកណាខ្លះមានសិទ្ធិ និងមានការទទួលខុសត្រូវលើការប្រើប្រាស់ និងគ្រប់គ្រងលើធនធាន និងប្រព័ន្ធធារាសាស្ត្រទាំងនោះ?
- តើអ្នកណាត្រួតត្រាលើប្រព័ន្ធធារាសាស្ត្រ ឬធ្វើសេចក្តីសម្រេចប៉ះពាល់ដល់ការប្រើប្រាស់ និងលក្ខណៈសំខាន់ផ្សេងៗនៃធនធានទាំងនោះ ហើយអ្នកណាខ្លះដែលមិនធ្វើកិច្ចការទាំងនេះ?

បំណែងចែកអ្នកពាក់ព័ន្ធជាពួក ត្រូវបានធ្វើឡើងដើម្បីជ្រើសរើស និងកំណត់អាទិភាពអ្នកពាក់ព័ន្ធ។ បំណែងចែកនេះផ្អែកលើ អំណាច (ឥទ្ធិពល) នៃអ្នកពាក់ព័ន្ធ ភាពពេញច្បាប់នៃផលប្រយោជន៍របស់ពួកគេ និងភាពបន្ទាន់នៃការទាមទាររបស់ពួកគេ[៨]។ ការងារនេះសំខាន់ណាស់ ជាពិសេសបានផ្តល់ការយល់ដឹងស៊ីជម្រៅពីតួនាទីអ្នកពាក់ព័ន្ធក្នុងដំណើរការគ្រប់គ្រង និងអភិបាលកិច្ចធនធានទឹក។ លទ្ធផលនៃការវិភាគតួនាទីអ្នកពាក់ព័ន្ធ ត្រូវបានសំយោគ និងបង្ហាញក្នុងទម្រង់ដ្យាក្រាម និងម៉ាទ្រិកដែលអាចឲ្យគេកំណត់ឃើញបញ្ហាសំខាន់ៗ ដែលត្រូវដោះស្រាយនៅពេលរៀបចំផែនការ។

## ២.២ ការប្រមូលទិន្នន័យ

### *២.២.១ ការសម្ភាសអ្នកពាក់ព័ន្ធសំខាន់ៗ*

ការសម្ភាសពាក់កណ្តាលរៀបរយជាមួយអ្នកពាក់ព័ន្ធ បានធ្វើឡើងនៅតាមទីតាំង និងតាមកម្រិតផ្សេងៗគ្នា ដូចជា នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន ដើម្បីសម្រួលដល់ការវិភាគអ្នកពាក់ព័ន្ធ។ គោលបំណង និងចំណុចសំខាន់ក្នុងការសម្ភាសអ្នកពាក់ព័ន្ធមានពីរយ៉ាង ទី១) ដើម្បីឲ្យបានដឹងច្បាស់ពីតួនាទី និងការរំពឹងទុករបស់ពួកគេលើការងារគ្រប់គ្រងធនធាន

---

៧ វិធីសាស្ត្រនេះផ្អែកលើ Step-wise analytical process ដោយ Hatfield Consultants។ ជំហានទី១ ពាក់ព័ន្ធនឹងការសិក្សាឯកសារស្តីពីរបៀបរៀបចំស្ថាប័នគ្រប់គ្រងទឹក ទី២ ការចុះបញ្ជីនិងកំណត់អ្នកពាក់ព័ន្ធនិង ទី៣ ការកំណត់តួនាទី និងមុខងារអ្នកពាក់ព័ន្ធផ្អែកតាមប្រភេទអ្នកពាក់ព័ន្ធ (viewed on 18 January 2010 at http://www.popstoolkit.com/riskmanagement/module/step3/implementationplanning/stakeholders.aspx)។

៨ សូមអានការពន្យល់នៅផ្នែកបន្ទាប់។

ទឹកក្នុងបរិបទនៃការអភិវឌ្ឍធារាសាស្ត្រនិងទី២) ដើម្បីស្វែងយល់ពីបទពិសោធន៍របស់ពួកគេនៅពេលធ្វើការជាមួយអ្នកពាក់ព័ន្ធសំខាន់ៗឯទៀត ក្នុងក្របខ័ណ្ឌអភិបាលកិច្ចធនធានទឹកនៅកម្ពុជា។

ការសម្ភាសនេះ ក៏ដើម្បីកំណត់ភាពស្របគ្នាក្នុងការយល់ដឹងពីទិដ្ឋភាពធំៗនៃអភិបាលកិច្ចធនធានទឹកក្នុងចំណោមអ្នកពាក់ព័ន្ធសំខាន់ៗផងដែរ។ សម្ភាសន៍បានអនុវត្តតាមវិធីសាស្ត្រពាក់កណ្តាលរៀបរយដោយផ្អែកតាមសំណួរណែនាំមួយចំនួនបានរៀបចំឡើង ដើម្បីឲ្យស្របតាមតួនាទី ការរំពឹងទុក និងបទពិសោធន៍ជាក់លាក់របស់បុគ្គល និងស្ថាប័នពាក់ព័ន្ធ។ សំណួរទាំងនោះ (ឧបសម្ព័ន្ធ ក១) បានយកមកប្រើដើម្បីតម្រែតម្រង់ការពិភាក្សា មិនមែនសម្រាប់សួរឲ្យឆ្លើយចំៗគ្មានល្អៀងនោះទេ។ វិធីសាស្ត្រនេះបានរចនារៀបចំឡើងក្នុងលក្ខណៈអាចបត់បែនទៅតាមបញ្ហា និងអាទិភាពជាក់លាក់របស់អ្នកពាក់ព័ន្ធនៅតាមកម្រិត និងសមត្ថកិច្ចខុសៗគ្នា។

សម្ភាសន៍បានធ្វើឡើងជាលក្ខណៈបុគ្គល ឬជាក្រុម ដូចជា ស្ថាប័នរដ្ឋាភិបាល អ្នកផ្តល់ជំនួយ វិស័យឯកជន អង្គការសង្គមស៊ីវិល (ដូចជា អង្គការមិនមែនរដ្ឋាភិបាល កសិករ សកបទ និងវិទ្យាស្ថានស្រាវជ្រាវ) ប្រធានភូមិ និង ក្របយ (សូមមើលបញ្ជីអ្នកពាក់ព័ន្ធសំខាន់ៗ ក្នុងឧបសម្ព័ន្ធ ក១)។

### ២.២.២ អង្កេតដល់មូលដ្ឋាន និងការប្រជុំក្រុមគោលដៅ

អង្កេតដល់មូលដ្ឋាន និងការប្រជុំក្រុមគោលដៅ បានធ្វើឡើងនៅតាមប្រព័ន្ធធារាសាស្ត្រចំនួន ១០ ក្នុង ៣ខេត្ត នៅក្នុងប្រទេសកម្ពុជា (សូមមើលទីតាំងសិក្សាក្នុងផែនទីនៃរូបភាព ១)។ ការជ្រើសយកទីតាំងទាំងនោះមកសិក្សា ផ្អែកលើស្ថានភាពទីតាំង (ស្ថិតនៅខ្សែទឹកខាងលើ ឬខ្សែទឹកខាងក្រោម) របស់ប្រព័ន្ធ និងភាពខុសប្លែកពីគ្នានៃ ទំហំ សណ្ឋាន និងលក្ខណៈនៃការរៀបចំ ។ ទីតាំងសិក្សាទាំង ១០ រួមមាន៖

- ខេត្តកំពង់ឆ្នាំង មានបួនប្រព័ន្ធគឺ ត្រពាំងត្របែក តាំងក្រសាំង ស្វាយចេក និងប៉ក់ប៉ែន។
- ខេត្តពោធិ៍សាត់ មានបីប្រព័ន្ធគឺ វត្តលាប កំប៉ាង និងដំណាក់អំពិល។
- ខេត្តកំពង់ធំ មានបីប្រព័ន្ធគឺ អូរស្វាយ ស្ទឹងជីនិត និងរលួស។

ការប្រជុំក្រុមគោលដៅធ្វើឡើងដោយប្រើបញ្ជីសំណួរពាក់កណ្តាលរៀបរយ ឯការពិភាក្សាផ្តោតលើបញ្ហានានាទាក់ទិននឹងការគ្រប់គ្រងទឹក។ សមាសភាពក្រុមគោលដៅបានកំណត់ឡើងសម្រាប់ធ្វើការពិភាក្សា ដើម្បីបង្កើនការយល់ដឹងពី វិធីដែលកសិករដោះស្រាយបញ្ហាក្នុងបរិយាកាសជាសមូហភាព ដោយមាន ឬគ្មានវត្តមានប្រធានភូមិ ឬសមាជិក សកបទ។ ការចុះអង្កេតដល់មូលដ្ឋាន បានធ្វើឡើងដំណាលគ្នានឹងការប្រជុំក្រុមគោលដៅ ដើម្បីអាចស្វែងយល់បានកាន់តែងាយថែមទៀតពីហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងទំហំនៃប្រព័ន្ធធារាសាស្ត្រ។

រូបភាព ១៖ ផែនទីនៃទីតាំងសិក្សា




ប្រភព៖ NRE/CDRI 2011

## ២.២.៣ សិក្ខាសាលាថ្នាក់ខេត្ត

វិធីប្រមូលទិន្នន័យមានការបំពេញបន្ថែមមួយចំនួនទៀតអំពី សិក្ខាសាលាផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវថ្នាក់ខេត្តដែលបានរៀបចំឡើងនៅខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងកំពង់ធំ ក្នុងចន្លោះពេលពីឆ្នាំ២០០៩ ដល់ ២០១០ ដោយប្រើវិធីសាស្ត្រឈ្មោះថា វិធានវិភាគផលប៉ះពាល់ប្រកបដោយការចូលរួម[៩] ដើម្បីជួយឲ្យសិក្ខាកាមអាចកំណត់ឧបសគ្គ និងបញ្ហាប្រឈមចំបងៗដែលពួកគាត់កំពុងជួបប្រទះក្នុងការប្រើប្រាស់ទឹក និងដើម្បីរួមគ្នាពិចារណារិះរកវិធីសាស្ត្រសមស្របយកមកដោះស្រាយ ។ សិក្ខាសាលាក៏បានលើកយកមកពិភាក្សានូវលទ្ធផលដំបូងៗនៃការស្រាវជ្រាវ ដើម្បីឲ្យសិក្ខាកាមមកពីតាមខេត្ត ស្រុក និងឃុំ/សង្កាត់ អាចផ្តល់ការប្រឹក្សា និងយោបល់ត្រឡប់។

សិក្ខាកាមបានផ្តុំគ្នាជាបីក្រុមសំខាន់ៗ គឺក្រុមទី១ មានសិក្ខាកាមមកពីមន្ទីរជំនាញខេត្តដូចជា មន្ទីរធនធានទឹក មន្ទីរកសិកម្ម រដ្ឋបាលជលផលខេត្ត (របជខ) មន្ទីរបរិស្ថាន និងអង្គការមិនមែនរដ្ឋាភិបាល។ ក្រុមទី២ ជាសិក្ខាកាមផ្នែក

៩ Boru D., Sophie A., Graham Th. and Ronald M. (2008) បង្ហាញថា Participatory Impact Pathways Analysis (PIPA) ជាវិធានសម្រាប់ធ្វើផែនការ ពិនិត្យតាមដាន និងវាយតម្លៃ ដែលគេបង្កើតឡើងសម្រាប់ប្រើក្នុងគម្រោងមានភាពសាំញ៉ាំក្នុងវិស័យទឹក និងអាហារ។ វិធាននេះ ចាប់ផ្តើមពីសិក្ខាសាលាប្រកបដោយការចូលរួម ដែលក្នុងនោះ សិក្ខាកាមលើកបញ្ជាក់នូវការប៉ាន់ស្មានរបស់ខ្លួនអំពីផលប៉ះពាល់ដែលគម្រោងរបស់គាត់អាចនឹងសម្រេចបាន។

អាជ្ញាធរមូលដ្ឋាន មានដូចជា តំណាងអភិបាលខេត្ត អភិបាលឬអភិបាលរងស្រុក មេឃុំ និងក្រុមប្រឹក្សាឃុំ។ ក្រុមទី៣ ជាសិក្ខាកាមដែលជាកសិករ និង សកបទ។ សិក្ខាសាលា ក៏ផ្តល់ជាវេទិកាដើម្បីបង្កើតកិច្ចសហការ និងជួយឲ្យសិក្ខាកាមទាំងបីក្រុមអាចរួមកម្លាំងគ្នា ១) ស្វែងរក និងកំណត់អាទិភាពលើបញ្ហាសំខាន់ៗក្នុងការគ្រប់គ្រងទឹក ២) កំណត់ទស្សនវិស័យ និងដំណោះស្រាយលើបញ្ហាទាំងនោះ ៣) កំណត់អ្នកពាក់ព័ន្ធសំខាន់ៗ និងតួនាទីរបស់ពួកគេក្នុងការគ្រប់គ្រងទឹក ៤) កំណត់យុទ្ធសាស្ត្រ និងការស្រាវជ្រាវចាំបាច់ដើម្បីសម្រេចបានលទ្ធផលរំពឹងទុក និង ៥) ផ្តល់យោបល់ ដើម្បីជួយបង្កើតជាគោលការណ៍ណែនាំសម្រាប់ការអភិវឌ្ឍធារាសាស្ត្រ និងការបែងចែកទឹកក្នុងបរិបទផ្ទៃរងទឹកភ្លៀង។

វិធីសាស្ត្រនេះបានជួយឲ្យក្រុមស្រាវជ្រាវអាចផ្តល់ជាការយល់ដឹងមួយចំនួនដល់អ្នកពាក់ព័ន្ធ ដើម្បីគ្រប់គ្រង និងលើកកម្ពស់ការប្រើប្រាស់ទឹក និងអភិបាលកិច្ចធនធានទឹកនៅមូលដ្ឋាន។

# ការសិក្សាបណ្ណាល័យសាស្ត្រ (ការសិក្សាតាមឯកសារស្រាវជ្រាវ)

ការសិក្សាបណ្ណាល័យសាស្ត្របានធ្វើឡើងដើម្បីកំណត់ ពិភាក្សា និងវិភាគអំពីអ្នកពាក់ព័ន្ធ។ ដំបូងការសិក្សានេះបានធ្វើឡើងក្នុងទស្សនទានដាច់ដោយឡែកពីគ្នា ហើយនៅលើកទី២ ក្នុងទស្សនទានមានជាប់ទាក់ទងទៅនឹងការងារអភិបាលកិច្ចធនធានទឹកសំខាន់ៗដូចជា ការចូលរួម កិច្ចសហការ និងការគ្រប់គ្រងទឹកចម្រុះ។

## ៣.១ មតិឯកភាពបច្ចុប្បន្នលើនិយមន័យពាក្យ "អ្នកពាក់ព័ន្ធ"

ទស្សនទានអំពីពាក្យ "អ្នកពាក់ព័ន្ធ" មាននិយមន័យច្រើនយ៉ាងនៅក្នុងឯកសារស្រាវជ្រាវនានា។

លោក Bryson (2003) បានសង្កត់ន័យធ្ងន់ថា ទស្សនទានអំពីពាក្យ "អ្នកពាក់ព័ន្ធ" មានប្រវត្តិ និងការវិវត្តជាយូរលង់មកហើយ។ ឧទាហរណ៍ ដើមឡើយនៅឆ្នាំ១៧០៨ ពាក្យ អ្នកពាក់ព័ន្ធ សំដៅដល់ ជនទំនុកចិត្តដែលកាន់ប្រាក់ភ្នាល់ឲ្យគេ គឺនៅពេលមានអ្នកឈ្នះ ជននោះត្រូវប្រគល់ប្រាក់ភ្នាល់ ទៅឲ្យអ្នកឈ្នះក្នុងការភ្នាល់គ្នានោះ (តាមសៀវភៅ Merrian-Webster Collegiate Dictionary, 10th Edition, 1998)។ ក្រោយមកកើតមាននិយមន័យទី២ មួយថែមទៀត ដែលក្នុងនោះពាក្យ "អ្នកពាក់ព័ន្ធ" មានន័យថា អ្នកដែលមានភាគហ៊ុន ឬផលកំរៃនៅក្នុងក្រុមហ៊ុនណាមួយ (តាមវចនានុក្រម American Heritage Dictionary of the English Language, 4th Edition, 2000)។

នៅពេលធ្វើការស្ទង់មតិលើក្រុមអ្នកពាក់ព័ន្ធផ្សេងៗគ្នាដូចជា អ្នកពាក់ព័ន្ធសកម្ម និងអ្នកពាក់ព័ន្ធអកម្ម ឬអ្នកពាក់ព័ន្ធទី១ និងអ្នកពាក់ព័ន្ធទី២ (សំខាន់ និងមិនសូវសំខាន់) លោក Grimble & Wellard (1997) បានទទួលស្គាល់ថា ការបែងចែកអ្នកពាក់ព័ន្ធជាពីរក្រុមដូចខាងលើនេះ មិនអាចដាច់ណាត់ទាំងស្រុងទេ។ ឧទាហរណ៍ ក្នុងបរិបទនៃបណ្តាប្រទេសកសិកម្មនៅអាស៊ីអាគ្នេយ៍ ក្រុមកសិករតូចៗ តែងពាក់ព័ន្ធក្នុងលក្ខណៈជាអ្នកបែងចែកទឹកសកម្ម និងជាអ្នកទទួលទឹកអកម្មនៃប្រព័ន្ធធារាសាស្ត្រ។ ក្នុងបញ្ហាដ៏ស្មុគស្មាញនេះ ពាក្យអ្នកពាក់ព័ន្ធអាចមានន័យស្មើនឹងពាក្យថា "អ្នកដែលមានទំនាក់ទំនង" ជាមួយនឹងអ្នកពាក់ព័ន្ធឯទៀត យោងទៅតាមឥទ្ធិពល (អំណាច) និងផលប្រយោជន៍របស់ពួកគេ (ទំហំត្រូវប៉ះពាល់) នៅក្នុងប្រព័ន្ធជាក់លាក់ណាមួយ។ ប្រសិនបើក្រុមអ្នកទទួលផល យល់ឃើញថាផលប្រយោជន៍របស់ពួកគេកំពុងរងការគំរាមកំហែងដោយក្រុមម្ខាងទៀត នោះពួកគេនឹងប្រើអំណាច និងឥទ្ធិពលរបស់ពួកគេ ដើម្បីរារាំងក្រុមម្ខាងទៀត កុំឲ្យសម្រេចបំណងបាន (FAO 1997)។ ការយល់ដឹងច្បាស់ពីផលប្រយោជន៍របស់ក្រុមអ្នកពាក់ព័ន្ធ អាចនាំឲ្យមានជោគជ័យក្នុងការរៀបចំផែនការ និងសកម្មភាពអនុវត្តនានា។

ក្នុងបញ្ហានិយមន័យនេះដែរ លោក Mitchell *et al.* (1997) បានលើកយកអថេរចំនួន៣ មកធ្វើការកំណត់ និងផ្តល់អាទិភាពលើអ្នកពាក់ព័ន្ធសំខាន់ៗគឺ **អំណាច** របស់អ្នកពាក់ព័ន្ធ **ភាពពេញច្បាប់** នៃផលប្រយោជន៍របស់ពួកគេ និង **ភាពបន្ទាន់** នៃការទាមទាររបស់ពួកគេ មកបកស្រាយពន្យល់។

នៅក្នុងបំណែងចែកជាពួកនេះ អំណាច ភាពពេញច្បាប់ និង ភាពបន្ទាន់ អាចទាក់ទិនគ្នា ឬត្រួតផ្សំគ្នាច្រើនបែបយ៉ាង ហើយអាចយកមកពិចារណាក្នុងពេលដំណាលគ្នាព្រោះថា "អំណាចទទួលបានសមត្ថកិច្ចតាមរយៈភាពពេញច្បាប់ ហើយវាត្រូវបានយកមកអនុវត្តដោយសារ ភាពបន្ទាន់" (Mitchell *et al.* 1997)។ ពេលគេយកទៅអនុវត្តលើទំនាក់ទំនងនៃអ្នកពាក់ព័ន្ធសំខាន់ៗក្នុងប្រព័ន្ធអភិបាលកិច្ចធនធានទឹក ក្របខ័ណ្ឌនៃទំនាក់ទំនងនេះ អាចជួយបំភ្លឺ (និងជួយពន្យល់) ពីមូលដ្ឋានគ្រឹះនៃទស្សនវិស័យផ្សេងៗគ្នារបស់ កសិករ អ្នកគ្រប់គ្រងថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។

ចំណាត់ថ្នាក់នៃក្រុមអ្នកពាក់ព័ន្ធក្នុងរូបភាព ២ បានបង្ហាញនូវទស្សនទានអំពីក្រុមអ្នកពាក់ព័ន្ធនានា ដែលមានជាអាទិ៍៖

១. "អ្នកពាក់ព័ន្ធទាំងស្រុង" គឺជាអ្នកមានមែកធាងទាំងបី គឺ អំណាច ភាពពេញច្បាប់ និង ភាពបន្ទាន់។ ក្រុមនេះទទួលបានការយកចិត្តទុកដាក់ខ្លាំងជាងគេ។

២. "អ្នកពាក់ព័ន្ធដ៏មានអំណាច" ស្ថិតនៅលំដាប់ទី២ និងមានអំណាចក្នុងការទាមទារអ្វីមួយ ស្របទៅតាមច្បាប់។ ឯក្រុម "អ្នកពាក់ព័ន្ធដោយការពឹងពាក់" គឺជាក្រុមដែលការទាមទាររបស់ពួកគេហាក់មានភាពពេញច្បាប់ និងបន្ទាន់។ ចំណែកក្រុម "អ្នកពាក់ព័ន្ធដ៏មានគ្រោះថ្នាក់" ជាក្រុមមានអំណាច និងមានទាមទារបន្ទាន់ តែមិនពេញច្បាប់ទេ។

៣. ក្រុមនៅសេសសល់ គឺមាន "អ្នកពាក់ព័ន្ធស្ងាត់ស្ងៀម" ដែលមិនសូវលេចធ្លោទេ តែអ្នកផងយល់ថា ពោរពេញដោយអំណាច ប៉ុន្តែខ្លួនគេអះអាងថា គ្មានភាពបន្ទាន់ និងគ្មានសមត្ថកិច្ចទេ។ ចំណែកឯក្រុម"អ្នកពាក់ព័ន្ធដោយសារការសម្រេច" គឺមានសមត្ថកិច្ច ប៉ុន្តែគ្មានអំណាច ឬភាពបន្ទាន់នោះទេ។ ឯក្រុម "អ្នកពាក់ព័ន្ធដោយសារការទាមទារ" គឺមានភាពបន្ទាន់ ក៏ប៉ុន្តែក្រុមនោះគ្មានអំណាច ឬសមត្ថកិច្ចទេ។ ក្រុមចុងក្រោយគឺ "ក្រុមអ្នកមិនពាក់ព័ន្ធ" ដែលជាក្រុមគ្មានអំណាច គ្មានភាពបន្ទាន់ និងគ្មានផលប្រយោជន៍នៅក្នុងគំរោង ឬសហគមន៍ (Mitchell *et al.* 1917, Cited in Chevalier, 2002) ។

រូបភាព ២៖ បំណែងចែកអ្នកពាក់ព័ន្ធ ការបង្ហាញមែកធាង មួយ ពីរ ឬបី




ប្រភព៖ លោក Mitchell *et al.* (1997)

នៅក្នុងឯកសារស្រាវជ្រាវនេះ "អ្នកពាក់ព័ន្ធ" គឺសំដៅលើក្រុមតួអង្គដែលចែករំលែកផលប្រយោជន៍គ្នានៅក្នុងប្រព័ន្ធសេដ្ឋកិច្ច សង្គមកិច្ច ឬបរិស្ថានជាក់លាក់ណាមួយ។ ស្របគ្នាទៅនឹងភស្តុតាងបញ្ជាក់ឡើងតាមរយៈការវិភាគ អ្នកពាក់ព័ន្ធអាចមានប្រភពមកពីផ្នែកណាមួយនៃសង្គម ដូចជា ស្ថាប័នរដ្ឋបាល ឬទីភ្នាក់ងារអន្តរជាតិចម្រុះ ឬក៏បណ្តាញនៅស្រទាប់ក្រោម និងប្រជាពលរដ្ឋឬបុគ្គលណាមួយ (Grimble and Wellard 1997)។ ដូចគ្នានេះដែរ ការចែករំលែកផលប្រយោជន៍ដូចលើកខាងលើ អាចធ្វើឡើងនៅកម្រិតគ្រួសារ មូលដ្ឋាន តំបន់ ឬក៏សាកល។

## ៣.២ ការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងការធ្វើឲ្យវិវត្តទស្សនទាននៃអភិបាលកិច្ចធនធានទឹក

ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ការចូលរួមរបស់អ្នកពាក់ព័ន្ធបានក្លាយជាប្រធានបទដ៏លេចធ្លោមួយនៅក្នុងការស្រាវជ្រាវសង្គម និងនៅក្នុងការពិភាក្សាអំពីការអភិវឌ្ឍគោលនយោបាយ។ ការប្រែប្រួលនិន្នាការងាកទៅលើកកម្ពស់ "អភិបាលកិច្ចធនធានទឹក" នាពេលថ្មីៗ ធ្វើឲ្យការចូលរួមរបស់អ្នកពាក់ព័ន្ធ កាន់តែមានលក្ខណៈរាប់បញ្ចូល និងគ្រប់ជ្រុងជ្រោយ ប៉ុន្តែការប្រែប្រួលនេះ ស៊ីជម្រៅ និងធំទូលាយប៉ុណ្ណា គឺនៅមិនទាន់ច្បាស់ទេ។ បច្ចុប្បន្ន ការចូលរួមរបស់សហគមន៍នៅក្នុងដំណើរការរៀបចំរបៀបរបបសម្រាប់ត្រួតពិនិត្យការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ តែងជួយលើកកម្ពស់ជោគជ័យនៃសកម្មភាពរួមគ្នា និងដំណើរការប្រកបដោយប្រសិទ្ធភាពនៃប្រព័ន្ធធារាសាស្ត្រ (Isham & Satu 1998)។

លោក Cooke & Kothari (2001) បានលើកឡើងថា ការគ្រាន់តែអនុវត្តតាមនីតិវិធីផ្លូវការ និងការណែនាំបច្ចេកទេសណែនាំនៃ "វិធីសាស្ត្រប្រកបដោយការចូលរួមដើម្បីអភិវឌ្ឍន៍" វាមិនគ្រប់គ្រាន់ទេ គឺត្រូវពិចារណាផងដែរអំពីទិដ្ឋភាពសង្គមដ៏សំខាន់នៃការធ្វើសេចក្តីសម្រេចចិត្តដោយស្មើភាព និងការចូលរួមដែលគួរកើតមានឡើងនៅគ្រប់ដំណាក់កាលនៃដំណើរការអភិវឌ្ឍន៍សង្គម (Bagaolion & Korten 1991)។ ឧទាហរណ៍ កសិករជាអ្នកពាក់ព័ន្ធដ៏សំខាន់ដែលគួរមានឥទ្ធិពលខ្លះ តាំងពីដំណាក់កាលដំបូងនៃការរចនារៀបចំប្រព័ន្ធធារាសាស្ត្រ មិនមែនគ្រាន់តែចូលរួមតាមក្រោយនៅក្នុងកិច្ចដំណើរការ និងការ

ថែទាំប្រព័ន្ធដែលសង់ឡើងដោយអ្នកជំនាញការពីខាងក្រៅនោះទេ (សូមអានឧទាហរណ៍របស់លោក Ostrom 1992)។ នៅក្នុងទិដ្ឋភាពទូទៅ ស្ថាប័នជំនាញសម្រាប់អភិបាលកិច្ចធនធានទឹក គួរតែកសាងឡើងដោយមានការចូលរួមពីសហគមន៍នៅគ្រប់ដំណាក់កាល។

> *"វិធីសាស្ត្រប្រកបដោយការចូលរួម (ឬដំណើរការដោះស្រាយពីក្រោមទៅលើ ដូចជាការពិគ្រោះយោបល់ជាមួយអ្នកទទួលផល ការធ្វើផែនការរួមគ្នា ការពាក់ព័ន្ធនៃអង្គការមិនមែនរដ្ឋាភិបាល និងការបង្កើតក្រុមអ្នកទទួលផលជាដើម) ត្រូវបានបង្កើតឡើង និងយកទៅអនុវត្តទូទាំងសាកលលោក បន្ទាប់ពីមានការយល់ឃើញថា ដំណោះស្រាយពីលើចុះក្រោម ឬដំណោះស្រាយជម្រុញដោយអ្នកគាំទ្រ គឺជាមូលហេតុបង្កបញ្ហាចោទ"* (ADB 2009a:1)។

ច្បាប់ទឹករបស់ប្រទេសកម្ពុជាដែលបានតាក់តែងឡើង ដោយមានជំនួយគាំទ្រពីអ្នកជំនាញការ (ក្នុងការព្រាង) និងការផ្ដល់មូលនិធិពីអន្តរជាតិ អាចទទួលផលច្រើនពីរបៀបដោះស្រាយដូចខាងលើ។ ដើម្បីឲ្យមានការចូលរួមយ៉ាងសកម្មពីអ្នកពាក់ព័ន្ធទាំងឡាយ ការសិក្សាឯកសារស្រាវជ្រាវបានបង្ហាញពី របៀបដោះស្រាយមួយចំនួនដែលអាចសមស្របតាមបរិបទនៅកម្ពុជា និងដែលត្រូវបានយកមកសាកល្បងប្រើដោះស្រាយបញ្ហាមួយចំនួន ដូចមានលើកឡើងនៅក្នុងឯកសារស្រាវជ្រាវនេះ។ ឧទាហរណ៍ វិធីកៀងគរឲ្យអ្នកពាក់ព័ន្ធចូលរួម ប្រហែលត្រូវកែសម្រួលឲ្យប្រសើរឡើងទៀត ដើម្បីអាចដំណើរការបាននៅក្នុងបណ្ដាញសង្គម និងនយោបាយដែលមានស្រាប់ ដូចជា ក្រុមប្រឹក្សាឃុំ និងអង្គការគ្រប់គ្រងធនធានធម្មជាតិរបស់សហគមន៍មូលដ្ឋានជាដើម។

## ៣.៣ ឯកសារស្រាវជ្រាវ និងការអនុវត្តជាក់ស្ដែងស្ដីពី កគទច និងការចូលរួមរបស់អ្នកពាក់ព័ន្ធ

ទស្សនទាននៃ កគទច ត្រូវបានពង្រឹងពង្រីកឲ្យក្លាយជាគោលការណ៍ណែនាំ នៅក្នុងឯកសារច្បាប់អន្តរជាតិសំខាន់ៗជាច្រើនដូចជា សេចក្ដីថ្លែងការក្រុង Dublin ឆ្នាំ១៩៩២ (The Dublin Statement, ជំពូកទី១៨ នៃ Agenda 21 of Rio Earth Summit, UNCED 1992) និងនៅក្នុងឯកសារនៃកិច្ចប្រជុំសាកលស្ដីពីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពជាដើម។ ដោយមានចែងនៅក្នុងគោលការណ៍ណែនាំ និងសេចក្ដីប្រកាសជាអន្តរជាតិខាងលើ គោលការណ៍រួមស្ដីពី "ការចែករំលែក" ត្រូវបានបង្កើតឡើង[១០] ដោយមានបញ្ជាក់ថា "ត្រូវតែធ្វើប្រតិភូកម្មការគ្រប់គ្រងទឹក ទៅឲ្យថ្នាក់គ្រប់គ្រងនៅស្រទាប់ក្រោមបំផុតដែលសមស្រប"។ គំនិតមានបង្កប់នូវតម្រូវការឲ្យមានស្វ័យភាពមួយកម្រិតក្នុងការធ្វើសេចក្ដីចម្រេចចិត្ត "ពីក្រោមទៅលើ" មិនមែនមានត្រឹមតែការធ្វើប្រតិភូកម្មការទទួលខុសត្រូវពីលើចុះក្រោម ទៅតាមលំដាប់ឋានានុក្រមនោះទេ។

> *ដើម្បីសម្រេចបានការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព សមភាព និងនិរន្តរភាព តាមវិធាននៃ កគទច ត្រូវតែមានការផ្លាស់ប្ដូរផ្នែកស្ថាប័ន។ ការចូលរួមរបស់អ្នកពាក់ព័ន្ធទាំងអស់ ទាំងពីលើចុះក្រោម និងពីក្រោមទៅលើ ត្រូវតែលើកកម្ពស់ឡើង ពោលគឺពីកម្រិតថ្នាក់ជាតិ ទៅថ្នាក់ភូមិ ឬថ្នាក់ក្រុង ឬពីកម្រិតផ្ទៃរងទឹកភ្លៀង ឡើងទៅកម្រិតអាងទន្លេ។ គោលការណ៍ចែករំលែក ដែលតម្រូវឲ្យធ្វើសកម្មភាពពីលើចុះទៅកម្រិតក្រោមបំផុតដ៏សមស្របមួយ ក៏ត្រូវធ្វើការពិនិត្យអង្កេតផងដែរ (Global Water Partnership, 2000: 33)*។

ឈរលើទស្សនៈធ្វើយ៉ាងណាឲ្យមានកិច្ចសហការកាន់តែស៊ីជម្រៅ និងការធ្វើប្រតិភូកម្មដូចខាងលើ ឯកសារសំខាន់ៗមួយចំនួនបានបង្ហាញថា ការបណ្ដុះបណ្ដាលសមត្ថភាពអ្នកពាក់ព័ន្ធ ជាយុទ្ធសាស្ត្រគាំទ្រមួយដ៏សំខាន់។ ឧទាហរណ៍ Global Water Partnership (GWP 2000: 50) បានបង្ហាញថា ការកសាងសមត្ថភាព គឺជាមធ្យោបាយផ្ដល់អំណាច និងជាការបំពាក់នូវមធ្យោបាយសមស្រប និងធនធានមិនចេះរីងស្ងួតដល់ប្រជាជន និងអង្គការនានា សម្រាប់យកទៅដោះស្រាយបញ្ហាផ្សេងៗរបស់ពួកគេផ្ទាល់ក្នុងការប្រើប្រាស់ទឹក។

ឯកសារស្រាវជ្រាវសំខាន់ៗខ្លះទៀតបង្ហាញថា ទិដ្ឋភាពនៃ កគទច របស់កម្ពុជាកំពុងវិវត្តនៅឡើយ និងនៅមានការត្រួតគ្នាជាមួយនឹងតួនាទីរបស់ស្ថាប័នមួយចំនួន។ យុត្តាធិការ និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងទឹកមិនទាន់កំណត់បានច្បាស់លាស់ និងនៅមានកម្រិតនៅឡើយ។ ក្នុងបរិបទនេះ អ្នកពាក់ព័ន្ធដែលគិតតែផលប្រយោជន៍ខ្លួនឯង អាចមានបារម្ភពី

---

១០ លោក Garfield (1998) បានបញ្ជាក់ថា "ការចែករំលែក" គឺជាការផ្ទេរមុខងារជាក់លាក់មួយទៅឲ្យក្រុមសហគមន៍មូលដ្ឋាន ដោយរួមទាំងការធ្វើប្រតិភូកម្មនៃការត្រួតពិនិត្យទៅឲ្យក្រុមដែលនៅថ្នាក់ទាបបំផុត ដើម្បីរៀបចំផែនការនិងអនុវត្តកម្មវិធីវិបុលកម្មនានា (Garfield 1998, cited in WB 2004; 2)។

គោលនយោបាយធ្វើសមាហរណកម្ម តាមខ្សែបណ្តោយ និងខ្សែទទឹង ដោយពួកគេយល់ថា វាជាការប៉ុនប៉ងបែងចែកអំណាចឡើងវិញ ដើម្បីឈានទៅសម្រេចគោលបំណងអ្វីមួយ។ ឧទាហរណ៍ ក្នុងការបង្កើតអង្គការគ្រប់គ្រងអាងទន្លេសាប មានស្ថាប័នពាក់ព័ន្ធខ្លះយល់ឃើញថា ជាការគំរាមគំហែងមួយដល់យុត្តាធិការនៃការទទួលខុសត្រូវ និងអំណាចរបស់ខ្លួន (Mang 2009, p. 42) ហើយអង្គការនេះក្រោយមក ក៏ត្រូវបានជំនួសដោយ អាជ្ញាធរទន្លេសាប។ មូលហេតុមួយនៃភាពស្មុគស្មាញក្នុងការគ្រប់គ្រងទន្លេសាប អាចមកពីអ្នកពាក់ព័ន្ធនៅកម្រិតខុសៗគ្នា (កម្រិត មូលដ្ឋាន ជាតិ តំបន់ និងសាកល) គេមានទស្សនៈខុសៗទៅលើទន្លេសាប និងធនធានរបស់វា (Kerkinen *et al.* 2009)។ បញ្ហាសំខាន់គឺ ផលប្រយោជន៍ជាបុគ្គលរបស់អ្នកពាក់ព័ន្ធ (ក្នុងការរក្សាអំណាច និងការពាក់ព័ន្ធរបស់ខ្លួន) មិនមែនសុទ្ធតែស្របគ្នាទៅនឹងផលប្រយោជន៍រួមរបស់ប្រទេសកម្ពុជាដែលត្រូវមានការសម្របសម្រួលល្អ និងរបៀបរបបអភិបាលកិច្ចធនធានទឹកក្នុងកម្រិតមួយដ៏សមស្របនោះទេ។ លោក Mitchell (1990: 14) បានផ្តល់ទស្សនៈបន្ថែមលើបញ្ហានេះដោយអះអាងថា "ក្របខ័ណ្ឌខ្សែបណ្តោយ និងខ្សែទទឹងបង្កើតបានជាបរិស្ថានមួយដែលក្នុងនោះ រង្វាន់ខ័ណ្ឌនៅតែបានទៅដល់អ្នកដែលផ្តោតការយកចិត្តទុកដាក់ទៅលើ ឬខំការពារកន្លែងដែលផ្តល់ផលប្រយោជន៍ដល់ពួកគេ"។

## ៣.៤ ទស្សនទាននៃការវិភាគអ្នកពាក់ព័ន្ធ៖ និយមន័យ និងផលប្រយោជន៍សម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ

បច្ចុប្បន្នមានឯកសារស្រាវជ្រាវកាន់តែច្រើនហើយស្តីពី ការវិភាគអ្នកពាក់ព័ន្ធ និងសារៈសំខាន់របស់វា។ ការវិភាគអ្នកពាក់ព័ន្ធជម្រុញឲ្យមានការកំណត់បញ្ហា និងការស្វែងរកដំណោះស្រាយកាន់តែមានលក្ខណៈជាប្រព័ន្ធ និងជាទូទៅ ជាពិសេសក្នុងស្ថានភាពមានផលប្រយោជន៍ជាច្រើនប្រជែងគ្នា។ ក្នុងការរួមចំណែកដ៏សំខាន់ទៅលើទ្រឹស្តីបទនេះ លោក Grimble & Wellard (1997: 175) បានឲ្យនិយមន័យ វិភាគអ្នកពាក់ព័ន្ធថាជា៖

> *...វិធីសាស្ត្រ ឬនីតិវិធីជារួមមួយ ដើម្បីស្វែងយល់ពីប្រព័ន្ធមួយ និងវាយតម្លៃពីផលប៉ះពាល់នៃបម្រែបម្រួលលើប្រព័ន្ធនោះ តាមរយៈការកំណត់តួអង្គ ឬអ្នកពាក់ព័ន្ធសំខាន់ៗ និងការវាយតម្លៃពីផលប្រយោជន៍របស់ពួកគេនៅក្នុងប្រព័ន្ធនោះ។*

ក្នុងការអនុវត្តជាក់ស្តែង ការវិភាគខាងលើមានន័យថា ការធ្វើសេចក្តីសម្រេចចិត្តដោយរដ្ឋ ឬមិនមែនរដ្ឋ ជានិច្ចជាកាលគួរធ្វើឡើងដោយផ្អែកលើការវាយតម្លៃពីផលប្រយោជន៍ ទស្សនៈវិស័យ និងអន្តរសកម្មភាពផ្សេងៗនៃអ្នកពាក់ព័ន្ធទាំងឡាយ។

វិធីសាស្ត្រវិភាគអ្នកពាក់ព័ន្ធ សមស្របសម្រាប់ប្រើជាពិសេសក្នុងការគ្រប់គ្រងធនធានធម្មជាតិ ដែលតែងពាក់ព័ន្ធដល់ភាគីមានផលប្រយោជន៍ផ្សេងៗគ្នាជាច្រើនមកពីគ្រប់កម្រិតនៃសង្គម និងទាមទារការថ្លឹងថ្លែងឲ្យមានសមធម៌ ប្រសិទ្ធភាព និងនិរន្តរភាពបរិស្ថាន (Grimble & Wellard 1997) ហើយបញ្ហាអភិបាលកិច្ចធនធានទឹក បានជួយបញ្ជាក់បំភ្លឺលើចំណុចនេះ។ ដើម្បីគ្រប់គ្រងអ្នកប្រើប្រាស់ទឹកចម្រុះ និងការប្រើប្រាស់ទឹក ព្រមទាំងវត្តមានសិទ្ធិមិនច្បាស់លាស់ ឬរួមគ្នាក្នុងការទទួលបានទឹកប្រើប្រាស់ និងផលចំណេញ/ខាតប៉ះប៉ូវគ្នារវាងកន្លែង និងពេលវេលាខុសៗគ្នា ធ្វើឲ្យការវិភាគអ្នកពាក់ព័ន្ធក្លាយជាចំណុចចាប់ផ្តើមដ៏ស័ក្តិសម និងមានប្រយោជន៍សម្រាប់កំណត់ផលប្រយោជន៍របស់អ្នកពាក់ព័ន្ធនីមួយៗ។

ការប្រើវិធីសាស្ត្រវិភាគអ្នកពាក់ព័ន្ធ នៅក្នុងការងារអភិបាលកិច្ច ក៏មានកម្រិតកំណត់របស់វាដែរ។ ការវិភាគអ្នកពាក់ព័ន្ធមិនអាចជំនួសឲ្យការងារស្វែងយល់ពីសង្គម ឬការវិភាគផ្អែកគោលនយោបាយ ឬផ្អែកច្បាប់បានទេ។ លោក Edmun & Wollenburg បានបង្ហាញថា វិធីសាស្ត្រវិភាគអ្នកពាក់ព័ន្ធ អាចក្លាយយ៉ាងងាយជាមធ្យោបាយសម្រាប់ដោះស្រាយបញ្ហាទំនាក់ទំនងដែលតែងតែមិនស្មើភាព ដោយចាត់ទុកដូចជាគ្រាន់តែមានបញ្ហាបច្ចេកទេសមួយដែលត្រូវដោះស្រាយ ហើយជាត់ចេញអស់នូវក្រុមអ្នកក្រីក្រ និងអ្នកទន់ខ្សោយជាងគេ (Edmund & Wollenburg 2001)។

ការវិភាគអ្នកពាក់ព័ន្ធក៏ងាយនឹងក្លាយជា ការពិពណ៌នាពីតួអង្គ និងតួនាទីផ្លូវការផ្សេងៗដែរ។ ពិតហើយ ទំនាក់ទំនងស្ថាប័ន និងទំនាក់ទំនងសង្គមក្នុងលោកនេះ វាស្មុគស្មាញណាស់ ដូច្នេះក្នុងការវិភាគអ្នកពាក់ព័ន្ធ បើសិនមិនបានគិតគូរពីរបៀបរបបជាក់ស្តែងខាងវប្បធម៌ និងទំនាក់ទំនងនៃអំណាចដែលឃ្លាតចេញពីតួនាទីផ្លូវការរបស់អ្នកពាក់ព័ន្ធ ដូចមានចែងក្នុងអនុក្រឹត្យរបស់រដ្ឋាភិបាលនោះទេ ការវិភាគនេះមិនអាចជួយបង្ហាញពីដំណើរការជាក់ស្តែង ទាំងមានជោគជ័យ និងបរាជ័យ នៃអភិបាលកិច្ចបានទេ។

# ការវិភាគអ្នកពាក់ព័ន្ធ

ផ្នែកនេះផ្តល់នូវព័ត៌មានគ្រឹះអំពីបច្ចេកទេសរៀបចំបច្ចុប្បន្ន នៅកម្រិតផ្សេងៗគ្នា ដូចជា កម្រិតប្រព័ន្ធធារាសាស្ត្រ និងអាងទន្លេ កម្រិតថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ដែលទទួលបានតាមរយៈការសម្ភាសអ្នកពាក់ព័ន្ធ ដែលមានតួនាទីពាក់ព័ន្ធយ៉ាងជិតស្និតក្នុង កគទច ការគ្រប់គ្រងធារាសាស្ត្រដោយមានការចូលរួម និងកិច្ចអភិវឌ្ឍន៍ និងការគ្រប់គ្រងទឹក។ ព័ត៌មានទាំងនេះ គឺជាចំណុចគោលសម្រាប់ធ្វើការវាស់វែង (Benehmark) ពីស្ថានភាពនៃការអនុវត្ត គោលនយោបាយគ្រប់គ្រងធនធានទឹកចម្រុះ និង PIMD ហើយវាក៏បានកំណត់ផងដែរនូវបញ្ហាដែលមិនទាន់ស៊ីសង្វាក់គ្នាមួយចំនួន ដែលកើតមានឡើងពីការវិភាគអំពីតួនាទី និងការអនុវត្តជាក់ស្តែងរបស់អ្នកពាក់ព័ន្ធផ្ទាល់។ គំហើញនៃការវិភាគទាំងនោះ នឹងត្រូវលើកយកមកពិភាក្សានៅផ្នែកបន្ទាប់នៃឯកសារស្រាវជ្រាវនេះ។

## ៤.១ ព័ត៌មានសង្ខេបអំពីទិដ្ឋភាពនៃអ្នកពាក់ព័ន្ធក្នុងតំបន់សិក្សា

កម្ពុជា ជាប្រទេសដែលមានផ្ទៃដីទំនាប និងមានប្រជាជនភាគច្រើន (ប្រមាណ ៨០%) រស់នៅតំបន់ជនបទ ហើយប្រហែល ៧០% នៃកម្លាំងពលកម្មរបស់ប្រទេស បានពឹងផ្អែកលើវិស័យកសិកម្ម (NIS 2008)។ ប្រទេសកម្ពុជា ក៏សម្បូរទៅដោយធនធានទឹកជាច្រើន ដោយមានទន្លេមេគង្គជាប្រភពផ្តល់ធនធានទឹកនៅភាគខាងកើតនៃប្រទេស ចំណែកទន្លេសាប និងអាងនានារបស់វា បានផ្តល់ធនធានទឹកនៅភាគកណ្តាល និងភាគខាងលិចនៃប្រទេស។

អភិបាលកិច្ចនៃអាងទន្លេសាប ក៏ដូចជាអភិបាលកិច្ចនៅអាងទន្លេដទៃឯទៀតដែរ គឺនៅមានសភាពស្មុគស្មាញ និងកំណត់ចរិតលក្ខណៈដោយទម្រង់នៃការគ្រប់គ្រងចម្រុះ ដែលបង្កើតបានជាសំណួរថា តើប្រព័ន្ធគ្រប់គ្រងនោះ អាចត្រូវបានគ្រប់គ្រងក្នុងលក្ខណៈសមស្រប ហើយងាយយល់ដោយស្ថាប័នណាមួយដែរឬទេ (Sokhem & Sunada, 2006:400)។ ទម្រង់ការគ្រប់គ្រងចម្រុះបួនយ៉ាងសំខាន់ៗនៃទន្លេសាប និងអាងទន្លេមេគង្គទាំងមូលមាន៖

១. *អធិបតេយ្យភាពចម្រុះ* គឺការគ្រប់គ្រងដោយប្រទេសទាំង ៦ នៅក្នុងអាងទន្លេមេគង្គ និងខេត្តទាំង៨ នៅជុំវិញអាងបឹងទន្លេសាប

២. *កម្រិតគ្រប់គ្រងចម្រុះ* គឺការគ្រប់គ្រងដោយអ្នកដែលទទួលបានផលប្រយោជន៍ពីតំបន់នោះចម្រុះគ្នា ដែលត្រូវការ និងដណ្តើមគ្នាគ្រប់គ្រងតំបន់នោះក្នុងកម្រិតសហគមន៍ កម្រិតថ្នាក់ក្រោមផ្ទៃរងទឹកភ្លៀង កម្រិតអាងទន្លេ កម្រិតតំបន់ កម្រិតជាតិ និងកម្រិតសាកល

៣. *ទស្សនវិស័យចម្រុះ* គឺការគ្រប់គ្រងផ្អែកលើគោលបំណងផ្សេងគ្នានៃសេដ្ឋកិច្ច នយោបាយ សង្គមកិច្ច ហើយនិងវិសមភាពនៃសមត្ថភាពបច្ចេកទេស និងហិរញ្ញវត្ថុដែលបានកំណត់នូវទស្សនវិស័យផ្សេងៗគ្នា ដែលមានភាពខុសប្លែកគ្នាពីប្រទេសមួយទៅប្រទេសមួយ ពីខេត្តមួយទៅខេត្តមួយ ទៅតាមផ្នែកនៃធនធាន ទៅតាមអ្នករៀបចំគោលនយោបាយសង្គម និងទៅតាមកម្រិតនៃគោលការណ៍ណែនាំ និង

៤. *វិស័យចម្រុះ* គឺការគ្រប់គ្រងទៅតាមវិស័យ និងទៅតាមទស្សនៈផ្សេងៗគ្នាយ៉ាងច្រើន (នៃអ្នកធ្វើគោលនយោបាយនៃធនធានរបស់អ្នកធ្វើផែនការ និងការអភិវឌ្ឍសហគមន៍វិទ្យាសាស្ត្រ និងអ្នកពាក់ព័ន្ធឯទៀត)។

មានអ្នកពាក់ព័ន្ធសំខាន់ៗជាច្រើន ដូចជា បណ្តាប្រទេសនៅតាមដងទន្លេមេគង្គ និងភ្នាក់ងាររដ្ឋាភិបាលរបស់ពួកគេ សហគមន៍អាងទន្លេ អង្គការសង្គមស៊ីវិល វិស័យឯកជន ភ្នាក់ងារផ្តល់ជំនួយ និងវិទ្យាស្ថានអភិវឌ្ឍន៍ ដែលមានផលប្រយោជន៍ស្របច្បាប់ក្នុងការងារអភិបាលកិច្ចនៅអាងបឹងទន្លេសាប (Sokhem & Sunada, 2006: 400)។

រូបភាព ៣៖ ទិដ្ឋភាពដ៏មមាញឹកនៃអ្នកពាក់ព័ន្ធក្នុងអាងបឹងទន្លេសាប




ប្រភព៖ Sokhem, 2010

## ៤.២ តួនាទីអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងធនធានទឹក

### *៤.២.១ អ្នកពាក់ព័ន្ធថ្នាក់ជាតិ*

ការស្រាវជ្រាវនេះ ធ្វើឡើងនៅក្នុងតំបន់អាងបឹងទន្លេសាប ដែលនៅទីនោះការគ្រប់គ្រងធនធានទឹកមានលក្ខណៈចម្រុះ ដូចបានរៀបរាប់ខាងលើ។ នៅប្រទេសកម្ពុជា ប្រជាកសិករភាគច្រើន រស់នៅ និងធ្វើការនៅជនបទ ហើយផលិតកម្មស្រូវ គឺជាធនធានសំខាន់ដែលកសិករពឹងផ្អែកក្នុងជីវភាពរបស់ពួកគេ។ បញ្ហាដែលទាក់ទងនឹងធនធានទឹក ត្រូវបានដោះស្រាយដោយសារបណ្ដាក្រសួងពាក់ព័ន្ធ និងគណៈកម្មាធិការជាច្រើនដែលមានអាណត្តិ មានបំណងប្រាថ្នា និងគោលនយោបាយជាក់លាក់។ អង្គការអន្តរជាតិ អង្គការជាតិ អង្គការមូលដ្ឋាន និងអង្គការសង្គមស៊ីវិលជាច្រើន បាននិងកំពុងបំពេញការងារដើម្បីលើកកម្ពស់ការគ្រប់គ្រងធនធានទឹកនៅកម្ពុជា។ ស្ថាប័ន និងអ្នកពាក់ព័ន្ធផ្សេងៗគ្នា ដែលបានទាមទារអំណាចគ្រប់គ្រងលើអាងបឹងទន្លេសាប រួមមាន ក្រសួងធនធានទឹក ក្រសួងកសិកម្ម ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាដើម (សូមមើលរូបភាព ៤)។ របៀបរៀបចំស្ថាប័ន និងដំណើរការអភិបាលកិច្ចនៃអាងបឹងទន្លេសាប វាជាប់ទាក់ទងទៅនឹងភាពស្មុគស្មាញនៃប្រព័ន្ធអេកូឡូស៊ី និងការយល់ឃើញរបស់ថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់។

ប្រព័ន្ធអភិបាលកិច្ចដែលស្របទៅតាមច្បាប់ កំពុងប្រឈមដោយកង្វះយន្តការឆ្លើយតប និងសហការឲ្យបានត្រឹមត្រូវក្នុងចំណោមអ្នកគ្រប់គ្រងទាំងឡាយ (Kaskinen and Sithirith, 2009)។ មុខងារទំនាក់ទំនងខ្សែបណ្ដោយ រវាងរដ្ឋាភិបាលកណ្ដាល រដ្ឋអំណាចមូលដ្ឋាន និងរដ្ឋអំណាចខេត្ត និងអ្នកភូមិ ក៏ទាមទារឲ្យមានការកែលម្អជាបន្ទាន់ដែរ។ បញ្ហាប្រឈមឯទៀត គឺការពឹងផ្អែកជំនួយនៃប្រព័ន្ធរដ្ឋាភិបាលកម្ពុជា និងភាពគ្របដណ្ដប់ (ឧត្តមភាព) នៃប្រទេសផ្ដល់ជំនួយ ធនាគារ

អភិវឌ្ឍន៍ និងអង្គការអន្តរជាតិក្នុងការបង្កើតឡើងនូវទម្រង់នៃគោលនយោបាយរដ្ឋាភិបាល និងការបង្ហាញនូវនីតិវិធីដោះស្រាយថ្មីៗ។ ឧត្តមភាពនេះ អាចត្រូវមើលឃើញយ៉ាងច្បាស់នៅតំបន់បឹងទន្លេសាប ជាមួយនឹងគំនិតផ្ដួចផ្ដើមនៃការគ្រប់គ្រងផ្សេងៗគ្នារបស់វាផងដែរ (Kaskinen and Sithirith, 2009)។

រូបភាព ៤៖ ទិដ្ឋភាពអ្នកពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន




ប្រភព៖ Sokhem,2010

### *៤.២.១.១ ក្រសួងធនធានទឹក និងឧតុនិយម*

ក្រសួងធនធានទឹក ត្រូវបានបង្កើតឡើងជាផ្លូវការនៅឆ្នាំ១៩៩៩ យោងតាមសេចក្ដីប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ NS/RKM/0699108។ ក្រសួងធនធានទឹក មានអាណត្តិក្នុងតួនាទីជាអ្នកដឹកនាំរាល់សកម្មភាពដែលពាក់ព័ន្ធធនធានទឹកប្រកបដោយសមភាព និងនិរន្តរភាព សម្រាប់ជីវភាពរស់នៅ ហើយនិងដើម្បីលើកកម្ពស់គុណភាពបរិស្ថាន (Phalla *et al.* 2008:1)។ អនុក្រឹត្យឆ្នាំ១៩៩៩ (RGC 1999) បានកំណត់ពីតួនាទីរបស់ក្រសួងធនធានទឹក ដែលជាសង្ខេបគឺមានគោលបំណងសំខាន់ ៥ យ៉ាងគឺ ១) ការអភិវឌ្ឍន៍ និងគ្រប់គ្រងធនធានទឹក ២) ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត ៣) ការបង្កើតបទដ្ឋានច្បាប់ និងបទបញ្ញត្តិទាក់ទងនឹងធនធានទឹក ៤) ការគ្រប់គ្រងព័ត៌មានដែលទាក់ទងនឹងធនធានទឹក ៥) ការពង្រឹងកិច្ចការរដ្ឋបាលអភិវឌ្ឍន៍ និងគ្រប់គ្រងធនធានមនុស្ស (Phalla *et al.* 2008)។

ដើម្បីធានាការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព និងដើម្បីផ្គត់ផ្គង់ទឹក សម្រាប់កសិកម្មឲ្យបានគ្រប់គ្រាន់ ក្រសួងធនធានទឹកបានជួសជុលកែលម្អ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ និងពង្រីកផ្ទៃដីស្រោចស្រពជាច្រើន (MOWRAM 2009a)។ ក្នុងការអនុវត្តទៅតាមគោលនយោបាយរបស់រដ្ឋាភិបាលស្តីពី វិមជ្ឈការ និងវិសហមជ្ឈការ និងដើម្បីធានាឲ្យបាននូវការគ្រប់គ្រង ប្រព័ន្ធធារាសាស្ត្រប្រកបដោយនិរន្តរភាព ក្រសួងធនធានទឹក បាននិងកំពុងអនុវត្តនូវគោលនយោបាយផ្ទេរការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ និង PIMD[១១] ដែលនៅក្នុងគោលនយោបាយ PIMD នេះ កសិករត្រូវបានលើកទឹកចិត្ត ដើម្បីឲ្យពួកគេអាចគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយខ្លួនឯង។

ក្នុងគោលបំណងលើកកម្ពស់ផ្នែករដ្ឋបាល និងបណ្តុះបណ្តាលធនធានមនុស្ស ក្រសួងធនធានទឹកបានរៀបចំផែនការកសាងសមត្ថភាពមន្ត្រីរបស់ខ្លួននៅគ្រប់កម្រិតតាមរយៈ ១) ការបង្កើនសមត្ថភាពគ្រប់គ្រង និងរដ្ឋបាលតាមការរៀនផងអនុវត្តផងដល់មន្ត្រីទាំងឡាយឲ្យស្របទៅនឹងនិយាមជាតិ និងអន្តរជាតិ ២) ការពង្រឹងសមត្ថភាពមន្ត្រីថ្នាក់កណ្តាល (មន្ត្រីសំខាន់ៗ) និងមន្ត្រីថ្នាក់ក្រោមជាតិ ក៏ដូចជា សកបទ ដើម្បីជួយដល់កសិករឲ្យទទួលបានអត្ថប្រយោជន៍កាន់តែច្រើនថែមទៀតក្នុងជីវភាពរស់នៅ និងក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច។

នាយកដ្ឋាន សកបទ នៃក្រសួងធនធានទឹក មានភារកិច្ចដឹកនាំការរៀបចំបង្កើត សកបទ នៅថ្នាក់មូលដ្ឋាន។ ច្បាប់ដែលប្រើជាមូលដ្ឋានក្នុងការបង្កើត សកបទ រួមមាន ប្រកាសលេខ០១ដែលជា "ក្របខ័ណ្ឌច្បាប់ស្តីពីការអនុវត្តគោលនយោបាយគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រប្រកបដោយនិរន្តរភាព" ក្នុងការបង្កើត សកបទ ក៏ដូចជាគោលនយោបាយណែនាំពីការគ្រប់គ្រង សកបទ និងប្រកាសលេខ៣០៦ស្តីពីក្របខ័ណ្ឌច្បាប់និងបច្ចេកទេសដែលបង្កើតឡើងដោយក្រសួងធនធានទឹក។ដំណើរការចុះបញ្ជី សកបទ ត្រូវបានអនុវត្តតាមរយៈនាយកដ្ឋាន សកបទ នៃក្រសួងធនធានទឹក។ គិតដល់ឆ្នាំ២០០៨ មាន សកបទ ចំនួន ៣៥០ ហើយដែលត្រូវបានបង្កើតឡើងដែលក្នុងនោះ សកបទ ចំនួន ២៥០ ត្រូវបានចុះបញ្ជី និងទទួលស្គាល់ជាផ្លូវការដោយក្រសួងធនធានទឹក។

ក្រុមកសិករប្រើប្រាស់ទឹកត្រូវបានបង្កើតឡើង ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចសហការរវាង បណ្តាអ្នកពាក់ព័ន្ធទាំងឡាយ ដូចជា ក្រសួងពាក់ព័ន្ធ សហគមន៍អ្នកផ្តល់ជំនួយ និង NGOs និងដើម្បីផ្តល់បច្ចេកទេសក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ ក្រុមការងារនេះត្រូវបានបង្កើតឡើងដោយយោងតាមកំណើននៃការយល់ដឹងវិស័យកសិកម្ម និងទឹក កំពុងមានទំនាក់ទំនងជាមួយស្ថាប័នជាច្រើន ដែលកំពុងដំណើរការផ្នែកសង្គមកិច្ច សេដ្ឋកិច្ច និងបរិស្ថានជាដើម។ ក្រសួងធនធានទឹក និងក្រសួងកសិកម្ម គឺជាស្ថាប័នដឹកនាំក្នុងការអនុវត្តកម្មវិធីចំនួន ៥ ស្ថិតក្រោមយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងធនធានទឹក (SAW 2007) រួមមាន ១) កម្មវិធីគាំទ្រដល់ការគ្រប់គ្រងទឹក និងកសាងសមត្ថភាពស្ថាប័នសម្រាប់វិស័យកសិកម្ម និងធនធានទឹក ២) កម្មវិធីគាំទ្រសុវត្ថិភាពស្បៀង ៣) កម្មវិធីគាំទ្រកសិកម្ម និងជំនួញផលិតផលកសិកម្ម (Value Chain) ៤) កម្មវិធីគ្រប់គ្រងធនធានទឹក ៥) កម្មវិធីប្រព័ន្ធធារាសាស្ត្រនិងដីធ្លី ៦) កម្មវិធីអប់រំស្រាវជ្រាវនិងផ្សព្វផ្សាយអំពីកសិកម្ម និងទឹក (TWGAW 2007)។

មន្ត្រីនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងធនធានទឹក តែងបានធ្វើការយ៉ាងជិតស្និទជាមួយក្រសួងជាដៃគូ អាជ្ញាធរមូលដ្ឋាន ទាយក អង្គការសង្គមស៊ីវិល NGOs រដ្ឋាភិបាលជាតិ និងអន្តរជាតិ និងសហគមន៍កសិករ ដើម្បីសម្រេចឲ្យគោលបំណងរំពឹងទុកបានជោគជ័យ។

*៤.២.១.២ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ក្រករន)*

វិស័យកសិកម្ម គឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ ដែលរួមចំណែក ៣៤% នៃ GDP នៅឆ្នាំ២០០៨ (MAFF 2009)។ ក្នុងចំណោមផ្ទៃដីកសិកម្មនៅកម្ពុជាប្រមាណ ៣,៧៨លានហិកតា មានផ្ទៃដីសម្រាប់ដំណាំស្រូវសរុបមានចំនួន ៩១%។ នៅឆ្នាំ២០០៨ ប្រព័ន្ធធារាសាស្ត្រទាំងអស់មានចំនួន ២១០៣ ដែលនៅទីនោះ ទិន្នផលស្រូវជាមធ្យមគឺ ពី ៣,២ ទៅ ៣,៥តោនក្នុងមួយហិកតា (MOWRAM 2009c)។

មុខនាទី និងភាតព្វកិច្ចរបស់ក្រសួងកសិកម្ម ត្រូវបានកំណត់ក្នុងអនុក្រឹត្យលេខ១៧ ចុះថ្ងៃទី០៧ មេសា ឆ្នាំ២០០០ របស់រាជរដ្ឋាភិបាល។ អ្វីដែលទាក់ទិននឹងទឹក និងកសិកម្ម ក្រសួងកសិកម្ម មានអាណត្តិដើម្បីរៀបចំ និងដំណើរការនូវគោល

១១ ក្រសួងធនធានទឹក និងឧតុនិយម ឆ្នាំ២០០៥ យុទ្ធសាស្ត្រគ្រប់គ្រងធនធានទឹកចម្រុះនៅកម្ពុជា និងផែនទីបង្ហាញផ្លូវ។

នយោបាយក្នុងវិស័យកសិកម្ម ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងដើម្បីសហការ និងសហប្រត្តិបត្តិការជាមួយអង្គការជាតិ និងអន្តរជាតិ និង NGOs សំដៅអភិវឌ្ឍន៍វិស័យកសិកម្ម។

ក្រសួងកសិកម្ម បានជួយគាំទ្រដល់រាជរដ្ឋាភិបាលក្នុងការបង្កើតនូវក្របខ័ណ្ឌគោលនយោបាយ ដើម្បីដឹកនាំការអភិវឌ្ឍន៍កសិកម្មក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ និងពង្រឹកសុវត្ថិភាពស្បៀង។ ក្រសួងកសិកម្ម និងក្រសួងធនធានទឹក មានភារកិច្ចអនុវត្តកម្មវិធីសំខាន់ៗដូចមានចែងនៅក្នុងយុទ្ធសាស្ត្រកសិកម្ម និងទឹក (SAW 2007) ក្នុងការជំរុញកិច្ចសហការរវាងស្ថាប័ន និងអ្នកពាក់ព័ន្ធនានា ដែលមានផលប្រយោជន៍ និងការទទួលខុសត្រូវ ទាក់ទងនឹងកសិកម្ម និងធនធានទឹក (Ibid)។

ក្រសួងកសិកម្ម កំពុងអនុវត្តគម្រោងជាច្រើនដែលជួយឧបត្ថមដោយប្រទេសអ្នកផ្តល់ជំនួយ។ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពហិរញ្ញវត្ថុពិភពលោកបច្ចុប្បន្ន ក្រសួងកសិកម្មបានយកចិត្តទុកដាក់ពិចារណាទៅលើគោលដៅសំខាន់ៗ និងវិធានការមួយចំនួន (Ibid) រួមមាន ១) លើកកម្ពស់ផលិតកម្ម និងពិពិធកម្មវិស័យកសិកម្ម ធានាឲ្យបានសុវត្ថិភាពស្បៀងដល់ប្រជាពលរដ្ឋគ្រប់គ្នា កាត់បន្ថយភាពក្រីក្រ បង្កើន ផសស ក្នុងម្នាក់ៗ និងធានាឲ្យបាននូវនិរន្តរភាពធនធានធម្មជាតិ និងការអភិរក្ស តាមការអនុវត្តកម្មវិធីទាំង ៥ របស់ យទក ឆ្នាំ២០០៧ ២) ធ្វើប្រពលវប្បកម្ម និងពិពិធកម្មផលិតកម្មចំណីអាហារដោយសារកសិករមានក្បាលដីតូចៗសម្រាប់ដាំដុះ ពិសេសគ្រួសារដែលមានបញ្ហាសុវត្ថិភាពស្បៀង ៣) បង្កើនមធ្យោបាយឲ្យកសិករដែលមានក្បាលដីតូចៗទទួលបានបច្ចេកទេសថ្មីៗ ពូជជីថ្នាំល្អៗសម្លាប់សត្វល្អិត និងអាចកែប្រែ និងគ្រប់គ្រងគុណភាពដី និងទឹកបានល្អ ៤) បង្កើនការវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជា ការដឹកជញ្ជូនធារាសាស្ត្រ ទីផ្សារ ការស្រាវជ្រាវ និងការផ្សព្វផ្សាយកសិកម្ម ៥) ពង្រឹងសហគមន៍មូលដ្ឋាន ៦) អភិវឌ្ឍន៍ផលិតផល នឹងមុខជំនួញកសិកម្ម និង ៧) បង្កើតម៉ាក្រូឥណទាន។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម មានភារកិច្ចរួមចំណែកជួយដល់ការលើកកម្ពស់សុវត្ថិភាពស្បៀង ការបង្កើនប្រាក់ចំណូល និងផលិតកម្មកសិកម្មនៅកម្ពុជា។ នាយកដ្ឋានបានបង្កើត និងប្រើប្រាស់វិធាននៃការបណ្តុះបណ្តាល និងផ្សព្វផ្សាយដោយមានការចូលរួម និងវិធីសាស្ត្រនានា ដើម្បីផ្តល់ និងផ្ទេរចំណេះដឹងផ្នែកកសិកម្ម ព័ត៌មាន និងបច្ចេកទេស រួមមាន ការអភិវឌ្ឍន៍ប្រព័ន្ធក្សេត្របរិស្ថាន ការបង្កើតសមាគមកសិករ និងការអប់រំ ផ្សព្វផ្សាយអំពីអាហារប្រចាំគ្រួសារ។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក៏បានគាំទ្រ និងសហការល្អ ជាមួយការិយាល័យផ្សព្វផ្សាយកសិកម្មខេត្តរបស់មន្ទីរកសិកម្ម ដើម្បីជួយឧបត្ថម្ភដល់មន្ត្រីផ្សព្វផ្សាយកសិកម្មថ្នាក់ស្រុក ក្នុងគម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រទិសពាយ័ព្យ ដែលឧបត្ថម្ភដោយធនាគារអភិវឌ្ឍន៍អាស៊ី ដែលក្នុងគម្រោងនេះ មន្ទីរធនធានទឹក ដឹកនាំអភិវឌ្ឍន៍ធារាសាស្ត្រ ចំណែកមន្ទីរកសិកម្មបំពេញតួនាទីជាអ្នកផ្តល់កម្មវិធីអប់រំផ្សព្វផ្សាយកសិកម្មដល់កសិករ។ គេឃើញមានវិធានដែលមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធជាច្រើន ត្រូវបានគេយកមកអនុវត្ត ដូចជា ការវាយតម្លៃ និងធ្វើផែនការដោយមានការចូលរួមអភិវឌ្ឍន៍ បច្ចេកទេសវគ្គអប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាលដោយមានការចូលរួម ការបង្កើតសហគមន៍កសិករ និងសុវត្ថិភាពស្បៀងប្រចាំគ្រួសារ[១២]។

*៤.២.១.៣ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប/NCDD)*

NCDD បំពេញការងារដើម្បីរៀបចំការប្រតិភូកម្មរចនាសម្ព័ន្ធរដ្ឋបាល ដោយធ្វើការងារនេះជាមួយផ្នែករដ្ឋបាលមូលដ្ឋាន[១៣] ដើម្បីធានាឲ្យមានការពិគ្រោះយោបល់ និងការសម្របសម្រួលដ៏ពេញលេញមួយក្នុងចំណោម NCDD ក្រសួងនានា និងស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិដទៃទៀត ទាក់ទិននឹងការផ្ទេរមុខងារ អំណាច និងធនធានពីថ្នាក់ជាតិ ទៅថ្នាក់ក្រោមជាតិ[១៤]។

NCDD ត្រូវបានបង្កើតឡើងដើម្បីអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខ័ណ្ឌ (Oragic Law) ឆ្នាំ២០០៨ ដើម្បីឲ្យមានកំណែប្រែនៅក្នុងការងារអភិបាលកិច្ចនៅកម្ពុជា និងដើម្បីធ្វើឲ្យសេវាកម្មនានាត្រូវបានផ្តល់ដល់ប្រជាពលរដ្ឋ តាមរយៈការអនុវត្តកម្មវិធីកំណែទម្រង់ដែលមានរយៈពេល ១០ឆ្នាំ ពិសេសយុទ្ធសាស្ត្រដើម្បីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។ រាជរដ្ឋាភិបាលកម្ពុជា (RGC) រំពឹងថាដំណើរការវិមជ្ឈការ និងការពង្រឹងអំណាចនៅថ្នាក់

១២ ការសម្ភាសជាមួយ មន្ទីរធនធានទឹក ខេត្តពោធិ៍សាត់ និងមន្ត្រីនាយកដ្ឋានផ្សព្វផ្សាយ ក្រសួងកសិកម្មឆ្នាំ២០១០។
១៣ ការសម្ភាសជាមួយមន្ត្រី NCDD នៃកម្មវិធីគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន នៃក្រសួងមហាផ្ទៃ ឆ្នាំ២០០៩។
១៤ រាជក្រឹត្យលេខ NS/RD/0806/355 ចុះថ្ងៃទី ១៨ សីហា ២០០៦ ស្តីពីការបង្កើត NCDD។

*មូលដ្ឋានអាច "ដំណើរការបានដោយមានតម្លាភាព និងគណនេយ្យភាព ដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍នៅមូលដ្ឋាន និងដើម្បីផ្តល់នូវសេវាកម្មសាធារណៈ ឲ្យស្របទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋ និងរួមចំណែកកាត់បន្ថយកាត់បន្ថយភាពក្រីក្រនៅក្នុងវិស័យនានា"*[១៥]។

នៅថ្នាក់ជាតិ មានក្រុមការងារជាច្រើនកំពុងបំពេញការងារពង្រឹងកិច្ចសហការរវាងស្ថាប័នពាក់ព័ន្ធនានា ឧទាហរណ៍ ក្រុមការងារផ្នែករៀបចំផែនការ ផ្នែកវិមជ្ឈការ និងវិសហមជ្ឈការ និងផ្នែកទុនវិនិយោគ។ ផ្នែកធំៗ ៣ នៅក្នុង NCDD មាន៖

- ផ្នែកសង្គមស៊ីវិល មានតួនាទីដើម្បីបង្កើតសម្លេង ដើម្បីជួយដល់ផែនការអភិវឌ្ឍន៍មូលដ្ឋាន និងបង្កើតយុទ្ធសាស្ត្រទីផ្សារដើម្បីជួយដល់អ្នកក្រីក្រ និងដើម្បីគាំទ្រដល់អង្គការសង្គមតូចៗ[១៦]។
- ផ្នែករុក្ខាប្រមាញ់ ជលផល និងដីធ្លី បំពេញភារកិច្ចប្រមូលអ្នកពាក់ព័ន្ធមកពីគ្រប់វិស័យ ដើម្បីពិភាក្សាគ្នាអំពីបញ្ហាគ្រប់គ្រងធនធានខាងលើនៅក្នុងក្របខ័ណ្ឌវិមជ្ឈការ។
- ផ្នែកគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ដែលអាចរៀបចំបង្កើតផែនការសកម្មភាពដែលមានកិច្ចសហការគ្នាល្អ ដោយបញ្ចូលផែនការសកម្មភាពទាំងឡាយរៀបចំឡើងដោយផ្នែកពាក់ព័ន្ធឯទៀត ក្នុងគោលបំណងគ្រប់ផ្នែកទាំងអស់ ឲ្យធ្វើការជាមួយគ្នាប្រកបដោយប្រសិទ្ធភាពខ្ពស់[១៧]។

នៅថ្នាក់ខេត្ត គណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត (PRDC-Excom) ដើរតួនាទីយ៉ាងសំខាន់ក្នុងការងារសម្របសម្រួល និងសហការតាមកម្រិតខ្សែបណ្តោយ។ ស្ថាប័ននេះ ធ្វើការពិនិត្យពិចារណាលើការបែងចែកថវិកា និងបញ្ហាដទៃទៀត មុនពេលអភិបាលខេត្តធ្វើសេចក្តីសម្រេចចិត្ត។ សំអាងខ្លះលើកឡើងថា ប្រសិទ្ធភាពការងាររបស់គណៈកម្មាធិការនេះ អាចប្រែប្រួលពីខេត្តមួយទៅខេត្តមួយទៀត។

NCDD និងក្រុមប្រឹក្សាឃុំ/សង្កាត់ មានទំនាក់ទំនងនឹងគ្នាយ៉ាងល្អ ហើយធ្វើការរួមគ្នាក្នុងការជ្រើសរើសគម្រោងអាទិភាពនៃគម្រោង វិនិយោគឃុំដែលទាក់ទងនឹងកសិកម្ម ជលផល និងធារាសាស្ត្រ (កិច្ចដំណើរការ និងការថែទាំទំនប់ និងប្រឡាយទឹក)[១៨]។

### *៤.២.១.៤ លេខាធិការដ្ឋានបបនីយជីវមណ្ឌលទន្លេសាប (លបទស) និងអាជ្ញាធរទន្លេសាប (អទស)*

លបទស ដំណើរការក្រោមការដឹកនាំរបស់គណៈកម្មាធិការជាតិទន្លេមេគង្គ ដើម្បីសហការ និងពង្រឹងសហប្រតិបត្តិការរវាងក្រសួង ស្ថាប័ន រដ្ឋអំណាច មូលដ្ឋាន និងសហគមន៍ពាក់ព័ន្ធ ដើម្បីគ្រប់គ្រង និងការពារដោយនិរន្តរភាព (RGC 2001:4)[១៩]។ ក្របខ័ណ្ឌការងាររបស់ លបទស បង្កើតឲ្យមានការពាក់ព័ន្ធជាមួយ ធនាគារអភិវឌ្ឍន៍អាស៊ី នៅឆ្នាំ២០០៣ និងផែនការនានាសម្រាប់អង្គការគ្រប់គ្រងអាងបឹងទន្លេសាប (Keskinen & Sethirith, 2009)។

លបទស បានបោះពុម្ពផ្សាយឯកសារគោលនយោបាយនៅខែមករា ឆ្នាំ២០០៧ ដែលពិពណ៌នាអំពីបញ្ហាប្រឈមជាមួយនឹងការគ្រប់គ្រងនៅតំបន់បឹងទន្លេសាប ហើយបានបង្កើតឲ្យមានក្របខ័ណ្ឌទូទៅមួយ ដើម្បីរៀបចំគោលនយោបាយសម្រាប់សហការគ្នាឲ្យបានល្អ ដោយតម្លើង លបទស ទៅជាមជ្ឈមណ្ឌលសម្រាប់គ្រប់គ្រងបឹងទន្លេសាប ដែលមានយន្តការសហការមួយរួមមាន គណៈកម្មាធិការ លបទស និងក្រុមប្រឹក្សាបច្ចេកទេស ក្រុមការងារថ្នាក់ខេត្ត និងវេទិកាសំដែងមតិ (Keskinen & Sethirith, 2009)។ ប៉ុន្តែ យន្តការដែលបានស្នើបង្កើតឡើងនេះ ត្រូវបានជំនួសដោយការបង្កើតឡើងនូវអាជ្ញាធរអាងទន្លេសាប ដែលស្ថិតនៅក្រោមការដឹកនាំនៃខុទ្ទកាល័យគណៈរដ្ឋមន្ត្រីនៅឆ្នាំ២០០៧ (ចាប់ពីឆ្នាំ២០០៩ គេបាន

---

១៥ http://www.ncdd.gov.kh/component/content/article/30-ncdd/5-message-from-the-chairman (accessed on 26 October 2010)

១៦ រួមមាន ក្រុមកសិករប្រើប្រាស់ទឹក ក្រុមសន្សំប្រាក់ ឬស្រូវ និងក្រុមជួយគាំពារមនុស្សចាស់ និងស្ត្រីមានផ្ទៃពោះ។

១៧ ការសម្ភាសជាមួយមន្ត្រី NCDD នៅកម្មវិធីគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន នៃ ក្រមហជ ឆ្នាំ ២០០៩។

១៨ បានពីទំនាក់ទំនងជាមួយទីប្រឹក្សាបច្ចេកទេសខេត្ត គម្រោងធនធានធម្មជាតិនិងបរិស្ថាន និងជីវភាពរស់នៅ ដើម្បីគាំទ្រការអភិវឌ្ឍន៍ប្រជាធិប្បតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ (PSDD) នៅខេត្តពោធិ៍សាត់ ឆ្នាំ២០១០។

១៩ ទោះបីជាលេខាធិការដ្ឋានបបនីយជីវមណ្ឌលទន្លេសាប ត្រូវបានបង្កើតជាផ្លូវការ និងស្ថិតក្រោមការគ្រប់គ្រងដោយ CNMC ក្តី ក្នុងការអនុវត្តជាក់ស្តែងទំនាក់ទំនងជិតស្និទ្ធជាមួយ MoE ដែលនាំឲ្យមានការភ័ន្តច្រឡំពីមុខងារ និងអាណត្តិពិតរបស់ស្ថាប័ន។

ដាក់ឈ្មោះ ជាថ្មីថា "អាជ្ញាធរទន្លេសាប (អទស)" ស្ថិតនៅក្រោមការដឹកនាំនៃរដ្ឋមន្ត្រីក្រសួងធនធានទឹក (Keskinen & Sethirith, 2009)។ គេមិនអាចដឹងច្បាស់ពីនិរន្តរភាពរបស់ លបទស ទេ ប្រសិនបើមានការផ្តាច់ជំនួយពីបណ្តាទាយក។

ទោះជាយ៉ាងណា លបទស នៅតែអាចដំណើរការបានទូទាំងទំនាបលិចទឹកនៃបឹងទន្លេសាប ដែលតាមការជាក់ស្តែង ក្រសួងបរិស្ថានមានសមត្ថកិច្ចពេញលេញតែនៅលើតំបន់ស្នូលដែលត្រូវអភិរក្ស។ តំបន់ស្នូលទាំងនោះ មានផ្នែកខ្លះ ត្រួតស៊ីគ្នានឹងឡូត៍នេសាទដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់រដ្ឋបាលជលផលនៃ ក្រសួងកសិកម្ម (Keskinen & Sethirith, 2009)។

អាជ្ញាធរទន្លេសាប ត្រូវបានបង្កើតក្រោមព្រះរាជក្រឹត្យចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩[២០] ដើម្បីទទួលខុសត្រូវក្នុងកិច្ចសហការ គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍នៅអាងបឹងទន្លេសាប។ អាជ្ញាធរទន្លេសាប មានតួនាទីផ្តល់ប្រឹក្សា និងការទំនាក់ទំនងជាមួយបណ្តាអ្នកពាក់ព័ន្ធទាំងឡាយនៅតំបន់អាងទន្លេសាប។ អាជ្ញាធរទន្លេសាប ដឹកនាំដោយក្រសួងធនធានទឹក ដែលមានសមាជិកមកពីតំណាងនៃក្រសួង ពាក់ព័ន្ធសំខាន់ៗរបស់រដ្ឋាភិបាល និងអភិបាលខេត្តនៃខេត្តទាំងប្រាំបីនៅជុំវិញបឹងទន្លេសាប (RGC 2009)។

## ៤.២.២ អ្នកពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ

### ៤.២.២.១ មន្ទីរធនធានទឹក និងឧតុនិយម (មធទឧ)

ការធ្វើប្រតិភូកម្មការទទួលខុសត្រូវទៅរដ្ឋអំណាចនៅថ្នាក់ក្រោមជាតិ ដូចជា មន្ទីរធនធានទឹកជាដើម នៅក្នុងគោលនយោបាយ និងផែនការគ្រប់គ្រងធនធានទឹកថ្នាក់មូលដ្ឋាន មានការកើនឡើងជាខ្លាំងគួរឲ្យកត់សំគាល់។ ការធ្វើវិមជ្ឈការនៃការគ្រប់គ្រងទឹកនេះ មានភាពស្របគ្នាជាមួយនឹងដំណើរការកំណែទម្រង់អភិបាលកិច្ចថ្នាក់ក្រោមជាតិដ៏ទូលំទូលាយរបស់រដ្ឋាភិបាល ដូចជា កំណែទម្រង់រដ្ឋបាលខេត្ត ក្រុង ស្រុក ខ័ណ្ឌ តាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងការបន្តកំណែទម្រង់រដ្ឋបាលថ្នាក់ឃុំ/សង្កាត់ ជាដើម (RGC 2005)។

ផ្អែកតាមគោលនយោបាយជាតិ ស្តីពីការគ្រប់គ្រងធនធានទឹក[២១] ស្ថាប័នរដ្ឋាភិបាលជាច្រើនកំពុងមានតួនាទីដោយឡែកៗពីគ្នាពាក់ព័ន្ធនឹងការគ្រប់គ្រង និងប្រើប្រាស់ធនធានទឹក ក៏ប៉ុន្តែកិច្ចសហការ និងសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធទាំងនោះ នៅមានកម្រិតកម្រិតនៅឡើយ។ ដោយមូលហេតុនេះហើយទើប មន្ទីរធនធានទឹក បានត្រៀមធ្វើការងារក្នុងក្របខ័ណ្ឌស្ថាប័ន ដើម្បីផ្តល់នូវយន្តការសមស្របនានាសម្រាប់សហការគ្រប់គ្រង និងអភិបាលកិច្ចធនធានទឹក[២២]។ ឧទាហរណ៍ គម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រខ្នាតធំភាគច្រើន ត្រូវបានស្ថិតនៅក្រោមសមត្ថកិច្ចដឹកនាំរបស់ក្រសួងធនធានទឹក។ ឯកសារគម្រោងត្រូវបានបញ្ជូនទៅឲ្យរដ្ឋអំណាចខេត្ត ឬមូលដ្ឋាន មន្ទីរធនធានទឹក មន្ទីរពាក់ព័ន្ធជុំវិញខេត្ត និងសហគមន៍មូលដ្ឋានដើម្បីអនុវត្តតាមកម្រិតសមស្រប។

ក្នុងការអនុវត្តជាក់ស្តែង មន្ទីរធនធានទឹក ជួយសម្របសម្រួល សកបទ តាមវិធីសាស្ត្រពីរយ៉ាងគឺ ១) ជួយសម្របសម្រួលក្នុងការងារបែងចែក និងគ្រប់គ្រងធនធានទឹកទូទៅ ២) បំពេញតួនាទីជាសន្ធាការី (អ្នកសម្របសម្រួល) លើជម្លោះកើតចេញពីការបែងចែកទឹក កង្វះខាតទឹក គ្រោះទឹកជំនន់ និងរាំងស្ងួត។ មន្ទីរធនធានទឹកបានប្រមើលមើលពីវិធីនានាដែលអាចជួយកែ លម្អការផ្គត់ផ្គង់ទឹកដល់កសិករ និងវិធីសម្រាប់បំផុសឲ្យកសិករយកចិត្តទុកដាក់ថែរក្សាទ្រព្យសម្បត្តិរួម ដូចជា ធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ជលផល និងព្រៃលិចទឹកជាដើម។ ឧទាហរណ៍ នៅខេត្តកំពង់ធំ មន្ទីរធនធានទឹក បានរៀបចំក្រុមការងារគ្រប់គ្រងទឹកថ្នាក់មូលដ្ឋាននៅក្នុងគម្រោងនានា ដែលឧបត្ថម្ភដោយភាគីទាយក (ម្ចាស់ជំនួយ) ដើម្បីគាំទ្រដល់សកបទ នៅតាម ប្រព័ន្ធធារាសាស្ត្រសំខាន់ៗ និងជួយដល់បណ្តាភ្នាក់ងាររដ្ឋាភិបាល និង NGOs ដូចជា ក្រុមស្រាវជ្រាវ និងផ្លាស់ប្តូរបច្ចេកវិទ្យា (អង្គការហ្រ្គេត) អង្គការសេដាក អង្គការកម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា (អង្គការកាវ៉ាក់) និងអង្គការអេសប៊ីខេ (SBK Research & Development) ជាដើម។

២០ ក្រោយមកបានកែសម្រួលដោយរាជក្រឹត្យលេខ NS/RKR/0310/258 ចុះថ្ងៃទី២៤ មីនា ២០១០។
២១ រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ២០០៤ គោលនយោបាយធនធានទឹកជាតិ សម្រាប់ព្រះរាជាណាចក្រកម្ពុជា ទំព័រទី ១០។
២២ ការជួបសម្ភាសន៍ជាមួយលោកប្រធានមន្ទីរ។

ជម្លោះក្នុងការប្រើប្រាស់ទឹក តែងតែកើតមាននៅពេលដែលខ្វះខាតទឹក។ អ្នកពាក់ព័ន្ធជាច្រើន ពិសេស មន្ទីរធនធានទឹក ខេត្តកំពង់ធំ តែងពិនិត្យឃើញថា ជម្លោះក្នុងការចែកចាយទឹកកើតមកពីការដែលគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន និងការមិនយកចិត្តទុកដាក់ថែទាំទ្រព្យសម្បត្តិរួម ដូចមាននៅក្នុងប្រសាសន៍របស់លោកប្រធានមន្ទីរធនធានទឹក ខេត្តកំពង់ធំ នៅក្នុងសិក្ខាសាលាដូចខាងក្រោម៖

> *...ការធ្វើកសិកម្ម គឺគេត្រូវការទឹក។ នៅរដូវប្រាំងក្នុងពេលដែលមន្ទីរកំពុងខិតខំប្រឹងប្រែងធ្វើយ៉ាងណាឲ្យមានទឹកប្រើប្រាស់ កសិករខ្លះគិតតែនាំគ្នាដណ្តើមទឹកគ្នា។ ជម្លោះតែងតែកើតមាន ព្រោះតែកសិករយើងមិនមានការយោគយល់គ្នា ឬសម្បទានគ្នាទៅវិញទៅមក។ ពួកគេចង់មានចង់បាន និងចង់រស់តែឯង...*[២៣]

> *...ឥឡូវអ្នកដែលស្រលាញ់របស់រួមមានតិចណាស់ ពិសេសការថែទាំទំនប់ប្រឡាយ។ រឿងនេះវាអាស្រ័យលើឆន្ទៈរបស់មនុស្សម្នាក់ៗ។ យើងត្រូវតែរួមគ្នាភ្ញាក់រលឹកឡើង ព្រោះថាវាមានការពិបាកណាស់ក្នុងការសុំជំនួយ ឧបត្ថម្ភពីទាយក (ម្ចាស់ជំនួយ) ហើយសំណង់ប្រព័ន្ធធារាសាស្ត្រនីមួយៗមានតម្លៃថ្លៃណាស់...*[២៤]

ដូចគ្នានេះដែរ ដោយទទួលស្គាល់នូវបញ្ហាទាំងនេះ មន្ទីរធនធានទឹកខេត្តពោធិ៍សាត់បានរៀបចំឲ្យមានយន្តការមួយចំនួនដើម្បីការពារ និងដោះស្រាយជម្លោះដែលបង្កដោយការប្រើប្រាស់ទឹក។ ផែនការការពារជម្លោះនៃការប្រើប្រាស់ទឹកនេះ ត្រូវបានបង្កើតឡើងនៅកម្រិតមូលដ្ឋាន ដើម្បីជួយជាក្របខ័ណ្ឌការងារមួយសម្រាប់ សកបទ និងអាជ្ញាធរមូលដ្ឋាន យកទៅដោះស្រាយរាល់បញ្ហា ដែលអាចកើតមានឡើងក្នុងការងារគ្រប់គ្រងទឹក។

មន្ទីរធនធានទឹក គឺជាស្ថាប័នមួយដែលបំពេញតួនាទីដ៏សំខាន់ ក្នុងបណ្តាតួអង្គដែលពាក់ព័ន្ធនឹងការងារធារាសាស្ត្រ។ ក្នុងតួនាទីដ៏សំខាន់នៃការធានាឲ្យមានទឹកគ្រប់គ្រាន់ដល់កសិករសម្រាប់ធ្វើដំណាំកសិកម្ម មន្ទីរធនធានទឹក បានដើរតួនាទីដឹកនាំ និងលើកទឹកចិត្តឲ្យមានកិច្ចសហការល្អរវាងបណ្តាមន្ទីរពាក់ព័ន្ធជុំវិញខេត្ត NGOs និងវិស័យឯកជន លើការងារអភិវឌ្ឍន៍ និងគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ។ ឧទាហរណ៍ នៅខេត្តកំពង់ធំ មន្ទីរធនធានទឹក បានសហការយ៉ាងល្អជាមួយរដ្ឋបាលជលផលខេត្ត ដើម្បីធានាថា កសិករមានទឹកធ្វើស្រែផង មានត្រីសម្រាប់ធ្វើម្ហូបផង[២៥]។

*៤.២.២.២ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មករន)*

មន្ទីរកសិកម្ម បានរួមសហការគ្នាយ៉ាងសកម្មជាមួយមន្ទីរធនធានទឹក ដើម្បីផ្តល់ការអប់រំផ្សព្វផ្សាយកសិកម្មដល់ សកបទ និងក្រុមកសិករប្រើប្រាស់ទឹក។

ក្រសួងកសិកម្ម និងមន្ទីរកសិកម្ម បានព្យាយាមយ៉ាងយកចិត្តទុកដាក់ក្នុងការលើកទឹកចិត្តកសិករឲ្យធ្វើការកែលម្អការដាំដុះរបស់ពួកគេឲ្យបានខ្លាំងក្លា ដោយទាញយកធនធានទឹក ដែលមានពីប្រព័ន្ធធារាសាស្ត្រមកប្រើឲ្យអស់លទ្ធភាព។ មន្ទីរកសិកម្មខេត្តកំពង់ធំ បានឲ្យដឹងថា កសិករនៅតំបន់មួយចំនួននៅខេត្តកំពង់ធំបានផ្លាស់ប្តូរពូជស្រូវ និងរបៀបដាំដុះតាមការណែនាំ និងផ្តល់ប្រឹក្សាពីសំណាក់មន្ទីរកសិកម្ម គឺគាត់ប្តូរមកពីការប្រើពូជរយៈពេលវែង (ស្រូវធ្ងន់) មកពូជស្រូវមធ្យមវិញ[២៦]។ ប៉ុន្តែនៅប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិតនៃខេត្តកំពង់ធំនេះដែរ កសិករនៅតែបន្តរបៀបដាំដុះតាមបែបប្រពៃណីនៅឡើយ ហើយការអនុវត្តបែបនេះផ្តល់ទិន្នផលទាប។ លោកប្រធានមន្ទីរកសិកម្មខេត្តបានបញ្ជាក់ថា៖ "...កសិករខ្លះធ្វើស្រែដោយមិនសូវយកចិត្តទុកដាក់ក្នុងការថែទាំប៉ុន្មានទេ។ កសិករខ្លះបានមកជួបមន្ទីរ ដើម្បីស្នើសុំការជួយឧបត្ថម្ភ។ មន្ទីរបានជួយដល់ពួកគេ (ប្រឹក្សាយោបល់) ហើយពួកគេទទួលបានលទ្ធផលល្អជាងមុនច្រើនណាស់..."[២៧]។ មន្ត្រីនៃធនាគារអភិវឌ្ឍន៍អាស៊ីម្នាក់ក៏បានអះអាងដែរថា៖ "...ទិន្នផលស្រែគំរូបានកើនឡើងរហូតដល់ ៣០% បើធៀបទៅនឹងការដាំដុះតាមប្រពៃណីរបស់

---

២៣ យោបល់ជាអនុសាសន៍របស់ឯកឧត្តមប្រធានមន្ទីរនាសិក្ខាសាលាថ្នាក់ខេត្ត នៅមន្ទីរធនធានទឹក ខេត្តកំពង់ធំ ថ្ងៃទី២៣-២៤ កុម្ភៈ ២០១០។

២៤ Ibid.

២៥ Ibid.

២៦ ការជួបសម្ភាសន៍ជាមួយលោកប្រធានមន្ទីរកសិកម្មខេត្តកំពង់ធំ ថ្ងៃទី៤ មករា ២០១០។

២៧ Ibid.

កសិករ..."[២៨] ប៉ុន្តែនៅមានបញ្ហារាំខានជាច្រើន ដែលនាំឲ្យកសិករដែលចង់ធ្វើស្រែប្រាំងមិនអាចធ្វើទៅបាន ទោះបីជាមានទឹកគ្រប់គ្រាន់សម្រាប់ធ្វើស្រែក៏ដោយ។

ក្រសួងកសិកម្ម និងមន្ទីរកសិកម្មបានរៀបចំឲ្យមានការធ្វើស្រែគំរូជាច្រើនដើម្បីបង្ហាញដល់កសិករ ដោយបានជ្រើសរើសយកកសិករគំរូសំខាន់ៗ ហើយបានបណ្តុះបណ្តាល ឬបង្ហាញដល់ពួកគេអំពីបច្ចេកទេសល្អៗ ដើម្បីលើកស្ទួយការដាំដុះ ដោយសង្ឃឹមថា បើកសិករគំរូទាំងនោះបានទទួលជោគជ័យ កសិករឯទៀតនឹងអនុវត្តតាមដែរ។ បណ្តាកសិករដែលអនុវត្តតាមការណែនាំ និងបណ្តុះបណ្តាលពីមន្ទីរកសិកម្មបានឲ្យដឹងថា ទិន្នផលស្រូវរបស់ពួកគាត់បានកើនឡើងជាងមុនយ៉ាងល្អប្រសើរ[២៩]។

*...កត្តាជោគជ័យនោះគឺថា កសិករបានកែប្រែការដាំដុះតាមការណែនាំរបស់មន្ទីរកសិកម្ម ពីពូជស្រូវធ្ងន់ ទៅ ពូជស្រូវមធ្យម...[៣០]*

*...កសិករដែលជឿទុកចិត្តលើមន្ទីរកសិកម្ម បានទទួលលទ្ធផលយ៉ាងល្អប្រសើរ។ មន្ទីរមិនចង់ផ្តល់អំណោយជាផ្នែកៗដល់ប្រជាកសិករទេ តែយើងផ្តល់ដល់ពួកគាត់នូវជំនួយដ៏ពេញលេញ ដើម្បីឲ្យពួកគាត់មានការជឿជាក់ (ដូចជា ផ្តល់ពូជស្រូវ ជី វគ្គបណ្តុះបណ្តាល និងអ្វីៗផ្សេងទៀត)...[៣១]*

### *៤.២.២.៣ រដ្ឋអំណាចមូលដ្ឋាន (រម)*

ការទទួលខុសត្រូវសំខាន់ៗរបស់រដ្ឋអំណាចឃុំ (ប្រធានឃុំ និងប្រធានភូមិ) មានចែងនៅក្នុងច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ (RGC 2001)។ ច្បាប់នេះតម្រូវឲ្យក្រុមប្រឹក្សាឃុំ ធ្វើការលើកស្ទួយ និងគាំទ្រដល់អភិបាលកិច្ចល្អ ដោយប្រើប្រាស់គ្រប់ធនធានដែលមាន ដើម្បីដោះស្រាយតម្រូវការមូលដ្ឋានរបស់ប្រជាពលរដ្ឋ ពិសេសដើម្បីរក្សាសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ បំរើផលប្រយោជន៍រួមនៃប្រជាពលរដ្ឋស្របតាមគោលនយោបាយជាតិ លើកកម្ពស់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច និងលើកស្ទួយកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ថែរក្សា ការពារធនធានធម្មជាតិ និងបរិស្ថាន (មាត្រាទី៩,៤១,៤៣)។ ម៉្យាងទៀតនៅក្នុងមាត្រាទី ៤៨ និង៤៩ នៃច្បាប់នេះ ក៏បានផ្តល់ដល់ឃុំ/សង្កាត់ នូវអំណាចនីតិប្រតិបត្តិ និងនីតិបញ្ញត្តិ សម្រាប់យកទៅអនុវត្តតាមរយៈដីកាដែលធ្វើឡើងដោយរដ្ឋបាលឃុំ/សង្កាត់ ហើយអាចនឹងមានប្រសិទ្ធភាពសម្រាប់ចាត់វិធានការតាមផ្លូវច្បាប់ក្នុងឃុំ/សង្កាត់ដែលខ្លួនកាន់កាប់។ ក្នុងករណីនៃការគ្រប់គ្រងទឹក ច្បាប់នេះផ្តល់សិទ្ធអំណាច (អាណត្តិ) ដល់រដ្ឋអំណាចឃុំ ដើម្បីធ្វើការគ្រប់គ្រងលើធនធានទឹក និងដាក់ទោសដល់ជនណាដែលប្រព្រឹត្តល្មើសច្បាប់។

ទន្ទឹមនឹងនេះដែរ សេចក្តីប្រកាសរបស់ក្រសួងមហាផ្ទៃ (MOI *Praskas* 1994) បានផ្តល់អាណត្តិស្របច្បាប់ដល់អភិបាលខេត្ត និងស្រុក ដើម្បីបំពេញតួនាទីជានគរបាលរដ្ឋបាល និងនគរបាលយុត្តិធម៌ ដើម្បីដោះស្រាយជម្លោះស៊ីវិល ដាក់ទណ្ឌកម្មដល់បទល្មើសកម្រិតស្រាល សហការ និងត្រួតពិនិត្យសកម្មភាពមន្ត្រីថ្នាក់ឃុំ និងខេត្ត និងផ្តល់អាជ្ញាប័ណ្ណសម្រាប់ធ្វើពាណិជ្ជកម្ម សិប្បកម្ម និងជំនួញផ្សេងៗស្របតាមច្បាប់ជាតិ (RGC 1994)។

ម៉្យាងទៀត សេចក្តីប្រកាសរបស់ក្រសួងមហាផ្ទៃ ក៏បានផ្តល់ដល់រដ្ឋអំណាចស្រុក និងរដ្ឋអំណាចខេត្ត នូវអាណត្តិដ៏ពេញលេញ ដើម្បីគ្រប់គ្រងធនធានទឹក និងដាក់ទោសរាល់សកម្មភាពទាំងឡាយណាដែលល្មើសច្បាប់។ ប្រការទាំងនេះហើយដែលតម្រូវឲ្យ សកបទ ធ្វើកិច្ចសហការឲ្យបានល្អជាមួយរដ្ឋអំណាចដែលមានសមត្ថកិច្ចដូចខាងលើ។

---

២៨ ការជួបសម្ភាសន៍ជាមួយ មន្ត្រីនៃធនាគារអភិវឌ្ឍន៍អាស៊ី នៅនិវេសដ្ឋានបេសកកម្ម នៃធនាគារអភិវឌ្ឍន៍អាស៊ី ក្រុងភ្នំពេញ។
២៩ ការជួបសម្ភាសន៍ជាមួយលោកប្រធានមន្ទីរកសិកម្មខេត្តកំពង់ធំ ថ្ងៃទី ៤ មករា ២០១០។
៣០ Ibid.
៣១ Ibid.

## ៤.២.៣ បណ្តាអ្នកពាក់ព័ន្ធនៅកម្រិតប្រព័ន្ធធារាសាស្ត្រ

### *៤.២.៣.១ សហគមន៍កសិករប្រើប្រាស់ទឹក (សកបទ)*

សកបទ ត្រូវបានផ្តួចផ្តើមបង្កើតឡើងដោយក្រសួងធនធានទឹក ស្របតាមច្បាប់ ស្តីពីការគ្រប់គ្រងធនធានទឹក និងស្របតាមយុទ្ធសាស្ត្ររបស់ក្រសួងស្តីពី PIMD។ សកបទ បង្កើតឡើងក្នុងលក្ខណៈមួយដែលបង្ហាញឲ្យឃើញនូវការទទួលស្គាល់ការចូលរួមនៃអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានក្នុងការងារអភិបាលកិច្ចធនធានទឹក ពិសេសគឺការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ។

រូបភាព ៥៖ រចនាសម្ព័ន្ធ សកបទ




ប្រភព៖ Sinath C. 2002

ការបង្កើត សកបទ គឺផ្អែកទៅតាមប្រកាសលេខ ៣០៦ នៃ ក្រសួងធនធានទឹក ដើម្បីប្រគល់នូវការទទួលខុសត្រូវដោយផ្ទាល់សម្រាប់ដំណើរការ និងថែទាំប្រព័ន្ធធារាសាស្ត្រ[៣២] ដូចជា ១) រៀបចំផែនការការងាររបស់សហគមន៍ ២) បង្កើតលក្ខន្តិក កិច្ចសន្យានិងបទបញ្ជារបស់សហគមន៍ ៣) ថែទាំប្រព័ន្ធធារាសាស្ត្រឲ្យបានល្អដើម្បីបែងចែកទឹកឲ្យទាន់ពេលវេលា ៤) គ្រប់គ្រង និងចែកចាយទឹកទៅឲ្យសមាជិកសហគមន៍ ៥) បង្កើនសមត្ថភាពលើការងារប្រើប្រាស់ ថែទាំ និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ ៦) ដោះស្រាយរាល់បញ្ហាដែលស្នើឡើងដោយសមាជិកសហគមន៍ ៧) ប្រមូល ថ្លៃសេវាកម្មប្រើប្រាស់ទឹកទៅតាមចំនួនដែលបានព្រមព្រៀងនៅក្នុងសហគមន៍ (RGC 2000, Circular No.1, Article 10)។

ក្រសួងធនធានទឹក បានពិចារណាឃើញថា ការបង្កើត សកបទ គឺជាមធ្យោបាយមួយដែលធានាឲ្យមាននិរន្តរភាព និងលើកកម្ពស់ការប្រើប្រាស់សម្រាប់ធារាសាស្ត្រប្រកបដោយប្រសិទ្ធភាព ក្រោមការជួយឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ហើយកិច្ចការនេះ អាចកាត់បន្ថយចំណាយប្រចាំឆ្នាំរបស់រដ្ឋាភិបាល សម្រាប់ការដំណើរការ និងការថែទាំប្រព័ន្ធធារាសាស្ត្របាន។ ទន្ទឹមនឹងនេះ ការទទួលខុសត្រូវ និងផលប្រយោជន៍របស់កសិករ ត្រូវបានបង្កើនឡើងជាបណ្តើរៗផងដែរ (MOWRAM 2009a)។

ស្របតាមគោលនយោបាយគ្រប់គ្រងទឹក សកបទ មានភារកិច្ចសហការជាមួយរដ្ឋអំណាចមូលដ្ឋាន ស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល និងអង្គការអន្តរជាតិនានា។ នៅប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត សកបទ បានឲ្យដឹងថា កន្លងមកក្រោមការគាំទ្ររបស់មន្ទីរធនធានទឹក អង្គការហ្វ្រេត អង្គការសេដាក ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង សហគមន៍មូលដ្ឋាន និងសកបទ បានគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។ ដូចនេះ ប្រសិទ្ធភាព និងនិរន្តរភាពនៃប្រព័ន្ធធារាសាស្ត្រ នៅពឹងផ្អែកលើជំនួយគាំទ្រពីមជ្ឈដ្ឋានខាងក្រៅផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុនៅឡើយ។

---

៣២ ការព្រាងអនុក្រឹត្យស្តីពីសកបទត្រូវបានបញ្ជូនទៅគណៈរដ្ឋមន្ត្រីប្រហែលបីឆ្នាំមកហើយហើយក្រសួងធនធានទឹកបានប្រើប្រាស់ប្រកាសលេខ ៣០៦ ស្តីពីការបង្កើតសហគមន៍គ្រប់គ្រងធនធានទឹក ដើម្បីរៀបចំបង្កើតបានប្រមាណជាង ៣០០សកបទ។ ប្រការនេះ នាំឲ្យមានសំណួរខ្លះៗ ទាក់ទងដល់ភាពពេញច្បាប់របស់ សកបទ នៅតាមឃុំ/សង្កាត់មួយចំនួន។

នៅកម្រិតប្រព័ន្ធធារាសាស្ត្រ សមិទ្ធផលទូទៅនៃបំណងដ៏សំខាន់ជាងគេរបស់សកបទ ក្នុងការគ្រប់គ្រង ថែទាំ និងដំណើរការប្រព័ន្ធធារាសាស្ត្រខ្នាតតូច និងមធ្យម តាមលក្ខណៈមួយប្រកបដោយនិរន្តរភាពនោះ ស្ថិតនៅឆ្ងាយពីគោលដៅនៅឡើយ។ តាមរយៈគំហើញនៃការសិក្សានៅតាមភូមិមួយចំនួនបានឲ្យដឹងថា មានគម្លាតដ៏គួរឲ្យកត់សំគាល់រវាងអាណត្តិដែលទទួលបានតាមច្បាប់ និងប្រសិទ្ធភាពពិតប្រាកដនៃអណត្តិទាំងនោះ ដោយរួមមាន ការលំបាករបស់ពួកគេក្នុងការប្រមូលថ្លៃប្រើប្រាស់សេវាកម្មធារាសាស្ត្រផងដែរ។

ការប្រជុំពិភាក្សាជាមួយក្រុមគោលដៅ និងសិក្ខាសាលាថ្នាក់ខេត្តបានបង្ហាញឲ្យដឹងថា នៅកម្រិតអាងទន្លេសាប ទោះបីជា សកបទ មានការទទួលខុសត្រូវតាមច្បាប់ និងរដ្ឋបាលដើម្បីគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រក្តី កសិករភាគច្រើន ឬសកបទ ដែលនៅក្បែរ (ខ្សែទឹកខាងលើ ឬខាងក្រោម) មិនសូវមានស្មារតីជាម្ចាស់លើគម្រោង ឬប្រព័ន្ធធារាសាស្ត្រទាំងនោះប៉ុន្មានទេ។ ជាលទ្ធផល សកបទ ត្រូវស្វែងរកជំនួយគាំទ្រពីសំណាក់អាជ្ញាធរមូលដ្ឋាន មន្ទីរធនធានទឹក និងមន្ទីរជំនាញជុំវិញខេត្ត ដើម្បីដោះស្រាយជម្លោះនានាដែលកើតចេញពីការប្រើប្រាស់ទឹក ហើយបញ្ហានេះបង្កឲ្យមានការលំបាកដល់ សកបទ ក្នុងកិច្ចដំណើរការការងាររបស់ខ្លួនឲ្យប្រកបដោយប្រសិទ្ធភាព។

> *...សកបទ គ្រប់គ្រង និងចែកចាយទឹកដាច់ដោយឡែកពីគ្នា ហើយពីមុនមកមិនមានតំណាង សកបទ រួមទេ។ ភាគច្រើន សកបទ ធ្វើការតែជាមួយមន្ទីរខេត្តមួយចំនួនប៉ុណ្ណោះ ដូចជា មន្ទីរធនធានទឹក ឬមន្ទីរកសិកម្ម។ មន្ទីរជំនាញជុំវិញខេត្តមួយចំនួន ក៏មិនសូវមានទំនាក់ទំនងជិតស្និទ្ធជាមួយគ្នាដែរ...*[៣៣]

រូបភាព ៦៖ អាងស្ទឹងជ្រៃបាក់




ប្រភព៖ CDRI/NRE 2010

៣៣ មតិរបស់អាជ្ញាធរមូលដ្ឋាន ក្នុងក្រុមពិភាក្សានាសិក្ខាសាលាថ្នាក់ខេត្ត ថ្ងៃទី២៤-២៦ ខែកុម្ភៈ 2010 នៅខេត្តកំពង់ធំ។

ករណីអាងស្ទឹងជ្រៃបាក់ ស្ថិតក្នុងខេត្តកំពង់ឆ្នាំង កសិករដែលជួបសម្ភាស បានសំដែងអារម្មណ៍របស់ខ្លួនថា មានតែមន្ទីរធនធានទឹក ឬអាជ្ញាធរមូលដ្ឋានទេដែលមានសិទ្ធិគ្រប់គ្រងលើអាងទឹកទាំងមូល។ តាមជាក់ស្តែង មានអ្នកពាក់ព័ន្ធសំខាន់ៗបី ដែលមានការទទួលខុសត្រូវដើម្បីគ្រប់គ្រងស្ទឹងទន្លេនានា នៅក្នុងអាងស្ទឹង។ ដូច្នោះ ការកែលម្អរចនាសម្ព័ន្ធសហការរវាង សកបទ នៅតាមខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម នឹងផ្តល់យន្តការដ៏មានប្រសិទ្ធភាពមួយដើម្បីលើកកម្ពស់តួនាទីក្នុងការបែងចែកទឹក។ ប៉ុន្តែយន្តការនេះ កំពុងស្ថិតនៅក្រោមការពិចារណានៅឡើយ។

ទំហំនៃការទទួលខុសត្រូវរបស់ សកបទ កម្រិតនៅត្រឹមការគ្រប់គ្រងប្រព័ន្ធប្រឡាយរង និងប្រឡាយស្រោចស្រព។ ក្នុងករណីខ្លះ សកបទ ធ្វើប្រតិភូកម្មការគ្រប់គ្រងលើប្រព័ន្ធប្រឡាយស្រោចស្រព ឲ្យទៅក្រុមកសិករប្រើប្រាស់ទឹក (កកបទ) ដែលមានដីស្រែនៅក្នុងប្រព័ន្ធនោះ ជាអ្នកទទួលខុសត្រូវ។ ប្រធានក្រុមដឹកនាំនៃ កកបទ ជាទូទៅ គឺជាប្រធានភូមិ។ ចំពោះប្រព័ន្ធធារាសាស្ត្រខ្នាតធំ គេកត់សំគាល់ឃើញថា អាងស្តុកទឹក និងប្រឡាយមេ ស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ក្រសួងធនធានទឹក ឬមន្ទីរធនធានទឹក។

### *៤.២.៣.២ ក្រុមកសិករប្រើប្រាស់ទឹក (កកបទ)*

ដូចមានចែងក្នុងសារាចរលេខ ០១ កកបទ គឺជាអនុក្រុមនៃ សកបទ ដែលទទួលខុសត្រូវលើប្រព័ន្ធស្រោចស្រព (ប្រឡាយទី៣) ដែលហូរកាត់ភូមិ និងដីស្រែរបស់ពួកគេ។ រូបភាព ៧ បង្ហាញពីរចនាសម្ព័ន្ធ និងតួនាទីរបស់ កកបទ ដែលទាក់ទិនទៅនឹងអំណាចគ្រប់គ្រងរបស់ សកបទ។

នៅតាមប្រព័ន្ធធារាសាស្ត្រដែលបានចុះសិក្សាភាគច្រើននៃខេត្តទាំងបី សកបទ បានបង្កើត កកបទ លើកលែងតែនៅប្រព័ន្ធធារាសាស្ត្រ តាំងក្រសាំង ខេត្តកំពង់ឆ្នាំង និងដំណាក់អំពិល ខេត្តពោធិ៍សាត់ ដែលមិនទាន់បានបង្កើត កកបទ។ នៅប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត សកបទ នឹងបង្កើតអនុក្រុម ៥ ដើម្បីគ្រប់គ្រងប្រឡាយរងទាំង ៥ រួមទាំងប្រព័ន្ធប្រឡាយបង្ហូរមួយចំនួនដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន (មន្ទីរធនធានទឹកទទួលខុសត្រូវលើអាងស្តុកទឹក និងប្រឡាយមេ)។

រូបភាព ៧៖ រចនាសម្ព័ន្ធទូទៅនៃប្រព័ន្ធដែលបានសិក្សា




សំគាល់៖ រដ្ឋបាលជលផលគ្រប់គ្រងត្រីនៅក្នុងអាងស្តុកទឹក មន្ទីរធនធានទឹកគ្រប់គ្រងទឹកនៅក្នុងអាងស្តុកទឹក និងប្រឡាយមេ (A) សកបទ គ្រប់គ្រងប្រឡាយរង (B) និង កកបទ គ្រប់គ្រងប្រឡាយទី៣ (C)

នៅរដូវធ្វើស្រែនៅខែប្រាំង ឬវស្សា កសិករស្នើសុំទឹកតាមរយៈប្រធានក្រុមកសិករប្រើប្រាស់ទឹក ដើម្បីឲ្យគាត់សុំទៅគណៈកម្មាធិការ សកបទ ដើម្បីបង្ហូរទឹកពីប្រឡាយរងទៅប្រឡាយស្រោចស្រព។ ពេលដែលខ្វះទឹកនៅក្នុងប្រឡាយរង សមាជិកគណៈកម្មាធិការ សកបទ ទាក់ទងទៅមន្ទីរធនធានទឹក ដើម្បីបើកទឹកពីប្រឡាយមេ បង្ហូរចូលទៅប្រឡាយរង។ នៅប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត រាល់បញ្ហាដែលទាក់ទងនឹងការបែងចែកទឹក ត្រូវបានគេលើកយកទៅពិភាក្សា និងដោះស្រាយក្នុងអង្គប្រជុំប្រចាំសប្តាហ៍ ឬប្រចាំខែ ក្រោមអធិបតេយ្យភាពនៃគណៈកម្មាធិការទ្រទ្រង់[៣៤]។

អ្នកដែលបានជួបសម្ភាសនៅតាមប្រព័ន្ធធារាសាស្ត្រដែលបានចុះសិក្សាបានឲ្យដឹងថា នៅដំណាក់កាលដំបូងនៃការបង្កើតក្រុមកសិករប្រើប្រាស់ទឹក តួនាទីរបស់សមាជិកក្រុមនីមួយៗត្រូវបានកំណត់យ៉ាងច្បាស់លាស់។ ប៉ុន្តែមកទល់បច្ចុប្បន្ន ដោយសារមានការលំបាកក្នុងជីវភាពរស់នៅ និងដោយមិនសូវមានកិច្ចសហការគ្នាល្អ រវាងសមាជិកក្រុមកសិករប្រើប្រាស់ទឹក និងកសិករ ធ្វើឲ្យសមាជិកមួយចំនួនរបស់ក្រុមកសិករប្រើប្រាស់ទឹក ដែលបានបង្កើតឡើង បោះបង់ចោលតួនាទីរបស់ខ្លួន។ ក្រុមកសិករប្រើប្រាស់ទឹក បច្ចុប្បន្នត្រូវបានដឹកនាំភាគច្រើនដោយប្រធានភូមិ។ តាមរយៈមធ្យោបាយនេះ កសិករ និងក្រុមកសិករប្រើប្រាស់ទឹក ជួនកាលត្រូវគេមើលឃើញថា អ្នកពាក់ព័ន្ធអកម្ម ឬ "អនិស្សរភាព" (យោងតាមលោក Mitchell *et al.* 1992 ដូចដែលបានបកស្រាយខាងដើម)។ កសិករ និងក្រុមកសិករប្រើប្រាស់ទឹក មានអំណាចតិចតួចប៉ុណ្ណោះ ទោះបីជាពួកគេមានផលប្រយោជន៍ពេញតាមច្បាប់ និងមានភាពបន្ទាន់នៅក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រក៏ដោយ។

### ៤.២.៤ ទិដ្ឋភាព និងទស្សនវិស័យអ្នកផ្តល់ជំនួយ

ការវិនិយោគវិស័យធនធានទឹកនៅកម្ពុជា ពឹងផ្អែកយ៉ាងខ្លាំងលើជំនួយពីសហគមន៍អន្តរជាតិ (ADB, 2003) រួមមាន ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងបណ្តាភ្នាក់ងារនៃប្រព័ន្ធអង្គការសហប្រជាជាតិ ដូចជា អង្គការស្បៀង និងកសិកម្ម (FAO) កម្មវិធីអភិវឌ្ឍន៍ អង្គការសហប្រជាជាតិ (UNDP) អង្គការសុខភាពពិភពលោក (WHO) និងអង្គការកម្មវិធីស្បៀងអាហារពិភពលោក (WFP) ជាដើម។ ជំនួយទ្វេភាគី ក៏បានរួមវិភាគទានយ៉ាងសំខាន់ក្នុងវិស័យនេះ ដូចជា ជំនួយទ្វេភាគីនៃរាជរដ្ឋាភិបាលកម្ពុជា ជាមួយសហភាពអឺរ៉ុប ប្រទេសបារាំង អ៊ីតាលី ជប៉ុន និងអូស្ត្រាលីជាដើម។ NGOs អង្គការអន្តរជាតិ ក៏បានចូលរួមពាក់ព័ន្ធក្នុងការងារនេះដែរ ពិសេសនៅតាមតំបន់ជនបទលើការងាររដ្ឋាករទឹក អនាម័យ ប្រព័ន្ធធារាសាស្ត្រកសិកម្មខ្នាតតូច និងការអភិវឌ្ឍន៍សហគមន៍ (ADB 2003)។ តារាងបញ្ជីអ្នកផ្តល់ជំនួយសំខាន់ៗក្នុងការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា មាននៅក្នុងឧបសម្ព័ន្ធទី ២។

#### *៤.២.៤.១ ការរួមចំណែក និងតួនាទីផ្នែកហិរញ្ញវត្ថុរបស់អ្នកផ្តល់ជំនួយ*

ប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធជនបទភាគច្រើន បានការគាំទ្រផ្នែកហិរញ្ញវត្ថុពីសំណាក់រដ្ឋាភិបាល និងទាយក ហើយនិងការចូលរួមបដិភាគ (ដូចជា ថវិកា ដីធ្លី ឬកម្លាំងពលកម្ម) របស់អ្នកទទួលផលពីគម្រោងផងដែរ។ ដោយឡែកចំពោះការងារគ្រប់គ្រងទឹក ជំនួយហិរញ្ញវត្ថុទទួលបានពីទាយក ត្រូវបានយកទៅប្រើប្រាស់ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធ (រឹង) ដូចជាការងារធារាសាស្ត្ររូបវ័ន្ត និងសម្រាប់កម្មវិធីអប់រំផ្សព្វផ្សាយកសិកម្ម។

នៅខេត្តកំពង់ធំ ធនាគារអភិវឌ្ឍន៍អាស៊ី និងទីភ្នាក់ងារអភិវឌ្ឍន៍បារាំង គឺជាភ្នាក់ងារផ្តល់ជំនួយដ៏សំខាន់ ដែលផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រដែលកំពុងសិក្សានេះ។ ឧទាហរណ៍ ករណីការវិនិយោគលើប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត នៅក្នុងចំណោមទឹកប្រាក់សរុបប្រមាណ ២៣,៨លានដុល្លារ ធនាគារអភិវឌ្ឍន៍អាស៊ី បានរួមផ្តល់ឥណទានចំនួន ១៦លានដុល្លារ ភ្នាក់ងារដើម្បីការអភិវឌ្ឍន៍បារាំងផ្តល់ចំនួនប្រមាណ ០,៤លានដុល្លារ[៣៥]។ តាមការសម្ភាសជាមួយមន្ត្រីនៃអង្គការសេដាក បានឲ្យដឹងបន្ថែមថា វិភាគទានរបស់រដ្ឋាភិបាល គឺបានប្រើប្រាស់ជាសំខាន់ទៅលើការទូទាត់

---

៣៤ គណៈកម្មាធិការទ្រទ្រង់ ត្រូវបានដឹកនាំដោយអភិបាលស្រុក។ សកបទ អាជ្ញាធរមូលដ្ឋាន នគរបាលស្រុក និងមន្ទីរពាក់ព័ន្ធជុំវិញខេត្ត ដូចជា មន្ទីរធនធានទឹក និងមន្ទីរកសិកម្ម ជាសមាជិក។ រាល់បញ្ហា ត្រូវបានលើកឡើងដោយសមាជិកនាអង្គប្រជុំប្រចាំខែ។ ស្ថាប័នពាក់ព័ន្ធ ឬអាជ្ញាធរមូលដ្ឋាន នឹងត្រូវគេស្នើសុំឲ្យដោះស្រាយបញ្ហាពាក់ព័ន្ធ ដើម្បីធានាឲ្យមានកិច្ចសហការល្អរវាងអ្នកពាក់ព័ន្ធទាំងឡាយ។

៣៥ តាមការសម្ភាសមន្ត្រីធនាគារអភិវឌ្ឍន៍អាស៊ី ថ្ងៃទី ១៨ ធ្នូ ២០០៩ និងតាមរយៈគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ីស្តីពី Stung Chinit Irrigation and Rural Infrastructure Project: Cambodia, http://pid.adb.org/pid/LoanView.htm?projNo=29257&seqNo=01&typeCd=3 (accessed 15 June 2010)។

សំណងដល់បណ្តាកសិករដែលបាត់បង់ដីស្រែក្នុងអំឡុងពេលអនុវត្តគម្រោង។ អ្នកទទួលផលបានចូលរួមចំណែកផ្តល់វិភាគទានរបស់ខ្លួនជាដីធ្លី ស្រែ ឬប្រព័ន្ធ ប្រឡាយ ដល់គម្រោងដើម្បីអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ[៣៦]។

លោកប្រធានមន្ទីរធនធានទឹកខេត្តពោធិ៍សាត់ បានឲ្យដឹងថា អ្នកផ្តល់ជំនួយ ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ឬធនាគារពិភពលោកជាដើម តម្រូវឲ្យមានការចូលរួមបដិភាគមួយផ្នែកតូចពីរដ្ឋាភិបាលសម្រាប់ការអនុវត្តគម្រោង ហើយដែលអាចសន្មតបានថា វិភាគទាននេះ គឺជាការចូលរួមចំណែកជាថវិកាផង និងដើម្បីបង្ហាញភាពជាម្ចាស់ និងការប្តេជ្ញាចិត្ត[៣៧]ផងដែរ។ ជួនកាលបដិភាគដែលត្រូវការនោះ គឺជាចំនួនទឹកប្រាក់ដ៏ច្រើនគួរសមសម្រាប់រដ្ឋាភិបាល ដែលពេលខ្លះពុំអាចឆ្លើយតបបាន។ លោកបានឲ្យដឹងបន្ថែមទៀតថា គម្រោងដែលអនុវត្តដោយទាយកភាគច្រើន បានដំណើរការទៅដោយរលូន ព្រោះពួកគេមានធនធានបច្ចេកទេស និងហិរញ្ញវត្ថុគ្រប់គ្រាន់។ ការពឹងផ្អែកលើជំនួយបរទេសនេះ បានបង្ហាញថា ទាយក (អ្នកផ្តល់ជំនួយ) ស្ថិតនៅក្នុងក្រុមអ្នកពាក់ព័ន្ធទាំងស្រុង ដោយហេតុថាពួកគេសំដែងឲ្យឃើញនូវការទាមទារ អំណាច ភាពបន្ទាន់ និងភាពពេញច្បាប់នៅក្នុងខណៈពេលមួយ។ ក្នុងករណីដែលគេមើលឃើញថា មានកង្វះភាពពេញច្បាប់ និងភាពបន្ទាន់ ពួកគេអាចស្ថិតនៅក្នុងចំណោមក្រុមអ្នកពាក់ព័ន្ធដ៏មានអំណាចតាមគំរូបំណែងចែកជាក្រុមរបស់លោក មីតឆែល (Mitchell *et al.* 1997)។

### *៤.២.៤.២ តួនាទីផ្នែកបច្ចេកទេសរបស់ទាយក*

ជំនួយអន្តរជាតិសម្រាប់ការអភិវឌ្ឍ នៅតែមានសារៈសំខាន់យ៉ាងខ្លាំងដល់កម្ពុជា។ គេឃើញមានបំលាស់ប្តូរយ៉ាងរហ័សទៅកាន់សករាជថ្មីដ៏ទូលំទូលាយក្នុងភាពជាដៃគូជាមួយសហគមន៍អន្តរជាតិ ដែលជាអ្នកផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុដ៏សំខាន់ ដែលឆ្លើយតបនឹងតម្រូវការបន្ទាន់របស់កម្ពុជាដើម្បីប្រយុទ្ធប្រឆាំងជាមួយនឹងភាពក្រីក្រ (RGC 2007)។

ការសម្ភាសបានឲ្យដឹងថា អង្គការសេដាក និងអង្គការប្រេ្កត ដោយមានជំនួយឧបត្ថម្ភពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង បានដើរតួនាទីដ៏សំខាន់ក្នុងការគាំទ្រផ្នែកបច្ចេកទេសដល់ សកបទ និងកសិករនៅប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត ស្របតាមផែនការសាងសង់នៃគម្រោងដែលបានអនុម័តដោយក្រសួងធនធានទឹក[៣៨]។ អង្គការប្រេ្កត និងអង្គការសេដាក បានគាំទ្រផ្នែកបច្ចេកទេសតាមរយៈការបណ្តុះបណ្តាលពីកសិកម្មប្រពលវប្បកម្ម ស្រែបង្ហាញ និងវគ្គបណ្តុះបណ្តាលផ្សេងៗទៀតនៅតំបន់នោះ ដូចជា ការគ្រប់គ្រង ថវិកា ការប្រមូលថ្លៃប្រើប្រាស់ទឹក និងការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការជាដើម។

កន្លងមក នៅខេត្តពោធិ៍សាត់ ធនាគារអភិវឌ្ឍន៍អាស៊ី បានបណ្តុះបណ្តាលលើការងារប្រើប្រាស់ទឹកដល់មន្ត្រីជំនាញនៃមន្ទីរដែលពាក់ព័ន្ធពិសេសដល់មន្ត្រីមកពីការិយាល័យខេត្ត ឬស្រុក[៣៩]។ ចំពោះគម្រោងធារាសាស្ត្រ ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ផងដែរនូវជំនួយហិរញ្ញវត្ថុ និងសម្ភារៈសម្រាប់ដំណើរការគម្រោង ដូចជា ប្រាក់ឧបត្ថម្ភសម្រាប់មន្ត្រីសហការគម្រោង (នៃមន្ទីរធនធានទឹក ឬមន្ទីរកសិកម្ម) សម្ភារៈការិយាល័យ ម៉ាស៊ីន និងរថយន្តជាដើម (PDOWRAM, 2010)[៤០]។

---

៣៦ ផ្អែកតាមការប្រាស្រ័យទាក់ទងផ្ទាល់ជាមួយមន្ត្រីអង្គការសេដាក ថ្ងៃទី២២ មិថុនា ២០១០។
៣៧ តាមការសម្ភាសជាមួយលោកប្រធានមន្ទីរធនធានទឹក និងឧតុនិយម ខេត្តពោធិ៍សាត់ ឆ្នាំ២០១០។
៣៨ តាមការសម្ភាសជាមួយមន្ត្រីអង្គការសេដាក ក្រុមស្រាវជ្រាវ និងផ្លាស់ប្តូរបច្ចេកវិទ្យា ថ្ងៃទី៨ ធ្នូ ២០០៩ និងការបន្តទំនាក់ទំនងជាមួយមន្ត្រីអង្គការសេដាក ថ្ងៃទី ៣០ តុលា ២០១០។
៣៩ តាមការសម្ភាសជាមួយលោកប្រធានមន្ទីរធនធានទឹកខេត្តពោធិ៍សាត់ ឆ្នាំ២០១០។
៤០ មតិរបស់ឯកឧត្តមប្រធានមន្ទីរធនធានទឹកខេត្តកំពង់ធំ ក្នុងសិក្ខាសាលាផ្សព្វផ្សាយគំហើញនៃការស្រាវជ្រាវ នៅខេត្តកំពង់ធំ ថ្ងៃទី២២ ដល់ ២៣ ឧសភា ២០១០។

# ការពិភាក្សា និងបទពិសោធន៍

## ៥.១ តួនាទី និងទស្សនវិស័យរបស់អ្នកពាក់ព័ន្ធលើគោលនយោបាយគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) ឬការគ្រប់គ្រងធារាសាស្ត្រដោយមានការចូលរួម និងកិច្ចអភិវឌ្ឍន៍ (PIMD)

តួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធក្នុងគោលនយោបាយ IWRM/PIMD ហាក់មិនទាន់មានភាពច្បាស់លាស់នៅឡើយ ពិសេសចំពោះតួអង្គដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងអនុវត្តគោលនយោបាយនេះជាប្រចាំ។ ខ្សែរយៈរដ្ឋអំណាច យុត្តាធិការ និងរបាយការណ៍ទាក់ទងនឹងប្រព័ន្ធធារាសាស្ត្រ ជួនកាលនៅមានភាពត្រួតស៊ីគ្នា និងមិនទាន់ច្បាស់លាស់។ អ្នកពាក់ព័ន្ធនីមួយៗហាក់មើលមិនឃើញថា តួនាទី និងការទទួលខុសត្រូវរបស់ពួកគេ ខុសប្លែកពីវិធីដែលអ្នកពាក់ព័ន្ធដទៃទៀតយល់ឃើញ។ អ្នកពាក់ព័ន្ធជាច្រើន ត្រូវបានដឹកនាំតាមរបៀបជាលក្ខណៈបុគ្គល ឬស្ថាប័ន ជាជាងការដឹកនាំទៅតាមគំរូនៃគោលនយោបាយ IWRM/PIMD។ អ្នកពាក់ព័ន្ធជាច្រើនប្រភេទខុសៗគ្នាដែលត្រូវបានសម្ភាស ដូចជា កសិករ និងតំណាងអាជ្ញាធរខេត្ត បានប្រាប់ឲ្យដឹងថា អ្នកដែលធ្វើការពាក់ព័ន្ធនឹងប្រព័ន្ធធារាសាស្ត្រ តែងតែមិនសូវដោះស្រាយបញ្ហាជម្លោះរួមគ្នាទេ ពួកគេតែងតែជឿថា ក្រុមអ្នកពាក់ព័ន្ធនីមួយៗ គួរតែបំពេញតួនាទីក្នុងការដោះស្រាយជម្លោះដោយពួកគេផ្ទាល់។ ឧទាហរណ៍ ទំនាក់ទំនងអ្នកពាក់ព័ន្ធកម្រិតខ្ពស់ អាចពន្យល់បានពីរបៀបដែលរបាំងស្ថាប័នជាច្រើនកើតមានឡើង ដូចមាននៅក្នុងកម្មវិធីមួយចំនួនដែលក្រសួងធនធានទឹក/មន្ទីរធនធានទឹក និងក្រសួងកសិកម្ម/មន្ទីរកសិកម្មធ្វើការជាមួយគ្នា។ ក្រសួងធនធានទឹក/មន្ទីរធនធានទឹក ទទួលខុសត្រូវលើទឹកសម្រាប់ស្រោចស្រព រីឯក្រសួងកសិកម្ម/មន្ទីរកសិកម្ម ពឹងផ្អែកទឹកពីប្រព័ន្ធស្រោចស្រពដើម្បីផលិតកសិកម្ម។ ទោះបីជាការងារទាំងនេះមានលក្ខណៈអន្តរអនិស្សរភាពក្តី ក៏គេបានដឹងថាស្ថាប័នទាំងនេះនៅមានការប្រកាន់ផលប្រយោជន៍ ការប្រយេម និងសមិទ្ធផលរបស់ពួកគេដោយឡែកពីគ្នានៅឡើយ។ ឧទាហរណ៍ បើគ្មានទឹកសម្រាប់ស្រោចស្រពនោះ ក្រសួងធនធានទឹក/មន្ទីរធនធានទឹក ជាអ្នកទទួលខុសត្រូវ ហើយប្រសិនបើមានទឹកច្រើន ហើយការស្រោចស្រពបានទទួលជោគជ័យនោះ ក្រសួងកសិកម្ម/មន្ទីរកសិកម្ម ជាអ្នកទទួលខុសត្រូវលើទិន្នផលកសិកម្ម។ អ្នកពាក់ព័ន្ធខ្លះបានលើកអំណះអំណាងថា ស្ថាប័ននានាគួរតែធ្វើការរួមគ្នាឲ្យកាន់តែមានប្រសិទ្ធភាពជាងមុន ហើយធ្វើការចែករំលែកបរាជ័យ ឬស្នាដៃរួមគ្នា។

ការចូលរួមនៅក្នុងការងារគ្រប់គ្រងធារាសាស្ត្រ តម្រូវឲ្យមានកសិករពាក់ព័ន្ធនៅក្នុងដំណើរការបង្កើតគោលនយោបាយ។ ប៉ុន្តែជាទូទៅកសិករ និងអ្នកពាក់ព័ន្ធឯទៀត ធ្វើការនៅក្នុងរចនាសម្ព័ន្ធមួយ ហើយពឹងផ្អែកតែលើរដ្ឋាភិបាលជាន់ខ្ពស់ក្នុងការដឹកនាំ។ ភាពស្មុគស្មាញក្នុងការរៀបចំស្ថាប័នថ្នាក់ជាតិ ក៏អាចនាំឲ្យមានភាពរអាក់រអួលដល់ដំណើរការធ្វើសេចក្តីសម្រេចចិត្ត ដោយមានការចូលរួមពីអ្នកទទួលផលផងដែរ។ ឧទាហរណ៍ NCDD មានសមាជិកមកពីក្រសួងពាក់ព័ន្ធជាច្រើន តែពុំមានក្រសួងធនធានទឹកទេ។ NCDD បានខិតខំបង្កើតអំណាចឲ្យអាជ្ញាធរ និងសហគមន៍មូលដ្ឋាន (លើកទឹកចិត្តឲ្យធ្វើសេចក្តីសម្រេចចិត្តពីក្រោមទៅលើ) ទន្ទឹមនឹងនេះ ក្រសួងធនធានទឹក ក៏បានបានបង្កើត សកបទ នៅកម្រិតមូលដ្ឋាន ស្របតាមគោលនយោបាយ PIMD ដែលនៅមានលក្ខណៈពីលើចុះក្រោមនៅឡើយ ព្រោះថា សកបទ ត្រូវបានបង្កើត និងចុះបញ្ជីដោយក្រសួងធនធានទឹក។ នេះអាចត្រូវគេមើលឃើញថា ជាការកម្រិតការចូលរួមរបស់កសិករក្នុងដំណើរការអភិបាលកិច្ច។

ម៉្យាងទៀត ការគោរពអំណាចនយោបាយ និងរដ្ឋបាលនៅតែជាប់ក្នុងសង្គមកម្ពុជានៅឡើយ គឺអ្នកដឹកនាំនៅមូលដ្ឋានត្រូវបានប្រជាជនគោរព និងទទួលស្គាល់។ លក្ខណៈនៃអន្តរសកម្មភាពអំណាចបែបនេះ បានសំដែងឲ្យឃើញនូវបញ្ហាប្រឈមដែល សកបទ កំពុងជួបប្រទះក្នុងពេលអនុវត្តគោលនយោបាយ PIMD។ ភាពស្មុគស្មាញទាំងនេះ អាចត្រូវបានដោះស្រាយនៅពេលមានការចូលរួមពីសំណាក់រដ្ឋអំណាចមូលដ្ឋាន ដូចជា ក្រុមប្រឹក្សាឃុំ ជាដើម ក្នុងការគ្រប់គ្រងសកបទ (ដូចជានៅប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល ខេត្តពោធិ៍សាត់ជា ដែលសមាសភាគ សកបទ ចូលរួមដោយក្រុមប្រឹក្សាឃុំទាំង៧ ដែលនៅក្នុងប្រព័ន្ធ) ដំណើរការចូលរួមរបស់កសិករ អាចប្រព្រឹត្តិទៅដោយរលូនក្នុងការបង់ថ្លៃសេវាកម្មប្រើប្រាស់ទឹក កិច្ចដំណើរការ និងការថែទាំប្រព័ន្ធជាដើម)។ ខណៈដែលការពាក់ព័ន្ធរបស់ពួកគេ អាចជួយសំរួលដំណើរការរបស់ សកបទ ដើម្បីឲ្យប្រព្រឹត្តទៅដោយរលូន ភាពខុសប្លែកគ្នារវាងសហគមន៍រដ្ឋ (រដ្ឋអំណាចមូលដ្ឋាន) និងសហគមន៍មិនមែនរដ្ឋ រឹតតែមានភាពស្រពិចស្រពិល។

ក្រុមអ្នកពាក់ព័ន្ធសំខាន់ៗក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ តែងមានទស្សនវិស័យខុសប្លែកពីគ្នា។ តំណាងមន្ទីរធនធានទឹក ដែលបានផ្តល់បទសម្ភាសបានឲ្យដឹងថា គម្រោងធារាសាស្ត្រដំណើរការទៅបានល្អ ដោយសារមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់។ នៅពេលអាចរកថវិកាបាន គេអាចយកធនធានថវិកានោះ ទៅទូទាត់ដោះស្រាយតម្លៃសម្រាប់ការតាំងទីលំនៅថ្មីរបស់កសិករ ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ ប៉ុន្តែអាជ្ញាធរមូលដ្ឋានខ្លះបានអះអាងថា សូចនាករសំខាន់សម្រាប់គម្រោងសាងសង់ប្រព័ន្ធធារាសាស្ត្រមួយដ៏ល្អនោះ គឺនៅពេលដែលប្រព័ន្ធនោះជួយសំរួលដល់ការបែងចែកទឹកដល់កសិករទាំងអស់ដោយគ្មានបញ្ហាជម្លោះ។ ទស្សនវិស័យពីរនេះ ផ្តោតទៅលើដំណាក់កាលពីរខុសៗគ្នា។ ដើម្បីឆ្លើយតបការទាមទារបន្ទាន់របស់កសិករ (ដូចជា ទឹកសម្រាប់ដំណាំដាំដុះ ឬទំនប់ការពារទឹកជំនន់) តួនាទីរបស់រដ្ឋាភិបាល គឺត្រូវទោះបីតាមរយៈមធ្យោបាយណាក៏ដោយ ឲ្យតែអាចចាប់ផ្តើមគម្រោងសាងសង់ប្រព័ន្ធធារាសាស្ត្របានល្អ នោះជាការល្អគ្រប់គ្រាន់ហើយ។ កសិករច្រើនផ្តោតការយកចិត្តទុកដាក់ទៅលើផលប៉ះពាល់នៃគម្រោង ដែលអាចលើកស្ទួយជីវភាពរស់នៅរបស់ពួកគេតាមរយៈការផ្តល់ទឹកគ្រប់គ្រាន់សម្រាប់ប្រកបរបរកសិកម្ម។ប្រការនេះនាំឲ្យមានការជាប់ជំពាក់ទៅនឹងអ្វីដែលថាគម្រោងប្រព័ន្ធធារាសាស្ត្រ អាចត្រូវគេមើលឃើញតាមទស្សនវិស័យផ្សេងៗគ្នាក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងក្នុងលក្ខខណ្ឌដែលថា តើគម្រោងនោះអាច ឬមិនអាចផ្គត់ផ្គង់ទឹកប្រកបដោយនិរន្តរភាព។ ជាធម្មតាអ្នកផ្តល់ជំនួយតែងមានលទ្ធភាពសម្របសម្រួលគ្រប់គ្រាន់ក្នុងការផ្តល់ថវិកាជំនួយបន្ថែមដើម្បីធានាថា ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រធ្វើទៅបានស្របតាមកិច្ចព្រមព្រៀងរបស់គម្រោង។ អ្វីដែលកសិករផ្តោតការយកចិត្តទុកដាក់ជាងគេនោះគឺ តើប្រព័ន្ធធារាសាស្ត្រនោះ អាចកែលម្អការប្រកបរបរធ្វើស្រែចំការរបស់គាត់ដូចម្តេច ហើយតើគាត់ត្រូវធ្វើដូចម្តេចខ្លះ ដើម្បីឲ្យទទួលបានទឹកគ្រប់គ្រាន់សម្រាប់ធ្វើស្រែ នៅពេលដែលគម្រោងជំនួយនោះត្រូវបានបញ្ចប់។

ការយល់ឲ្យបានច្បាស់លាស់អំពីតួនាទីរបស់ សកបទ ក្នុងការងារគ្រប់គ្រងធនធានទឹក ពិសេសការប្រមូលថ្លៃសេវាកម្មប្រើប្រាស់ទឹក គឺជាការប្រឈមដ៏លំបាកមួយសម្រាប់អ្នកពាក់ព័ន្ធជាច្រើន។ ដោយយោងទៅតាមលក្ខណៈជាក់ស្តែងរបស់ប្រព័ន្ធធារាសាស្ត្រដែលបានអង្កេតនាពេលចុះសិក្សានៅតាមមូលដ្ឋាន ការអនុវត្ត PIMD បច្ចុប្បន្ន មិនអាចលើកទឹកចិត្តកសិករឲ្យចូលរួមបានពេញលេញក្នុងការបង់ថ្លៃសេវាកម្មប្រើប្រាស់ទឹក ឬក៏ចូលរួមក្នុងការងារដំណើរការ និងថែទាំប្រព័ន្ធនៅឡើយទេ ដោយសារនៅមានកង្វះខាតផ្នែកហេដ្ឋារចនាសម្ព័ន្ធដែលខូចខាត ដោយសារគ្មានការថែទាំ ឬក៏ដោយសារតែពុំមានការយល់ដឹងត្រឹមត្រូវអំពីលក្ខណៈធម្មជាតិពិតប្រាកដ និងសារៈសំខាន់នៃថ្លៃសេវាកម្មប្រើប្រាស់ទឹក ។ ឧទាហរណ៍ គេសួរមន្ត្រីមន្ទីរធនធានទឹកថា៖ ហេតុអ្វីបានជារាជរដ្ឋាភិបាលសាងសង់ប្រឡាយឲ្យប្រជាពលរដ្ឋហើយ តែបែរជាបង្កើតច្បាប់ដើម្បីប្រមូលថ្លៃទឹកពីប្រជាពលរដ្ឋទៅវិញ ? បញ្ហានេះនៅតែជាសំណួរសម្រាប់ដំណើរការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រប្រកបដោយនិរន្តរភាព[៤១]។

បញ្ហាគ្រប់គ្រងធារាសាស្ត្រកម្រិតប្រព័ន្ធធារាសាស្ត្រ ហាក់ដូចជាត្រូវបានដោះស្រាយឈរលើមូលដ្ឋាននៃផែនការ ឬវិធានយុទ្ធសាស្ត្រ ព្រោះថា សកបទ មិនទាន់មានសមត្ថភាពគ្រប់គ្រាន់ដើម្បីធ្វើផែនការអភិវឌ្ឍន៍ និងគ្រប់គ្រងធារាសាស្ត្រសម្រាប់រយៈពេលវែងនៅឡើយ។ រាល់បញ្ហាតែងត្រូវបានដោះស្រាយទៅតាមករណីនីមួយៗ ដោយ សកបទ អាជ្ញាធរមូលដ្ឋាន និងមន្ទីរធនធានទឹក/ក្រសួងធនធានទឹក។ មន្ទីរធនធានទឹកបានបញ្ជាក់អះអាងថា ក្នុងនាមមន្ទីរជំនាញ[៤២] មន្ទីរបានបង្កើតរួចជាស្រេចនូវយន្តការ (ឬមុខងារ) សម្រាប់ដោះស្រាយជម្លោះ ដើម្បីការពារ និងដោះស្រាយបញ្ហានៃការប្រើប្រាស់ទឹក ដោយហេតុថា កសិករ និងក្រុមប្រឹក្សា ឃុំ/សង្កាត់ មិនទាន់មានសមត្ថភាពគ្រប់គ្រាន់ដើម្បីដោះស្រាយបញ្ហាទាំងនោះ។

តាមទ្រឹស្តី សកបទ មានតួនាទីពេញច្បាប់ក្នុងការគ្រប់គ្រងទឹកសម្រាប់ស្រោចស្រព ប៉ុន្តែមិនមានអំណាចដើម្បីធ្វើនិយ័តកម្ម និងគ្រប់គ្រងធនធានទឹកទេ។ គេសង្កេតឃើញថា នៅកម្រិតប្រព័ន្ធធារាសាស្ត្រ និងកម្រិតអាងទន្លេ ការទទួលខុសត្រូវតាមលក្ខណៈច្បាប់ និងរដ្ឋបាលរបស់ សកបទ លើប្រព័ន្ធធារាសាស្ត្រមិនសូវមានប្រសិទ្ធភាព ដោយសារមូលហេតុច្រើនយ៉ាងដូចជា អំណាច និងសមត្ថកិច្ចនៅមានកម្រិត ជំនួយគាំទ្រក៏នៅមានកម្រិត មិនមានសមត្ថភាពគ្រប់គ្រាន់ និងកង្វះធនធានមនុស្ស។ លើសពីនេះទៀត មានយន្តការគណនេយ្យភាពតិចតួចក្នុងរចនាសម្ព័ន្ធអភិបាលកិច្ចរបស់ សកបទ ហើយនិងដំណើរការប្រព្រឹត្តទៅមិនបានល្អនៃការផ្តល់សេវាកម្មសាធារណៈដល់កសិករ និង សកបទ ខាងលើ ឬខាងក្រោមស្ទឹង ដែលជាលទ្ធផល គឺការធ្លាក់ចុះនៃភាពជឿជាក់ពីសំណាក់កសិករ។ នៅតាមប្រព័ន្ធជាច្រើន (ដូចជា តាំងក្រសាំង វត្តលៀប និងកំប៉ាង) សមាជិកគណៈកម្មាធិការ សកបទ ខ្លះបានបោះបង់ចោលកាតព្វកិច្ច ក៏ដូចជាផលប្រយោជន៍របស់ខ្លួន (ការធ្វើស្រែ) ដែលមាននៅក្នុងប្រព័ន្ធថែមទៀតផង។

---

៤១ ការសម្ភាសជាមួយប្រធានមន្ទីរធនធានទឹកខេត្តពោធិ៍សាត់ ថ្ងៃទី ២៧ មករា ២០១០។
៤២ ស្ថាប័នដែលមានបច្ចេកទេស/ជំនាញ។

## ៥.២ បញ្ហាដែលកើតមានឡើង

ផ្អែកលើទស្សនៈ ការយល់ដឹង ការសន្និដ្ឋាន គោលបំណង បទពិសោធន៍ និងការវាយតម្លៃរបស់អ្នកពាក់ព័ន្ធលើការរៀបចំអភិបាលកិច្ចធនធានទឹកបច្ចុប្បន្ននៅក្នុងគោលនយោបាយគ្រប់គ្រងធនធានទឹកចម្រុះ (IWRM)/ការគ្រប់គ្រងធារាសាស្ត្រដោយមានការចូលរួម និងកិច្ចអភិវឌ្ឍន៍ (PIMD) ដូចបានរៀបរាប់ពីខាងដើម តម្រូវការសំខាន់ៗមួយចំនួនបានលេចជារូបរាងឡើងដូចជា៖

- សេចក្តីត្រូវការឲ្យមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធឲ្យកាន់តែមានប្រសិទ្ធភាពជាងមុន ក្នុងការអនុវត្តគោលនយោបាយគ្រប់គ្រងធនធានទឹកចម្រុះ/ការគ្រប់គ្រងធារាសាស្ត្រដោយមានការចូលរួម និងកិច្ចអភិវឌ្ឍន៍
- សេចក្តីត្រូវការឲ្យមានការកែលម្អ កិច្ចសហការរវាងអ្នកពាក់ព័ន្ធទាំងឡាយ
- សេចក្តីត្រូវការឲ្យមានដំណោះស្រាយបញ្ហាប្រឈមនានាក្នុងកិច្ចសហការនៅទូទាំងអាងផ្ទែរងទឹកភ្លៀង ឬអាងទន្លេ
- សេចក្តីត្រូវការឲ្យមានការលើកកម្ពស់តួនាទី និងប្រសិទ្ធភាពរបស់ សកបទ និង
- តម្រូវការឲ្យមានថវិកាគាំទ្ររយៈពេលវែង

ផ្នែកបន្ទាប់នៃឯកសារស្រាវជ្រាវនេះ នឹងសិក្សាពីតម្រូវការខាងលើ បន្ទាប់មកស្វែងរកជម្រើសសមស្របនានា ដើម្បីផ្សារភ្ជាប់គោលនយោបាយទឹក ដែលបង្កើតឡើងដោយរដ្ឋាភិបាល ជាមួយនឹងការអនុវត្តរបស់អ្នកពាក់ព័ន្ធ ដើម្បីឲ្យអន្តរសកម្មភាពរវាងផ្នែកនានានៃប្រព័ន្ធនេះកាន់តែមានប្រសិទ្ធភាព។

### *៥.២.១ ការលើកកម្ពស់ការចូលរួមរបស់អ្នកពាក់ព័ន្ធ*

ការទាក់ទាញសហគមន៍ពាក់ព័ន្ធឲ្យចូលរួមក្នុងការគ្រប់គ្រងទឹក ត្រូវបានគាំទ្រដោយគោលនយោបាយ ដើម្បីគ្រប់គ្រងធនធានទឹកមួយចំនួនរបស់រដ្ឋាភិបាល។ នៅឆ្នាំ១៩៩៤ ធនាគារពិភពលោក បានកំណត់ពាក្យ "ចូលរួម" ថាជាដំណើរការមួយដែលតាមរយៈនោះ អ្នកពាក់ព័ន្ធអាចមានឥទ្ធិពល និងចែករំលែកការទទួលខុសត្រូវលើគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ និងការសម្រេចចិត្ត ហើយនិងធនធានដែលប៉ះពាល់ដល់ពួកគេ[៤៣]។ គោលនយោបាយជាតិសម្រាប់វិស័យធនធានទឹក ក៏មានគោលបំណងពង្រឹង និងបង្កើនការចូលរួមរបស់ សកបទ ក្នុងការងារគ្រប់គ្រង ការបែងចែកទឹក និងដើម្បីថែទាំប្រព័ន្ធធារាសាស្ត្រឲ្យមាននិរន្តរភាពផងដែរ (RGC 2004)។ ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកឆ្នាំ២០០៧ បានអំពាវនាវឲ្យមានការចូលរួមសហការបន្ថែមទៀតពីសំណាក់ស្ថាប័នពាក់ព័ន្ធនានា វិស័យឯកជន ក្រុមអ្នកទទួលផល NGOs និងអង្គការអន្តរជាតិ ក្នុងរាល់សកម្មភាពទាក់ទងទៅនឹងការគ្រប់គ្រង វិនិយោគ រុករក អភិរក្ស និងអភិវឌ្ឍន៍ធនធានទឹក ដោយផ្តោតការយកចិត្តទុកដាក់លើតុល្យភាពសង្គម និងបរិស្ថាន (RGC 2007)។

ប៉ុន្តែ កង្វះការចូលរួមរបស់សហគមន៍នៅក្នុងដំណើរការធ្វើសេចក្តីសម្រេចទាក់ទិននឹងគម្រោងអភិវឌ្ឍន៍ធារាសាស្ត្រដូចជាការវាយតម្លៃដំបូង ការធ្វើផែនការ ការអនុវត្ត ការត្រួតពិនិត្យ និងវាយតំលៃពីអតីតកាល បានរុញច្រានឲ្យកសិករឃ្លាតឆ្ងាយពីការចូលរួមដ៏មានអត្ថន័យនេះ។ ឧទាហរណ៍ ដោយសារមានពេលវេលាខ្លី និងថវិកាមានកំណត់ ប្រព័ន្ធធារាសាស្ត្រមួយចំនួននៅខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ ត្រូវបានសាងសង់ឡើងដោយពុំមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធសំខាន់ៗទេនៅដំណាក់កាលដំបូងនៃការគូរប្លង់ និងសាងសង់។ ជាលទ្ធផល ប្រព័ន្ធទាំងនោះសាងសង់ទាបជាងកម្រិតកម្ពស់ទឹកចាំបាច់ ហើយទឹកមិនអាចហូរចូលទៅក្នុងប្រឡាយមេបាន។ បញ្ហានេះធ្វើឲ្យកសិករលែងចង់ចូលរួមនៅក្នុងដំណើរការ និងថែទាំបន្ទាប់ពីប្រគល់ប្រព័ន្ធនោះ ទៅឲ្យពួកគាត់គ្រប់គ្រង។ ផលវិបាកនៃបទពិសោធន៍ទាំងនេះបានស្តែងឲ្យឃើញថា ការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងវិធានបច្ចេកទេសគូរ/គ្រោងប្លង់សំណង់ គឺជាការចាំបាច់ដើម្បីធានានូវការគ្រប់គ្រងយូរអង្វែងនៃប្រព័ន្ធធារាសាស្ត្រ។

---

៤៣ ដូចមាននៅក្នុង Warren A. Van Wicklin ស្តីពីបទពិសោធន៍ជាមួយនឹងការចូលរួមរបស់មូលដ្ឋាន និងភាពជាដៃគូ របស់ក្រុមធនាគារពិភពលោក ឆ្នាំ២០០១។

ស្ថាប័នរដ្ឋ និងអ្នកផ្តល់ជំនួយ គឺជាអ្នកពាក់ព័ន្ធដ៏សំខាន់ក្នុងការបង្កើត និងដាក់ឲ្យអនុវត្តនូវគោលនយោបាយ PIMD និងវិមជ្ឈការ និងវិសហមជ្ឈការ។ ដំណើរការបញ្ជ្រាបគោលនយោបាយបច្ចុប្បន្ន មានការប្រែប្រួលគួរឲ្យកត់សំគាល់ ប៉ុន្តែជាទូទៅ កម្រិតនៃការចូលរួមរបស់សហគមន៍ក្នុងការងារជាក់ស្តែងតាមតំបន់មួយចំនួន មិនទាន់អាចឆ្លើយតបទៅនឹងគោលបំណងនៃគោលនយោបាយទាំងនោះទេ។ មតិខ្លះបានអះអាងថា "ដោយសារគោលនយោបាយត្រូវបានចាត់ទុកថាជាការព្រមទទួលយកគម្រោងដែលជាផ្នែកមួយនៃកញ្ចប់ជំនួយហិរញ្ញវត្ថុ ការអនុវត្តគោលនយោបាយទាំងនោះ នឹងទទួលបរាជ័យព្រោះតែខ្វះការចូលរួមពាក់ព័ន្ធពីប្រជាជនមូលដ្ឋាន និងជាពិសេស គឺកង្វះឆន្ទៈនយោបាយ..." (SaciWATERs 2009: 8)។ កម្ពុជាកំពុងធ្វើកំណែទម្រង់គោលនយោបាយរបស់ខ្លួនទៅរក វិមជ្ឈការនៃការអភិវឌ្ឍន៍ និងការគ្រប់គ្រងធនធានធម្មជាតិ។ សហគមន៍ និងកសិករមូលដ្ឋាន មានឱកាសយ៉ាងច្រើនក្នុងការធ្វើផែនការ និងគ្រប់គ្រងធនធានរបស់ពួកគេ។ ប៉ុន្តែពេលអនុវត្តន៍ផែនការនេះ នៅមានឧបសគ្គជាច្រើន ដូចជាការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និង PIMD ជាដើម។ ក្នុងបញ្ហានេះ ក្រុមកសិករប្រើប្រាស់ទឹកក៏បានទទួលស្គាល់ថា នៅមានចន្លោះប្រហោង ការត្រួតស៊ីគ្នា និងកិច្ចសហការមិនទាន់ពេញលេញនៃមុខងារផ្សេងៗក្នុងកំណែទម្រង់រដ្ឋបាលសាធារណៈបច្ចុប្បន្ន ដែលតម្រូវឲ្យមានការកែលម្អថែមទៀត (SAW 2007: 4)។ ការចុះសិក្សាដល់មូលដ្ឋានបង្ហាញថា នៅប្រព័ន្ធធារាសាស្ត្រអូរស្វាយ ក្នុងខេត្តកំពង់ធំ សកបទ មានអាណត្តិដែលចែងក្នុងលក្ខន្តិកដើម្បីបែងចែកទឹក និងសហការជាមួយអាជ្ញាធរមូលដ្ឋាន ដែលមានសិទ្ធិ និងអំណាច ដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល (Organic Law) ដើម្បីដាក់ទោសដល់រាល់សកម្មភាពល្មើសច្បាប់ ដូចជា ការបំផ្លាញប្រឡាយ ទប់ទំនប់ចាប់ត្រី បើកបង្ហូរទឹកដោយគ្មានការអនុញ្ញាតជាដើម។ ដោយសារកិច្ចសហការពីសំណាក់អាជ្ញាធរមូលដ្ឋានមានកំណត់ សកបទ មិនអាចដោះស្រាយបញ្ហាខាងលើបានទេ ហើយបាននាំឲ្យកសិករអស់ជំនឿ និងមិនចង់ចូលរួមក្នុងការគ្រប់គ្រងទឹក ហើយពួកគេងាកទៅពឹងក្រុមប្រឹក្សាឃុំ/សង្កាត់ ឲ្យដោះស្រាយបញ្ហាជម្លោះដែលបណ្តាលពីការប្រើប្រាស់ទឹក។

កម្រិតនៃការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងបរិបទនៃ IWRM/PIMD មានការប្រែប្រួលពីប្រព័ន្ធមួយទៅប្រព័ន្ធមួយ។ កសិករចូលរួមការអនុវត្តគោលនយោបាយនេះក្នុងទំនាក់ទំនងជាមួយនឹងសកម្មភាពសំខាន់ៗមួយចំនួន ដូចជា រួមវិភាគទានដីធ្លីសម្រាប់សាងសង់ប្រព័ន្ធ បង់ថ្លៃប្រើប្រាស់សេវាកម្មធារាសាស្ត្រ និងដំណើរការ និងថែទាំប្រព័ន្ធធារាសាស្ត្រ។ ការគ្រប់គ្រងធារាសាស្ត្រ អាចមាននិរន្តរភាពក្រោមលក្ខខណ្ឌមួយចំនួន ដូចជា នៅពេលដែលសហគមន៍អាចដំណើរការ និងថែទាំប្រព័ន្ធដោយខ្លួនឯងបាន។ នេះមានន័យថា ប្រាក់ដែលប្រមូលបានពីការបង់ថ្លៃប្រើប្រាស់សេវាកម្មធារាសាស្ត្រ អាចរ៉ាប់រងលើដំណើរការ និងថែទាំប្រព័ន្ធ។ ប៉ុន្តែដូចមានចែងនៅក្នុងសារាចរលេខ ០១ គឺដំណាក់កាលដំបូង រដ្ឋាភិបាលនឹងមានលទ្ធភាពផ្តល់ហិរញ្ញវត្ថុខ្លះដើម្បីជួយទប់ថ្លៃដំណើរការ។ ក្នុងករណីប្រព័ន្ធធារាសាស្ត្ររលួស ក្នុងខេត្តកំពង់ធំ ដែលបានទទួលការខូចខាតយ៉ាងធ្ងន់ធ្ងរពីព្យុះកេតសាណាឆ្នាំ២០០៩ ហើយទំនប់ប្រវែង ១៨០ម៉ែត្រ ត្រូវរងការខូចខាត ឯថ្លៃប្រើប្រាស់សេវាកម្មធារាសាស្ត្រ (៥០០០រៀល/គ្រួសារ/ឆ្នាំ) ត្រូវបានប្រមូលជារៀងរាល់ឆ្នាំសម្រាប់ដំណើរការ និងថែទាំប្រព័ន្ធ។ ប្រាក់នេះភាគច្រើនប្រមូលបានតែពីគ្រួសារកសិករដែលទទួលផលពីការប្រើទឹកនៃប្រព័ន្ធ (ពីអ្នកដែលរស់នៅភាគខាងជើងនៃប្រព័ន្ធ)។ គេមិនអាចប្រមូលថ្លៃប្រើប្រាស់សេវាកម្មធារាសាស្ត្រនេះពី កសិករភាគខាងត្បូងប្រព័ន្ធបានទេ ដោយហេតុថា គណៈកម្មាធិការ សកបទ មិនអាចឆ្លើយតបទៅនឹងតម្រូវការនានារបស់កសិករឲ្យបានទាន់ពេលវេលា។ ថ្លៃប្រើប្រាស់សេវាកម្មធារាសាស្ត្រ នៅតែផ្អែកលើគោលការណ៍ស្ម័គ្រចិត្តនៅឡើយ ដូច្នោះបរិមាណប្រាក់ទទួលបាន មិនអាចប៉ះប៉ូវថ្លៃជួសជុលប្រព័ន្ធបានទេ។ ដូចនេះហើយបានជា សកបទ ពឹងផ្អែកលើថវិកាឧបត្ថម្ភរបស់ក្រុមប្រឹក្សាឃុំ (ចំនួន ៧លានរៀលសម្រាប់ពីរឆ្នាំ គឺ ២០០៨-០៩) និងប្រាក់សម្រាប់ករណីសង្គ្រោះបន្ទាន់ ផ្តល់ដោយមន្ទីរធនធានទឹក ដើម្បីយកទៅថែទាំប្រព័ន្ធ។

ទន្ទឹមនេះ ការធ្វើប្រាស្រ័យទាក់ទងគ្នាដោយផ្ទាល់ ឬទល់មុខគ្នាដ៏មានប្រសិទ្ធភាព ក៏តម្រូវឲ្យមានការចំណាយច្រើនដែរ។ ក្នុងករណីប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល អ្នកទទួលផលមានចំនួន ៧ឃុំ។ ការចែករំលែកព័ត៌មានរវាងបណ្តាឃុំនៅក្នុងប្រព័ន្ធមានការលំបាក ដោយសារកង្វះខាតហេដ្ឋារចនាសម្ព័ន្ធ។ ម៉្យាងទៀត កង្វះខាតធនធានថវិកាសម្រាប់ឧបត្ថម្ភដល់ការអញ្ជើញមករួមប្រជុំនៃសមាជិកគណៈកម្មាធិការ ក៏កាន់តែធ្វើឲ្យការមកចូលរួមប្រជុំឲ្យមានការលំបាកផងដែរ។

ជំនួយហិរញ្ញវត្ថុអន្តរជាតិ នៅតែត្រូវការជាចាំបាច់ ទោះបីជាហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រភាគច្រើនបានសាងសង់រួចហើយក្តី។ នៅប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត ក្នុងខេត្តកំពង់ធំ ជំនួយហិរញ្ញវត្ថុរបស់អង្គការប្រេ្កត និងអង្គការសេដាក បានបញ្ចប់នៅខែមិថុនា ឆ្នាំ២០០៩។ ប្រការនេះ បានបង្ហាញពីមន្ទិលសង្ស័យលើនិរន្តរភាពរបស់ សកបទ ព្រោះថា មកទល់បច្ចុប្បន្នជំនួយថវិកាដែលប្រមូលបានតាមរយៈការបង់ថ្លៃសេវាកម្មប្រើប្រាស់ទឹក មានចំនួនស្មើនឹង៥០-៦០% នៃចំនួនថវិកាសរុបដែលប្រើប្រាស់ក្នុងការងារដំណើរការ និងថែទាំប៉ុណ្ណោះ។ សកបទ នៅស្ទឹងជីនិត មានបំណងតម្លើងថ្លៃប្រើប្រាស់សេវាកម្មធារាសាស្ត្រពី ៣០.០០០រៀល ទៅ ៦០.០០០រៀល/ហ.ត/ឆ្នាំ (ប្រហែល ១៥ដុល្លារ) ដើម្បីធានាការចំណាយលើការងារដំណើរការ និង

ថៃទាំប្រព័ន្ធ។ ប៉ុន្តែកសិករនឹងត៉ាលើការបង់ថ្លៃប្រើប្រាស់សេវាកម្មធារាសាស្ត្រ ព្រោះពួកគាត់មិនចង់បង់ថ្លៃប្រើប្រាស់សេវាកម្មធារាសាស្ត្រកាន់តែច្រើនទៅៗទេ ក្នុងខណៈពេលដែលទិន្នផលស្រូវរបស់ពួកគាត់នៅដដែល។ ប្រការនេះអាចមានន័យថាជំនួយអន្តរជាតិនៅតែជាតម្រូវការ សម្រាប់យកទៅគាំទ្រដល់ចំណាយលើការងារដំណើរការ និងថៃទាំប្រព័ន្ធ។ គេអាចមានដំណោះស្រាយមួយលើបញ្ហានេះ គឺត្រូវបង្កើនការដាំស្រូវពី ១ ដល់ ៣ដងក្នុងមួយឆ្នាំ ដើម្បីទប់ទល់ចំណាយលើការបង់ថ្លៃប្រើប្រាស់សេវាកម្មធារាសាស្ត្រ ប៉ុន្តែការងារនេះអាចជួបការលំបាកបីយ៉ាងសំខាន់ៗ ដូចជា ១) កសិករមិនទម្លាប់ និងមិនសូវមានជំនឿលើការធ្វើស្រែប្រាំង ២) មានសត្វល្អិតបំផ្លាញស្រូវនៅរដូវប្រាំងច្រើន ៣) កសិករមានទម្លាប់លែងគោ ក្របី ឲ្យស៊ីស្មៅពាសវាលពាសកាល ហើយអាចស៊ី ឬបំផ្លាញស្រូវប្រាំង។

ក្នុងតំបន់សិក្សា មានសហគមន៍ច្រើនប្រភេទដែលស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរជំនាញខេត្ត ដូចជា សកបទ ស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរធនធានទឹក សហគមន៍កសិករកសិកម្ម ( សមាគមស្រូវប្រាំង ) ស្ថិតក្រោមការជួយគាំទ្រពីមន្ទីរកសិកម្ម និងសហគមន៍អភិវឌ្ឍន៍ភូមិ ដែលបានការជួយឧបត្ថម្ភពីមន្ទីរអភិវឌ្ឍន៍ជនបទជាដើម។ ប៉ុន្តែកម្រិតនៃការចូលរួមរបស់ពួកគេក្នុងការគ្រប់គ្រងទឹកនៅមានកម្រិតនៅឡើយ។ លោក សែលដុន ( Sheldon, 2005 ) បានអះអាងថា ប្រសិទ្ធភាពនៃវិធានបង្កើនទំហំសមាជិកសហគមន៍ គឺវាបានធ្វើឲ្យចំនួនអ្នកពាក់ព័ន្ធមានការកើនឡើងនៅក្នុងដំណើរការសម្រេចចិត្ត ហើយប្រការនេះ ក៏អាចនាំឲ្យកើតមានជម្លោះដោយសារការដណ្តើមផលប្រយោជន៍គ្នាក្នុងចំណោមអ្នកពាក់ព័ន្ធទាំងនោះផងដែរ។ បញ្ហានេះអាចត្រូវបានគេមើលឃើញក្នុងឧទាហរណ៍មួយនៃកិច្ចសហការគ្នា រវាងមន្ទីរធនធានទឹក មន្ទីរកសិកម្ម និងមន្ទីរអភិវឌ្ឍន៍ជនបទ ដែលកំពុងកសាងកេរ្តិ៍ឈ្មោះក្នុងការគ្រប់គ្រងធនធានទឹក ពិសេសគឺធ្វើយ៉ាងណាឲ្យប្រជាជនជឿទុកចិត្ត។ ការសិក្សាបានបង្ហាញថា បរាជ័យក្នុងការសម្រេចឲ្យបានជោគជ័យលើការងារគ្រប់គ្រងទឹក គឺស្ថិតលើបរាជ័យក្នុងការបញ្ចុះបញ្ចូលឲ្យអ្នកពាក់ព័ន្ធទាំងអស់ កុំផ្តោតការយកចិត្តទុកដាក់តែទៅលើផលប្រយោជន៍របស់ស្ថាប័ន ឬផលប្រយោជន៍បុគ្គលខ្លាំងពេក។ ឧទាហរណ៍ បរាជ័យក្នុងការធ្វើស្រែប្រាំងគំរូ ដើម្បីជំរុញ និងបង្ហាញដល់កសិករនៅស្ទឹងជីនិត ឲ្យនាំគ្នាធ្វើស្រែប្រាំង បាននាំឲ្យកសិករអសកម្មក្នុងការយកចិត្តទុកដាក់ ឬចូលរួមជាមួយស្ថាប័នទទួលខុសត្រូវ និងក្នុងគោលនយោបាយកសិកម្មទំនើបពិសេសលើកសិកម្មប្រពលវប្បកម្ម និងកម្មវិធីគ្រប់គ្រងថ្នាំសម្លាប់សត្វល្អិតចម្រុះ (IPMP)។ កិច្ចសហការ និងសុខដុមភាពក្នុងចំណោមស្ថាប័នពាក់ព័ន្ធទាំងឡាយ គឺជាតម្រូវការដ៏ចាំបាច់បំផុត។

## ៥.២.២ ពង្រឹងកិច្ចសហការក្នុងចំណោមអ្នកពាក់ព័ន្ធ

ការពង្រឹងកិច្ចសហការក្នុងចំណោមអ្នកពាក់ព័ន្ធ គឺជាការចាំបាច់បំផុត ព្រោះវាអាចធានានិរន្តរភាពក្នុងការវិនិយោគប្រព័ន្ធធារាសាស្ត្រ និងធានាបាននូវនិរន្តរភាពក្នុងការគ្រប់គ្រង និងថៃទាំប្រព័ន្ធធារាសាស្ត្រទៀតផង។

ផ្អែកតាមទ្រឹស្តី សកបទ មានតួនាទីគ្រប់គ្រងធនធានទឹកនៅមូលដ្ឋានដោយឯករាជ្យពីរចនាសម្ព័ន្ធនយោបាយរបស់ក្រុមប្រឹក្សាឃុំ។ ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង ការរៀបចំអភិបាលកិច្ចក្រៅផ្លូវការ តែងធ្វើឲ្យភាពឯករាជ្យនេះលែងមានប្រយោជន៍ ដោយសារសមត្ថភាព សកបទ នៅមានកម្រិត កង្វះធនធានមនុស្ស និងធនធានចាំបាច់ដទៃទៀត។ សមាជិកគណៈកម្មាធិការ សកបទ នៅតាមប្រព័ន្ធធារាសាស្ត្រដែលសិក្សាក្នុងខេត្តទាំង ៣ បានឲ្យដឹងថា ទោះបីជារដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ ដោយសង្កត់ធ្ងន់លើវិមជ្ឈការនៃការគ្រប់គ្រងធនធានធម្មជាតិក្តី សកបទ និងកសិករភាគច្រើន នៅតែពឹងផ្អែកលើកិច្ចសហការ និងគាំទ្រពីរចនាសម្ព័ន្ធនយោបាយមូលដ្ឋាននៅឡើយ ដូចជា ក្រុមប្រឹក្សាឃុំ អាជ្ញាធរស្រុក ស្ថាប័នជំនាញ។ល។ ដើម្បីធ្វើសេចក្តសម្រេចចិត្តសំខាន់ៗ។

ករណីដែល សកបទ មានឥទ្ធិពលពិតប្រាកដនោះ គឺតែងកើតមាននៅក្នុងក្របខ័ណ្ឌរដ្ឋបាលនៃក្រុមប្រឹក្សាឃុំ/សង្កាត់ជាងនៅក្នុងក្របខណ្ឌរដ្ឋបាលឯករាជ្យរបស់ សកបទ។ ឧទាហរណ៍ នៅប្រព័ន្ធធារាសាស្ត្រស្វាយចេក ក្នុងខេត្តកំពង់ធំ ប្រធានភូមិត្រូវបានជ្រើសរើសធ្វើជាអនុប្រធានទីមួយនៃ សកបទ។ នៅប្រព័ន្ធធារាសាស្ត្រ ប៉ក់ប៉ែន ក្នុងខេត្តកំពង់ឆ្នាំង ប្រធានឃុំក្រុមប្រឹក្សាឃុំ/សង្កាត់ និងគណៈកម្មាធិការ សកបទ បានរួមគ្នាយ៉ាងសកម្មថៃទាំប្រព័ន្ធធារាសាស្ត្រ។ ក្នុងករណីដទៃទៀតកសិករតែងរាយការណ៍បញ្ហានានាទាក់ទងនឹងការប្រើប្រាស់ ទៅក្រុមប្រឹក្សាឃុំ/សង្កាត់ ជាងរាយការណ៍ទៅ សកបទ។ ដូចគ្នានេះដែរ តាមរយៈការសម្ភាស តំណាងក្រុមប្រឹក្សាឃុំនៅ ប៉ក់ប៉ែន បានបញ្ចេញទស្សនៈថា "អាជ្ញាធរមូលដ្ឋាន សកបទ និងកសិករមានប្រពៃណីសហការ ឬសហប្រតិបត្តិការគ្នាទៅវិញទៅមកបានយ៉ាងល្អក្នុងវិស័យកសិកម្ម ក៏ដូចជានៅក្នុងការគ្រប់គ្រង និងចែកចាយទឹក"។

តំណាងមន្ទីរធនធានទឹក បានកត់សំគាល់ថា ទោះបីជា សកបទ មានការទទួលខុសត្រូវដោយប្រុងប្រយ័ត្ន និងតែងតែយកផលប្រយោជន៍រួមជាអាទិភាពក្តី មានករណីជាច្រើនបានបង្ហាញថា សមត្ថភាពរបស់ សកបទ នៅមានកម្រិតនៅឡើយ ហើយមិនទាន់អាចដំណើរការបំពេញតួនាទីដោយខ្លួនឯងបានទេ គឺពួកគាត់នៅតែត្រូវការការគាំទ្រពីមជ្ឈដ្ឋានខាងក្រៅ/មន្ទីរធនធានទឹកនៅពេលដែលខ្វះទឹក ដោយគូសបញ្ជាក់ថា៖ "...ពួកគាត់អាចគ្រប់គ្រងទឹកដោយឯករាជ្យនៅពេលមានទឹក តែពេលខ្វះទឹក ពួកគាត់ទៅរកមន្ទីរធនធានទឹកឲ្យជួយដោះស្រាយ..."[៤៤]។ ករណីប្រហែលគ្នានេះដែរ គឺនៅប្រព័ន្ធធារាសាស្ត្រកំប៉ាង ខេត្តពោធិ៍សាត់ សកបទ តែងតែពឹងផ្អែកលើក្រុមប្រឹក្សាឃុំ/សង្កាត់ ដើម្បីបំពេញតួនាទីផ្នែកខ្លះនៃការងាររបស់ សកបទ ក្នុងការងារគ្រប់គ្រងទឹក ព្រោះថាសមាជិករបស់គណៈកម្មាធិការ សកបទ ខ្លះ បានជាប់រវល់ការងារដទៃទៀតអស់ទៅហើយ (ប្រកបមុខរបរចិញ្ចឹមជីវិតផ្សេងទៀត)។ បញ្ហានេះដូចគ្នាទៅនឹងការរកឃើញក្នុងការសិក្សាអំពីគោលនយោបាយ PIMD និងកត្តាដែលប៉ះពាល់ដល់ការបង្កើត សកបទ របស់អ្នកនិពន្ធ ប៉េរ៉េរ៉ា (Perera L.R 2006) ដែលគាត់ក៏បានរកឃើញដែរថា សកម្មភាពរបស់ សកបទ ភាពច្រើនត្រូវបានអនុវត្តក្រោមការដឹកនាំរបស់ប្រធានឃុំ។ នេះមិនមែនជាលទ្ធផលរំពឹងទុកសម្រាប់ផ្ញើជូនទៅក្រសួងធនធានទឹក មន្ទីរធនធានទឹក អ្នកផ្តល់ជំនួយ និង NGOs ដែលកំពុងចង់ឃើញថា តើជំនួយបច្ចេកទេស និងហិរញ្ញវត្ថុដ៏ច្រើន ត្រូវបានវិនិយោគលទ្ធផលជាក់ស្តែងដូចម្តេចនោះទេ។ តាមអង្កេតនាពេលចុះសិក្សាដល់មូលដ្ឋាន សកបទ តែងផ្តោតការយកចិត្តទុកដាក់លើការងារបែងចែកទឹក ច្រើនជាងការធ្វើពិពិធកម្មចំណូលរបស់កសិករ។ អនុសាសន៍ថាខាងក្រោម គឺជាការក្រើនរំលឹកដាស់តឿន សកបទ របស់មន្ទីរធនធានទឹក។

> *...សកបទ ដែលប្រជាជនបោះឆ្នោតឲ្យត្រូវពិចារណាជ្រើសរើសពូជ ជី ថ្នាំសម្លាប់សត្វល្អិត ដំណាំដាំដុះផ្សេងៗ ហើយធ្វើផែនការ ដើម្បីអនុវត្ត ដឹកនាំកសិករឲ្យទទួលបានផលច្រើន មិនមែនគ្រាន់តែដើរប្រមូលថ្លៃប្រើប្រាស់សេវាកម្មធារាសាស្ត្រពេលដែលកសិករច្រូតកាត់ហើយ ដើម្បីយកទៅថែទាំទំនប់ប្រឡាយ ឬអង្គុយចាំតែស្នើសុំឲ្យរដ្ឋអំណាចជួយនៅពេលមានបញ្ហានោះទេ។ សកបទ ត្រូវពង្រីកយុទ្ធសាស្ត្រ ដើម្បីដឹកនាំកសិករឲ្យទទួលបានប្រាក់ចំណូលកាន់តែច្រើន...*[៤៥]

នៅពេលដែលខ្វះខាតទឹក កិច្ចសហការគ្នាក្នុងចំណោមអ្នកទទួលផលមានការធ្លាក់ចុះ។ នៅពេលខ្វះទឹក អ្នកទទួលផលតែងមាននិន្នាការយកផលប្រយោជន៍បុគ្គលជាអាទិភាព ជាងការឲ្យអាទិភាពលើប្រយោជន៍រួម។ លោក ខែលសី (Kelsey 2009) បានអះអាងថា អ្នកប្រើទឹកត្រូវតែសហការគ្នាក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិរួម ដូចជា ធនធានទឹកជាដើម ជាពិសេសអ្នកប្រើប្រាស់ទឹកម្នាក់ៗ ត្រូវកាត់បន្ថយតម្រូវការទឹករបស់ខ្លួនខ្លះ ដើម្បីទុកសម្រាប់អ្នកដទៃប្រើប្រាស់ផង ហើយត្រូវមានគំនិតថា រាល់ការបាត់បង់ចំណែកណាមួយនៃធនធានទាំងនោះនាពេលបច្ចុប្បន្ន នឹងពាក់ព័ន្ធជាមួយនឹងការប្រើប្រាស់វាទៅអនាគត។ ដូច្នោះរាល់អ្នកប្រើប្រាស់ទឹក គួរកាត់បន្ថយការប្រើប្រាស់របស់ខ្លួនខ្លះនៅពេលមានការខ្វះខាតទឹក។ ប្រការនេះអាចធ្វើ ទៅបានយ៉ាងមានប្រសិទ្ធភាពតាមរយៈការចូលរួមសហការគ្នា។ នៅតាមប្រព័ន្ធជាច្រើន ដោយសារមិនបានពង្រឹងការអនុវត្តច្បាប់ ឬការអនុវត្តច្បាប់ មិនសូវមានប្រសិទ្ធភាព កសិករមិនចង់បើកទឹកទៅឲ្យកសិករដទៃទៀតនៅផ្នែកខាងក្រោមប្រឡាយទេ។ ជម្លោះផលប្រយោជន៍ដែលបណ្តាលមកពីកង្វះកិច្ចសហការគ្នា មានភាពស្រួចស្រាលណាស់។ ក្នុងករណីខ្លះ សកបទ មិនអាចដោះស្រាយជម្លោះទាំងនោះទេ ហើយបានបញ្ជូនបញ្ហាទាំងនោះឲ្យមន្ទីរធនធានទឹក ឬអាជ្ញាធរមូលដ្ឋានជាអ្នកដោះស្រាយ។ មន្ទីរធនធានទឹកបានឲ្យដឹងពីទំនាក់ទំនង ឬការពឹងផ្អែកទៅលើមន្ទីរធនធានទឹក ដើម្បីឲ្យជួយ សកបទ ដោះស្រាយជម្លោះខាងក្រោម៖

> *...នៅពេលដែលពួកគេ (សកបទ) ជួបប្រទះបញ្ហា ដូចជា ជម្លោះក្នុងការប្រើប្រាស់ទឹក គ្រោះទឹកជំនន់ ឬគ្រោះរាំងស្ងួត ពួកគាត់កោះប្រជុំដើម្បីដោះស្រាយបញ្ហានេះនៅមូលដ្ឋាន។ បើពួកគាត់ដោះស្រាយមិនបាន ពួកគាត់នឹងសុំឲ្យមន្ទីរធនធានទឹកជួយ។ មន្ទីរធនធានទឹកតែងជួយពួកគាត់ ហើយម្យ៉ាងទៀត មន្ទីរធនធានទឹកមានកញ្ចប់ថវិកាតូចមួយសម្រាប់ប្រើប្រាស់ (ឬជួយ សកបទ) នៅពេលមានករណីបន្ទាន់ ដូចជា គ្រោះរាំងស្ងួត ឬគ្រោះទឹកជំនន់ជាដើម...*[៤៦]

តាមគោលនយោបាយ PIMD និរន្តរភាពនៃការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ផ្អែកជាសំខាន់លើការអនុវត្តរបស់ សកបទ ដោយប្រើប្រាស់ធនធានក្នុងមូលដ្ឋាន ក្រោមការគាំទ្ររបស់រដ្ឋាភិបាល។ អ្នកទទួលផល ឬអ្នកប្រើប្រាស់ទឹក មានកាតព្វកិច្ចបង់ថ្លៃចំណាយសម្រាប់ការងារដំណើរការ និងថែទាំ។ តែក្នុងករណីជាច្រើន កសិករតែងមានមូលហេតុជាច្រើនយ៉ាង

---

៤៤ តាមការសម្ភាសជាមួយលោកប្រធានមន្ទីរធនធានទឹក និងឧតុនិយម ខេត្តពោធិ៍សាត់ ឆ្នាំ២០១០។
៤៥ អនុសាសន៍របស់ឯកឧត្តមប្រធានមន្ទីរធនធានទឹកក្នុងសិក្ខាសាលាផ្សព្វផ្សាយគំហើញការស្រាវជ្រាវនៅខេត្តកំពង់ធំ ឆ្នាំ២០១០។
៤៦ តាមការសម្ភាសជាមួយលោកប្រធានមន្ទីរធនធានទឹក ខេត្តពោធិ៍សាត់ ឆ្នាំ២០១០។

ដើម្បីមិនរួមចំណែកក្នុងការងាររបស់ សកបទ។ បញ្ហានេះបាននាំឲ្យ សកបទ ពឹងផ្អែកសំខាន់លើការបន្តសហការ និងការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីបណ្ដាស្ថាប័នពាក់ព័ន្ធនានា ដូចជា ក្រសួងធនធានទឹក មន្ទីរធនធានទឹក អាជ្ញាធរមូលដ្ឋាន មន្ទីរកសិកម្ម មន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរសុរិយោដី នគរូបនីយកម្ម និងសំណង់ មន្ទីរបរិស្ថាន រដ្ឋបាលជលផលខេត្ត NGOs និងទាយកអន្តរជាតិ ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (អង្គការ JICA) ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង ជាដើម។

### ៥.២.៣ ដោះស្រាយបញ្ហាប្រឈមនៃកិច្ចសហការក្នុងអាងផ្ទៃរងទឹកភ្លៀង ឬអាងទន្លេ

ការអនុវត្តប្រព័ន្ធរដ្ឋបាលមជ្ឈិម (កណ្ដាល) ជាទូទៅមិនមែនមានតែនៅក្នុងវិស័យរដ្ឋបាលប៉ុណ្ណោះទេ តែវាក៏មានក្នុងវិស័យគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹកផងដែរ (Lee, 1999)។ ការអនុវត្តបែបនេះ ស្ដែងឡើងពីការគ្រប់គ្រងធនធានទឹកដែលក្នុងនោះ "ស្ថាប័ននានាដែលពាក់ព័ន្ធនឹងការងារធនធានទឹក មាននិន្នាការគោរពព្រំដែនរដ្ឋបាលជាងព្រំដែននៃផ្ទៃរងទឹកភ្លៀង" (ibid: 38)។ ការអនុវត្តវិធានដាក់បញ្ចូលការគ្រប់គ្រងក្នុងដែនសមត្ថកិច្ចមជ្ឈិម ដោយផ្អែកលើព្រំដែនរដ្ឋបាល គឺជាឧបសគ្គដែលរារាំងដល់ការចូលរួមពីសំណាក់មន្ទីរពាក់ព័ន្ធជុំវិញខេត្ត។ ប្រព័ន្ធធារាសាស្ត្រភាគច្រើនដែលបានសិក្សាបង្ហាញឲ្យឃើញពីបញ្ហាប្រឈមនេះ។ សកបទ ជាច្រើន ត្រូវបានបង្កើតតាមជំរាលនៃផ្ទៃរងទឹកភ្លៀង ហើយអ្នកប្រើប្រាស់ទឹកនៅខ្សែទឹកខាងលើ និងខាងក្រោម បានជួបប្រទះបញ្ហាជម្លោះជាច្រើនបណ្ដាលមកពីការប្រើទឹក ខណៈដែលប្រភពទឹកនោះហូរឆ្លងកាត់តំបន់របស់ពួកគេ។ ឧទាហរណ៍ ទឹកហូរពីប្រព័ន្ធដំណាក់អំពិល ឆ្លងកាត់ខេត្តពីរ គឺខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង ដែលជម្លោះតែងមានភាពលំបាកដោះស្រាយ ខណៈដែលកសិករនៅខេត្តបាត់ដំបង ស្ថិតនៅខ្សែទឹកខាងក្រោម ត្រូវការឲ្យកសិករនៅខេត្តពោធិ៍សាត់ដែលនៅខ្សែទឹកខាងលើ បង្ហូរទឹកឲ្យពួកគេ។ ករណីជម្លោះដ៏ធ្ងន់ធ្ងរមួយបានកើតឡើងនៅពេលដែលអ្នកភូមិ និងប្រធានភូមិដែលឡើងមកពីឃុំអ្នកតាទ្វារ ខេត្តបាត់ដំបង នាំគ្នាទៅជួប សកបទ នៅប្រព័ន្ធធារាសាស្ត្រកំប៉ាង ខេត្តពោធិ៍សាត់ ហើយសុំយ៉ាងសង្គ្រួញឲ្យបើកទឹកទៅតំបន់ពួកគេ ដោយមិនស្ដាប់ការពន្យល់បកស្រាយរបស់ សកបទ ឡើយ។ ឧទាហរណ៍មួយទៀត ករណីជម្លោះកើតមានឡើងពីការចែកចាយទឹកនៃប្រព័ន្ធធារាសាស្ត្រ ៤ នៅអាងស្ទឹងជ្រៃបាក់ ក្នុងខេត្តកំពង់ឆ្នាំង (មើលរូបភាព ៦)។ អាងស្ទឹងជ្រៃបាក់ហូរពីភ្នំឱរ៉ាល់ កាត់តាមប្រព័ន្ធធារាសាស្ត្រប៉ក់ប៉ែន ស្វាយចេក តាំងក្រសាំង និងត្រពាំងត្របែក។ ពីអតីតកាល នៅពេលដែលមានការខ្វះទឹក ក្រោមការដឹកនាំរបស់មន្ទីរធនធានទឹក សកបទ និងកសិករនៅត្រពាំងត្របែក បានចរចាជាមួយ សកបទ នៅតាំងក្រសាំង និងស្វាយចេក ដើម្បីសុំបើកទឹកខ្លះ ដើម្បីធ្វើស្រែប្រាំង។ សកបទ និងកសិករនៅត្រពាំងត្របែកបានឲ្យដឹងថា ការចរចាភាគច្រើនមានជោគជ័យតែប្រមាណ ១០% ប៉ុណ្ណោះ សម្រាប់កសិករនៅត្រពាំងត្របែក ហើយការមិនទទួលបានទឹក គឺមានចំនួន ៩០% ឯណោះ។ ករណីខ្លះ កិច្ចសហការគាំទ្រពីអាជ្ញាធរមូលដ្ឋាន ពីប្រព័ន្ធមួយទៅប្រព័ន្ធមួយទៀត គឺពិតជាមានការលំបាកទ្វេដងសម្រាប់អភិបាលកិច្ចមូលដ្ឋាន។

អវត្តមានក្របខ័ណ្ឌច្បាប់សមស្របនៅកម្រិតផ្ទៃរងទឹកភ្លៀង បង្កើតបានជាឧបសគ្គចំពោះប្រសិទ្ធភាពនៃកិច្ចសហការរបស់អ្នកពាក់ព័ន្ធ។ អនុក្រឹត្យសំខាន់ៗបីស្ដីពី សកបទ ការគ្រប់គ្រងអាងទន្លេ និងការបែងចែកទឹក និងការផ្ដល់អាជ្ញាប័ណ្ណទឹក កំពុងនៅជាសេចក្ដីព្រាងនៅឡើយ។ អវត្តមាននៃក្របខ័ណ្ឌច្បាប់ទាំងនេះ នាំឲ្យមានការលំបាកសម្រាប់ស្ថាប័នពាក់ព័ន្ធដែលអនុវត្តការងារគ្រប់គ្រងទឹកក្នុងតំបន់ដែលស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន។ រីឯកង្វះខាតការពង្រឹងការអនុវត្តច្បាប់ និងការគ្រប់គ្រងច្បាប់ ក៏ជារបាំងដ៏លំបាកមួយផងដែរ។

ទន្ទឹមនឹងមានសេចក្ដីត្រូវការឲ្យមានការគ្រប់គ្រងកាន់តែប្រសើរនៃធនធានទឹកក្នុងបរិបទអាងផ្ទៃរងទឹកភ្លៀង ក៏ទាមទារឲ្យមានគោលនយោបាយគ្រប់គ្រងធនធានទឹកមួយសមស្រប ក្នុងគោលបំណងផ្ដល់នូវគណនេយ្យភាព តម្លាភាព សមភាព និងការចូលរួមសាធារណៈប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ពីសំណាក់អ្នកពាក់ព័ន្ធទាំងឡាយ ក្នុងការយល់ព្រម និងប្រតិបត្តិតាមច្បាប់ និងគោលនយោបាយពាក់ព័ន្ធ។ ប្រព័ន្ធអភិបាលកិច្ចធនធានទឹក ដែលបានកែលម្អក្រោមក្របខ័ណ្ឌច្បាប់របស់រដ្ឋាភិបាលក្នុងកម្រិតអាងទន្លេ នឹងជួយគាំទ្រដល់សមត្ថភាព សកបទ អាជ្ញាធរមូលដ្ឋាន និងស្ថាប័នមូលដ្ឋាន ដើម្បីគ្រប់គ្រងធនធានទឹកប្រកបដោយនិរន្តរភាពក្នុងទិដ្ឋភាពមួយដ៏ទូលំទូលាយ។

### ៥.២.៤ ពង្រឹងតួនាទី និងគណនេយ្យភាព[៤៧]របស់ សកបទ

នៅថ្នាក់មូលដ្ឋាន ការគ្រប់គ្រងរបស់ សកបទ គឺផ្អែកទៅលើលក្ខន្តិករបស់ សកបទ ហើយមន្ទីរធនធានទឹកណែនាំការអនុវត្ត។ សកបទ ត្រូវបានបង្កើតឡើងស្របតាមការស្នើសុំរបស់ក្រុមកសិករ ឬអ្នកភូមិ ដោយមានការអនុមតិពីអាជ្ញាធរមូលដ្ឋាន និងមន្ទីរធនធានទឹក។ ប៉ុន្តែ សកបទ ដែលបានបង្កើតឡើងយូរមកហើយ ខ្លះក៏មិនទាន់បានចុះបញ្ជីទទួលស្គាល់ដោយក្រសួងធនធានទឹកនៅឡើយទេ។

តាមទ្រឹស្តី សកបទ ត្រូវបានបង្កើតឡើងដើម្បីធ្វើវិមជ្ឈការអភិបាលកិច្ចធនធានទឹក។ ចំពោះមន្ទីរធនធានទឹក ការបង្កើត សកបទ ក៏អាចចាត់ទុកថា ជាមធ្យោបាយមួយសំដៅកាត់បន្ថយបន្ទុកការងារមួយចំនួនពីស្ថាប័នជំនាញ[៤៨] (មន្ទីរធនធានទឹក) ផងដែរ។ ដើម្បីជួយឲ្យ សកបទ ធ្វើការក្នុងសហគមន៍របស់ខ្លួនប្រកបដោយប្រសិទ្ធភាព សកបទ គួរមានភាពឯករាជ្យតាមលក្ខណៈបច្ចេកទេស។ តាមការអនុវត្តជាក់ស្តែង សកបទ មានតួនាទីស្របច្បាប់ក្នុងការគ្រប់គ្រងធនធានទឹក ប៉ុន្តែពួកគេពុំទាន់មានអំណាចគ្រប់គ្រាន់ដើម្បីធ្វើនិយ័តកម្ម និងគ្រប់គ្រងធនធានទឹកទេ។

ការសម្រេចបាននូវភាពឯករាជ្យតាមលក្ខណៈបច្ចេកទេសរបស់ សកបទ ខ្លះមិនទាន់អាចទទួលបានដោយផ្ទាល់នៅឡើយ។ តំណាងមន្ទីរធនធានទឹកបានសង្កេតឃើញថា សមត្ថភាពរបស់ សកបទ មួយចំនួនក្នុងការគ្រប់គ្រងធារាសាស្ត្រនៅមានកម្រិតនៅឡើយ។ ពួកគេប្រឈមនឹងបញ្ហានេះ នៅស្ទើរគ្រប់តំបន់ទាំងអស់ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ។ តំណាង សកបទ ជាច្រើនបានយល់ឃើញថា ទាំងកសិករ ទាំងតំណាងគណៈកម្មាធិការ សកបទ ត្រូវការបណ្តុះបណ្តាលស្តីពី ច្បាប់ និងគោលនយោបាយគ្រប់គ្រងធនធានទឹក លក្ខន្តិក សកបទ និងការទទួលខុសត្រូវដទៃទៀតរបស់ពួកគេ។ បញ្ហាសំខាន់ តើច្បាប់ និងបទដ្ឋានច្បាប់ដែលមានបច្ចុប្បន្ន អាចឆ្លើយតបតម្រូវការរបស់កសិករកម្រិតណាក្នុងការដោះស្រាយបញ្ហាទាំងនោះ។ យន្តការវិមជ្ឈការនេះ នៅតែជាបញ្ហាប្រឈមនៅឡើយ។

សកបទ មានភារកិច្ចទទួលខុសត្រូវចាត់ចែង និងអភិបាលលើប្រព័ន្ធធារាសាស្ត្រ ប៉ុន្តែ អាជ្ញាធរមូលដ្ឋាន មានភារកិច្ចទទួលខុសត្រូវក្នុងការពង្រឹងការអនុវត្តច្បាប់[៤៩]។ លើសពីនេះទោះបីជាអង្គការឯករាជ្យដែលមានអាណត្តិដើម្បីសហការ និងសម្របសម្រួលការងារទាក់ទងនឹងការប្រើប្រាស់ទឹកក្តី សកបទ បានជួបឧបសគ្គរារាំងដោយសារកត្តាដែលថា ពួកគាត់គ្មានអំណាចក្នុងការដោះស្រាយបញ្ហាទេ។ សមាជិកគណៈកម្មាធិការ សកបទ ត្រូវបានចោទសួរពីវិធីដែល សកបទ អាចដោះស្រាយបញ្ហាដែលប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ ឬលើការបែងចែកទឹកនៅតំបន់មួយចំនួន ដូចជា នៅអូរស្វាយ និងនៅស្ទឹងជីនិត ខេត្តកំពង់ធំ និងនៅកំប៉ាង ខេត្តពោធិ៍សាត់។ យោងតាមលក្ខន្តិក[៥០] សមាជិកគណៈកម្មាធិការ សកបទ មិនអាចចាត់វិធានការអ្វីមួយលើសពីការពិន័យ ទៅលើកសិករណាដែលមិនអនុវត្តតាមលក្ខន្តិកទេ។ តួនាទីរបស់ពួកគេ ហាក់បីដូចជា ចាំតែរាយការណ៍ជូនទៅអាជ្ញាធរមូលដ្ឋាន ហើយសង្ឃឹមថា វិធានការរដ្ឋបាល ឬការពង្រឹងការអនុវត្តច្បាប់ អាចនឹងត្រូវបានអនុវត្ត ចំពោះការមិនគោរពតាមលក្ខន្តិក ឬអ្នកបំផ្លាញធារាសាស្ត្រប៉ុណ្ណោះ។

កង្វះភាពជាម្ចាស់សហគមន៍ មួយផ្នែកបានកើតឡើងដោយសារកង្វះភាពពេញច្បាប់របស់ សកបទ ហើយជួនកាលបណ្តាលមកពីការលំបាក ឬភាពយឺតយូរក្នុងដំណើរការចុះបញ្ជី សកបទ ផងដែរ។ ដើម្បីឲ្យមានការទទួលស្គាល់ជាផ្លូវការ ឬស្របច្បាប់ សកបទ នីមួយៗ (ស្របតាមលក្ខន្តិករបស់ខ្លួន) ត្រូវចុះបញ្ជីជាមួយនាយកដ្ឋានពាក់ព័ន្ធ ខេត្ត ក្រុង របស់ក្រសួងធនធានទឹក។ អាស្រ័យដោយមូលហេតុមួយចំនួន សកបទ ខ្លះ បានឲ្យដឹងថា ពួកគាត់ត្រូវរង់ចាំជាច្រើនខែឆ្នាំដើម្បីទទួលបានការចុះបញ្ជីទទួលស្គាល់ពីក្រសួងធនធានទឹកជាផ្លូវការ។ ករណីនេះ បានកើតមានចំពោះគណៈកម្មាធិការ សកបទ នៅ

---

៤៧ តាមធនាគារពិភពលោក ទស្សនទាននៃពាក្យ "គណនេយ្យភាព" ទាក់ទងនឹងដំណាក់កាលពីរខុសគ្នាគឺ ការឆ្លើយតប (answerability) និងការពង្រឹងការអនុវត្ត (enforcement)។ ការឆ្លើយតប គឺសំដៅលើកាតព្វកិច្ចរបស់រដ្ឋាភិបាល ស្ថាប័នជំនាញ និងមន្ត្រីសាធារណៈ ដើម្បីផ្តល់ព័ត៌មានអំពីការសម្រេចចិត្ត និងសកម្មភាពរបស់ខ្លួន និងដើម្បីកែតម្រូវការងារទាំងនេះទៅតាមគណនេយ្យភាពសាធារណៈ និងគណនេយ្យភាពស្ថាប័ន ដែលត្រូវបានគេផ្តល់ភារកិច្ចឲ្យ។

៤៨ មន្ត្រីមន្ទីរធនធានទឹកបានឲ្យដឹងថា មន្ទីរធនធានទឹកកាលមុនធ្លាប់បានបង្កើត សកបទ ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យធនធានទឹកនៅតាមប្រព័ន្ធធារាសាស្ត្រគោលដៅ។ មន្ទីរធនធានទឹកមាន សកបទ ដើម្បីទទួលខុសត្រូវក្នុងការបើក ឬបិទទ្វារទឹក។

៤៩ សកម្មភាពមិនស្របច្បាប់ ជាទូទៅ គឺច្រើនពាក់ព័ន្ធនឹងការបើកបង្ហូរទឹកដោយគ្មានការអនុញ្ញាតពី សកបទ ការកាប់បំផ្លាញប្រឡាយ ឬការលើកទំនប់ ដើម្បីបាចត្រីជាដើម។

៥០ លក្ខន្តិក សកបទ ដូចមាននៅក្នុងសារាចរលេខ០១ ចុះថ្ងៃទី១១ មករា ១៩៩៩ ស្តីពី "គោលនយោបាយអនុវត្តន៍ប្រព័ន្ធធារាសាស្ត្រដោយនិរន្តរភាព"

ត្រពាំងត្របែក ស្វាយចេក និងប៉ក់ប៉ែន ក្នុងខេត្តកំពង់ឆ្នាំង ដែលគាត់បានឲ្យដឹងថា ពួកគាត់បានធ្វើឯកសារដើម្បីចុះបញ្ជីតាមរយៈមន្ទីរធនធានទឹក ហើយមន្ទីរធនធានទឹក បានបញ្ជូលឯកសារនោះទៅក្រសួងធនធានទឹក ដើម្បីអនុម័តចុងក្រោយតាំងពីជាងពីរឆ្នាំមុនម្ល៉េះ ប៉ុន្តែការចុះបញ្ជីជាផ្លូវការរបស់ពួកគេ កំពុងស្ថិតក្នុងការរង់ចាំ[៥១]នៅឡើយ។ សកបទ ពុំទទួលបាននូវភាពពេញច្បាប់ពីកសិករ និងអាជ្ញាធរមូលដ្ឋាន ដោយគ្មានការអនុមតិនៃឯកសារចុះបញ្ជីផ្លូវការឡើយ។

## *៥.២.៥ ធានាការគាំទ្រហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងធនធានទឹក*

ប្រទេសកម្ពុជា បានទទួលប្រាក់ជំនួយអន្តរជាតិជាច្រើន សម្រាប់យកទៅអភិវឌ្ឍន៍ធនធានទឹក។ ការធ្លាក់ចុះជំនួយហិរញ្ញវត្ថុអន្តរជាតិរយៈពេលយូរ នឹងអាចជាមធ្យោបាយផ្លាស់ប្តូរនៃទុនវិនិយោគដែលត្រូវការ (ADB 2003)។

ជាច្រើនទសវត្សរ៍មកហើយដែលរដ្ឋាភិបាលបានខិតខំប្រឹងប្រែងជាខ្លាំង ទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីកាត់បន្ថយដល់កម្រិតអប្បបរមានូវការពឹងផ្អែកលើទឹកភ្លៀង សម្រាប់ការដាំដុះរបស់កសិករនៅទូទាំងប្រទេស។ ដើម្បីឲ្យសម្រេចបាននូវគោលដៅរបស់ខ្លួនដែលមានចែងនៅក្នុងផែនការអនុវត្តន៍ ស្តីពីការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹកឆ្នាំ២០០៩-២០១៣ រាជរដ្ឋាភិបាលកម្ពុជា ត្រូវការថវិកាប្រមាណ ៧៣៦លានដុល្លារ ដែលក្នុងនោះចំនួនទឹកប្រាក់ ៩៩លានដុល្លារ ជាថវិការបស់រាជរដ្ឋាភិបាល និង ៦៣៦លានដុល្លារទៀត គឺជាថវិកាជំនួយអន្តរជាតិ។ នៅឆ្នាំ២០០៩ ទឹកប្រាក់ជំនួយអន្តរជាតិសរុបប្រមាណ ២០៦លានដុល្លារ ត្រូវបានចុះកិច្ចសន្យាជាមួយដៃគូអភិវឌ្ឍន៍ (MOWRAM 2009b)។

ចាប់ពីឆ្នាំ១៩៧៩ មកទល់បច្ចុប្បន្ន ចំនួនទឹកប្រាក់ដ៏ច្រើន រួមមាន ថវិកាជាតិ ប្រាក់កម្ចីពីធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) មូលនិធិអន្តរជាតិដើម្បីអភិវឌ្ឍន៍កសិកម្ម (IFAD) ប្រទេសចិន គូវ៉ែត សាធារណរដ្ឋកូរ៉េ ជប៉ុន និងជំនួយហិរញ្ញវត្ថុអន្តរជាតិ ដើម្បីយកទៅស្តារ សាងសង់ (និងគ្រប់គ្រង) ប្រព័ន្ធធារាសាស្ត្រ ទំនប់ការពារទឹកជំនន់ និងតម្លើងស្ថានីយបូមទឹក (Ibid)។ ទឹកប្រាក់សម្រាប់ចំណាយលើដំណើរការ និងថែទាំប្រព័ន្ធធារាសាស្ត្រ ជាទូទៅមិនសូវទទួលបានគាំទ្រដោយភ្នាក់ងារផ្តល់ជំនួយទេ។ ឧបសម្ព័ន្ធ ២ បង្ហាញពីអ្នកដៃគូអភិវឌ្ឍន៍សំខាន់ៗលើប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា។

ការអភិវឌ្ឍន៍ និងការស្តារប្រព័ន្ធធារាសាស្ត្រ ឬកម្មវិធីអប់រំផ្សព្វផ្សាយ អំពីប្រព័ន្ធធារាសាស្ត្រត្រូវបានអនុវត្តដោយឈរលើមូលដ្ឋាននៃលទ្ធភាព និងតម្រូវការរបស់ប្រជាកសិករភាគច្រើន។ និរន្តរភាពហិរញ្ញវត្ថុសម្រាប់ទ្រទ្រង់ការផ្តល់សេវាកម្មធារាសាស្ត្រ គួរតែអាចសម្រេចទៅបាន ព្រោះសេវាកម្មនេះបានផ្តល់ទៅអ្នកប្រើប្រាស់ទឹក និងជាអ្នកដែលបានយល់ព្រមបង់ថ្លៃសេវាកម្មនេះ។ គោលនយោបាយ PIMD បានលើកទឹកចិត្តកសិករឲ្យគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយខ្លួនឯងផ្ទាល់ និងប្រើប្រាស់ឲ្យបានសមស្របនូវធនធាន (ដែលមានកម្រិត) របស់រដ្ឋាភិបាល របស់ទាយក និងធនធានរបស់ពួកគេផ្ទាល់។ ដោយហេតុថា អ្នកទទួលផលមានការរួញរាក្នុងការងារបង់ថ្លៃសេវាដែលផ្តល់ឲ្យពួកគាត់មិនបានល្អ ឬដោយសារពួកគាត់អល់អែកមិនចង់ចូលរួមចំណែកក្នុងការដំណើរការ និងថែទាំ ធ្វើឲ្យនិរន្តរភាពនៃប្រព័ន្ធធារាសាស្ត្រក្រោយពីគម្រោងបានបញ្ចប់ ស្ថិតនៅក្នុងសភាពគ្រោះថ្នាក់។ ការបណ្តុះបណ្តាលសមត្ថភាពបន្ថែម និងការផ្តល់ហិរញ្ញវត្ថុដ៏គួរឲ្យទុកចិត្តរយៈពេលយូរសម្រាប់គ្រប់គ្រងធារាសាស្ត្រ គឺជាសេចក្តីត្រូវការចាំបាច់។ គោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏បានលើកទឹកចិត្តដល់វិស័យឯកជន NGOs និងអង្គការអន្តរជាតិឲ្យចូលរួមវិនិយោគ និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រខ្នាតតូច មធ្យម និងធំ ផងដែរ។ ដូច្នេះការធានាការគាំទ្រហិរញ្ញវត្ថុរយៈពេលយូរសម្រាប់អភិវឌ្ឍន៍ និងគ្រប់គ្រងធនធានទឹក នៅតែជាការប្រឈមមិនចេះចប់សម្រាប់ប្រទេសកម្ពុជា ហើយការគាំទ្រផ្នែកហិរញ្ញវត្ថុអន្តរជាតិនៅតែមានសារៈសំខាន់បំផុត។

---

៥១ មន្ត្រីតំណាងមន្ទីរធនធានទឹកបានឲ្យដឹងថា មន្ទីរបានបញ្ជូនឯកសារសុំចុះបញ្ជីទៅនាយកដ្ឋានជំនាញនៃក្រសួងធនធានទឹករួចហើយ។ ឯមន្ត្រីនៃនាយកដ្ឋានជំនាញតបថា ពុំទាន់បានទទួលឯកសារនោះទេ ហើយក៏ពុំមានហេតុផលអ្វីដែលត្រូវពន្យាពេលនោះទេ។ ដើម្បីបំបាត់មន្ទិលនៃបញ្ហានេះ ក្រសួងធនធានទឹកបានបញ្ជាក់ថា នៅពេលដែល សកបទ បានផ្ញើឯកសារសុំចុះបញ្ជីរួចហើយ និងក្នុងខណៈដែលឯកសារនោះ កំពុងដំណើរការដោយមន្ទីរធនធានទឹក/ក្រសួងធនធានទឹក សកបទ ត្រូវអនុវត្ត និងបំពេញមុខងារ និងតួនាទីរបស់ខ្លួនជាធម្មតា។

## ៥.៣ មេរៀនដែលទទួលបាន៖ឆ្ពោះទៅអភិបាលកិច្ចល្អក្នុងការគ្រប់គ្រងធារាសាស្ត្រ

ការវិភាគខាងលើ បានឆ្លុះបង្ហាញឲ្យឃើញនូវបញ្ហា និងបទពិសោធន៍មួយចំនួន ដែលកំពុងកើតមានឡើងចំពោះក្រុមអ្នកពាក់ព័ន្ធទាំងឡាយ។ ផ្នែកបន្ទាប់នឹងបង្ហាញនូវមេរៀន និងបទពិសោធន៍សំខាន់ៗដែលទទួលបាន និងវិធីសាស្ត្រ សម្រាប់យកមកដោះស្រាយបញ្ហាខាងលើ បន្ថែមដោយការប្រើប្រាស់ទិន្នន័យ (នៃដំណោះស្រាយ) ដែលទទួលបានពីសិក្ខាសាលាថ្នាក់ជាតិ និងថ្នាក់ខេត្ត។

### *៥.៣.១ លើកកម្ពស់កិច្ចសហការរវាង សកបទ និង អាជ្ញាធរមូលដ្ឋាន*

អាជ្ញាធរមូលដ្ឋាន មានការទទួលខុសត្រូវក្នុងការរៀបចំផែនការអនុវត្តន៍ និងការគ្រប់គ្រងធនធានធម្មជាតិ ហើយតាមការរំពឹងទុក អាជ្ញាធរមូលដ្ឋាន នឹងពង្រីកការទទួលខុសត្រូវជាច្រើនបន្ថែមទៀត។ នៅកម្រិតថ្នាក់ក្រោមជាតិ គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ដើរតួនាទីជាយន្តការមួយដ៏សំខាន់ ដើម្បីធានានូវប្រសិទ្ធភាពទំនាក់ទំនងរវាងស្ថាប័នរដ្ឋាភិបាល និង NGOs។ ការគ្រប់គ្រងធារាសាស្ត្រប្រកបដោយជោគជ័យ តម្រូវឲ្យមានកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន ដែលមានអំណាចគ្រប់គ្រាន់ក្នុងការប្រើវិធានពង្រឹងការអនុវត្តច្បាប់ ដូចជា អំណាចក្នុងការចាប់ឃុំឃាំង និងអំណាចធ្វើការចោទប្រកាន់អ្នកដែលប្រព្រឹត្តិខុស ក្នុងខណៈដែល សកបទ មានអំណាចត្រឹមតែផាកពិន័យកសិករដែលមិនគោរពបទបញ្ជាផ្ទៃក្នុងប៉ុណ្ណោះ។ ផ្អែកតាមក្របខ័ណ្ឌច្បាប់នេះ កិច្ចសហការរវាង សកបទ និងអាជ្ញាធរមូលដ្ឋាន មានសារៈសំខាន់ណាស់។

តាមការសិក្សាអង្កេតនៅមូលដ្ឋាន ការសម្ភាស និងការជួបប្រជុំផ្ទាល់ជាមួយបណ្តាអាជ្ញាធរមូលដ្ឋានបង្ហាញថា នៅតំបន់ខ្លះ កិច្ចសហការល្អរវាង សកបទ និងអាជ្ញាធរមូលដ្ឋាន នាំមកនូវអត្ថប្រយោជន៍យ៉ាងច្រើន ហើយអាចមានកាលានុវត្តភាពជាច្រើន ក្នុងការនាំយកអត្ថប្រយោជន៍/បទពិសោធន៍ទាំងនេះ ទៅអនុវត្តនៅសហគមន៍ឯទៀត ដើម្បីលើកកម្ពស់ការគ្រប់គ្រងទឹកឲ្យមានប្រសិទ្ធភាព៖

- សកម្មភាពគ្រប់គ្រងទឹករបស់ សកបទ អាចកាន់តែមានអំណាច ដោយអ្នកពាក់ព័ន្ធដទៃទៀតពីក្រៅប្រព័ន្ធធារាសាស្ត្រដែលទទួលស្គាល់ និងពង្រឹងតួនាទីរបស់ សកបទ ក្នុងប្រព័ន្ធធារាសាស្ត្រនីមួយៗ និងរវាងប្រព័ន្ធធារាសាស្ត្រមួយទៅប្រព័ន្ធមួយទៀត។ មធ្យោបាយដ៏ល្អដើម្បីសម្រេចការងារនេះ គឺអាជ្ញាធរមូលដ្ឋាន ត្រូវជួយគាំទ្រ សកបទ ឲ្យកាន់តែខ្លាំងថែមទៀត ព្រោះសមត្ថកិច្ចរបស់អាជ្ញាធរមូលដ្ឋានខ្ពស់ជាង សកបទ។ ម៉្យាងទៀត សកបទ បានឲ្យដឹងថា បើមានកិច្ចសហការល្អពីអាជ្ញាធរមូលដ្ឋាន នោះកិច្ចសហការគ្នារវាងបណ្តា សកបទ នៅខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម មានលក្ខណៈកាន់តែល្អប្រសើរ។
- ការសម្របសម្រួល និងពង្រឹងកិច្ចសហការរវាងអ្នកពាក់ព័ន្ធ អាចបង្កើតបាននូវបណ្តាញមួយដ៏ល្អរវាង សកបទ អាជ្ញាធរមូលដ្ឋាន សហគមន៍ និងស្ថាប័នរដ្ឋាភិបាល ដូចជា មន្ទីរធនធានទឹក និងមន្ទីរកសិកម្ម ជាដើម។
- កិច្ចសហការគ្នាល្អរវាង សកបទ អាជ្ញាធរមូលដ្ឋាន និងមន្ទីរពាក់ព័ន្ធជុំវិញខេត្ត ក៏បង្កើតបានជាបណ្តាញមួយដែលអាចជួយលើកកម្ពស់ការចែករំលែកទិន្នន័យ និងព័ត៌មាន ស្តីពីបរិមាណទឹកដែលផ្សព្វផ្សាយពីកសិកម្ម ច្បាប់ និងគោលការណ៍ណែនាំផ្សេងៗលើការប្រើប្រាស់ធនធានទឹក និងគម្រោងអភិវឌ្ឍន៍ធារាសាស្ត្រ ទៅដល់អ្នកអនុវត្តទាំងអស់។ ការកែលម្អការយល់ដឹង អាចជួយដោះស្រាយ និងគ្រប់គ្រងជម្លោះប្រកបដោយប្រសិទ្ធភាពថែមទៀតផង។
- កិច្ចសហការបានជួយលើកកម្ពស់សមត្ថភាពក្នុងការធ្វើផែនការ និងការសម្រេចចិត្ត តាមរយៈការផ្តល់ថែមទៀតនូវកាលានុវត្តភាពដល់ សកបទ ដើម្បីរួមចំណែក និងបណ្តុះបណ្តាលផ្នែករៀបចំផែនការ និងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។
- កិច្ចសហការកាន់តែល្អរវាង សកបទ និងអាជ្ញាធរមូលដ្ឋាន បានជួយលើកកម្ពស់ការចូលរួមពីសាធារណជនក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍មូលដ្ឋាន និងសកម្មភាពនានា ដូចជា ការថែទាំផ្លូវថ្នល់ ដំណើរការ និងការថែទាំប្រព័ន្ធធារាសាស្ត្រ ការអភិវឌ្ឍ ការការពារទំនប់ប្រឡាយ និងធនធានធម្មជាតិជាដើម។ ឧទាហរណ៍ នៅប្រព័ន្ធធារាសាស្ត្រ ស្វាយចេក និងតាំងក្រសាំង ក្នុងខេត្តកំពង់ធំ អាជ្ញាធរមូលដ្ឋាន ដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកទឹកចិត្ត និងដឹកនាំកសិករ ដើម្បីស្តារ និងថែទាំហេដ្ឋារចនាសម្ព័ន្ធនានា។

- សមត្ថកិច្ចរបស់អាជ្ញាធរមូលដ្ឋាន ត្រូវបានគេគោរពយ៉ាងទូលំទូលាយនៅក្នុងសហគមន៍ ហើយអាជ្ញាធរមូលដ្ឋាន អាចជួយពង្រឹងដល់ការងាររដ្ឋបាល ការពង្រឹងការអនុវត្តច្បាប់ និងការដោះស្រាយជម្លោះ ព្រោះថា សកបទ ពុំមានអំណាចនេះទេ។
- កិច្ចសហការអាចជួយ សកបទ ទទួលបាននូវមូលនិធិ និងថវិកា ព្រោះអាជ្ញាធរមូលដ្ឋាន មានលទ្ធភាពទទួលបានថវិកា វិនិយោគឃុំ ស្រុក និងខេត្ត វិស័យវិនិយោគឯកជន NGOs និងវិទ្យាស្ថានអប់រំ ស្រាវជ្រាវនានា ដូចជា វិទ្យាស្ថាន CDRI វិទ្យាស្ថាបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញជាដើម។
- កិច្ចសហការអាចនឹងទទួលបានតាមរយៈការបង្កើតអនុគណៈកម្មាធិការទ្រទ្រង់មួយ សម្រាប់គ្រប់គ្រងធនធានទឹក និងដោះស្រាយជម្លោះ ដូចជាករណីនៃការបង្កើតអនុគណៈកម្មាធិការទ្រទ្រង់នៅស្ទឹងជីនិតជាដើម (ការលម្អិតពីករណីនេះ នឹងលើកយកមកពិភាក្សានៅក្នុងផ្នែកបន្ទាប់)។

### ៥.៣.២ សំណើបង្កើតរចនាសម្ព័ន្ធសហការថ្មី៖ "បង្កើនទំហំ" វិធាននៃការគ្រប់គ្រងសហគមន៍

រចនាសម្ព័ន្ធសហការថ្មីមួយ ត្រូវបានស្នើឡើងដោយបណ្តាអ្នកពាក់ព័ន្ធសំខាន់ៗ[៥២] ដើម្បីកែលម្អបណ្តាញការងារ និងកិច្ចសហការពីប្រព័ន្ធធារាសាស្ត្រមួយទៅមួយ និងដើម្បីផ្តល់ឲ្យនូវអាណត្តិពេញលេញ និងសមត្ថកិច្ចដ៏មានប្រសិទ្ធភាពលើការគ្រប់គ្រងធនធានទឹកនៅកម្រិតផ្ទៃរងទឹកភ្លៀង (រូបភាព ៨)។

រូបភាព ៨៖ អនុគណៈកម្មាធិការសម្រាប់គ្រប់គ្រងធារាសាស្ត្រ និងផ្ទៃរងទឹកភ្លៀង (ICMS )ដែលស្នើឲ្យបង្កើតឡើង




៥២ រួមមាន កសិករ សកបទ ប្រធានភូមិ មេឃុំ ក្រុបឃ អភិបាលស្រុក មន្ត្រីខេត្ត ស្ថាប័នរដ្ឋាភិបាល និង NGOs ដែលបានចូលរួមសិក្ខាសាលានៅខេត្តដែលចុះសិក្សាទាំង៣ ចាប់ពីខែកុម្ភៈ ដល់ មេសា ឆ្នាំ២០១០។

នៅក្នុងរចនាសម្ព័ន្ធថ្មីដែលបានស្នើឡើងនេះ ICMS[៥៣] នឹងធ្វើការកោះប្រជុំបន្ទាន់ (ក្នុងករណីចាំបាច់) ឬក៏ប្រជុំមួយខែម្តង ដែលក្នុងពេលនោះសមាជិករបស់អនុគណៈកម្មាធិការ ឬ សកបទ និងរាយការណ៍រាល់បញ្ហាផ្សេងៗដល់អង្គប្រជុំ ដើម្បីឲ្យអនុគណៈកម្មាធិការ ឬផ្នែកដែលទទួលខុសត្រូវ ចាត់វិធានការដោះស្រាយបញ្ហាទាំងនោះ។ ក្នុងករណីត្រូវចាត់វិធានការពង្រឹងការអនុវត្តច្បាប់ ប្រធានអនុគណៈកម្មាធិការ នឹងស្នើសុំការគាំទ្រពីស្ថាប័នមានសមត្ថកិច្ច ដូចជា ប៉ូលីស ឬអាវុធហត្ថជាដើម ដើម្បីលុបបំបាត់រាល់សកម្មភាពល្មើសច្បាប់។ របាយការណ៍នៃអង្គប្រជុំត្រូវបានរាយការណ៍ជូនអភិបាលខេត្ត ដើម្បីសុំយោបល់ ឬអនុសាសន៍ លើសកម្មភាពពេលអនាគត និងដើម្បីកែលម្អគុណភាពដឹកនាំរបស់អនុគណៈកម្មាធិការនេះ។

### ៥.៣.៣ លើកកម្ពស់ការទទួលការខុសត្រូវរបស់អ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងធារាសាស្ត្រ និងផ្នែវងទឹកភ្លៀង

ចំណាត់ថ្នាក់នៃអ្នកពាក់ព័ន្ធ អាចជួយឲ្យគេកំណត់បាននូវនិយមន័យនៃពាក្យ អំណាច (ឥទ្ធិពល) ភាពពេញច្បាប់ (ប្រយោជន៍) និង បន្ទាន់ភាព នៃបណ្តាអ្នកពាក់ព័ន្ធសំខាន់ៗនៅតំបន់សិក្សា។ លទ្ធផលស្រាវជ្រាវបានបន្ថែមតម្លៃមួយដ៏ពិសេស គឺការយល់ដឹងស៊ីជម្រៅអំពីក្នុងតួនាទីនៃអ្នកពាក់ព័ន្ធនឹងអភិបាលកិច្ច និងដំណើរការគ្រប់គ្រងធនធានទឹក។

លទ្ធផលនៃការវិភាគពីតួនាទីរបស់អ្នកពាក់ព័ន្ធបានច្របាច់បញ្ចូលគ្នាជាមួយនឹងលទ្ធផលដែលទទួលបានពីសិក្ខាសាលាថ្នាក់ខេត្ត (តាមវិធីសាស្ត្រដូចបានបង្ហាញនៅផ្នែកទី ២) ដែលធ្វើចំណាត់ថ្នាក់ដោយក្រុមអ្នកពាក់ព័ន្ធ ដើម្បីពិនិត្យមើលថា តើតួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធបានចាត់ចែងឡើងយ៉ាងដូចម្តេច ហើយក្រុមអ្នកពាក់ព័ន្ធត្រូវការតួនាទី និងការទទួលខុសត្រូវអ្វីខ្លះ ក្នុងការងារគ្រប់គ្រងធនធានទឹក។ លទ្ធផលចុងក្រោយត្រូវបានយកទៅសំយោគចូលគ្នា (សូមមើលតារាង ១) ដែលធ្វើឲ្យងាយស្រួលកំណត់ និងរាយការណ៍ពីដំណោះស្រាយដ៏មានសក្តានុពល ទៅនឹងបញ្ហាដែលកំណត់បានតាមរយៈការពិភាក្សាដូចបានរៀបរាប់ខាងដើម។ មិនតែប៉ុណ្ណោះ ដំណើរការកំណត់ និងវិភាគអ្នកពាក់ព័ន្ធនៅក្នុងសិក្ខាសាលាថ្នាក់ខេត្ត ចាប់ផ្តើមឡើងដោយផ្តោតលើលទ្ធផលដែលចង់បាន ហើយរិះរកយុទ្ធសាស្ត្រធ្វើយ៉ាងណាឲ្យទទួលបានលទ្ធផលនោះត្រឡប់មកវិញ បន្ទាប់មកគឺការផ្លាស់ប្តូរដែលត្រូវការ ស្របតាមយុទ្ធសាស្ត្រ និងការផ្លាស់ប្តូរនៃការអនុវត្ត ដែលត្រូវការក្នុងចំណោមអ្នកពាក់ព័ន្ធទាំងឡាយ។ ដូចនេះ សញ្ញាព្រួញបង្ហាញក្នុងតារាងទី១ នាំយើងពីចំណុចចុងបញ្ចប់ដែលយើងចង់បាន ទៅកាន់ចំណុចដែលត្រូវផ្លាស់ប្តូរជាមូលដ្ឋាន មិនមែនពីចំណុចដែលត្រូវផ្លាស់ប្តូរ ទៅកាន់ចំណុចទីបញ្ចប់ដែលយើងចង់បានទេ។

---

៥៣ ទស្សនវិស័យ និងយុទ្ធសាស្ត្ររបស់គណៈកម្មាធិការនេះមាននៅក្នុងតារាងទី ១។

តារាងទី ១៖ ម៉ាទ្រីកវិភាគ និងកំណត់អ្នកពាក់ព័ន្ធ ក្នុងការងារគ្រប់គ្រងធារាសាស្ត្រ និងផ្ទៃរងទឹកភ្លៀងនៅប្រទេសកម្ពុជា

| អ្នកពាក់ព័ន្ធ | ការផ្លាស់ប្តូរការអនុវត្ត | ការផ្លាស់ប្តូរចំណេះដឹង ជំនាញ ឬអត្តចរិត | គម្រោងយុទ្ធសាស្ត្រ សម្រាប់សម្រេចការផ្លាស់ប្តូរ ដែលចង់បាន | លទ្ធផលដែលចង់បាន |
|---|---|---|---|---|
| កសិករ ឬ ក្រុមកសិករ ប្រើប្រាស់ទឹក (កកបទ) | - អាន ឬស្វែងរកព័ត៌មាន ស្តីពីបរិមាណទឹក និង ទឹកដែលអាចមាន ទៅតាម ពេលវេលាក្នុងឆ្នាំនីមួយៗ<br>- អនុវត្តតាមបទបញ្ជាផ្ទៃក្នុង របស់ សកបទ<br>- បង្កើតប្រក្រតិទិនដាំដុះ<br>- រាយការណ៍បញ្ហាប្រើប្រាស់ ទឹកទៅថ្នាក់ដឹកនាំ កកបទ ឬ សកបទ។<br>- ជ្រើសរើសកសិករ ដែលមានឆន្ទៈខ្ពស់ ហើយ បោះឆ្នោតឲ្យធ្វើជាសមាជិក គណៈកម្មាធិការ សកបទ<br>- កសិករ និង កកបទ ត្រូវធ្វើការដាំដុះរបស់ខ្លួន ផ្អែកតាមការណែនាំ និង ព័ត៌មានដែលផ្តល់ដោយ មធទឧ និង មករន ស្តីពី បរិមាណទឹក និងទឹកដែល មាន ដើម្បីចៀសវាង កង្វះខាត ទឹកនៅរដូវប្រាំង | - យល់ដឹងពីអត្ថប្រយោជន៍ នៃប្រព័ន្ធធារាសាស្ត្រ<br>- យល់ដឹងអំពីបរិមាណ ទឹក ឬទឹកដែលមាន និង ផ្ទៃដីសម្រាប់ដាំដំណាំ<br>- យល់ដឹងពីតម្រូវការទឹក និងតំបន់ធារាសាស្ត្រ | - ចែករំលែកព័ត៌មានអំពី បរិមាណទឹកដែលមាន ដល់ សកបទ និងកសិករ ឯទៀត ឲ្យបានសមស្រប ទាន់ពេលវេលា | - ចែកចាយ និងប្រើ ប្រាស់ទឹកតាម បរិមាណ និងពេលវេលា សមស្របតាមឆ្នាំ ដើម្បី ទទួលបានទិន្នផល អតិបរមា |
| | - រួមចំណែកក្នុងដំណើរការ និង ការថែទាំប្រព័ន្ធធារាសាស្ត្រ<br>- ត្រូវផ្តល់ផ្នែកខ្លះនៃដីរបស់ខ្លួន សម្រាប់អភិវឌ្ឍប្រព័ន្ធ ទំនប់ប្រឡាយ ឬគិតក្នុង តម្លៃមួយសមស្រប និងអាច ទទួលយកបាន<br>- ត្រូវបង់ ថសទ ដូចមាន ចែង ក្នុងលក្ខន្តិក | - បង្កើនចំណេះដឹងផ្នែក ជលសាស្ត្រ និងប្រព័ន្ធ អាងទន្លេ ហើយនិងទំនាក់ ទំនងរវាងការប្រើប្រាស់ ទឹកផ្នែកខាងលើ និងខាង ក្រោមខ្សែទឹក<br>- បង្កើនការយល់ដឹងពីច្បាប់ បរិស្ថាន ច្បាប់ទឹក ច្បាប់ ជលផល និងគោល នយោបាយដទៃទៀត ពាក់ព័ន្ធនឹងការគ្រប់គ្រង ធនធានទឹក<br>- ប្រែទម្លាប់ឆ្ពោះទៅធ្វើ អ្វីមួយដែលផ្តល់ ផលប្រយោជន៍ដល់ សហគមន៍ | - បង្កើនស្មារតីរួម ហើយ ចែករំលែកប្រយោជន៍ ផ្ទាល់ខ្លួន ដើម្បីការពារ ទ្រព្យសម្បត្តិសហគមន៍ (ធនធានធម្មជាតិ និង ហេដ្ឋារចនាសម្ព័ន្ធ ជលសាស្ត្រ តាមរយៈការ ប្រាស្រ័យទាក់ទង ប្តូរ បទពិសោធន៍វិជ្ជមាន ជាមួយសហគមន៍ ដទៃទៀត<br>- គាំទ្រការដឹកនាំល្អនៅ កម្រិត សកបទ ដើម្បី បំផុសសហគមន៍ឲ្យគិតគូរ ថែទាំទ្រព្យសម្បត្តិរួម | - បែងចែកទឹកដល់អ្នក ប្រើប្រាស់ឯទៀត ដោយ ឈរលើគោលការណ៍ សមភាព |

| អ្នកពាក់ព័ន្ធ | ការផ្លាស់ប្តូរការអនុវត្ត | ការផ្លាស់ប្តូរចំណេះដឹង ជំនាញ ឬអត្តចរិត | គម្រោងយុទ្ធសាស្ត្រ សម្រាប់សម្រេចការផ្លាស់ប្តូរ ដែលចង់បាន | លទ្ធផលដែលចង់បាន |
|---|---|---|---|---|
| សកបទ | - លើកកម្ពស់ការធ្វើសេចក្តីសម្រេចចិត្តក្នុងការបែងចែកទឹក<br>- មានឆន្ទៈខ្ពស់ហើយចូលរួមចំណែកស្តារ និងអភិវឌ្ឍន៍ ហើយនិងដំណើរការ និងថែទាំប្រព័ន្ធធារាសាស្ត្រ | - បង្កើនចំណេះដឹងពីបរិមាណទឹកដែលមាន និងផ្ទៃដីដាំដុះ<br>- បរិមាណទឹកត្រូវការចាំបាច់ និងផ្ទៃដីស្រោចស្រពដែលមាន | - ធ្វើការកត់ត្រា និងសារពើភ័ណ្ឌម្ចាស់ដីស្រែ<br>- កសាងទិន្នន័យស្តីពីប្រព័ន្ធប្រឡាយ និងទិន្នន័យម្ចាស់ដីស្រែ | - បែងចែកទឹកឲ្យទាន់ពេលវេលាឲ្យដល់ទីកន្លែង និងដល់កសិករដែលត្រូវការចាំបាច់ ដើម្បីទទួលបានទិន្នផលខ្ពស់ និងដើម្បីទទួលបាននូវទំនុកចិត្តពីកសិករថែមទៀត និងដែលអាចបង្កើតបានគណនេយ្យភាពជាមួយកសិករ |
| | - សកបទ ត្រូវប្រមូលថសទ ឲ្យបានកាន់តែច្រើន ហើយដំណើរការ និងថែទាំប្រព័ន្ធឲ្យសមស្របទៅនឹងផែនការដែលបានព្រមព្រៀង។ | - សកបទ ត្រូវលើកកម្ពស់ការយល់ដឹងពីថវិកា និងចំណេះដឹងគ្រឹះផ្នែកគណនេយ្យ | - ធ្វើផែនការកម្រិត សកបទ ដើម្បីធានានូវការប្រមូលថសទ<br>- បង្កើតការងារសម្រាប់ដំណើរការ និងថែទាំប្រព័ន្ធនៅថ្នាក់ សកបទ<br>- រក្សាឲ្យបាននូវកិច្ចសហការជាមួយ អម និងមន្ទីរពាក់ព័ន្ធជុំវិញខេត្ត | - ធានាឲ្យបានគ្រប់គ្រាន់នូវថវិកាសម្រាប់ប្រត្តិបត្តិ និងទុកសម្រាប់ដំណើរការចាំបាច់ ដើម្បីគាំទ្រដល់និរន្តរភាពនៃប្រព័ន្ធធារាសាស្ត្រ |
| | - អនុវត្តជំនាញ និងចំណេះដឹងដែលទទួលបានពីការដាំដុះប្រចាំថ្ងៃ<br>- ដោះស្រាយជម្លោះបង្កឡើងដោយការប្រើប្រាស់ទឹក | - បង្កើនការយល់ដឹងពីរបៀបអនុវត្តជំនាញតាមបែបប្រពៃណីក្នុងការគ្រប់គ្រងទឹក និងបែងចែកទឹកដែលអាចជួយបំពេញឲ្យការអនុវត្ត គគធទច និង គធកក ប្រព្រឹត្តិទៅបានល្អ<br>- មានលទ្ធភាពដើម្បីបង្កើតប្រក្រតិទិនដាំដុះ<br>- មានលទ្ធភាព និងជំនាញ ក្នុងការដោះស្រាយជម្លោះកើតចេញពីការប្រើប្រាស់ទឹក | - បង្កើនកាលានុវត្តភាព និងមធ្យោបាយដើម្បីទទួលបានការបណ្តុះបណ្តាលពី NGOs មធទឧ និង អមផ្នែកជលសាស្ត្រ គគធទច គធកក និងធ្វើការជាមួយសហគមន៍ដើម្បីបង្កើតយុទ្ធសាស្ត្រថ្នាក់មូលដ្ឋាន និងបង្ហាញថាតើក្របខ័ណ្ឌការងារដ៏ធំទូលំទូលាយនេះ អាចយកទៅអនុវត្តនៅថ្នាក់មូលដ្ឋានដោយវិធីណា<br>- ធ្វើការប្រជុំជាទៀងទាត់ជាមួយគណៈកម្មាធិការទ្រទ្រង់ដើម្បីគ្រប់គ្រងធនធានទឹក។ | - មានសមត្ថភាពខ្ពស់ក្នុងដំណើរការក្រោមក្របខ័ណ្ឌ គគធទច និង គធកក ដើម្បីដោះស្រាយបញ្ហានានា ដែលកើតចេញពីការប្រើប្រាស់ទឹកប្រកបដោយសន្តិវិធី។ |

| អ្នកពាក់ព័ន្ធ | ការផ្លាស់ប្តូរការអនុវត្ត | ការផ្លាស់ប្តូរចំណេះដឹង ជំនាញ ឬអត្តចរិត | គម្រោងយុទ្ធសាស្ត្រសម្រាប់សម្រេចការផ្លាស់ប្តូរដែលចង់បាន | លទ្ធផលដែលចង់បាន |
|---|---|---|---|---|
| ថ្នាក់ក្រោមជាតិ អម * និង ICMSC** | - រក្សាកិច្ចសហការល្អជាមួយ សកបទ NGOs និងបណ្តាមន្ទីរពាក់ព័ន្ធជុំវិញខេត្ត<br>- ធ្វើការកោះប្រជុំជាទៀងទាត់ ស្តីពីការគ្រប់គ្រងធនធានទឹក<br>- ផ្តល់ការបណ្តុះបណ្តាលជំនាញស្តីពីកសិកម្ម រដ្ឋបាល និងការធ្វើផែនការសម្រាប់ដឹកនាំមូលដ្ឋាន ហិរញ្ញវត្ថុ ទីផ្សារ និងការគ្រប់គ្រងគណនេយ្យ | - អភិវឌ្ឍន៍បច្ចេកទេសជំនាញ ស្តីពីជលសាស្ត្រ<br>- កិច្ចសហការ និងសម្របសម្រួលការលើកកម្ពស់ចំណេះដឹង<br>- ចំណេះដឹងអំពីតំបន់កសិកម្ម និងកម្លាំងពលកម្ម (កសិករ) | - គាំទ្រការបណ្តុះបណ្តាលបច្ចេកទេសក្នុងការបែងចែកទឹក និងការគ្រប់គ្រងធនធានទឹក<br>- ផ្សព្វផ្សាយព័ត៌មានស្តីពីគោលនយោបាយគ្រប់គ្រងធនធានទឹក និងផលប៉ះពាល់នៃការប្រើប្រាស់ទឹកមិនត្រឹមត្រូវឲ្យបានជាប្រចាំដល់កសិករ និងអ្នកប្រើប្រាស់ទឹកដទៃទៀត<br>- ផ្តល់ការបណ្តុះបណ្តាលជាប្រចាំនូវជំនាញស្តីពីជលសាស្ត្រ និងបញ្ហាពាក់ព័ន្ធនឹងការប្រើប្រាស់ទឹក<br>- រៀបចំគោលនយោបាយ ផែនការ និងយុទ្ធសាស្ត្របែងចែក និងគ្រប់គ្រងទឹក<br>- បង្កើតទិន្នន័យគោលស្តីពីធនធានទឹក និងការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងទឹកនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន | - បង្កើនសមត្ថភាពរបស់អនុគណៈកម្មាធិការ និងយន្តការសម្រាប់ដោះស្រាយជម្លោះ<br>- កសាងសមត្ថភាពក្នុងការគ្រប់គ្រង និងបែងចែកទឹក និងបង្កើនសមត្ថភាពបច្ចេកទេស និងផ្នែកជលសាស្ត្រ |
| | - ស្វែងរកថវិកាសម្រាប់អភិវឌ្ឍន៍ធារាសាស្ត្រ | - លើកកម្ពស់ចំណេះដឹង និងជំនាញផ្នែកជលសាស្ត្រ និងកសិកម្ម<br>- បង្កើនការប្រាស្រ័យទាក់ទង និងជំនាញក្នុងការគ្រប់គ្រងធនធានធម្មជាតិ | - ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់ សកបទ<br>- ផ្តល់បទដ្ឋានគតិយុត្តិ និងសេវាកម្មបច្ចេកទេស<br>- បង្កើនការទាក់ទងជាមួយទាយក NGOs និងបណ្តាស្ថាប័នពាក់ព័ន្ធ និងការងារគ្រប់គ្រងទឹក និងអភិវឌ្ឍន៍វិស័យធារាសាស្ត្រ | - ស្តារនីតិសម្បទា និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ |

* អភិបាលខេត្ត និងអភិបាលស្រុក និងក្រុមប្រឹក្សាឃុំ។

** គណៈកម្មាធិការ ឬអនុគណៈកម្មាធិការអន្តរៈស្រុក ដែលស្ថិតក្រោមគណៈបញ្ជាការ (ឬគណៈកម្មាធិការ) ខេត្ត។

| អ្នកពាក់ព័ន្ធ | ការផ្លាស់ប្តូរការអនុវត្ត | ការផ្លាស់ប្តូរចំណេះដឹង ជំនាញ ឬអត្តចរិត | គម្រោងយុទ្ធសាស្ត្រសម្រាប់សម្រេចការផ្លាស់ប្តូរដែលចង់បាន | លទ្ធផលដែលចង់បាន |
|---|---|---|---|---|
| ក្រធទឧ ក្រករន ក្រសហ*** មធទឧ មករន និងបណ្តាមន្ទីរពាក់ព័ន្ធជុំវិញខេត្ត | - បន្តកិច្ចសហការល្អជាមួយសកបទ NGOs និងមន្ទីរពាក់ព័ន្ធជុំវិញខេត្ត<br>- អភិបាលកិច្ចសហប្រត្តិបត្តិការអន្តរជាតិ<br>- សហការជាមួយរដ្ឋអំណាចថ្នាក់ក្រោមជាតិដើម្បីបង្កើតគណៈកម្មាធិការទ្រទ្រង់ដែលនឹងត្រូវបានតែងតាំងដោយអភិបាលខេត្ត<br>- រៀបការប្រជុំស្តីពីការងារគ្រប់គ្រងទឹកឲ្យបានទៀងទាត់ | - យល់ដឹងកាន់តែប្រសើរក្នុងការងារគ្រប់គ្រងធនធានទឹក កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | - ចូលរួមការរៀបចំគោលនយោបាយពាក់ព័ន្ធនឹងការគ្រប់គ្រងទឹក កសិកម្ម រុក្ខាប្រមាញ់ និងជលផល<br>- ផ្តល់ការប្រឹក្សាផ្នែកបច្ចេកទេស និងគាំទ្រផ្នែកហិរញ្ញវត្ថុ<br>- បង្កើត សកបទ | - បង្កើន និងលើកកម្ពស់កិច្ចសហការ និងបញ្ចូលផែនការ និងការគ្រប់គ្រងក្នុងចំណោមស្ថាប័នសំខាន់ៗ |
| | - ក្រធទឧ/រដ្ឋាភិបាលត្រូវផ្តល់សំណងសមស្របសម្រាប់ចំណែកក្បាលដីដែលត្រូវការសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ | - ចំណេះដឹងក្នុងការវិភាគផលប៉ះពាល់សង្គមបរិស្ថានក្នុងពេលអភិវឌ្ឍន៍ និងស្តារប្រព័ន្ធធារាសាស្ត្រ<br>- ចំណេះដឹងផ្នែកជលសាស្ត្រ និងដំណើរការ និងថែទាំប្រព័ន្ធធារាសាស្ត្រ<br>- បង្កើនការយល់ដឹងពីបច្ចេកទេសទំនើបដែលផ្តល់ទិន្នផលខ្ពស់<br>- ចំណេះដឹងពីពលកម្ម និងតម្រូវការទឹក ការជ្រើសរើសពូជ ការប្រើប្រាស់ដី ការរៀបចំដី និងការធ្វើផែនការប្រើប្រាស់ដីធ្លី | - ផ្តល់វគ្គបណ្តុះបណ្តាលជំនាញសំខាន់ៗ<br>- ស្រាវជ្រាវត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត និងរៀបចំការគ្រប់គ្រងនៅថ្នាក់មូលដ្ឋាន និងបង្កើតគោលនយោបាយគ្រប់គ្រងធនធានទឹកឲ្យបានសមស្រប<br>- បង្កើត និងគ្រប់គ្រងវិធានជំរុញការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងធនធានទឹកដែលពាក់ព័ន្ធ និងអ្នកប្រើប្រាស់គ្រប់កម្រិត អ្នកកសាងផែនការ និងអ្នករៀបចំគោលនយោបាយ<br>- ស្វែងរកថវិកា ដើម្បីអភិវឌ្ឍន៍ធារាសាស្ត្រ | - សាងសង់ប្រព័ន្ធធារាសាស្ត្រឲ្យបានសមស្រប និងគ្រប់គ្រងការបែងចែកទឹក<br>- មានភាពឯករាជ្យក្នុងការផ្សះផ្សា និងដោះស្រាយជម្លោះ<br>- ពង្រឹងការអនុវត្តច្បាប់ការត្រួតពិនិត្យ និងវាយតម្លៃការគ្រប់គ្រងទឹក<br>- ដោះស្រាយជម្លោះពាក់ព័ន្ធនឹងការប្រើប្រាស់ទឹក |

*** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

| អ្នកពាក់ព័ន្ធ | ការផ្លាស់ប្តូរការអនុវត្ត | ការផ្លាស់ប្តូរចំណេះដឹង ជំនាញ ឬអត្តចរិត | គម្រោងយុទ្ធសាស្ត្រសម្រាប់សម្រេចការផ្លាស់ប្តូរដែលចង់បាន | លទ្ធផលដែលចង់បាន |
|---|---|---|---|---|
| NGOs វិទ្យាស្ថានអប់រំ និងស្រាវជ្រាវ | - ផ្តល់ការបណ្តុះបណ្តាលដល់ សកបទ ស្តីពីរដ្ឋបាលមូលដ្ឋាន គជកក កសិកម្ម ប្រពលវប្បកម្ម និងការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត<br>- ផ្សព្វផ្សាយច្បាប់ទឹក ច្បាប់ ជលផល និងច្បាប់បរិស្ថានដល់កសិករ កកបទ និងសមាជិក សកបទ<br>- រៀបចំ និងត្រួតពិនិត្យលក្ខន្តិកៈរបស់ សកបទ<br>- ផ្តល់ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍន៍ និងស្តារប្រព័ន្ធធារាសាស្ត្រ | - បន្តអភិវឌ្ឍជំនាញគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ជំនាញ និងសមត្ថភាពជលសាស្ត្រ និងរដ្ឋបាល<br>- យល់ដឹងអំពីទឹក ជលផល បរិស្ថាន និងគោលនយោបាយនានាដែលពាក់ព័ន្ធនឹងធនធានទឹក | - ស្រាវជ្រាវ និងបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់ទឹក គគធទច គជកក និងអំពីកសិកម្ម ប្រពលវប្បកម្ម និងការគ្រប់គ្រងថ្នាំសម្លាប់សត្វល្អិតដល់ សកបទ<br>- ផ្តល់ ឬចែករំលែកបទពិសោធន៍ល្អៗដែលទទួលបានពី សកបទ គំរូ ដល់ សកបទ ឯទៀត<br>- បណ្តុះបណ្តាល និងផ្សព្វផ្សាយព័ត៌មានពីសារៈសំខាន់នៃការប្រើប្រាស់ទឹកដោយចីរភាព និងការអភិវឌ្ឍន៍ធនធានធម្មជាតិ និងការការពារបរិស្ថាន<br>- ធ្វើការស្រាវជ្រាវ និងករណី សិក្សានៅថ្នាក់មូលដ្ឋាន<br>- ជួយ សកបទ បង្កើតទិន្នន័យគោល និងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការប្រើប្រាស់ទឹក | - ផ្តល់ការស្រាវជ្រាវ និងការបណ្តុះបណ្តាលដែលផ្អែកតាមគំហើញនៃការស្រាវជ្រាវ និងអនុសាសន៍នានាសម្រាប់រៀបចំគោលនយោបាយអាទិភាព |
| អ្នកពាក់ព័ន្ធដទៃទៀត | - ផ្តល់សេវាកម្មច្បាប់ និងបច្ចេកទេស សម្រាប់ធ្វើសេចក្តីសម្រេចចិត្ត<br>- អនុម័តថវិកាជាតិ និងការរៀបចំផែនការ<br>- អនុម័តអនុសញ្ញាអន្តរជាតិ<br>- អភិវឌ្ឍន៍ច្បាប់ និងក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនានា<br>- ស្វែងរកមូលនិធិសម្រាប់អភិវឌ្ឍន៍ធារាសាស្ត្រ<br>- ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ | - ពហុជំនាញ និងវិជ្ជាជីវៈក្នុងវិស័យដែលពាក់ព័ន្ធនឹង ធនធានទឹក និងកសិកម្ម<br>- ជំនាញក្នុងការគ្រប់គ្រងការដឹកនាំ និងការធ្វើសេចក្តី សម្រេចចិត្ត<br>- ចំណេះដឹងក្នុងការបង្កើតគោលនយោបាយ យុទ្ធសាស្ត្រច្បាប់ និងបទដ្ឋានច្បាប់នានា | - ផ្តល់ការណែនាំក្នុងការអនុវត្តគោលនយោបាយពាក់ព័ន្ធ | - កែលម្អកិច្ចសហការជាមួយបណ្តាក្រសួងពាក់ព័ន្ធ<br>- បង្កើត/អនុម័តច្បាប់ និងក្របខ័ណ្ឌច្បាប់<br>- បន្តពង្រឹងការអនុវត្តច្បាប់ ការត្រួតពិនិត្យ និងវាយតម្លៃការគ្រប់គ្រងទឹក |

ប្រភព៖ ក្រុមអ្នកនិពន្ធ NRE/CDRI, 2010

# សេចក្តីសន្និដ្ឋាន

ទស្សនទានថ្មីនៃការគ្រប់គ្រងធនធានទឹក ដូចជា គោលនយោបាយគ្រប់គ្រងធនធានទឹកចម្រុះ PIMD និងគោលនយោបាយផ្ទេរការគ្រប់គ្រងធារាសាស្ត្រ និងការបង្កើត សកបទ ត្រូវអនុវត្តឲ្យបានសមស្រប និងប្រុងប្រយ័ត្ននៅថ្នាក់មូលដ្ឋាន ដោយយកចិត្តទុកដាក់ពិសេសលើលក្ខណៈគោលនយោបាយ វប្បធម៌ សេដ្ឋកិច្ចសង្គម និងលក្ខណៈរូបវន្ត ដែលមាននៅតំបន់នីមួយៗជាក់លាក់។ ទោះបីជារាជរដ្ឋាភិបាលកម្ពុជាខិតខំជំរុញការងារវិមជ្ឈការនៅថ្នាក់មូលដ្ឋានក្តី ក៏វិស័យអភិបាលកិច្ចធនធានទឹក នៅមានភាពយឺតយ៉ាវនៅឡើយ ហើយត្រូវការពេលវេលាបន្ថែមទៀត ដើម្បីឲ្យការងារនេះសម្រេចបានល្អតាមគោលដៅ។ នៅតំបន់ជាច្រើនជុំវិញអាងទន្លេសាប ប្រជាជន និងសហគមន៍មូលដ្ឋាន នៅបន្តពឹងផ្អែកលើកិច្ចសហការ ឬគាំទ្រពីរចនាសម្ព័ន្ធនយោបាយមូលដ្ឋាននៅឡើយ ដូចជា ក្រុមប្រឹក្សាឃុំ អភិបាលស្រុក និងមន្ទីរពាក់ព័ន្ធនានាជាដើម ដើម្បីធ្វើការសម្រេចចិត្តសំខាន់ៗ។ តែកិច្ចសហការរវាងមន្ទីរពាក់ព័ន្ធជុំវិញខេត្ត នៅមានកម្រិតនៅឡើយ ដែលនាំឲ្យប្រជាជន និងសហគមន៍មានការលំបាកនៅពេលទៅរកកិច្ចសហការគាំទ្រ។ ក្រុមកសិករប្រើប្រាស់ទឹកក៏បានទទួលស្គាល់ផងដែរថា នៅមានគម្លាត ការត្រួតស៊ីគ្នា និងកង្វះកិច្ចសហការនៅក្នុងកំណែទម្រង់រដ្ឋបាលសាធារណៈ ដែលតម្រូវឲ្យធ្វើការកែលម្អ។

នៅមានការងារជាច្រើនដែលត្រូវធ្វើបន្ត ពិសេសផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៃប្រព័ន្ធធារាសាស្ត្រដែលមានបច្ចុប្បន្ន។ ប្រព័ន្ធធារាសាស្ត្រ ពុំមានតម្លៃបច្ចេកទេស និងហិរញ្ញវត្ថុទេ ប្រសិនបើវាពុំអាចផ្តល់អត្ថប្រយោជន៍ពិតប្រាកដ និងទាន់ពេលវេលាដល់កសិករ។ ដូច្នេះស្ថាប័នទទួលខុសត្រូវ ត្រូវពង្រីកអត្ថប្រយោជន៍នៃធារាសាស្ត្រដល់កសិករឲ្យបានច្រើន ហើយការងារនេះអាចសម្រេចទៅបានតាមរយៈការបញ្ចូលគ្នានូវបច្ចេកវិទ្យាថ្មីនៃការគ្រប់គ្រងទឹក និងកសិកម្មប្រពលវប្បកម្ម។

វិធីសាស្ត្រក្នុងការប្រមូលថ្លៃសេវាកម្មប្រើប្រាស់ទឹក បច្ចុប្បន្ន (ដូចជា ការបង់តាមកាតព្វកិច្ច ស្ម័គ្រចិត្ត ឬការបង់នៅពេលមានករណីបន្ទាន់) មិនបានបង្កនូវភាពមន្ទិលដែលថា វានឹងមិនប៉ះពាល់ដល់ប្រសិទ្ធភាពនៃដំណើរប្រត្តិបត្តិការរបស់ សកបទ នោះទេ។ ការឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស និងការកសាងសមត្ថភាពក្នុងការទទួលយកនូវការគ្រប់គ្រងធារាសាស្ត្រភាគច្រើននៅមានភាពយឺតយ៉ាវ ម៉្យាងទៀត សកបទ ក៏នៅមានកម្រិតក្នុងការយល់ដឹងអំពីការងារទាក់ទងនឹងការគ្រប់គ្រងធារាសាស្ត្រ ឬក៏កសិកម្មប្រពលវប្បកម្មនៅឡើយ។ វគ្គបណ្តុះបណ្តាលផ្នែកជលសាស្ត្រ ហិរញ្ញវត្ថុ និងជំនាញសមស្របផ្សេងៗទៀតដែលពាក់ព័ន្ធធនធានទឹក កសិកម្ម និងការគាំទ្រផ្នែកហិរញ្ញវត្ថុគ្រប់គ្រាន់ ត្រូវតែរៀបចំគ្រោងឡើង ដើម្បីលើកកម្ពស់ការអនុវត្តរបស់ សកបទ ក្នុងការគ្រប់គ្រងធនធានទឹក។

ក្នុងខណៈដែលអនុក្រឹត្យសំខាន់ៗមួយចំនួន ដូចជា អនុក្រឹត្យស្តីពី សកបទ អនុក្រឹត្យស្តីពីការគ្រប់គ្រងអាងទន្លេ និងអនុក្រឹត្យស្តីពីការចែកចាយ និងការផ្តល់អាជ្ញាប័ណ្ណទឹកដែលកំពុងព្រាងនៅឡើយ ស្ថាប័ន ឬអ្នកពាក់ព័ន្ធទាំងឡាយ គួរបង្កើតយន្តការសហការមួយសមស្របដើម្បីគ្រប់គ្រងធនធានទឹក ដោយផ្អែកលើក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ ដែលក្នុងកម្រិតណាមួយនោះ បានចែងអំពីអាណត្តិ និងតំបន់ដែលស្ថិតនៅក្រោមការទទួលខុសត្រូវនៃស្ថាប័នពាក់ព័ន្ធទាំងនោះ។ អន្តរាគមន៍របស់ស្ថាប័ន ដែលផ្អែកលើផលប្រយោជន៍បុគ្គល ឬកេរ្តិ៍ឈ្មោះ ស្ថាប័នពុំអាចជួយកែលម្អការបែងចែកទឹក និងការប្រត្តិបត្តិរបស់ សកបទ បានទេ ផ្ទុយទៅវិញវាអាចនឹងនាំឲ្យយន្តការគ្រប់គ្រងធនធានទឹកពុំមានប្រសិទ្ធភាព មានការត្រួតស៊ីគ្នានៃតួនាទី និងការទទួលខុសត្រូវនៃស្ថាប័នពាក់ព័ន្ធ ហើយនិងជម្លោះរវាងក្រុម ឬសហគមន៍អ្នកប្រើប្រាស់ទឹកតែប៉ុណ្ណោះ។

ទន្ទឹមនេះ សកម្មភាពកែលម្អមួយចំនួន គួរតែអនុវត្តឡើងដើម្បីដោះស្រាយបញ្ហានៃការអនុវត្តដែលមិនស៊ីចង្វាក់គ្នារវាងអ្នកពាក់ព័ន្ធសំខាន់ៗនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដូចជា ក្រសួងធនធានទឹក មន្ទីរធនធានទឹក មន្ទីរជំនាញជុំវិញខេត្ត អាជ្ញាធរមូលដ្ឋាន និង សកបទ គឺតាមរយៈការបង្កើតឡើងនូវអង្គការគ្រប់គ្រងអាងទន្លេ ឬអនុគណៈកម្មាធិការគ្រប់គ្រងអាងទន្លេ ដូចដែលបានស្នើឡើងខាងលើ និងតាមរយៈសកម្មភាពមួយចំនួនដែលបានលើកឡើងជាអនុសាសន៍ ដូចមានពិពណ៌នានៅផ្នែកខាងក្រោម។

គំហើញនៃការស្រាវជ្រាវ នាំឲ្យយើងអាចសន្និដ្ឋានបានថា ត្រូវមានរចនាសម្ព័ន្ធមួយចំនួនដើម្បីកែលម្អកិច្ចសហការកម្រិតអាងទន្លេ ឬកម្រិតខេត្ត ដែលអាចបង្កើននូវបច្ចេកទេសជំនាញដើម្បីជួយដល់ សកបទ បណ្តាស្ថាប័នរដ្ឋាភិបាល និងក្រុមអ្នកពាក់ព័ន្ធឯទៀត ដោយមិនបានផ្តាច់ចេញនូវអំណាចរបស់ពួកគេក្នុងការធ្វើសេចក្តីសម្រេចលើធនធានរបស់ពួកគេឡើយ។ ផ្អែកលើមូលដ្ឋាននៃការឆ្លើយតបរបស់អ្នកពាក់ព័ន្ធ ការស្រាវជ្រាវនេះ ក៏បានស្នើឲ្យមានរចនាសម្ព័ន្ធថ្មីមួយ គឺការបង្កើតអនុគណៈ

កម្មាធិការគ្រប់គ្រងធារាសាស្ត្រ និងអាងទន្លេ (ICMS) ដើម្បីគ្រប់គ្រងធនធានទឹកនៅថ្នាក់ក្រោមជាតិ។ អនុគណៈកម្មាធិការនេះ អាចមានទម្រង់ផ្សេងៗគ្នា ផ្អែកតាមភូមិសាស្ត្រជាក់ស្តែង។

ដើម្បីជាជំនួយដល់ការពិភាក្សា អនុសាសន៍ខាងក្រោមបានបកស្រាយពីគោលបំណង និងមុខងាររបស់អនុគណៈកម្មាធិការ ដោយកំណត់ពីជម្រើសមួយចំនួន និងការពិចារណាសំខាន់ៗ សម្រាប់បង្កើតអនុគណៈកម្មាធិការនេះ។ គោលបំណងចម្បងនៃគំនិតពិចារណាទាំងនេះ គឺដើម្បីធានាឲ្យបានថា បទពិសោធន៍ពីអតីតកាលបានជួយដល់ការអភិវឌ្ឍរចនាសម្ព័ន្ធថ្មី ហើយកំណែប្រែថ្មី នឹងជួយគាំទ្ររចនាសម្ព័ន្ធដែលមាន និងមិនបង្កបង្កើតឲ្យមានភាពត្រួតស៊ីគ្នានៃតួនាទី និងជាជំនួយសម្រាប់កិច្ចពិភាក្សាដើម្បីឈានដល់ការយល់ស្របគ្នា (Consensus) លើបញ្ហាថាតើ អនុគណៈកម្មាធិការនេះមាន អាណត្តិកម្រិតណា និងតើគួររក្សាតម្លាភាពយ៉ាងណាដើម្បីកុំឲ្យប៉ះពាល់ដល់តួនាទី និងអំណាចដ៏សំខាន់នៅមូលដ្ឋានរបស់ សកបទ ដែលទើបបង្កើតថ្មី។

អនុសាសន៍នៃគោលនយោបាយទាំងនេះ បានលើកយកមកពិភាក្សានៅក្នុងសិក្ខាសាលាពិគ្រោះយោបល់នៅកម្រិតសហគមន៍បន្ទាប់មកទើបដាក់ឆ្លងសិក្ខាសាលាថ្នាក់ខេត្តដែលមានការចូលរួមពី សកបទ និងមន្ទីរធនធានទឹក។ សិក្ខាសាលាទាំងនេះ ធ្វើឡើងក្នុងគោលបំណងដោះស្រាយបញ្ហាសំខាន់ៗទាក់ទងនឹងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងគោលនយោបាយគ្រប់គ្រងធនធានទឹកចម្រុះ ដែលកំណត់បានតាមរយៈការវិភាគអ្នកពាក់ព័ន្ធទាំងអស់។

## អនុសាសន៍ទី ១៖ គួរបង្កើតអនុគណៈកម្មាធិការគ្រប់គ្រងធារាសាស្ត្រ និងអាងទន្លេ (អកធអ)

គួរពិចារណាបង្កើត ICMS នៅថ្នាក់ក្រោមជាតិ ដើម្បីជួយជំរុញកិច្ចសហការរវាង សកបទ មន្ទីរពាក់ព័ន្ធខេត្ត និងអាជ្ញាធរមូលដ្ឋាន ក្នុងការធ្វើសេចក្តីសម្រេចលើការងារសមាហរណកម្មផែនការ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹកក្នុងកម្រិតអាងទន្លេ។ អនុគណៈកម្មាធិការនេះ នឹងជួយបង្កើនការយល់ដឹងទូទៅអំពី PIMD និងគោលនយោបាយគ្រប់គ្រងធនធានទឹកចម្រុះ ក្នុងចំណោម សកបទ អាជ្ញាធរមូលដ្ឋាន និងមន្ទីរពាក់ព័ន្ធខេត្ត ក៏ដូចជាជួយគាំទ្រដល់ការធ្វើសមាហរណកម្មនៃបណ្តាសហគមន៍នៅប៉ែកខាងលើ និងខាងក្រោមខ្សែទឹក ហើយនិងដឹកនាំសហគមន៍ទាំងនោះ ឲ្យជួយផ្តល់នូវធនធានចាំបាច់សម្រាប់ជាមធ្យោបាយដល់ការកសាងរចនាសម្ព័ន្ធអភិបាលកិច្ច នៅក្នុងគោលនយោបាយគ្រប់គ្រងអាងទន្លេរបស់រាជរដ្ឋាភិបាលកម្ពុជាថែមទៀតផង។

### *មុខងាររបស់ អកធអ*

- លើកកម្ពស់ដំណើរការ "ពីក្រោមទៅលើ" នៃគម្រោងអភិវឌ្ឍន៍ និងគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រខ្នាតតូច មធ្យម និងធំ ក្នុងបរិបទអាងទន្លេ ដោយគិតគូរដល់គោលការណ៍គ្រឹះរបស់គោលនយោបាយគ្រប់គ្រងធនធានទឹកចម្រុះ ផលប្រយោជន៍អ្នកពាក់ព័ន្ធទាំងអស់ និងនិរន្តរភាពនៃធនធានធម្មជាតិ។
- រួមសហការជាមួយស្ថាប័នពាក់ព័ន្ធ ដូចជា ក្រសួងធនធានទឹក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរធនធានទឹក មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គការសង្គមស៊ីវិល អភិបាលខេត្ត អាជ្ញាធរមូលដ្ឋាន រាជបណ្ឌិតសភា និង មជ្ឈមណ្ឌលស្រាវជ្រាវ ដូចជា វិទ្យាស្ថាន CDRI វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យអន្តរជាតិ និងទាយក ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ភ្នាក់ងារអភិវឌ្ឍន៍បារាំង ធនាគារពិភពលោក ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ដើម្បីស្វែងរកជំនួយគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ។
- ផ្តល់ទីកន្លែងដើម្បីផ្លាស់ប្តូរជំនាញបច្ចេកទេសបន្ថែម រួមមានការផ្តល់ប្រឹក្សាជំនាញផ្សេងៗ ជាមួយមន្ទីរពាក់ព័ន្ធខេត្ត NGOs ទាយក និងជំនាញការអន្តរជាតិ ក្នុងការងារជលសាស្ត្រ និងការគ្រប់គ្រងធនធានទឹកចម្រុះ ដើម្បីឲ្យអនុគណៈកម្មាធិការអាចបំពេញមុខងារជាមជ្ឈមណ្ឌលផ្តល់សេវាកម្មដល់ សកបទ។
- ផ្តល់ជាវេទិកាដើម្បីរៀអង្គាសថវិកា និងផ្តល់ប្រឹក្សាផ្តល់ដោយ NGOs និងទាយក។
- ផ្តល់កាលានុវត្តភាពសម្រាប់ដោះស្រាយជម្លោះពីប្រព័ន្ធធារាសាស្ត្រមួយទៅមួយ និងសម្រាប់ សកបទ រួមគ្នាធ្វើផែនការដាំដុះរបស់ពួកគេ តាមរយៈព័ត៌មានចាំបាច់ស្របទៅតាមចំណេះដឹងផ្នែកសង្គម និងជលសាស្ត្រ។

- ត្រួតពិនិត្យ និងវាយតំលៃផលប៉ះពាល់ និងការងារផ្សេងៗពាក់ព័ន្ធនឹងធនធានទឹក នយោបាយទឹក និងប្រសិទ្ធភាពនៃសមភាពរបស់អនុគណៈកម្មាធិការ ដោយប្រើវិធីសាស្ត្រវាយតម្លៃដោយមានការចូលរួម។

### *បញ្ហាគួរពិនិត្យពិចារណា*

ក្នុងការកំណត់រចនាសម្ព័ន្ធអភិបាលកិច្ចនៃ ICMS គួរពិចារណាអំពីបញ្ហាមួយចំនួនដូចខាងក្រោម៖

- *ស្ថាប័នដឹកនាំ និងសមាជិកអនុគណៈកម្មាធិការ៖* ការកំណត់ស្ថាប័នរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ និងសមស្រប ដើម្បីដឹកនាំអនុគណៈកម្មាធិការ មានសារៈសំខាន់ណាស់។ បញ្ហានេះរួមមាន ការកំណត់ថាតើអនុគណៈកម្មាធិការនេះត្រូវស្ថិតក្រោមការដឹកនាំរបស់ថ្នាក់គ្រប់គ្រងខេត្ត ឬថ្នាក់អាងទន្លេ? ហើយតើស្ថាប័នរដ្ឋាភិបាលណាខ្លះដែលត្រូវធ្វើជាប្រធានអនុគណៈកម្មាធិការនេះ ឬមួយខុទ្ទកាល័យខេត្ត គួរត្រូវដឹកនាំការងារនេះដោយផ្អែកលើគោលនយោបាយថ្នាក់ជាតិរបស់រាជរដ្ឋាភិបាលស្តីពីការគ្រប់គ្រងធនធានទឹកចម្រុះ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ?
- *អាណត្តិ និងសមត្ថកិច្ច៖* អនុគណៈកម្មាធិការនេះ ត្រូវមានអាណត្តិពេញលេញ មានប្រសិទ្ធភាព និងតម្លាភាព និងមិនប៉ះពាល់ដល់អំណាចនៃការសម្រេចចិត្តរបស់ សកបទ និងស្ថាប័នពាក់ព័ន្ធដទៃ។ យន្តការសម្រាប់ផ្តល់គណនេយ្យភាពដល់រដ្ឋបាលថ្នាក់ក្រោម មានសារៈសំខាន់ណាស់ដើម្បីធ្វើឲ្យ សកបទ បំពេញតួនាទីជាតំណាងសហគមន៍ពិតប្រាកដ និងអាចទទួលជំនួយបច្ចេកទេស និងថវិកា តាមរយៈអនុគណៈកម្មាធិការនេះ។ សកបទ ត្រូវរាយការណ៍ទៅអនុគណៈកម្មាធិការ ដើម្បីអនុវត្តសមត្ថកិច្ចរបស់ខ្លួនក្នុងករណីចរចា កាត់ក្តី និងសហការជាមួយបណ្តា សកបទ ពាក់ព័ន្ធ។ ជាការចាំបាច់ អនុគណៈកម្មាធិការនេះ ត្រូវមានតួនាទីជាអ្នកផ្តល់ប្រឹក្សា ច្រើនជាងមានសមត្ថកិច្ចលើការសម្រេចលើការងារបែងចែកទឹកនៅកម្រិតប្រព័ន្ធធារាសាស្ត្រ ឬកម្រិតអាងទន្លេ ដើម្បីទុកឲ្យសហគមន៍មូលដ្ឋាន នៅមានតួនាទីសំខាន់ក្នុងការត្រួតពិនិត្យការសម្រេចចិត្តលើបញ្ហាសំខាន់ៗ[៥៤]។
- *ភាពខុសប្លែកគ្នារវាងអាងទន្លេ និងប្រព័ន្ធធារាសាស្ត្រ៖* ការបង្កើតឲ្យមានអនុគណៈកម្មាធិការនៅថ្នាក់ខេត្ត ឬថ្នាក់អាងទន្លេ បានផ្តល់នូវរចនាសម្ព័ន្ធដឹកនាំក្នុងបរិបទមួយជាក់លាក់ ដែលក្នុងនោះសមត្ថកិច្ចអាចក្លាយជាកម្លាំងក្នុងការធ្វើសេចក្តីសម្រេចលើការងារគ្រប់គ្រងទឹក និងធារាសាស្ត្ររបស់ សកបទ អាជ្ញាធរមូលដ្ឋាន និងមន្ទីរជុំវិញខេត្ត។ អនុគណៈកម្មាធិការនេះ អាចមានទម្រង់ និងរចនាសម្ព័ន្ធដឹកនាំផ្សេងៗគ្នានៅតាមតំបន់នីមួយៗ ដោយផ្អែកលើលក្ខណៈធម្មជាតិនៃអាងទន្លេ និងកម្រិតសមត្ថភាពអ្នកពាក់ព័ន្ធ។ ICMS នេះ គួរត្រូវបានរៀបចំឡើងសម្រាប់អាងទន្លេមួយជាក់លាក់ ដោយផ្អែកលើកត្តាថាតើ ICMS នេះ មានតួនាទីស្របគ្នានឹងសមត្ថកិច្ចនៃរដ្ឋបាលខេត្តក្នុងកម្រិតណា?
- *ការពិគ្រោះយោបល់បន្ថែមជាមួយអ្នកពាក់ព័ន្ធ៖* អនុគណៈកម្មាធិការគួរត្រូវបានបង្កើតឡើង បន្ទាប់ពីមានការសិក្សា ឬការពិគ្រោះយោបល់រួមគ្នា។ អនុគណៈកម្មាធិការនេះ មិនគួរត្រូវបានបង្កើតសម្រាប់ជា "ខែលការពារ" ដោយពុំមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធទេ។ ដំណើរការបង្កើតអនុគណៈកម្មាធិការនេះ ត្រូវមានការសម្របសម្រួលគ្នារវាងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីឲ្យអនុគណៈកម្មាធិការទទួលបានជោគជ័យ។

---

៥៤ អ្នកពាក់ព័ន្ធគាំទ្រការស្នើបង្កើតអនុគណៈកម្មាធិការថ្មី ដើម្បីគ្រប់គ្រងធនធានទឹកកម្រិតអាងផ្ទៃរងទឹកភ្លៀងរួមមាន កសិករ សកបទ អាជ្ញាធរមូលដ្ឋាន (ប្រធានភូមិ/ឃុំ អភិបាលស្រុក មន្ត្រីខេត្ត និងអភិបាលរងខេត្ត) ស្ថាប័នរដ្ឋាភិបាល និង NGOs ដែលចូលរួមក្នុងសិក្ខាសាលាថ្នាក់ខេត្ត ដែលរៀបចំឡើងនៅខេត្តកំពង់ឆ្នាំង កំពង់ធំ និងពោធិ៍សាត់ កាលពីខែកុម្ភៈ ដល់ ខែមេសា ឆ្នាំ២០១០។

## អនុសាសន៍ទី ២៖ ការអប់រំបណ្តុះបណ្តាល

ត្រូវយកចិត្តទុកដាក់បណ្តុះបណ្តាលអ្នកពាក់ព័ន្ធនៅមូលដ្ឋាន ពិសេសមន្ត្រីមន្ទីរធនធានទឹក ក្រុមប្រឹក្សាឃុំ/សង្កាត់ កសិករ និងសមាជិកគណៈកម្មាធិការ សកបទ អំពីគោលនយោបាយ និងច្បាប់សំខាន់ៗ ដើម្បីឲ្យគាត់បានយល់ដឹងពីសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគាត់ក្នុងការប្រើប្រាស់ធនធានធម្មជាតិ។ វគ្គបណ្តុះបណ្តាលគួរផ្តោតលើមុខវិជ្ជាដូចខាងក្រោម៖

- ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ព្រៃឈើ ជលផល ដីធ្លី និងបរិស្ថាន
- គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និង PIMD
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល[៥៥] (Organic Law)
- គោលការណ៍ណែនាំ និងបទដ្ឋាន ស្តីពីច្បាប់រដ្ឋបាល

## អនុសាសន៍ទី ៣៖ កសាងសមត្ថភាពគ្រប់គ្រង និងដឹកនាំនៅមូលដ្ឋាន

កសាងសមត្ថភាពគណៈកម្មាធិការ សកបទ និងក្រុមប្រឹក្សាឃុំ/សង្កាត់ ដើម្បីគ្រប់គ្រងធនធានទឹកឲ្យបានត្រឹមត្រូវ និងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដឹកនាំសហគមន៍បានល្អ ពិសេសសមត្ថភាពជំនាញដែលពាក់ព័ន្ធនឹង៖

- ការដឹកនាំ សម្របសម្រួល និងទំនាក់ទំនង
- ការបែងចែកថវិកា និងគ្រប់គ្រងហិរញ្ញវត្ថុ
- ការគ្រប់គ្រងធនធានធម្មជាតិ
- គ្រប់គ្រង និងអភិវឌ្ឍន៍គម្រោង
- ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ និងដំណាំកសិកម្ម

## អនុសាសន៍ទី ៤៖ លើកកម្ពស់គណនេយ្យភាព សកបទ

លើកកម្ពស់គណនេយ្យភាព សកបទ និងអាជ្ញាធរមូលដ្ឋាន តាមរយៈកិច្ចសហការរឹងមាំពីសំណាក់អ្នកពាក់ព័ន្ធ។ គណៈកម្មាធិការ សកបទ ត្រូវអនុវត្តការងាររបស់ខ្លួនស្របតាមតួនាទី និងកាតព្វកិច្ចដែលមានចែងក្នុងលក្ខន្តិក ដោយទទួលស្គាល់ថា ជំនួយឧបត្ថម្ភផ្នែកថវិកាមានកម្រិត។ បញ្ហាដែលត្រូវយកចិត្តទុកដាក់រួមមាន៖

- លើកទឹកចិត្តកសិករឲ្យយល់ដឹងពីសារៈសំខាន់នៃថ្លៃសេវាកម្មប្រើប្រាស់ទឹក ហើយចូលរួមដោយសាទរក្នុងដំណើរការ និងការថែទាំ (ជនថ) ប្រព័ន្ធធារាសាស្ត្រប្រកបដោយនិរន្តរភាព។
- ផ្សព្វផ្សាយ និងបំផុសកសិករឲ្យចូលរួមក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ធារាសាស្ត្រ តាំងពីដំណាក់កាលដំបូង និងដំណាក់បន្តបន្ទាប់នៃគម្រោង។
- ធ្វើឲ្យប្រព័ន្ធធារាសាស្ត្រផ្តល់ប្រយោជន៍ដល់កសិករកាន់តែច្រើនឡើងៗ ដោយរិះរកបច្ចេកទេសថ្មីៗ និងសមស្របសម្រាប់គ្រប់គ្រងទឹក និងស្វែងរកបច្ចេកទេសកសិកម្ម ប្រពលវប្បកម្មល្អៗ ដើម្បីឲ្យកសិករទទួលបានផល និងចំណូលកាន់តែច្រើន។
- ផ្តល់ទឹក និងព័ត៌មានកសិកម្មទាន់ពេលវេលាដល់កសិករ និងជំរុញពួកគាត់ឲ្យមានស្មារតីស្រលាញ់ទ្រព្យសម្បត្តិសាធារណៈ។

---

[៥៥] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ រាជរដ្ឋាភិបាល ឆ្នាំ២០០៨។

***បញ្ហាគួរពិនិត្យពិចារណា***

សកបទ ខ្លះបានលើកឡើងថា បើហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ និងសមត្ថភាពគ្រប់គ្រងរបស់ សកបទ មិនទាន់លើកកម្ពស់ឲ្យបានសមស្របតាមការរំពឹងចង់បានរបស់កសិករ ដែលចង់បានទឹកគ្រប់គ្រាន់ពីប្រព័ន្ធធារាសាស្ត្រទេ នោះការបង្កើនគណនេយ្យភាព សកបទ ការអនុវត្តតាមគោលនយោបាយគ្រប់គ្រងធនធានទឹកខាងលើ និងការចូលរួមរបស់អ្នកពាក់ព័ន្ធ នឹងជួបការលំបាក។

## អនុសាសន៍ទី ៥៖ ពង្រីកកិច្ចសហការឲ្យបានរឹងមាំនៅតំបន់អាងទន្លេសាប

ការធ្វើវិមជ្ឈការនៃការគ្រប់គ្រងធនធានទឹក នឹងមិនអាចសម្រេចបានទេ ប្រសិនបើអ្នកពាក់ព័ន្ធទាំងអស់ ពិសេសកសិករ មិនបានយល់ច្បាស់ និងមិនចូលរួមការពារ និងថែទាំទ្រព្យសម្បត្តិរួម។ បញ្ហាសំខាន់មួយចំនួនដែលអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធនៅជុំវិញអាងទន្លេសាប គួរគិតគូរពិចារណារួមមាន៖

- ចែករំលែកការយល់ដឹង អំពីគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ និងការគ្រប់គ្រងធារាសាស្ត្រដោយមានការចូលរួម និងកិច្ចអភិវឌ្ឍន៍ ដល់អ្នកពាក់ព័ន្ធទាំងអស់ ដើម្បីឲ្យពួកគេបានយល់ដឹងច្បាស់។
- ធ្វើប្រតិភូកម្មការទទួលខុសត្រូវក្នុងកម្រិតមួយសមស្រប ដូចជា ការធ្វើផែនការ ការអនុវត្ត ការគ្រប់គ្រង ការធ្វើសេចក្តីសម្រេចក្នុងការងារគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹក ដល់សហគមន៍មូលដ្ឋាន សកបទ អង្គការសង្គមស៊ីវិល វិស័យឯកជន។ល។ ដើម្បីបង្កើនការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន។
- ចែករំលែកថវិកាសម្រាប់ដំណើរការប្រតិបត្តិ និងកិច្ចការរដ្ឋបាល ដើម្បីគាំទ្រសហគមន៍មូលដ្ឋាន រួមមាន ផ្នែកគណនេយ្យភាព និងហិរញ្ញវត្ថុ/សហប្រត្តិការហិរញ្ញវត្ថុ។
- ធ្វើកំណែទម្រង់ និងលើកកម្ពស់ការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងកម្រិតអាងទន្លេសាប ដើម្បីឲ្យមានសមាជិកចូលរួមច្រើនជាងសមាជិករបស់អនុគណៈកម្មាធិការ ដោយបង្កើនកិច្ចសហការល្អរវាងសហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិល វិស័យឯកជន និងមន្ទីរពាក់ព័ន្ធជុំវិញខេត្ត ហើយកំណត់បញ្ហាអាទិភាព និងបញ្ហាបន្ទាន់ ដើម្បីយកមកដោះស្រាយ ឲ្យបានសមស្រប និងទាន់ពេលវេលា ។

## អនុសាសន៍ទី ៦៖ ការស្រាវជ្រាវបន្ថែម

ករណីសិក្សា និងសិក្ខាសាលាថ្នាក់ខេត្ត ដែលធ្វើឡើងនៅបណ្តាខេត្តទាំងបី បានបង្ហាញឲ្យឃើញថា ការបញ្ចូលសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ទៅក្នុងរចនាសម្ព័ន្ធ សកបទ ( ជាសមាជិកគណៈកម្មាធិការ សកបទ ) អាចជួយរក្សាមុខងារច្បាប់ និងការប្រត្តិបត្តិរបស់ សកបទ បានល្អ។ អ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានមួយចំនួនបានលើកឡើងថា ការធ្វើសមាហរណកម្មនេះ នឹងបង្កើនតួនាទី និងគណនេយ្យភាពរបស់គណៈកម្មាធិការ សកបទ តាមរយៈ៖

- ការពង្រឹងអំណាច សកបទ ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ។
- កិច្ចសហការ និងសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ។
- ការលើកកម្ពស់ការចែករំលែកព័ត៌មានស្តីអំពី គោលនយោបាយទឹក និងកសិកម្ម។
- ការកែលម្អគុណភាព និងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងផែនការ លើគ្រប់គម្រោងអភិវឌ្ឍន៍ និងវិនិយោគ។
- ការកាត់បន្ថយទំនាស់តឹងតែងជាមួយអាជ្ញាធរមូលដ្ឋាន ហើយបង្កើនទំនុកចិត្ត និងការចូលរួមជាសាធារណៈ។

ដូច្នេះ ការស្រាវជ្រាវបន្ទាប់ត្រូវអនុវត្តលើប្រធានបទមួយចំនួនដូចខាងក្រោម៖

- តើ សកបទ និងក្រុមប្រឹក្សាឃុំ/សង្កាត់ អាចលើកកម្ពស់ការចូលរួមរបស់កសិករ ឬការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងធនធានទឹកយ៉ាងណា ដើម្បីធានាឲ្យបាននិរន្តរភាពនៃប្រព័ន្ធធារាសាស្ត្រ?
- ក្នុងបរិបទនៃអភិបាលកិច្ចធារាសាស្ត្រ និងផ្ទៃរងទឹកភ្លៀង តើគោលនយោបាយ PIMD និងវិមជ្ឈការ និងវិសហមជ្ឈការ អាចត្រូវបានបន្សាំ និងអនុវត្តដោយមានប្រសិទ្ធភាពយ៉ាងដូចម្តេច?
- តើភាពជាដៃគូនៃរដ្ឋាភិបាល អ្នកផ្តល់ជំនួយ សហគមន៍ និងវិស័យឯកជន ក្នុងការគ្រប់គ្រងធារាសាស្ត្រ ត្រូវបានបង្កើតឡើងយ៉ាងដូចម្តេច? តើអ្វីជាយន្តការដ៏មានប្រសិទ្ធភាពបំផុតដើម្បីពង្រឹងភាពជាដៃគូនេះ?
- តើគួរបញ្ចូលសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃគណៈកម្មាធិការ សកបទ ដើម្បីជួយគាំទ្រផ្នែកបច្ចេកទេស និងសមត្ថកិច្ចដែរឬទេ?

# ឯកសារយោង


Ackerman, J. ( 2004 ), "Co-governance for accountability: Beyond 'exit' and 'voice' ", *World Development*, Vol. 32 ( 3 ), pp. 447-463

Asian Development Bank ( 2003 ), "Water Sector Roadmap: Kingdom of Cambodia", http://www.adb.org/Water/CFWS/Roadmap-CAM.pdf ( accessed 20 October 2010 )

Asian Development Bank ( 2009a ), "Effectiveness of Participatory Approaches: Do the New Approaches Offer an Effective Solution to the Conventional Problems in Rural Development Projects ?" http://www.adb.org/Documents/Reports/Evaluation/sst-reg-2005-01.pdf ( accessed 28 December 2010 )

Asian Development Bank ( 2009b ), "Cambodia: Stung Chinit Irrigation and Rural infrastructure Project", http://www.adb.org/Documents/PCRs/CAM/29257-CAM-PCR.pdf ( accessed 1 November 2010 )

Asian Development Bank ( 2009c ), "Country Operations Business Plan 2009-2012", http://www.adb.org/Documents/CPSs/CAM/2009-2012/COBP-CAM-2009-2012.pdf ( accessed 1 November 2010 )

Asian Development Bank ( 2010 ), "Water Resources Management Sector Development Programme" ( RRP CAM 38558 ), http://www.adb.org/Documents/RRPs/CAM/38558/38558-02-cam-dc.pdf ( accessed 1 November 2010 )

Bagadion, B.U. & F.F. Korten ( 1991 ), "Developing Irrigators' Organisations: A Learning Process Approach", in M.M. Cernea ( ed. ) *Putting People First: Sociological Variables in Rural Development* ( New York: Oxford University Press )

Boru, D., A. Sophie, T.H. Graham & M. Ronald ( 2008 ), "Participatory Impact Pathways Analysis: A Practical Method for Project Planning and Evaluation", http://boru.pbworks.com/f/PIPA-ILAC-Brief-pre-print.doc ( accessed 3 January 2011 )

Bryson, J. M. ( 2003 ), "What To Do When Stakeholders Matter: A Guide to Stakeholder Identification and Analysis Techniques", paper presented at the London School of Economics and Political Sciences, 10 February 2003

Cambodia Development Resource Institute ( 2010 ), *Empirical Evidence of Irrigation Management in the Tonle Sap Basin: Issues and Challenges*, Working Paper No. 48 ( Phnom Penh: CDRI )

Chevalier, J. M. ( 2002 ), "Natural Resource Project/Conflict Management: Stakeholders Doing 'Class' Analysis", in F. Yoshitaro *et al.* ( eds. ), *Evolving Concept of Peace-building: Natural Resource Management and Conflict Prevention* ( Tokyo, Japan: Foundation for Advanced Studies on International Development )

Chou. C. ( 2009 ), "Local Governance of Common Pool Research: The Case Study of Irrigation Water in Cambodia", Vol. 13, Issue 4, October 2009 ( Phnom Penh: CDRI )

Clever, F. and Franks, T. ( 2005 ), "Water Governance and Poverty: A Framework for Analysis", Research Paper No.13, Bradford Centre for International Development, University of Bradford, UK.

Cooke & U. Kothari ( eds. ) *Participatory: The New Tyranny ?* ( London; New York: Zed Books )

Cooke, B. & Kothari, U. ( eds. ) ( 2001 ) "Participation: The New Tyranny ?" ( London: Zed Books ).

Coward, E.W. (1991), "Planning Technical and Social Change in Irrigated Areas," in M.M. Cernea (ed.), *Putting People First: Sociological Variables in Rural Development* (New York: Oxford University Press)

Edmunds D. & E. Wollenberg (2001), "A Strategic Approach to Multi-stakeholder Negotiations", *in Development and Change* Vol. 32 (2001), pp. 231-253, Institute of Social Studies

FAO (1997), "Guide for the conduct of the constraints analysis component, Participatory survey methods for gathering information", http://www.fao.org/docrep/W8016E/w8016e01.htm#stakeholder%20analysis (accessed 22 December 2010)

Fitzgerald, I. & Sovannarith, S. (2007), "Moving out of Poverty: Trends in Community Well-being and Household Mobility in Nine Cambodian Villages"(Phnom Penh: CDRI)

Freeman, R. E. (1994), "The politics of stakeholder theory: Some future directions", *Business Ethics Quarterly,* Vol. 4, pp. 409-421

Gilfillan, Beth (2010), *Coercion and Resistance: International Aid in Cambodia* (Saarbrucken, Germany: VDM Publishing).

Global Water Partnership (2000), "Integrated Water Resources Management, Technical Advisory Committee Background Papers", No. 4, Stockholm, Sweden http://www.gwptoolbox.org/images/stories/gwplibrary/background/tac_4_english.pdf (accessed 2 June 2011)

Grace, M. (2009), "Moving Blindly towards Integrated Water Resources Management? Challenges and Constraints facing Cambodia's New Water Law", *Asia Pacific Journal of Environmental Law,* Vol. 12, Issue 1, Sydney, Australia

Grimble, R. & K. Wellard (1997), "Stakeholder Methodologies in Natural Resource Management: A review of principles, contexts, experiences and opportunities", Agricultural *Systems Journal,* Vol.55 (2), pp. 173-193

Hofman, B. & K. Kaiser (2006), Decentralisation, Democratic Transition, and Local Governance in Indonesia, in P. Bardhan & D. Mookherjee (eds.), *Decentralisation and Local Governance in Developing Countries* (Cambridge, Massachusetts; London: The MIT Press)

Isham, J. & K. Satu (1998), "The Institutional Determinants of the Impact of Community-based Water Services: Evidence from Sri Lanka and India", background paper for the Operations Evaluation Department, World Bank

Jack, Kelsey (2010), "Barriers to the Adoption of Agricultural Technologies in Developing Countries", Agricultural Technology Adoption Initiative, Draft whitepaper paper for JPAL http://are.berkeley.edu/courses/ARE251/fall2009/Papers/ATAIwhitepaper111409.doc (accessed 31 December 2010)

Keskinen, M. & Sithirith, M. (2009), "Tonle Sap Lake and its Management: The Diversity of Perspectives and Institutions", research paper on improving Mekong water allocation project (PN67), http://www.mpowernet.org/mweb.php?pg=208 (accessed 4 January 2011)

Koma, Y.S., K. Sophanna & T. Try (2009), "CEDAC M-Power meeting report: Summary Report on Activities Completed in 2008 and Plan for 2009", http://www.sea-user.org/download_pubdoc.php?doc=4785 (accessed 16 November 2009)

Lee, T. R. (1999), *Water Management in the 21st Century: The Allocation Imperative* (Cheltenham; Northampton: Edward Elgar)

MAFF (2009), "Agriculture Related Social Safety-net: A response to Global Financial Crisis", paper by H.E. Chan Tong Yves, Secretary of State, presented at the 14th GDCC Meeting of the CDC, Phnom Penh, Cambodia, 28 April 2009 http://www.cdc-crdb.gov.kh/cdc/gdcc/fourteen/session1/presentation_maff.htm (accessed 24 January 2011)

Mak, S. (2007), "Agricultural Extension Overview 2007", (Phnom Penh: DAE-MAFF)

Matsaert, H. (2002), "Institutional Analysis in Natural Resources Research – Socioeconomic Methodologies for Natural Resources Research: Best Practice Guidelines" (Chatham, UK: Natural Resources Institute)

Mekong River Commission (2010), "Stakeholder analysis for the MRC basin development plan programme phase 2 (BDP2): Complementary document to the stakeholder participation and communication plan for the basin development planning in the lower Mekong Basin", final report, http://www.foodsecurity.gov.kh/otherdocs/BDP-SHA-Final-Mar-2010-Eng.pdf (accessed 16 June 2010)

Mitchell, B. (1990, *Integrated Water Management: International Experiences and Perspectives* (London; New York: Belhaven)

Mitchell, R.K., B.R. Agle & D.J. Wood (1997), "Towards a theory of stakeholder identification: Defining the principle of who and what really counts," *Academy of Management Review,* Vol. 22(4), pp. 853-886

MOE (2006), "Cambodia Environmental Performance Assessment Report 2006: Expenditure on Irrigation System Construction and Maintenance 1999-2003" (Phnom Penh: MOE)

Mollinga, P. P. (2008), Water, politics and development: Framing a political sociology of water resources management, http://www.water-alternatives.org/index.php?option=com_docman&task=doc_download&gid=15 (accessed 4 January 2011)

MOWRAM (1999), Circular No. 1, 11 January 1999 on the "Implementation Policy of Sustainable Irrigation Systems" (Phnom Penh: MOWRAM)

MOWRAM (2009a), "Action Plan on the Management and Development of Water Resources and Meteorology in the Implementation of RGC Rectangular Strategy, Second Step (2009-2013)" (Phnom Penh: RGC)

MOWRAM (2009b), "Lessons Learned and Resolutions on PIMD", paper presented at CEDAC National Workshop, Phnom Penh Hotel, 17 December 2009 (unpublished)

National Institute of Statistics (2008), "General Population Census of Cambodia 2008, Final Census Results" (Phnom Penh: Ministry of Planning)

NCDD (2010), National Committee for Decentralisation and Deconcentration Reform, Message from the Chairman http://www.ncdd.gov.kh/component/content/article/30-ncdd/5-message-from-the-chairman (accessed 26 October 2010)

Ostrom, E. (1992), *Crafting Institutions for Self-governing Irrigation Systems* (California, USA: Institute for Contemporary Studies Press)

Overseas Development Administration (1995), "Guidance notes on how to do stakeholder analysis of aid projects and programmes" (London, UK: Social Development Department, ODA)

Perera, L.R. (2006), *Factors Affecting the Formation of FWUCs in Institution building for PIMD in Cambodia: Two Case Studies*, Working Paper No. 113 (Colombo, Sri Lanka: International Water Management Institute) pp.25

Phalla, C. *et al.* (2008), *Framing Research on Water Resources Management and Governance in Cambodia: A Literature Review,* Working Paper No. 37 (Phnom Penh: CDRI)

Ribot, J.C. (2000), "Decentralisation, Participation, and Representation: Administrative Apartheid in Sahelian Forestry", in P.E. Peters (ed.), *Development Encounters: Sites of Participation and Knowledge* (Cambridge, MA: Harvard University Press)

Rowe, G. & L.J. Frewer (2004), "Evaluation of public participation exercises: A research agenda", *Science, Technology, and Human Values*, Vol. 29(4), pp. 512-556

Royal Government of Cambodia (1994), "Roles, Responsibilities and Organisational Structure of Provincial and Municipal Administrations", MoI *Prakas* 1994 (Phnom Penh: RCG)

Royal Government of Cambodia (1999), Royal Proclamation NS/RKM/0699/108, "Organisation and Function of Ministry of Water Resources and Meteorology" (Phnom Penh: RGC)

Royal Government of Cambodia (2000a), Sub-decree No. 17 SDC, "Role and Function of Ministry of Agriculture, Forestry and Fisheries" (Phnom Penh: RGC)

Royal Government of Cambodia (2000b), Sub-decree No.17 SDC, 7 April 2000, "Organisation and Function of Ministry of Agriculture, Forestry and Fisheries"(Phnom Penh: RGC)

Royal Government of Cambodia (2001), Law on Khum/Sangkat Administrative Management 2001, Article 41 (Phnom Penh: RCG)

Royal Government of Cambodia (2004), "National Water Resources Policy in the Kingdom of Cambodia" (Phnom Penh: MOWRAM)

Royal Government of Cambodia (2005), "Strategic Framework for Decentralisation and Deconcentration Reform" (Phnom Penh: RCG)

Royal Government of Cambodia (2006), Royal Decree No. NS/RD/0806/355, 18 August 2006, "The Establishment of NCDD" (Phnom Penh: RGC)

Royal Government of Cambodia (2007), "Progress in Achieving Cambodia Millennium Development Goals: Challenges and Opportunities", Annual Ministerial Review of the High Level Segment of ECOSOC, Geneva, 2-4 July 2007 (Phnom Penh: MOP)

Royal Government of Cambodia, (2008), Law on "Administrative Management of the Capital, Provinces, Municipalities, Districts and Khans", No. NS/RKM/0508/017, dated 22 May 2008 (Phnom Penh: RGC) http://www.ncdd.gov.kh/legal-framework/law (accessed on June 7, 2011)

Royal Government of Cambodia (2009), "Royal Decree on the Establishment of the Tonle Sap Authority", No. NS/RKR/0609/705, 30 June 2009 (Phnom Penh: RGC)

SaciWATERs (2009), "The International Conference on Water Resources Policy in South Asia", report on conference, 17-20 December 2008, Colombo, Sri Lanka, (Andhra Pradesh, India: SaciWATERs), http://www.saciwaters.org/colomboconference/downloads/CONFERENCE%20REPORT%20FINALfor%20Web%20Iridium_web.pdf (accessed 14 February 2011)

Sheldon, T. (ed.) (2005), *River Basin Management: A Negotiated Approach,* (Amsterdam: Both ENDS; Pune, India: Gomukh Publishing)

Sinath, C. (2002), "Investment in Land and Water in Cambodia", proceedings of the Regional Consultation (Bangkok: FAO/RAP), http://webcache.googleusercontent.com/search?q=cache:wx4zzSqiXoYJ:www.fao.org/docrep/005/ac623e/ac623e0c.htm+ISF+collect+guideline,+MOWRAM&cd=1&hl=km&ct=clnk&gl=kh (accessed 23 June 2010)

Sneddon, C. & C. Fox (2007), "Power, Development and Institutional Change: Participatory Governance in the Lower Mekong Basin", *World Development*, Vol. 35(12), pp. 2161-2181

Sokhem, P. & K. Sunada (2006), "The Governance of the Tonle Sap Lake, Cambodia: Integration of Local, National and International Levels", *Water Resources Development*, Vol. 22, No. 3, pp. 399–416, http://www.sea-user.org/UserFiles/File/docs/Sokhem%26Sunada_Fisheries_Session_draft_270606(1).pdf (accessed 4 January 2011)

Sokhem, P. (2010),. "Cambodian and Mekong Water Resources Governance", in J. Sato (ed.) *Transboundary Resources and Eenvironment in Mainland Southeast Asia*, Institute for Advanced Studies on Asia, the University of Tokyo

Stoker, G. (1998), *Governance as Theory: Five Propositions* (Oxford, UK: Blackwell Publishers) http://classwebs.spea.indiana.edu/kenricha/Oxford/Archives/Oxford%202006/Courses/Governance/Articles/Stoker%20-%20Governance.pdf (accessed 28 December 2010)

TWGWA (2007), "Strategy on Agriculture and Water" (Phnom Penh: TWGWA)

UNCED (1992), United Nations Conference on Environment and Development (UNCED), The Earth Summit "Agenda 21", Rio de Janeiro, 3-14 June 1992 http://www.un.org/esa/dsd/agenda21/res_agenda21_18.shtml (accessed 2 June 2011)

UNESCAP (2009), *Participatory Approaches to Rural Development and Rural Poverty Alleviation,* Working Paper http://www.unescap.org/pdd/publications/poverty_and_development/participatory_rural.pdf (accessed 28 December 2010)

UNESCAP (2011), "What is Good Governance?" http://www.unescap.org/pdd/prs/ProjectActivities/Ongoing/gg/governance.pdf (accessed 26 January 2011)

Veldwisch, G.J. (2006), "Local Governance Issues after Irrigation Management Transfer: A Case Study from Limpopo Province, South Africa", in S. Perret, S. Farolfi & R. Hassan R. (eds.), *Water Governance for Sustainable Development: Approaches and Lessons from Developing and Transitional Countries* (London: Earthscan)

World Bank (2004),"Volume 1, Decentralized Systems: Case Studies of International Initiatives", (Washington DC: World Bank), http://www.g-fras.org/fileadmin/UserFiles/Documents/Case-studies/Decentralized-Systems.pdf, (accessed 28 December 2010)

World Bank Group (2001), "The World Bank's Experience with Local Participation and Partnerships: Lessons from an OED Evaluation, The World Bank Group" http://www.worldbank.org/html/oed/partnershipconference/images/warren-wicklin.pdf (accessed 30 December 2010)

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១៖ ការប្រជុំ ឬប្រធានបទពិភាក្សា និងអ្នកផ្តល់ព័ត៌មាន

*១. ប្រធានបទពិភាក្សា*

១. សូមពិពណ៌នាតួនាទីសំខាន់ៗរបស់ស្ថាប័នអ្នកដែលទាក់ទងនឹងការអភិវឌ្ឍន៍ និងគ្រប់គ្រងធារាសាស្ត្រ ឬអាងផ្ទៃរងទឹកភ្លៀង?

២. តើអ្វីជាការប្រឈមចំបងៗ ជ័យជំនះសំខាន់ៗ និងបរាជ័យ ដែលជាការយល់ឃើញដោយស្ថាប័នរបស់អ្នកក្នុងការអភិវឌ្ឍ និងគ្រប់គ្រងធារាសាស្ត្រនៅកម្ពុជា?

៣. តើអ្វីជាការប្រឈមចំបងៗ ជ័យជំនះសំខាន់ៗ និងបរាជ័យដែលជាការយល់ឃើញដោយស្ថាប័នរបស់អ្នក ក្នុងការអភិវឌ្ឍ និងគ្រប់គ្រងអាងផ្ទៃរងទឹកភ្លៀងនៅកម្ពុជា?

៤. ចូរពិពណ៌នាពីផ្នែកសំខាន់ៗនៃកិច្ចសហការរវាងស្ថាប័នរបស់អ្នក និងស្ថាប័នដទៃ ក្នុងការគ្រប់គ្រងធារាសាស្ត្រ និងអាងផ្ទៃរងទឹកភ្លៀង។ តើអ្វីជាការប្រឈមពាក់ព័ន្ធនឹងកិច្ចសហការរវាងស្ថាប័ននានា និងរវាងកម្រិតផ្សេងៗគ្នានៃស្ថាប័នដែលមានកម្រិតខុសៗគ្នា?

៥. តាមបទពិសោធន៍នៃស្ថាប័នរបស់អ្នក តើអ្វីជាការប្រឈមក្នុងវិមជ្ឈការនៃការគ្រប់គ្រងធារាសាស្ត្រ ពិសេសដែលទាក់ទងនឹងតួនាទីរបស់ សកបទ?

៦. អ្វីជាតួនាទី និងបទពិសោធន៍ក្នុងការប្រើប្រាស់វិធានសេដ្ឋកិច្ច ពិសេសការគ្រប់គ្រង និងវិធានដទៃទៀត ដើម្បីគ្រប់គ្រងធនធានទឹកនៅតាមជនបទនៃប្រទេសកម្ពុជា?

៧. ពេលនិយាយអំពីការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹកនៅប្រទេសកម្ពុជា តើអ្វីជាការខ្វះខាត និងប្រកួតប្រជែងជាងគេលើធនធាន (ហិរញ្ញវត្ថុ ធម្មជាតិ មនុស្ស)?

៨. តើអ្វីជាការប្រកួតប្រជែង និងជម្លោះចំបងជាងគេក្នុងការអភិវឌ្ឍ និងគ្រប់គ្រងធារាសាស្ត្រ និងអាងផ្ទៃរងទឹកភ្លៀងនៅកម្ពុជា? តើមានមធ្យោបាយអ្វីសម្រាប់ដោះស្រាយជម្លោះទាំងនោះ?

៩. ក្នុងការងារស្ថាប័នរបស់អ្នកលើផ្នែកគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹកក្នុងបរិបទធារាសាស្ត្រ និងអាងផ្ទៃរងទឹកភ្លៀង សូមពិពណ៌នាពីគោលបំណងសំខាន់របស់អ្នកលើលទ្ធផលសេដ្ឋកិច្ច សមភាពក្នុងការយកទឹកមកប្រើប្រាស់ និងការធ្វើឲ្យមាននិរន្តរភាពបរិស្ថាន។

១០. តើការរំពឹងទុករបស់អ្នកផ្តល់ជំនួយ គោលបំណង និងបទពិសោធន៍របស់ស្ថាប័នអ្នក និងការអនុវត្តនៅកម្រិតមូលដ្ឋានមានភាពស្របល្អគ្នាយ៉ាងណា?

១១. កម្រិតស្ថាប័នជាច្រើន មានការកែប្រែ និងបានអនុវត្តនៅកម្ពុជាក្នុងប៉ុន្មានទសវត្សរ៍កន្លងមក ពិសេសមានដូចជា ការបង្កើត សកបទ អង្គការគ្រប់គ្រងអាងផ្ទៃរងទឹកភ្លៀង ក្រុមការងារបច្ចេកទេស និងកំណែទម្រង់ច្បាប់នានា ទាក់ទងនឹងការគ្រប់គ្រងទឹក។ តើអ្នកអាចវាយតម្លៃបានទេថា ការងារទាំងនេះដំណើរការល្អយ៉ាងណា?

១២. តើមានផ្នែកណាខ្លះទៀតនៃអភិបាលកិច្ចធនធានទឹកដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ និងគ្រប់គ្រងធារាសាស្ត្រ និងការគ្រប់គ្រងអាងផ្ទៃរងទឹកភ្លៀងដែលអ្នកចង់លើកយកមកពិភាក្សា?

## ២. អ្នកផ្តល់ព័ត៌មាន

| លរ | កាលបរិច្ឆេទ | ស្ថាប័ន | អ្នកផ្តល់សម្ភាសន៍ | ទីកន្លែង |
|---|---|---|---|---|
| ១ | ២៣ មីនា ២០០៩ | ក្រធទឧ | ប្រធាននាយកដ្ឋាន សកបទ | ក្រធទឧ |
| ២ | ១៥ តុលា ២០១០ | ក្រករន | ជំនួយការផ្នែកប្រព័ន្ធកសិកម្ម នៃនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម | វសអក |
| ៣ | ៨ ធ្នូ ២០០៩ | គជអប | ក្រុមគាំទ្រកម្មវិធីគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន | ក្រមហជ |
| ៤ | ១៣ កញ្ញា ២០១០ | កគវវ (PSDD) | មន្ត្រីផ្នែកធនធានធម្មជាតិ និងបរិស្ថាន និងកគវវ | ខេត្តពោធិ៍សាត់ |
| ៥ | ១៨ ធ្នូ ២០០៩ | ធអអ | មន្ត្រីអនុវត្តន៍គម្រោង | ការិយាល័យ ធអអ |
| ៦ | ៩ ធ្នូ ២០០៩ | អង្គការ FACT | នាយកប្រតិបត្តិ | អង្គការ FACT |
| ៧ | ៨ ធ្នូ ២០០៩ | អង្គការ CEDAC | មន្ត្រីផ្នែកសម្របសម្រួលប្រព័ន្ធធារាសាស្ត្រ និងសហគមន៍ | អង្គការ GRET |
| ៨ | ៨ ធ្នូ ២០០៩ | អង្គការ GRET | មន្ត្រីផ្នែកសម្របសម្រួលគម្រោង ISC | អង្គការ GRET |
| ៩ | ៨ ធ្នូ ២០០៩ | អទស | អនុប្រធានអចិន្ត្រៃយ៍ និងអគ្គលេខាធិការ | អទស |
| ១០ | ១១ ធ្នូ ២០០៩ | មធទឧ កំពង់ឆ្នាំង | ប្រធានមន្ទីរ | មធទឧ |
| ១១ | ៤ មករា ២០១០ | មធទឧ កំពង់ធំ | ប្រធានការិយាល័យរដ្ឋបាល | មធទឧ |
| ១២ | ៤ មករា ២០១០ | មករន កំពង់ធំ | ឯ.ឧ ប្រធានមន្ទីរ | មករន |
| ១៣ | ២៧ មករា ២០១០ | មធទឧ ពោធិ៍សាត់ | ប្រធានមន្ទីរ | មធទឧ |
| ១៤ | ២៧ មករា ២០១០ | មករន ពោធិ៍សាត់ | ប្រធានមន្ទីរ | មករន |
| ១៥ | ១១-១៤ វិច្ឆិកា ២០០៩ | កបយ សកបទ និងក្រុមពិភាក្សា នៅខេត្តកំពង់ឆ្នាំង | កបយ សកបទ និងក្រុមពិភាក្សា | ប្រព័ន្ធធារាសាស្ត្រ ប៉ក់ប៉ែន ស្វាយចេក តាំងក្រសាំង និងត្រពាំងក្របៃក |
| ១៦ | ២-៥ មករា ២០១០ | កបយ សកបទ និងក្រុមពិភាក្សា នៅខេត្តកំពង់ធំ | កបយ សកបទ និងក្រុមពិភាក្សា | ប្រព័ន្ធធារាសាស្ត្រ រលួស ស្ទឹងជីនិត និងអូរស្វាយ |
| ១៧ | ២៦-២៩ មករា ២០១០ | កបយ សកបទ និងក្រុមពិភាក្សា នៅខេត្តពោធិ៍សាត់ | កបយ សកបទ និងក្រុមពិភាក្សា | ប្រព័ន្ធធារាសាស្ត្រ ដំណាក់អំពិល កំប៉ាង និងវត្តលៀប |

PSDD = គម្រោងដើម្បីគាំទ្រការអភិវឌ្ឍន៍ប្រជាធិប្បតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ (Project to Support Democratic Development through D&D)

## ឧបសម្ព័ន្ធទី ២៖ ដៃគូអភិវឌ្ឍន៍សំខាន់ៗ

| Development Partner | Project Name | Duration | Amount |
|---|---|---|---|
| *Water Resources Management Policy, and Institutional Capacity Building* | | | |
| ADB | Agriculture Sector Programme | 1996–2000 | $30.0 million (Loan) |
| AFD | Support for the Development of Agriculture and Water Sector Policies | 2006-2009 | $1.5 million (Grant) |
| AFD | Northwest Irrigation Sector project | 2004-2010 | €4 million |
| Australia | Water Resource Management Research Capacity Development Programme | 2006-2011 | A$2.99 million |
| FAO | Strengthening the Participatory Irrigation Management and Development Strategy | 2007-2009 | $0.375 million |
| JICA | Technical Services Centre for Irrigation Systems, phase I and II | 2001-5 2006-9 | $5.0 million |
| KOICA | Master plan of water resources development in Cambodia | 2006-8 | $1.5 million |
| UK (DfID) | Natural Resource Management and Livelihoods programme | 2006 - 2010 | £13.6 million |
| UNDP, GEF, the Nether-lands | Mekong River basin wetland conservation and sus-tainable use programme | Ongoing | $31.5 million |
| *Projects (including preparation studies) – Integrated Water Resource Management, Irrigation, Flood Control, Water supply and sanitation* | | | |
| ADB | Tonle Sap Environmental Management Project | 2003-2008 | $19.3 million |
| ADB | Emergency Flood Rehabilitation Project, rural infrastructure and irrigation and flood control components | 2001-3 | $10.8 million (irrigation and flood), $6.4 million (rural infrastructure) |
| ADB | PPTA Second Rural Water Supply and Sanitation Sector Project | 2008–2009 | $0.6 million |
| ADB | PPTA Water resources management sector | 2007–2010 | $1.56 million |
| ADB, AFD | Stung Chinit irrigation and rural infrastructure | 2001–2006 | $23.8 million |
| ADB, AFD | Northwest Irrigation Sector (NWISP) | 2005–2010 | $22.6 million |
| AFD | Rehabilitation of Prey Nup polders | 2002–2008 | € 3.8 million |
| Australia | Cambodia Agriculture Value Chain Programme (CAVAC) | 2007–2012 | A$45 million |
| China | Stung Staung Water resources development | 2005–2008 | n.a. |
| India | Rehabilitation West Baray Irrigation scheme | 2005–2008 | $5.0 million |
| Japan | Project for the Rehabilitation of the Kandal Stung Irrigation System | 2005–2008 | Y 1,740 million (grant) |
| Japan | Study – Comprehensive Agricultural Development of Prek Thnot River Basin | 2003–2008 | Y 423.353 million |
| Japan | The Basin-Wide Basic Irrigation and Drainage Master Plan Study | 2007–2009 | Y 147.914 million |
| Japan | Rehabilitation of small irrigation rehabilitation projects in Kampong Cham Takeo, Kandal, Pursat and Kratie Provinces | 2008–2009 | $0.35 million |

| | | | |
|---|---|---|---|
| Japan | Improvement of Agricultural River Basin Management ad Development Project (TSC3) | 2009–2014 | $0.72 million |
| Japan | The Project for Rehabilitating Boeung Veam Irrigation System in Kampong Cham Province | 2010–2011 | $0.096 million |
| Japan | The Project for Rehabilitating Kbal Tonsoung Irrigation System in Kampong Cham Province | 2008–2009 | $0.085 million |
| Japan | The Project for Rehabilitating Portasu Irrigation in Takeo Province | 2009–2011 | $0.175 million |
| Japan | The Project for Rehabilitating Thanal Cham Reservoir in Kandal Province | 2008–2009 | $0.085 million |
| Japan | The Project for Rehabilitation of Toul Kou Irrigation in Pursat Province | 2007–2008 | $0.080 million |
| Japan | The Project of Rehabilitation of Bos Leave Irrigation System in Kratie Province | 2007–2008 | $0.086 million |
| Japan/Republic of Korea | The JICA/KOICA Joint Programme for the Rehabilitation of Irrigation System and Rural Community Development in Cambodia | Jun 2009– Dec 2009 | $0.30 million |
| JICA, APS (Italy), WFP | Kamping Pouy irrigation rehabilitation and rural development | 1998–2006 | $5.6 million |
| Republic of Korea | Krang Ponley Water Resources Development Project | 2006–2010 | $27 million |
| Republic of Korea | Construction of irrigation System in Batheay District | 2009–2010 | $2.5 million |
| Republic of Korea | Tamauk Irrigation Rehabilitation Project | 2002–2004 | $1.9 million |
| Republic of Korea | Multi-purpose water resources development, Krang Ponley | 2004–2009 | n.a |
| Republic of Korea | Multi-purpose dam development, Battambang | 2006–2007 | n.a |
| UNDP | Promoting Climate-resilient Water Management and Agriculture in Rural Cambodia | 2009–2013 | $4.09 million |
| World Bank | Provincial and Peri-Urban Water Supply and Sanitation Project | 2003– on going | $23.0 million (including IDA) |

ប្រភព៖ ADB 2010, accessible on 11/2/2010 at: http://www.adb.org/Documents/RRPs/CAM/38558/38558-02-cam-dc.pdf

# បញ្ជីឯកសារពិភាក្សារបស់វិទ្យាស្ថាន CDRI

២១. Bhargavi Ramamurthy ស៊ិក-ប៊ូរ៉ក្ស, Per Ronnås និង សុក-ហាច (មីនា ២០០២) ប្រទេសកម្ពុជា ឆ្នាំ១៩៩៩-២០០០៖ *ការផ្តោតលើបញ្ហាដីធ្លី កំលាំងពលកម្ម និងការចិញ្ចឹមជីវិត នៅជនបទ* (ឯកសារពិភាក្សាលេខ ២១) តម្លៃ ៨.០០០រៀល ។

២២. ច័ន្ទ-សុផល និង Sarthi Acharya (កក្កដា ២០០២) *ការលក់ដូរដីធ្លីនៅកម្ពុជា៖ ការវិភាគទិន្នន័យនៃការផ្ទេរ និងការលក់ដូរដីធ្លី* (ឯកសារពិភាក្សាលេខ ២២) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ។

២៣. Bruce McKenney និង ព្រុំ-តុលា (កញ្ញា ២០០២) *ធនធានធម្មជាតិ និងជីវភាពនៅតាម ជនបទក្នុងប្រទេសកម្ពុជា៖ ការវាយតម្លៃជាមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៣) ជាភាសា ខ្មែរ តម្លៃ ១០.០០០រៀល ជាអង់គ្លេស តម្លៃ ១០.០០ដុល្លារ ។

២៤. ច័ន្ទ-សុផល គឹម-សេតារា និង Sarthi Acharya (ធ្នូ ២០០២) *ដីធ្លី ជីវភាពជនបទ និងសន្តិសុខស្បៀងនៅកម្ពុជា៖ ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៤) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាអង់គ្លេស តម្លៃ ៧.០០ដុល្លារ ។

២៥. ច័ន្ទ-សុផល និង Sarthi Acharya (ធ្នូ ២០០២) *បញ្ហាប្រឈមចំពោះការចិញ្ចឹមជីវិតនៅ ជនបទ៖ ការសិក្សាលើភូមិចំនួន ៩ នៅកម្ពុជា* (ឯកសារពិភាក្សា លេខ២៥) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០.០០ដុល្លារ ។

២៦. Sarthi Acharya គឹម-សេតារា ចាប-សុចារិទ្ធ និង មាច-យ៉ាឌី (កញ្ញា ២០០៣) *ការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្ម៖ ទស្សនៈស្តីពីការបង្កើតការងារនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២៦) ជាភាសាខ្មែរ តម្លៃ ៧.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ ។

២៧. យឹម-ជា និង Bruce McKenney (ធ្នូ ២០០៣) *ការនាំចេញត្រីពីបឹងទន្លេសាបទៅប្រទេសថៃ៖ ការវិភាគលើការរាំងស្ទះពាណិជ្ជកម្ម អភិបាលកិច្ច និងបរិយាកាសសម្រាប់ការលូតលាស់* (ឯកសារពិភាក្សាលេខ២៧) ជាភាសាខ្មែរ តម្លៃ ៧.០០០រៀល ជាភាសាអង់គ្លេស ១០,០០ដុល្លារ ។

២៨. ព្រុំ-តុលា និង Bruce McKenney (ធ្នូ ២០០៣) *ការធ្វើពាណិជ្ជកម្មផលព្រៃឈើនៅកម្ពុជា៖ ការប្រឈម ការគំរាមកំហែង និងឱកាសសម្រាប់ពាណិជ្ជកម្មជ័រទឹក* (ឯកសារពិភាក្សាលេខ២៨) ជាភាសាខ្មែរ ៧.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០,០០ដុល្លារ ។

២៩. យឹម-ជា និង Bruce McKenney (វិច្ឆិកា ២០០៣) *ពាណិជ្ជកម្មត្រីក្នុងស្រុក៖ ករណីសិក្សានៃម៉ាយីទីងត្រីពីបឹងទន្លេសាបទៅក្រុងភ្នំពេញ* (ឯកសារពិភាក្សាលេខ២៩) ជាភាសាខ្មែរ ៥.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ ។

៣០. Caroline Hughes និង គឹម-សេតារា (មិថុនា ២០០៤) *ការវិវត្តន៍នៃដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រងទំនាស់នៅកម្ពុជា៖ ការសិក្សាប្រៀបធៀបការបោះឆ្នោតបីលើកនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ៣០) ជាភាសាខ្មែរ តម្លៃ ១០.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១៣,៥០ដុល្លារ ។

៣១. Robert Oberndorf (កក្កដា ២០០៤) *សុខដុមនីយកម្មច្បាប់ទាក់ទងនឹងដំណើរការវិមជ្ឈការនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ៣១) ជាភាសាខ្មែរ តម្លៃ ៥.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៦,៥០ដុល្លារ ។

៣២. K. A. S. Murshid និង ទួត-សុខផល្លី (ឧសភា ២០០៥) *សេដ្ឋកិច្ចឆ្លងកាត់ព្រំដែនរបស់ ប្រទេសកម្ពុជា៖ ការសិក្សាជំហានដំបូង* (ឯកសារពិភាក្សាលេខ៣២) ជាភាសាខ្មែរ ៨.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ ។

៣៣. Hansen, Kasper K. និង នុប-នេត (ធ្នូ ២០០៦) *Natural Forest Benefits and Economic Analysis of Natural Forest Conversion in Cambodia* (Working Paper No. 33) ជាភាសាអង់គ្លេស តម្លៃ ៨.០០ដុល្លារ ។

៣៤. ប៉ក់-គឹមជឿន ហ៊ង-វុទ្ធី អេង-នេត្រា អាន-សុវត្ថា គឹម-សេតារា, Jenney Knowles និង David Craig (មីនា ២០០៧) *Accountability and Neo-patrimonialism in Cambodia: A Critical Literature Review* (ឯកសារពិភាក្សាលេខ៣៤) ជាភាសាអង់គ្លេស ៦,០០ដុល្លារ ។

៣៥. គឹម-សេតារា និង Joakim Öjendal (ឧសភា ២០០៧) *Where Decentralisation Meets Democracy: Civil Society, Local Government, and Accountability in Cambodia* (ឯកសារពិភាក្សាលេខ៣៥) ជាភាសាអង់គ្លេស តម្លៃ ៤,០០ដុល្លារ ។

៣៦. លឹម-សុវណ្ណារា (វិច្ឆិកា ២០០៧) *Youth Migration and Urbanistion in Cambodia* (ឯកសារពិភាក្សាលេខ ៣៦) ជាភាសាខ្មែរ ៦.០០០រៀល ជាភាសាអង់គ្លេស ៣,៥០ដុល្លារ ។

៣៧. Chem Phalla *et al.* (May 2008), *Framing Research on Water Resources Management and Governance in Cambodia: A Literature Review* ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ ។

៣៨. Pak Kimchoeun and David Craig, *Accountability and Public Expenditure Management in Decentralised Cambodia* (Working Paper No. 38) ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ ។

៣៩. Horng Vuthy and David Craig, *Accountability and Planning in Decentralised Cambodia* (Working Paper No. 39) ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ ។

៤០. Eng Netra and David Craig (forthcoming), *Accountability and Human Resource Management in Decentralised Cambodia* (Working Paper No. 40) ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ ។

៤១. ហ៊ីង វុត្ថា និង Hossein Jalilian (មេសា ២០០៩) *ផលប៉ះពាល់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ចំពោះបរិស្ថាននៅតាមបណ្តាប្រទេសក្នុងមហាអនុតំបន់មេគង្គ (ឯកសារពិភាក្សាលេខ ៤១)* ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ៣,០០ដុល្លារ ។

៤២. Thon Vimealea, Ou Sivhuoch, Eng Netra and Ly Tem (October 2009), *Leadership in Local Politics of Cambodia: A Study of Leaders in Three Communes of Three Provinces.*

៤៣. ហ៊ីង វុត្ថា និង បណ្ឌិត ធន់ វឌ្ឍនា (ធ្នូ ២០០៩) *ពាណិជ្ជកម្មកសិកម្មក្នុងមហាអនុតំបន់មេគង្គ៖ ករណីដំឡូងឈើ និងកៅស៊ូ នៅកម្ពុជា* (ឯកសារពិភាក្សាលេខ ៤៣) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាភាសាអង់គ្លេស ៣,០០ដុល្លារ ។

៤៤. ច័ន្ទ សុផល (ធ្នូ ២០០៩) *ផលប្រយោជន៍ និងចំណាយនៃទេសន្តរប្រវេសន៍កំលាំងពលកម្មក្នុងមហាអនុតំបន់មេគង្គ៖ ករណីសិក្សានៅប្រទេសកម្ពុជា* ជាភាសាខ្មែរតម្លៃ ៨,០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៣.០០ដុល្លារ ។

៤៥. CDRI Publication (December 2009), *Costs and Benefits of Cross-country Labour Migration in the GMS: Synthesis of the Case Studies in Thailand, Cambodia, Laos and Vietnam* ជាភាសាអង់គ្លេស តម្លៃ ១,៥០ដុល្លារ ។

៤៦. CDRI Publication (December 2009), *Agricultural Trade in the Greater Mekong Sub-region: Synthesis of the Case Studies on Cassava and Rubber Production and Trade in GMS Countries* ជាភាសាអង់គ្លេស តម្លៃ ១,៥០ដុល្លារ ។

៤៧. Chea Chou (August 2010), *The Local Governance of Common Pool Resources: The Case of Irrigation Water in Cambodia* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ ។

៤៨. CDRI Publication (August 2010), *Empirical Evidence of Irrigation Management in the Tonle Sap Basin: Issues and Challenges* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ ។

៤៩. ចែម ផល្លា និង សុមេធ ប៉ាវ៉ាឌី (ឧសភា ២០១១), *ការប្រើប្រាស់ចំណេះដឹងជលសាស្ត្រនៃអាងស្ទឹង និងការចូលរួមរបស់សហគមន៍ដើម្បីលើកកម្ពស់ការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយការចូលរួមស្តីពីការបែងចែកទឹកសម្រាប់ស្រោចស្រព* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ។

៥០. ប៉ាក់ គឹមជឿន (ឧសភា ២០១១), *វិមជ្ឈការហិរញ្ញវត្ថុនៅកម្ពុជា៖ ការងារសម្រេចបាន និងជំហានបន្ទាប់* ជាភាសាអង់គ្លេសតម្លៃ ២,៥០ដុល្លារ ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ។

៥១. Christopher Wokker, Paulo Santos, រស់ បានសុខ និង Kate Griffiths (មិថុនា ២០១១), *Irrigation Water Productivity in Cambodian Rice System* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៥២. អ៊ួច ច័ន្ទតាវ៉ានី សាំង ច័ន្ទហង្ស និង ផាន់ ដាលីស (សីហា ២០១១), *ការវាយតម្លៃផលប៉ះពាល់នៃប្រទេសចិន លើការកាត់បន្ថយភាពក្រីក្រនៅមហាអនុតំបន់ទន្លេមេគង្គ៖ ករណីសិក្សាប្រទេសកម្ពុជា* ជាភាសាអង់គ្លេស តម្លៃ ៣,៥០ដុល្លារ ជាភាសាខ្មែរ តម្លៃ ១០.០០០រៀល ។

៥៣. Chann Sopheak, Nathan Wales and Tim Frewer (August 2011), *An Investigation of Land Cover and Land Use Change in Stung Chrey Bak Catchment, Cambodia* ជាភាសាអង់គ្លេស តម្លៃ ៣.០០ដុល្លារ ។




**វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍**

☞ អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ខ័ណ្ឌទួលគោក

✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

☎ ទូរស័ព្ទ៖ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣

🖷 ទូរសារ៖ (៨៥៥-២៣) ៨៨០-៧៣៤

អ៊ីមែល៖ cdri@cdri.org.kh

គេហទំព័រ៖ http://www.cdri.org.kh


តម្លៃ 12.000 រៀល


9 789996 352454